# ភិក្ខុបាតិមោក្ខ

## បាលី-ប្រែ

ការផ្សាយរបស់

គណៈកម្មការរៀបចំបោះពុម្ពសៀវភៅ
ធម៌វិន័យព្រះពុទ្ធសាសនា

Reth

ព.ស ២៥៣២ គ.ស ១៩៨៨

# ភិក្ខុបាតិមោក្ខ

## បាលី ~ ប្រែ

ការផ្សាយរបស់
គណៈកម្មការរៀបចំបោះពុម្ពសៀវភៅ
ធម៌វិន័យព្រះពុទ្ធសាសនា

បោះពុម្ពលើកទី ១ ចំនួន ១០.០០០ ក្បាល

រក្សាសិទ្ធិ

ព.ស.២៥៣២ គ.ស.១៩៨៨

# អារម្ភកថា

មូលហេតុដែលនាំឲ្យបោះពុម្ពសៀវភៅភិក្ខុបាតិមោក្ខ បាលី ប្រែនេះជាថ្មីឡើងវិញដោយ :

- ប្រជាជនកម្ពុជាភាគច្រើន គោរពប្រតិបត្តិព្រះពុទ្ធសាសនា ។ ប៉ុន្តែទោះជាយ៉ាងណា ក៏ព្រះពុទ្ធសាសនានៅកម្ពុជា មិនដែលធ្លាក់ដល់កម្រិតសូន្យដែរ ។

- លុះដល់ក្នុងរបបប្រល័យពូជសាសន៍ គ្រប់គ្រងប្រទេសជាតិ ពីខែមេសា ឆ្នាំ ១៩៧៥ ដល់ខែ មករា១៩៧៩ព្រះពុទ្ធសាសនានៅកម្ពុជា ត្រូវបានពួកគេលុបបំបាត់ចោលទាំងស្រុង ។ ព្រះសង្ឃក៏គ្មាន។ វត្តអារាម និងគម្ពីរក្បួនច្បាប់នានា គេកម្ទេចចោលស្ទើរសូន្យ ។

- ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ អ្វីៗ ទាំងអស់ត្រូវបានរស់ឡើងវិញ ។ ក្នុងនោះ មានបើកទូលាយខាងជំនឿសាសនា ពិសេសគឺជំនឿក្នុងព្រះពុទ្ធសាសនារបស់ប្រជាជនភាគច្រើន ។

- ទន្ទឹមនឹងការរស់ឡើង នៃប្រទេសជាតិ ព្រះពុទ្ធសាសនាក៏បានរស់ឡើងវិញដែរ ។ ប៉ុន្តែព្រះពុទ្ធសាសនាដែលរស់ឡើងវិញនេះ ជាព្រះពុទ្ធសាសនាសាមគ្គីភាពឯកភាព គ្មានគណៈនិកាយទេ គឺជាព្រះពុទ្ធសាសនារបស់ព្រះសមណគោតមតែមួយព្រះអង្គគត់ ដោយមានគម្ពីរព្រះត្រៃបិដកជាគោលច្បាប់ សម្រាប់ប្រតិបត្តិតែមួយបែបប៉ុណ្ណោះ ។

- បក្ស-រដ្ឋ-រណសិរ្ស យកចិត្តទុកដាក់ឧបត្ថម្ភចាត់ចែងបំបួសឲ្យមានព្រះសង្ឃជាដំបូងឡើងវិញ ចំនួន ៧ អង្គនៅវត្តឧណ្ណាលោម ទុកជាពូជ ។ ភិក្ខុសង្ឃដែលកើតឡើងថ្មីនេះ ច្រើនតែមានវ័យចាស់ ។ មានសតិស្មារតីភ្លេចភ្លាំងច្រើន ហើយថែមទាំងគ្មានច្បាប់ ធម៌វិន័យរៀនសូត្ររំលឹកឡើងវិញផង ។

ដូច្នេះបក្ស-រដ្ឋ-រណសិរ្ស ក៏បានចេញគោលនយោបាយ **អនុញ្ញាតឲ្យ**បោះពុម្ពសៀវភៅធម៌-វិន័យព្រះពុទ្ធសាសនាឡើងវិញ ។

**អា**ស្រ័យហេតុនេះ គណៈកម្មការរៀបចំបោះពុម្ពសៀវភៅធម៌-វិន័យព្រះពុទ្ធសាសនាសម្រេចយកសៀវភៅ "ភិក្ខុបាតិមោក្ខ **បាលី**-ប្រែ" មកបោះពុម្ពជា**បន្ទាន់** ដើម្បីឆ្លើយត**ប**នឹងសំណូ**មព**ររបស់ព្រះសង្ឃ ។

យើងខ្ញុំគណៈកម្មការរង់ចាំទទួលការរិះគន់កែលម្អពីពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋាន ។

ដោយតេជានុភាព នៃភិក្ខុបាតិមោក្ខ បាលី-ប្រែនេះ សូមប្រជាជន និងប្រទេសកម្ពុជា ប្រកបដោយ សន្តិភាព សេរីភាព សុភមង្គល និងសំបូររុងរឿងជានិច្ចនិរន្តន៍ ។

## វិនយោ សាសនស្ស មូលំ

"វិន័យ ជាឫសគល់ នៃព្រះពុទ្ធសាសនា"

ភ្នំពេញ, ថ្ងៃទី ១៩ សីហា ឆ្នាំ ១៩៨៨

គណៈកម្មការរៀបចំ

បោះពុម្ពសៀវភៅធម៌-វិន័យព្រះពុទ្ធសាសនា

សាធារណរដ្ឋប្រជាមានិតកម្ពុជា
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រុមប្រឹក្សាទូទាំងប្រទេសរណសិរ្ស
សាមគ្គី កសាង ការពារ មាតុភូមិកម្ពុជា

*លេខ: ៣៥.៨៥ ក.រ.ស*

*ភ្នំពេញ, ថ្ងៃទី ៦ សីហា ១៩៨៥*

# សេចក្តីសម្រេច

## ស្តីពីការបង្កើតគណៈកម្មការរៀបចំបោះពុម្ពសៀវភៅ ធម៌វិន័យពុទ្ធសាសនា

- បានឃើញសេចក្តីសម្រេចលេខ ៣៧៧ ស.រ.ម.ឈ ចុះថ្ងៃទី ២៣ វិច្ឆិកា ១៩៨២ ស្តីពីការបង្កើតក្បាលម៉ាស៊ីន នៃទីស្តីការក្រុមប្រឹក្សាទូទាំងប្រទេសរណសិរ្ស,

- បានឃើញកំណត់ហេតុលេខ ៥៨.៨៥ ន.ស ចុះថ្ងៃទី ៣១ ឧសភា ១៩៨៥ ស្តីពីការប្រជុំរៀបចំសមាសភាព គណៈកម្មការបោះពុម្ពសៀវភៅធម៌វិន័យព្រះពុទ្ធសាសនា,

- បានឃើញសំណើឡើងរបស់គណៈកម្មការ ដោយមានការឯកភាពរបស់ព្រះវិន័យធរ *ទេព . វង្ស* ផង,

- បានឃើញកំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាទូទាំងប្រទេសរណសិរ្ស ចុះថ្ងៃទី ៦ សីហា ១៩៨៥,

## គណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សាទូទាំងប្រទេសរណសិរ្ស

## សម្រេច

ប្រការ ១ – បង្កើតគណៈកម្មការរៀបចំពិនិត្យ បោះពុម្ពសៀវភៅធម៌វិន័យព្រះពុទ្ធសាសនា ដែលមានសមាសភាព ដូចខាងក្រោមនេះ

| | | | |
|---|---|---|---|
| ១ — | ព្រះវិន័យធរ | *ទេព វង្ស* | សហប្រធានកិត្តិយស |
| ២ — | សមមិត្ត | *មិន យ៉ិន* | សហប្រធានកិត្តិយស |
| ៣ | ព្រះសង្ឃត្ថេរ | *អ៊ុម ស៊ុម* | ប្រធាន |
| ៤ | ព្រះតេជព្រះគុណ | *សរ មៀង* | អនុប្រធាន |
| ៥ | សមមិត្ត | *ដោក សាម៉ុល* | — |
| ៦ — | សមមិត្ត | *ស៊ិង ហ៊ុត* | |
| ៧ — | ព្រះតេជព្រះគុណ | *នន់ ង៉ែត* | សមាជិក |
| ៨ — | — | *កែន វង្ស* | — |
| ៩ — | – | *អ៊ុម ទិត* | — |
| ១០ — | — | *ង៉ិន កេន* | |
| ១១ — | — | *អន ហ៊ុម* | — |
| ១២ — | — | *គង់ នូ* | — |
| ១៣ — | សមមិត្ត | *ម៉ី យ៉ាំ* | — |
| ១៤ — | — | *ហាស់ កា* | — |
| ១៥ | | *ស៊ុម អ៊ុម* | — |
| ១៦ | — | *ហេង លោងហោ* | — |
| ១៧ | — | *ចាយ រ៉ស់* | — |
| ១៨ | — | *អ៊ុក ម៉ៅ* | — |
| ១៩ — | – | *ផា សាន* | - |
| ២០ | — | *ផា ក្រិស្នា* | — |

*ប្រការ ២* — គណៈកម្មការនេះ *មានសកម្មភាព* បំពេញការកិច្ចពិនិត្យស្រាវជ្រាវ ត្រិះរិះពិចារណា រៀបចំកែលម្អគ្រប់ខ្ទឹមសារ ជៀសវាងការខុសឆ្គងដល់ទំនៀមទម្លាប់សង្គមយើង ។

*ប្រការ ៣* — យោងតាមសំណើ របស់អង្គប្រជុំ តាមកំណត់ហេតុ

លេខ៥៨ / ៨៥ ន.ស ចុះថ្ងៃទី ៣១ ឧសភា ១៩៨៥ ស្តីបោះពុម្ពជាបំរុងនូវសៀវភៅ គោលគិហិបដិបត្តិ ។ និងបន្តទៀតនូវសៀវភៅសត្តបរិត្ត-ទ្វាទសបរិត្ត ព្រមទាំងភិក្ខុបាដិមោក្ខបាលី-ប្រែ ។

*ប្រការ ៤* - គ្រប់ឯកសារទាំងអស់ ដែលត្រូវបោះពុម្ព លុះតែមានការអនុញ្ញាតយល់ព្រមពីថ្នាក់លើជាមុនសិន ទើបអាចបោះពុម្ពបាន ។

*ប្រការ ៥* -- សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.គណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សាទូទាំងប្រទេសរណសិរ្ស

*សាមគ្គី កសាង ការពារមាតុភូមិកម្ពុជា*

អនុប្រធានអចិន្ត្រៃយ៍

ហត្ថលេខា និង ត្រា

*ម៉ែន ឆន*

# មាតិកា


| លេខរៀង | ឈ្មោះធម៌ | ទំព័រ |
|---|---|---|
| ១ | ប្រវត្តិ បាតិមោក្ខ | ក |
| ២ | របៀបធ្វើបុព្វករណបុព្វកិច្ច នៃ សង្ឃឧបោសថ | ១ |
| ៣ | របៀបធ្វើបុព្វករណបុព្វកិច្ច នៃ សង្ឃបវារណា | ៣១ |
| ៤ | សេចក្តីពន្យល់ | ៣៦ |
| ៥ | និទានុទ្ទេស | ៤១ |
| ៦ | បារាជិក ៤ | ៤២ |
| ៧ | សង្ឃាទិសេស ១៣ | ៤៥ |
| ៨ | អនិយត ២ | ៥៧ |
| ៩ | និស្សគ្គិយបាចិត្តិយ ៣០ | ៥៨ |
| ១០ | បាចិត្តិយ ៩២ | ៦៩ |
| ១១ | បាដិទេសនីយ ៤ | ៩០ |
| ១២ | សេខិយវត្ត ៧៥ | ៩៣ |
| ១៣ | ធម៌សម្រាប់រម្ងាប់នូវអធិករណ៍ ៧ | ១០៣ |
| ១៤ | ការសម្តែង បាតិមោក្ខសង្ខេប | ១០៦ |
| ១៥ | បារិសុទ្ធិឧបោសថ | ១០៩ |
| ១៦ | អធិដ្ឋានឧបោសថ | ១១១ |
| ១៧ | សង្ឃបវារណា | ១១៣ |
| ១៨ | បវារណានៃគណៈ គឺភិក្ខុ ៤ រូប | ១១៧ |
| ១៩ | បវារណានៃ ភិក្ខុ ៣ រូប | ១១៨ |

២០ បវារណានៃ ភិក្ខុ ២ រូប ១២០
២១ បវារណាដោយអធិដ្ឋាន ១២២
២២ សមានវស្សិកា បវារណា ១២២
២៣ របៀបចូលវស្សា ១២៤
២៤ បាលីសម្ដែងប្រោះព្រួសីល ១២៨
២៥ ប្រយោជន៍ នៃវិន័យ ១២៩
២៦ អភិណ្ហបច្ចវេក្ខណៈ ១៣០
២៧ ទសធម្មសុត្តកាថា ១៣០
២៨ សីមាវិធី ១៣២
២៩ សីមាវិនិច្ឆ័យសង្ខេប ១៣៦

## មុននឹងអានរៀនសូមកែពាក្យខុសឲ្យត្រូវសិន

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ |
|---|---|---|---|
| ឃ | ២១ | ដើម្ប | ដើម្បី |
| ១៩ | ៥ | បញ្ញត្តសិតិ | បញ្ញត្តិសតិ |
| ២០ | ៨ | បញ្ញត្តាឡស | បញ្ញត្តាឡើស |
| ២៩ | ១៣ | ចាតទ្ទសី | ចាតុទ្ទសី |
| ៣០ | ៩ | អរិជ្ជហិត្វា | អវិជហិត្វា |
| ៣៥ | ៦ | អរិជ្ជហិត្វា | អវិជហិត្វា |
| ៤២ | ១៥ | ជិវិតា | ជីវិតា |
| ៤៣ | ១១ | អញាត្រ | អញ្ញត្រ |
| ៤៨ | ២០ | សេនាសន្នៈ | សេនាសនៈ |
| ៥៣ | ៩ | ឧនោ | ឩនោ |
| ៥៥ | ២ | អនយត | អនិយត |

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ |
|---|---|---|---|
| ៥៥ | ១០ | វាចារ ួរជៀ | វាចាគួរជៀ |
| ៥៧ | ១៤ | ឧនស្ស | ឧុនស្ស |
| ៦២ | ៧ | បហិណេិត្ត | បហិណិត្ត |
| ៦២ | ១៧ | និស្សគ្គិយ | និស្សគ្គិយ |
| ៦២ | ១៦ | គប្ប | គប្ប៍ |
| ៦៤ | ៣ | ធោរវាបេយ្យ | ធោរាបេយ្យ |
| ៦៤ | ១៥ | ឧទបញ្ញ | ឧុនបញ្ញ |
| ៦៥ | ២ | ត្រាតែបែក | ត្រាតែបែក |
| ៦៥ | ៩ | សាដិកចីវរ | សាដិកចិវរ |
| ៦៥ | ១៦ | ចីវរនោះ | ចិវរនោះ |
| ៦៧ | ៣ | មាសិបុណ្ណមំ | មាសបុណ្ណមំ |
| ៧៦ | ២ | ភផ្លេយ្យ | ភុញ្ជេយ្យ |
| ៧៨ | ១២ | ចន្ទញ | ជន្ទញ |
| ៨០ | ១៥ | ឧទរីសតិវស្សំ | ឧុទរីសតវស្សំ |
| ១១១ | ២ | អធិដ្ឋាន ឧបោសថោ | អធិដ្ឋានឧបោសថោ |
| ១១១ | ៧ | ឧដ្ឋាបន | ឧបដ្ឋាន |
| ១១៥ | ១០ | មុខជាទិង | មុខជាទឹង |
| ១២៨ | ១៣ | នោសក្ខិតពុំ | នោ សក្ខិតពុំ |
| ១២៩ | ១២ | _ជិនគោចរ | _ជិនគោចរ |
| ១៣៤ | ៤ | ឧបោសថ-គារ | ឧបោសថាគារ |
| ១៤២ | ១៤-១៥ | ឮសាណា | ឮសាន |

# ប្រវត្តិបាតិមោក្ខ

គម្ពីរមហាវគ្គ. ផ្នែកខាងវិន័យបិដក បឋមភាគ សៀវភៅទី ៦ ទំព័រ ៣៤១ បានអធិប្បាយលើពាក្យបាតិមោក្ខថា : **អាទិមេតំ មុខមេតំ បមុខមេតំ កុសលានំ ធម្មានំ តេន វុច្ចតិ បាតិមោក្ខន្តិ** " ធម្មជាតនេះជាដើម ធម្មជាតនេះ ជាប្រធាន ធម្មជាតនេះ ជាប្រមុខនៃកុសលធម៌ទាំងឡាយ ហេតុនេះ តថាគត ហៅថា **បាតិមោក្ខ** " ។ បាតិមោក្ខ មានការទាក់ទងដោយឧបោសថកម្ម និងសីមាយ៉ាងជិតស្និទ្ធ ។

ក្នុងទីនេះ យើងនឹងធ្វើអត្ថាធិប្បាយអំពីប្រវត្តិបាតិមោក្ខ និងកិច្ចការខ្លះៗ នៃឧបោសថកម្ម ដែលព្រះពុទ្ធជាម្ចាស់ ទ្រង់អនុញ្ញាតដល់ភិក្ខុដែលចូលរួមក្នុងការសម្តែង បាតិមោក្ខ ។ ក្នុងគម្ពីរមហាវគ្គដដែលត្រង់ទំព័រ ៣៣៦ តទៅ យើងឃើញថា ដើមឡើយ នៅពេលដែលព្រះពុទ្ធជាម្ចាស់ទើបនឹងផ្តើមផ្សាយព្រះពុទ្ធសាសនា (កាលទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ) គេមិនទាន់ឃើញមានការសម្តែងបាតិមោក្ខក្នុងចំណោមពួកភិក្ខុ ( អ្នកបួស ) ក្នុងព្រះពុទ្ធសាសនានៅឡើយទេ ។ ចំណែកខាងពួកបរិព្វាជក អ្នកបួសក្នុងលទ្ធិដទៃទៀត ជាក្រុមអាជីវក ក្រោមការដឹកនាំនៃគ្រូម្នាក់ ឈ្មោះ និគន្ថនាដបុត្ត តែងប្រជុំគ្នាក្នុងថ្ងៃទី. ១៤ ទី ១៥ និងទី ៨ នៃបក្ស ( គឺ ១៥ ថ្ងៃ ម្តង ) ដើម្បីផ្ទៀងផ្ទាត់អំពីការប្រតិបត្តិរៀងៗខ្លួន ។ ព្រះបាទពិម្ពិសារ ដែលជាឧបដ្ឋាកមួយយ៉ាងចម្បង ក្នុងព្រះពុទ្ធសាសនាសម័យនោះ បានឃើញនូវការប្រជុំគ្នា នៃអ្នកបួសក្រុមនេះជាញឹកញយផ្ទាល់ព្រះអង្គ ក៏បាននាំរឿងនេះ ទៅទូលស្នើព្រះពុទ្ធជាម្ចាស់ឲ្យអ្នកបួសក្នុងព្រះពុទ្ធសាសនា មានការជួបជុំ ដើម្បីជាប្រយោជន៍ដល់ការផ្ទៀងផ្ទាត់ធម៌វិន័យ ដូចលទ្ធិដទៃផង ។ ព្រះអង្គទ្រង់អនុញ្ញាតឲ្យធ្វើតាម ។ នេះសឲ្យឃើញថា ពិធីប្រជុំដែលមានសភាពជាឧបោសថកម្ម ក្នុងព្រះពុទ្ធសាសនា មានដើមកំណើត

មកអំពីក្រុមអ្នកបួសក្រៅព្រះពុទ្ធសាសនា ដោយពិតប្រាកដ ។

នៅក្នុងវិន័យបិដក ព្រះពុទ្ធជាម្ចាស់បានអនុញ្ញាតឲ្យភិក្ខុសង្ឃជួបគ្នារាល់ៗ ថ្ងៃទី ៨ ថ្ងៃទី ១៤ ឬ ទី ១៥ ដើម្បីឲ្យមានសាមគ្គីធម៌ និងដើម្បីបញ្ជាក់សួរអំពីចំណុចខ្វះៗនៃធម៌វិន័យ ។ ប៉ុន្តែការជួបគ្នាបែបនេះ ក្លាយទៅជាការជួបគ្នាជជែកលេងឥតប្រយោជន៍ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់កម្រិតឲ្យសម្តែងប្រាប់គ្នា នូវចំណុចវិន័យទាំងឡាយ ដែលព្រះអង្គបានសម្តែងហើយ ថែមទាំងកម្រិតឲ្យសម្តែងនូវបាតិមោក្ខក្នុងថ្ងៃទី ១៤ ឬទី ១៥ ទាំងខ្នើតទាំងរនោចទៀតផង ដូចមានបាលីថា **យន្នូនាហំ យានិ មយា ភិក្ខូនំ បញ្ញត្តានិ សិក្ខាបទានិ តានិ នេសំ បាតិមោក្ខុទ្ទេសំ អនុជា-នេយ្យំ សោ នេសំ ភវិស្សតិ ឧបោសថកម្មន្តិ អនុ-ជានាមិ ភិក្ខវេ បាតិមោក្ខំ ឧទ្ទិសិតុំ** បើដូច្នោះមានតែតថាគតអនុញ្ញាតសិក្ខាបទទាំងឡាយនោះ ដែលតថាគតបញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយ ឲ្យជាបាតិមោក្ខុទ្ទេសដល់ភិក្ខុទាំងឡាយនោះ បាតិមោក្ខុទ្ទេសនោះនឹងបានជាឧបោសថកម្មរបស់ភិក្ខុទាំងឡាយនោះ, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុសម្តែងនូវបាតិមោក្ខ ។ ជាដំបូងបង្អស់ភិក្ខុដែលមករួមប្រជុំ ត្រូវប្រកាសប្រាប់បារិសុទ្ធិរបស់ខ្លួន ( **បារិសុទ្ធិំ អាយស្មន្តោ អារោចេថ** លោកទាំងឡាយអ្នកមានអាយុ សូមប្រាប់នូវបារិសុទ្ធិ ) ។ ត្រង់ចំណុចនេះ និកាយមួយឈ្មោះមូលសវាស្តិវាទ ដែលជានិកាយមានលក្ខណៈជិតគ្នាទៅនឹងថេរវាទនេះ ហើយជានិកាយមួយចាស់បំផុត ដែលឃ្លាតចេញមកពីថេរវាទនោះ បានប្រាប់យើងថា ការប្រកាសប្រាប់បារិសុទ្ធិនេះ សម្រាប់តែភិក្ខុដែលមិនបានចូលរួមប្រជុំធ្វើឧបោសថកម្មនោះប៉ុណ្ណោះ ។ គោលបំណងរបស់ឧបោសថ-កម្ម បញ្ជាក់យ៉ាងខ្លាំង ទៅលើបារិសុទ្ធិរបស់ភិក្ខុមួយរូបៗ ដូចមានបាលី ថា

**យស្ស សិយា អាបត្តិ សោ អាវិករេយ្យ** ភិក្ខុណាត្រូវអាបត្តិ, ភិក្ខុនោះត្រូវប្រកាសប្រាប់គេ ។ ក្នុងសមន្តបាសាទិកា យើងឃើញអត្ថាធិប្បាយរបស់ព្រះពុទ្ធឃោសាចារ្យថា **សាបត្តិកេន ភិក្ខុនា បាតិមោក្ខំ ន សោតព្វំ** ភិក្ខុដែលប្រកបដោយអាបត្តិមិនត្រូវស្តាប់បាតិមោក្ខទេ ។ បើយើងយកអត្ថបទទាំងនេះ មកពិចារណាមើលឃើញថា និកាយមូលសវ័ស្តិវាទ ចំពោះបារិសុទ្ធិរបស់ភិក្ខុដែលមិនបានមកប្រជុំនោះ បានន័យសមរម្យមែន ។

ចំណុចមួយទៀត ដែលហាក់ដូចជាមានការរេត់ពីចំណាងដើម នៃបាតិមោក្ខ គឺភិក្ខុទាំងអស់ដែលមកប្រជុំតាមទម្លាប់សព្វថ្ងៃនេះ ត្រូវតែសម្តែងអាបត្តិ, នេះជាទម្លាប់ដែលយើងមានសព្វថ្ងៃ ។ បើយើងពិចារណាមើលពាក្យសួររបស់លោកអ្នកសម្តែង នៅពេលបញ្ចប់ឧទ្ទេសនីមួយៗ ឧទាហរណ៍ដូចជា **យោ បន ភិក្ខុ យាវតតិយំ អនុស្សាវិយមានេ សរមានោ សន្តិំ អាបត្តឹ នាវិករេយ្យ សម្បជានមុសាវាទស្ស ហោតិ** ភិក្ខុណាមួយកាលរលឹកឃើញថាមានអាបត្តិហើយ មិនព្រមប្រកាសប្រាប់ទោសកំហុសរបស់ខ្លួនទេ, ភិក្ខុនោះត្រូវសម្បជានមុសាវាទទុក្កដ ។ ឃើញថាតាមលំនាំដើម ភិក្ខុត្រូវប្រកាសប្រាប់បារិសុទ្ធិ ក្នុងមួយឧទ្ទេសម្តងៗ ។ នេះជាហេតុនាំឲ្យយឺតយូរដល់ការសម្តែង ហើយជាហេតុមួយ នាំឲ្យមានការនឿយណាយទៀតផង ។ ដូច្នេះដើម្បីកុំឲ្យមានការអាក់អន្លួលតាមដំណាក់ឧទ្ទេសនីមួយៗ ភិក្ខុសង្ឃ ក៏បានសម្រេចចិត្ត ប្រកាសប្រាប់ទោសកំហុសរបស់ខ្លួន មុនពេលសម្តែងបាតិមោក្ខ ។ បើទុកជាដូច្នោះក៏ដោយ មាត្រាចាស់ដែលមាននៅក្នុងបាតិ-មោក្ខ ដែលថាសូមឲ្យប្រកាសប្រាប់ទោស នៅចុងចប់ឧទ្ទេសនីមួយៗ ក៏នៅតែមានក្នុងទីនោះៗដដែល ( មិនបានដកចេញទេ ) ។

ដើមកំណើតរបស់បាតិមោក្ខ យើងជួបប្រទះនៅក្នុងសុត្តន្តបិដកជាច្រើនកន្លែង ។ មាត្រាបាចិត្តិយមួយ បញ្ជាក់ចំណុចនេះយ៉ាងច្បាស់លាស់ ឧទាហរណ៍ ឥធាវុសោ ខោ អហំ ជានាមិ អយម្បិ ភិរ ធម្មោ សុត្តាគតោ សុត្តបរិយាបន្នោ អន្វឡោមាសំ ឧទ្ទេសំ អាគច្ឆតីតិ ខ្ញុំទើបតែនឹងដឹងក្នុងកាលអម្បាញ់មិញនេះឯងថា ធម្មជាសិក្ខាបទនេះមកហើយក្នុងសូត្រ រាប់ចូលហើយក្នុងសូត្រ មកកាន់ឧទ្ទេសរាល់កន្លះខែ ។

បាតិមោក្ខ មិនមែនបានសេចក្ដីថា ជាវិន័យបិដកទាំងមូលទេ គ្រាន់តែជាចំណែកមួយដ៏សំខាន់ ប្រាប់មាតិកាប្រតិបត្តិដល់ភិក្ខុសង្ឃប៉ុណ្ណោះ ។ ដើម្បីនឹងយល់បាតិមោក្ខឲ្យច្បាស់លាស់ យើងត្រូវមានគម្ពីរសុត្តវិភង្គដែលមានរបៀបរៀបចំសម្រាប់អាបត្តិនីមួយៗ ដូចតទៅ :

១. រឿងរ៉ាវដែលជាហេតុនាំឲ្យកើតមានមាត្រានៃអាបត្តិ ,

២. មាត្រាអាបត្តិ ;

៣. បទភាជនិយ ឬ អដ្ឋកថាចាស់ ( គឺអដ្ឋកថាដែលគេបានធ្វើហើយស្រេចដើម្បីអធិប្បាយពន្យល់មាត្រានីមួយៗ ឲ្យបានច្បាស់លាស់ នៅក្នុងវិន័យបិដកហ្នឹងឯង ) ,

៤. រឿងច្រើនទៀត ដែលបញ្ជាក់អំពីសភាពផ្សេងៗ កំហុសធ្ងន់ឬស្រាលៗ ជួនកាលគេឃើញមានរឿងប្រឌិត ដើម្បីដោះស្រាយស្ថានការណ៍មួយៗ ដោយមានទាក់ទងទៅដល់ទេវតាទៀតផង ។

## ប្រយោជន៍របស់បាតិមោក្ខគឺ

ក) ដើម្បីបញ្ជាក់អំពីជីវភាពអ្នកបួស ដែលប្លែកគ្នាអំពីជីវភាពគ្រហស្ថ ,

ខ) ដើម្បីបញ្ជាក់ការប្រព្រឹត្តមិនសមរម្យរបស់ភិក្ខុ ដែលជាហេតុនាំឲ្យមានការរិះគន់អំពីគ្រហស្ថ (នៅក្នុងវិន័យបិដកគេឃើញមានការរិះគន់ជាច្រើន ដែលជាហេតុ

នាំឱ្យព្រះពុទ្ធជាម្ចាស់ប្រកាសជាខឲ្យារិក ហាមប្រាមមិនឱ្យភិក្ខុប្រព្រឹត្តតទៅទៀត),

គ) ដើម្បីហាមឃាត់ភិក្ខុសង្ឃ កុំឱ្យទៅជាអ្នកមានភារៈដ៏ធ្ងន់ទ្រាំមិនបាន ខាងផ្នែកការរស់នៅ ទៅលើប្រជាជន ( សុភរតា ) ,

ឃ) ដើម្បីរក្សាសាមគ្គីធម៌និងសេចក្ដីសប្បាយរបស់សង្ឃ ;

ង ) ដើម្បីរក្សាសេចក្ដីបរិសុទ្ធិរបស់ភិក្ខុសង្ឃ ។

# ភិក្ខុប្បាតិមោក្ខ

## ពាក្យណែនាំ

មុននឹងសិក្សាព្រះពុទ្ធវចនៈ ជាមគធភាសា គឺភាសាបាលីដូចជាភិក្ខុប្បាតិ-មោក្ខជាដើម, ពុទ្ធសាសនិកជាតិខ្មែរមានភិក្ខុសង្ឃជាដើម ត្រូវចេះអក្ខរវិធី មានអក្ខ-រប្បភេទ ១០ យ៉ាងគឺ សិថិល, ធនិត, ទីឃៈ, រស្សៈ, គរុ, លហុ, និគ្គហិត, វិមុត្ត ជាដើម ដើម្បីវិនិច្ឆ័យថា តើការសូត្របាលីបែបណាទើបត្រឹមត្រូវ។ ការសូត្របាលី ឲ្យឃ្លាតចាកបែបនៃអក្ខរវិធី ឈ្មោះថាប្រព្រឹត្តល្មើសនឹងពុទ្ធប្បញ្ញត្តិ - ពុទ្ធានុញ្ញាត ដែលមានចែងទុកយ៉ាងច្បាស់លាស់ក្នុងគម្ពីរចុល្លវគ្គភាគទី ១០ ផ្នែកវិន័យបិដក ត្រង់ទំព័រ ២៣០-៣១ បទ: ២៥០-៥១ ថា :

**ន ភិក្ខវេ ឆន្ទសោ ពុទ្ធវចនំ អារោបេតព្វំ យោ អារោបេយ្យ អាបត្តិ ទុក្កដស្ស, អនុជានាមិ ភិក្ខវេ សកាយ និរុត្តិយា ពុទ្ធវចនំ បរិយាបុណិតុំ**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគប្បីលើកយកពុទ្ធវចនៈមកសូត្រតាមបែបឆន្ទ គឺឫគ្វេទភាសាសំស្ក្រឹតទេ, ភិក្ខុណាលើកមកសូត្របែបនេះត្រូវអាបត្តិទុក្កដ, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុរៀនពុទ្ធវចនៈ តាមសកនិរុត្តិ គឺភាសារបស់ខ្លួន ( មាគធី ) ។

ក្នុងគម្ពីរសមន្តបាសាទិកា អដ្ឋកថាវិន័យ ត្រង់ខុទ្ទកវត្ថុខន្ធកវណ្ណនាថា :

**សកាយ និរុត្តិយាតិ ឯត្ថ សកា និរុត្តិ នាម សម្មាសម្ពុទ្ធេន វុត្តប្បការោ មាគធិកវោហារោ**

ត្រង់ពាក្យថា "សកនិរុត្តិ" តាមភាសារបស់ខ្លួន សេចក្តីថា ដែលហៅថាភាសារបស់ខ្លួន សំដៅយកភាសាអ្នកមគធៈ មានប្រការដែលព្រះសម្មា-សម្ពុទ្ធ ពោលហើយ គឺភាសាមាគធីដ៏ត្រឹមត្រូវ ដែលព្រះអង្គបានយកមកប្រើក្នុងការពោលសម្តែងនូវព្រះធម៌វិន័យនោះៗឯង ។ ក្នុងដែនដីឥណ្ឌាមានរដ្ឋមួយធំឈ្មោះ "មគធៈ" ភាសា ឬពាក្យរបស់អ្នកមគធរដ្ឋនោះ ជាប្រាជ្ញគឺភាសាហៅថា មាគធី "ភាសាអ្នកមគធៈ ឬមគធភាសា" ជាភាសាដើមដំបូងអស់កាលជាយូរហើយ ដូចភាសាដទៃទៀត មានភាសាទ្រាវិឌ, មារាដ្ឋី, សិទ្ធិជាដើម មានគោលពិសោធបានដោយគាថា ដែលអ្នកប្រាជ្ញបុរមបុរាណប្រព័ន្ធទុកហើយនាំគ្នាមកថា :

**សា មាគធី មូលភាសា នរា យា យាទិកប្បិកា ព្រហ្មានោ ចស្សុតាលាបា សម្ពុទ្ធា ចាបិ ភាសរេ**

"ភាសាដែលមនុស្សពីព្រេងនាយក្តី, ព្រហ្មក្តី, អ្នកដែលមិនធ្លាប់ឮពាក្យមនុស្សសោះក្តី, ព្រះសម្ពុទ្ធក្តី ពោលសម្តែងឈ្មោះថា មាគធី ជាភាសាដើម"។ ( សូមមើលរូបសិទ្ធិ ពាលាវតារដីកា ) ។

សូមបញ្ជាក់ថា : ដើមហេតុដែលនាំឱ្យមានពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត ដូច្នេះនេះមកពីមានភិក្ខុពីររូបមានសេចក្តីលំបាកចិត្តមិនពេញចិត្ត នឹងបែបសូត្របាលីឮសូរសំឡេងផ្សេងៗគ្នា ព្រោះពួកភិក្ខុមានជាតិមានភាសាផ្សេងទីទៃពីគ្នា សូត្របាលីតាមអណ្តាតរាល់ជាតិ ឧទាហរណ៍ ដូចអ្នកកាន់ព្រះពុទ្ធសាសនា ដែលយើងបានដឹងជាក់សព្វថ្ងៃនេះ សុទ្ធតែសូត្របាលីឮសូរខុសគ្នាទាំងអស់ដូចយ៉ាងពាក្យបាលីថា "**បញ្ច**" ដែលប្រែថា "ប្រាំ" នេះខ្មែរថា "**បាញ់-ចៈ**"

ថៃ-លាវ ថា " ប៉ាន់-ចះ ", អ្នកលង្កាទ្វីប ថា " ប៉ាញ់-ចិ ".
ភូមា ថា "ប៉ិឞ-សះ" , មនថា "ប៉ាញ-ចៀះ" សំដៅសេចក្តីថា "ប្រាំ" ដូចគ្នាទាំងអស់ ។ល។ល។

ដោយហេតុដូចនេះឯង បានជាភិក្ខុទាំងពីររូបនោះ ក្រាបទូលសូមឲ្យព្រះសម្មាសម្ពុទ្ធ ទ្រង់អនុញ្ញាតឲយពួកពុទ្ធសាសនិក មានភិក្ខុសង្ឃជាដើម រៀនពុទ្ធវចនៈជាឆន្ទ គឺឲ្យត្រូវជាភាសាសំស្ក្រឹត តែព្រះអង្គយល់ឃើញកាលវែង ទ្រង់ត្រាស់បន្ទោសជាច្រើន ហើយទ្រង់ត្រាស់បញ្ញត្តហាមមិនឲ្យសូធ្យពុទ្ធវចនៈ ថែបជាឆន្ទគឺសំស្ក្រឹតភាសា ព្រោះភាសានេះជាមន្ត្រៈ មានបែបបទច្រើន លំបាកពេក មិនងាយអ្នកផងសូធ្យបានរាល់ជាតិដោយងាយ, ពុទ្ធសាសនាចម្រើនល្អតលាស់ពុំបាន ទ្រង់អនុញ្ញាតឲ្យសូធ្យពុទ្ធវចនៈ តាមសកនិរុត្តិ ឬសកភាសា គឺសូធ្យពុទ្ធវចនៈជាភាសាមគធៈ ឲ្យទន់ទៅតាមសូរសម្លេងនៃអណ្តាតជាតិខ្លួនអាចរលាស់ទៅបាន ។ មនុស្សជាតិដែលជាសកនិរុត្តិ ( សកាយ និរុត្តិយា ) ។ សេចក្តីសរុបយ៉ាងខ្លីងាយយល់ ខ្មែរត្រូវសូធ្យពុទ្ធវចនៈតាមខ្មែរ , ថៃតាមថៃ, លាវតាមលាវ, មនតាមមន, លង្កាតាមលង្កា ជាដើម ត្រូវសូធ្យតាមភាសារបស់ខ្លួនរាល់ជាតិ ។

សូមឲ្យពុទ្ធសាសនិកជាតិខ្មែរ សូធ្យពុទ្ធវចនៈរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ តាមសំនៀងភាសារបស់ខ្លួន ឲ្យត្រឹមត្រូវតាមបាលី ក្នុងគម្ពីរចុល្លវគ្គ ដែលបានចង្អុលប្រាប់មកហើយខាងដើម, មិនគួរសូធ្យ ទៅតាមសំនៀងភាសាបរទេសឡើយ ។

ដោយគណៈកម្មការសង្ឃ

ជាតិខ្មែរ

# បុព្វករណបុព្វកិច្ច

## នៃ សង្ឃឧបោសថ និង សង្ឃបវារណា

កិច្ចដែលត្រូវធ្វើមុនពេលធ្វើឧបោសថ ឬ បវារណារបស់សង្ឃ គឺមុនពេលដែលសង្ឃមកប្រជុំ ហៅថា **បុព្វករណៈ** មាន ៤ យ៉ាង គឺ **សម្មជ្ជនី** ការបោសច្រាសរោងឧបោសថ ឬបវារណា ១ **បទីបៈ** ការអុជប្រទីបក្នុងពេលយប់ (ងងឹត) ១ **ឧទកៈ** ការតម្កល់ទុកនូវទឹកឆាន់ និងទឹកប្រើប្រាស់ ១ **អាសនៈ** ការក្រាលអាសនៈមានកន្ទេលជាដើម ១ ។

កិច្ចការដែលត្រូវធ្វើក្នុងពេលនៃសង្ឃបានមកប្រជុំហើយ ជាកិច្ចត្រូវធ្វើមុនពេលធ្វើឧបោសថកម្ម ឬបវារណាកម្មរបស់សង្ឃ គឺមុនពេលសម្តែងបាតិមោក្ខ ឬតាំងញត្តិហៅថា **បុព្វកិច្ច** មាន ៥ យ៉ាងគឺ **ឆន្ទៈ** ការនាំឆន្ទៈរបស់ភិក្ខុដែលមិនបានមកប្រជុំ ១ **បារិសុទ្ធិ** ការនាំបារិសុទ្ធិរបស់ភិក្ខុដែលមិនបានមកប្រជុំ ១ **ឧតុក្ខានៈ** ការប្រាប់រដូវ ១ **ភិក្ខុគណនា** ការរាប់ចំនួនភិក្ខុ ១ **ឱវាទៈ** ការឲ្យឱវាទដល់ភិក្ខុនី ១ ។

# របៀបធ្វើបុព្វករណបុព្វកិច្ច

## នៃសង្ឃឧបោសថ (ឧបោសថរបស់សង្ឃ)

របៀបធ្វើបុព្វករណបុព្វកិច្ចនោះ ត្រូវធ្វើតាមវិធីដូចតទៅនេះ ជាដំបូងភិក្ខុអ្នកសូត្រ (អ្នកផ្តួចផ្តើមឧបោសថ ឬធ្វើឧបោសថ) ត្រូវសន្មតប្រកាសប្រាប់សង្ឃ សូធ្យថា **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (៣ ដង) ។

រួចសូត្រថា សុណាតុ មេ ភន្តេ សង្ឃោ, យទិ សង្ឃស្ស បត្តកល្លំ, អហំ អាយស្មន្តំ ឥត្ថន្នាមំ វិនយំ បុច្ឆេយ្យំ ។

ភិក្ខុអ្នកឆ្លើយ ( អ្នកសម្តែងបាតិមោក្ខ ) ត្រូវសូត្រប្រកាសប្រាប់សង្ឃ សូត្រថា នមោ តស្ស ភគវតោ អរហតោ សម្មា-សម្ពុទ្ធស្ស ( ៣ ដង ) ។ រួចសូត្រថា សុណាតុ មេ ភន្តេ សង្ឃោ, យទិ សង្ឃស្ស បត្តកល្លំ, អហំ អាយស្មតា ឥត្ថន្នាមេន វិនយំ បុដ្ឋោ វិស្សជ្ជេយ្យំ ។

( បើភិក្ខុ សួរ-ឆ្លើយមិនបានសន្មតជាមុនទេ ហើយស្រាប់តែ សួរ-ឆ្លើយវិន័យតែម្តង ត្រូវអាបត្តិទុក្កដ ដែលមានក្នុងឧបោសថក្ខន្ធកៈ ) ។

( ភិក្ខុ អ្នកសួរថា )

សម្មជ្ជនី បទីបោ ច ឧទកំ អាសនេន ច
ឧបោសថស្ស ឯតានិ បុព្វករណន្តិ វុច្ចតិ ។
ឱកាស សម្មជ្ជនី ។

( ភិក្ខុអ្នកឆ្លើយថា ) សម្មជ្ជនករណញ្ច ។

( ភិក្ខុអ្នកសួរថា ) បទីបោ ច ។

( បើក្នុងពេលយប់ ភិក្ខុអ្នកឆ្លើយថា ) បទីបឧជ្ជលនញ្ច ឥទានិ សុរិយាលោកស្ស នត្ថិតាយ បទីបកិច្ចំ អត្ថិ ។

( បើក្នុងពេលថ្ងៃ ភិក្ខុអ្នកឆ្លើយថា ) បទីបឧជ្ជលនញ្ច ឥទានិ សុរិយាលោកស្ស អត្ថិតាយ បទីបកិច្ចំ នត្ថិ ។

(ភិក្ខុអ្នកសួរថា) ឧទកំ អាសនេន ច ។

(ភិក្ខុអ្នកឆ្លើយថា) អាសនេន សហ បានីយបរិភោជនីយ-ឧទកដ្ឋបនញ្ច [១] ។

(ភិក្ខុអ្នកសួរថា) ឧបោសថស្ស ឯតានិ បុព្វករណន្តិ វុច្ចតិ ។

(ភិក្ខុអ្នកឆ្លើយថា ឯតានិ ចត្តារិ វត្តានិ សម្មជ្ជន-ករណាទីនិ សង្ឃសន្និបាតតោ បឋមំ កត្តព្វត្តា, ឧបោសថស្ស ឧបោសថកម្មស្ស បុព្វករណន្តិ វុច្ចតិ, បុព្វករណានីតិ អក្ខាតានិ ។

(ភិក្ខុអ្នកសួរថា) ឆន្ទបារិសុទ្ធិ ឧតុក្ខានំ ភិក្ខុគណនា ច ឱវាទោ ឧបោសថស្ស ឯតានិ បុព្វកិច្ចន្តិ វុច្ចតិ។ ឆន្ទបារិសុទ្ធិ ។

(ភិក្ខុអ្នកឆ្លើយថា) ឆន្ទារហានំ ភិក្ខូនំ ឆន្ទបារិសុទ្ធិ-អាហរណញ្ច [២] ឥធ នត្ថិ ។

(ភិក្ខុអ្នកសួរថា) ឧតុក្ខានំ ។

---

១ ថា បានីយបរិភោជនីយដ្ឋបនញ្ច ក៏បាន, ថា បានីយបរិភោជនីយឧទកដ្ឋបនញ្ច ក៏បាន

២ ថា ឆន្ទបារិសុទ្ធិអាហរណំ (កញ្ច ឥធ នត្ថិ) ។ បើវត្តដែលមានមហាសីមា ហើយមានភិក្ខុទៅឆន្ទៈ និងបារិសុទ្ធិមកនោះមិនបាច់ប្រើបាលីក្នុងវង់ក្រចកនេះឡើយ ។

(ភិក្ខុអ្នកឆ្លើយថា) ហេមន្តានំ តិណ្ណំ ឧតូនំ ឯត្តកំ អតិក្កន្តំ, ឯត្តកំ អវសិដ្ឋំ ឯវំ ឧតុអាចិក្ខនំ, ឧតូនីធ បន សាសនេ ហេមន្តគិម្ហវស្សានានំ វសេន តីណិ ហោន្តិ,

( តទៅក្នុងហេមន្តរដូវបានឧបោសថ ៨ គឺ )

( ១- បើថ្ងៃ ១៥ រោច ខែ កត្តិក ត្រូវថា ) អយំ ហេមន្តឧតុ, អស្មឹ ឧតុម្ហិ អដ្ឋ ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, (នត្ថិ ឧបោសថោ អតិក្កន្តោ[១]), សត្ត ឧបោសថា អវសិដ្ឋា ។

( ២- បើថ្ងៃ ១៥ កើត ខែ មិគសិរ ត្រូវថា ) អយំ ហេមន្តឧតុ, អស្មឹ ឧតុម្ហិ អដ្ឋ ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, ឯកោ ឧបោសថោ អតិក្កន្តោ, ឆ ឧបោសថា អវសិដ្ឋា ។

( ៣- បើថ្ងៃ ១៤ រោច ខែ មិគសិរ ត្រូវថា ) អយំ ហេមន្តឧតុ, អស្មឹ ឧតុម្ហិ អដ្ឋ ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, ទ្វេ ឧបោសថា អតិក្កន្តា, បញ្ច ឧបោសថា អវសិដ្ឋា ។

( ៤- បើថ្ងៃ ១៥ កើត ខែបុស្ស ត្រូវថា ) អយំ ហេមន្តឧតុ, អស្មឹ ឧតុម្ហិ អដ្ឋ ឧបោសថា, ឥមិនា បក្ខេន ឯកោ

---

១ បាលីក្នុងវង់ក្រចកនេះមិនបាច់ថាក៏បាន ។

ឧបោសថោ សម្បវត្តា, តយោ ឧបោសថា អតិក្កន្តា. ចត្តារោ ឧបោសថា អវសិដ្ឋា ។

( ៥. បើថ្ងៃ ១៥ រោច ខែ បុស្ស ត្រូវថា ) អយំ ហេមន្តឧតុ. អស្មិំ ឧតុម្ហិ អដ្ឋ ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បវត្តា, ចត្តារោ ឧបោសថា អតិក្ក-ន្តា, តយោ ឧបោសថា អវសិដ្ឋា ។

( ៦. បើថ្ងៃ ១៥ កើត ខែ មាឃ ត្រូវថា ) អយំ ហេមន្តឧតុ, អស្មិំ ឧតុម្ហិ អដ្ឋ ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បវត្តា, បញ្ច ឧបោសថា អតិក្កន្តា, ទ្វេ ឧបោសថា អវសិដ្ឋា ។

( ៧. បើថ្ងៃ ១៤ រោច ខែ មាឃត្រូវថា ) អយំ ហេមន្តឧតុ. អស្មិំ ឧតុម្ហិ អដ្ឋ ឧបោសថា. ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បវត្តា, ឆ ឧបោសថា អតិក្កន្តា, ឯកោ ឧបោសថោ អវសិដ្ឋោ ។

( ៨. បើថ្ងៃ ១៥ កើត ខែ ផល្គុណ ត្រូវថា ) អយំ ហេមន្តឧតុ, អស្មិំ ឧតុម្ហិ អដ្ឋ ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បវត្តា, សត្ត ឧបោសថា អតិក្កន្តា, អដ្ឋ ឧបោសថា បរិបុណ្ណា ។

( ចប់ ឧបោសថ ៨ ក្នុងហេមន្តរដូវ )

( ក្នុងគិម្ហរដូវមានឧបោសថ ៨ គឺ )

(១ - បើថ្ងៃ ១៥ រោច ខែ ផល្គុណ ត្រូវថា) អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ អដ្ឋ ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, (នត្ថិ ឧបោសថោ អតិក្កន្តោ), សត្ត ឧបោសថា អវសិដ្ឋា ។

(២ - បើថ្ងៃ ១៥ កើត ខែ ចេត្រ ត្រូវថា) អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ អដ្ឋ ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, ឯកោ ឧបោសថោ អតិក្កន្តោ, ឆ ឧបោសថា អវសិដ្ឋា ។

(៣ - បើថ្ងៃ ១៤ រោច ខែ ចេត្រ ត្រូវថា) អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ អដ្ឋ ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, ទ្វេ ឧបោសថា អតិក្កន្តា, បញ្ច ឧបោសថា អវសិដ្ឋា ។

(៤ - បើថ្ងៃ ១៥ កើត ខែ វិសាខ ត្រូវថា) អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ អដ្ឋ ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, តយោ ឧបោសថា អតិក្កន្តា, ចត្តារោ ឧបោសថា អវសិដ្ឋា ។

(៥ - បើថ្ងៃ ១៥ រោច ខែ វិសាខ ត្រូវថា) អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ អដ្ឋ ឧបោសថា, ឥមិនា បក្ខេន ឯកោ

ឧបោសថោ សម្បត្តោ, ចត្តារោ ឧបោសថា អតិក្កន្តា, តយោ ឧបោសថា អវសិដ្ឋា ។

( ៦ - បើថ្ងៃ ១៥ កើត ខែ ជេស្ឋ ត្រូវថា ) អយំ តិម្ហឧតុ, អស្មឹ ឧតុម្ហិ អដ្ឋ ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, បញ្ច ឧបោសថា អតិក្កន្តា, ទ្វេ ឧបោសថា អវសិដ្ឋា ។

( ៧ - បើថ្ងៃ ១៤ រោច ខែ ជេស្ឋ ត្រូវថា ) អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ អដ្ឋ ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, ឆ ឧបោសថា អតិក្កន្តា, ឯកោ ឧបោសថោ អវសិដ្ឋោ ។

( ៨ - បើថ្ងៃ ១៥ កើត ខែ អាសាឍ ត្រូវថា ) អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ អដ្ឋ ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, សត្ត ឧបោសថា អតិក្កន្តា, ( អដ្ឋ ឧបោសថា បរិបុណ្ណា ) ។

( ចប់ឧបោសថ ៨ ក្នុងគិម្ហរដូវ, ប៉ុន្តែបើឆ្នាំ ដែលមានអធិកមាស • លើក ៤ " នោះ ក្នុងគិម្ហរដូវ មានឧបោសថ ១០ គឺ

(១ - បើថ្ងៃ ១៥ រោច ខែ ផល្គុន ត្រូវថា អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ បកតិទសេន អដ្ឋ ឧបោសថា, អធិកមាសវសេន ទស ឧបោសថា,

ឥមស្មឹំ បន ឧតុម្ហិ អធិកមាសោ ភវិស្សតិ, តស្មា ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, (នត្ថិ ឧបោសថោ អតិក្កន្តោ), នវ ឧបោសថា អវសិដ្ឋា ។

(នេះបែបវែង, បើបែបខ្លីត្រូវថា) អយំ គិម្ហឧតុ, អស្មិំ ឧតុម្ហិ ទស ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, (នត្ថិ ឧបោសថោ អតិក្កន្តោ) នវ ឧបោសថា អវសិដ្ឋា ។

(២ - បើថ្ងៃ ១៥ កើត ខែ ចេត្រ ដែលជាខែចូលក្នុងឆ្នាំថ្មីហើយត្រូវថា)

អយំ គិម្ហឧតុ, អស្មិំ ឧតុម្ហិ បកតិវសេន អដ្ឋ ឧបោសថា, អធិកមាសវសេន ទស ឧបោសថា, ឥមស្មឹំ បន សំវច្ឆរេ អធិកមាសោ អត្ថិ, តស្មា ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, ឯកោ ឧបោសថោ អតិក្កន្តោ, អដ្ឋ ឧបោសថា អវសិដ្ឋា ។

(នេះបែបវែង, បើបែបខ្លីត្រូវថា) អយំ គិម្ហឧតុ, អស្មិំ ឧតុម្ហិ អធិកមាសវសេន ទស ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, ឯកោ ឧបោសថោ អតិក្កន្តោ, អដ្ឋ ឧបោសថា អវសិដ្ឋា ។

(៣ - បើថ្ងៃ ១៤ រោច ខែ ចេត្រ ត្រូវថា) អយំ គិម្ហឧតុ,

អស្មឹ ឧតុម្ហិ បកតិវសេន អដ្ឋ ឧបោសថា, អធិក-មាសវសេន ទស ឧបោសថា, តស្មឹ បន សំវច្ឆរេ អធិកមាសោ អត្ថិ, តស្មា ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, ទ្វេ ឧបោសថា អតិក្កន្តា, សត្ត ឧបោសថា អវសិដ្ឋា ។ (នេះបែបវែង, បើបែបខ្លីត្រូវថា) អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ អធិកមាសវសេន ទស ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, ទ្វេ ឧបោសថា អតិក្កន្តា, សត្ត ឧបោ-សថា អវសិដ្ឋា ។

( ៤ - បើថ្ងៃ ១៥ កើត ខែ វិសាខ ត្រូវថា ) អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ បកតិវសេន អដ្ឋ ឧបោសថា, អធិកមាស-វសេន ទស ឧបោសថា, តស្មឹ បន សំវច្ឆរេ អ-ធិកមាសោ អត្ថិ, តស្មា ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, តយោ ឧបោសថា អតិក្កន្តា, ឆ ឧបោសថា អវសិដ្ឋា ។ ( នេះបែបវែង, បើបែបខ្លីត្រូវថា ) អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ អធិកមាសវសេន ទស ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, តយោ ឧបោសថា អតិក្កន្តា, ឆ ឧបោ-សថា អវសិដ្ឋា ។

( ៥-បើថ្ងៃ ១៥ រោច ខែ វិសាខ ត្រូវថា ) អយំ គិម្ហឧតុ, អស្មិំ ឧតុម្ហិ បកតិទិវសេន អដ្ឋ ឧបោសថា, អធិកមាសទិវសេន ទស ឧបោសថា, ឥមស្មិំ បន សំវច្ឆរេ អធិកមាសោ អត្ថិ, តស្មា ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, ចត្តារោ ឧបោសថា អតិក្កន្តា, បញ្ច ឧបោសថា អវសិដ្ឋា ។

( នេះបែបវែង, បើបែបខ្លី ត្រូវថា ) អយំ គិម្ហឧតុ, អធិកមាសទិវសេន ទស ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, ចត្តារោ ឧបោសថា អតិក្កន្តា, បញ្ច ឧបោសថា អវសិដ្ឋា ។

( ៦-បើថ្ងៃ ១៥ កើត ខែ ជេស្ឋ ត្រូវថា ) អយំ គិម្ហឧតុ, អស្មិំ ឧតុម្ហិ បកតិទិវសេន អដ្ឋ ឧបោសថា, អធិកមាសទិវសេន ទស ឧបោសថា, ឥមស្មិំ បន សំវច្ឆរេ អធិកមាសោ អត្ថិ, តស្មា ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, បញ្ច ឧបោសថា អតិក្កន្តា, ចត្តារោ ឧបោសថា អវសិដ្ឋា ។

នេះបែបវែង, បើបែបខ្លី ត្រូវថា អយំ គិម្ហឧតុ, អស្មិំ ឧតុម្ហិ អធិកមាសទិវសេន ទស ឧបោសថា, ឥមិនា បក្ខេន

ឯកោ ឧបោសថោ សម្បត្តោ, បញ្ច ឧបោសថា អតិក្កន្តា, ចត្តារោ ឧបោសថា អវសិដ្ឋា ។

(៧- បើថ្ងៃ ១៤ រោច ខែ ជេស្ឋ ត្រូវថា) អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ បកតិវសេន អដ្ឋ ឧបោសថា, អធិកមាស-វសេន នវ ឧបោសថា, ឥមស្មឹ បន សំវច្ឆរេ អធិកមាសោ អត្ថិ, តស្មា ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, ឆ ឧបោសថា អតិក្កន្តា, តយោ ឧបោសថា អវសិដ្ឋា ។

(នេះបែបវែង, បើបែបខ្លី ត្រូវថា) អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ អធិកមាសវសេន នវ ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, ឆ ឧបោសថា អតិក្កន្តា, តយោ ឧបោសថា អវសិដ្ឋា ។

(៨_បើថ្ងៃ ១៥ កើត ខែ បឋមាសាឍ ត្រូវថា) អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ បកតិវសេន អដ្ឋ ឧបោសថា, អធិកមាសវសេន នវ ឧបោសថា, ឥមស្មឹ បន សំវច្ឆរេ អធិកមាសោ អត្ថិ, តស្មា ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, សត្ត ឧបោសថា អតិក្កន្តា, ទ្វេ ឧបោសថា អវសិដ្ឋា ។

( នេះបែបវែង, បើបែបខ្លី ត្រូវថា ) អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ អធិកមាសវសេន ទស ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, សត្ត ឧបោសថា អតិក្កន្តា, ទ្វេ ឧបោសថា អវសិដ្ឋា ។

( ៩-បើថ្ងៃ ១៥ រោច ខែ បឋមាសាឍ ត្រូវថា ) អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ បកតិវសេន អដ្ឋ ឧបោសថា, អធិកមាសវសេន ទស ឧបោសថា ឥមស្មឹ បន សំវច្ឆរេ អធិកមាសោ អត្ថិ, តស្មា ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, អដ្ឋ ឧបោសថា អតិក្កន្តា, ឯកោ ឧបោសថោ អវសិដ្ឋោ ។

( នេះបែបវែង, បើបែបខ្លី ត្រូវថា ) អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ អធិកមាសវសេន ទស ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, អដ្ឋ ឧបោសថា អតិក្កន្តា, ឯកោ ឧបោសថោ អវសិដ្ឋោ ។

( ១០-បើថ្ងៃ ១៥ កើត ខែ ទុតិយាសាឍ ត្រូវថា ) អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ បកតិវសេន អដ្ឋ ឧបោសថា, អធិកមាស-វសេន ទស ឧបោសថា, ឥមស្មឹ បន សំវច្ឆរេ អធិកមាសោ អត្ថិ, តស្មា ឥមិនា បក្ខេន ឯកោ

ឧបោសថោ សម្បត្តោ, នវ ឧបោសថា អតិក្កន្តា, ទស ឧបោសថា បរិបុណ្ណា ។

(នេះបែបវែង, បើបែបខ្លី ត្រូវថា) អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ អធិកមាសវសេន ទស ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, នវ ឧបោសថា អតិក្កន្តា, ទស ឧបោសថា បរិបុណ្ណា ។

(ចប់ឧបោសថ ១០ ក្នុងគិម្ហរដូវដោយអំណាចអធិកមាស) ។

(ក្នុងវស្សានរដូវមានឧបោសថ ៨ គឺ)

(១- បើថ្ងៃ ១៥ រោច ខែ អាសាឍ ឬ ទុតិយាសាឍ ត្រូវថា) អយំ វស្សានឧតុ, អស្មឹ ឧតុម្ហិ សត្ត ច ឧបោសថា ឯកា ច បវារណា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, (នត្ថិ ឧបោសថោ អតិក្កន្តោ) ឆ ច ឧបោសថា ឯកា ច បវារណា អវសិដ្ឋា ។

(២. បើថ្ងៃ ១៥ កើត ខែ ស្រាពណ៍ ត្រូវថា) អយំ វស្សានឧតុ, អស្មឹ ឧតុម្ហិ សត្ត ច ឧបោសថា ឯកា ច បវារណា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, ឯកោ ឧបោសថោ អតិក្កន្តោ, បញ្ច ច ឧបោសថា ឯកា ច បវារណា អវសិដ្ឋា ។

(៣- បើថ្ងៃ ១៥ រោច ខែ ស្រាពណ៍ ត្រូវថា ) អយំ វស្សានឧតុ, អស្មឹ ឧតុម្ហិ សត្ត ច ឧបោសថា ឯកា ច បវារណា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, ទ្វេ ឧបោសថា អតិក្កន្តា, ចត្តារោ ច ឧបោសថា ឯកា ច បវារណា អវសិដ្ឋា ។

(៤-បើថ្ងៃ ១៥ កើត ខែ ភទ្របទ ត្រូវថា ) អយំ វស្សានឧតុ, អស្មឹ ឧតុម្ហិ សត្ត ច ឧបោសថា ឯកា ច បវារណា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, តយោ ឧបោសថា អតិក្កន្តា, តយោ ច ឧបោសថា ឯកា ច បវារណា អវសិដ្ឋា ។

(៥-បើថ្ងៃ ១៥ រោច ខែ ភទ្របទ ត្រូវថា) អយំ វស្សានឧតុ, អស្មឹ ឧតុម្ហិ សត្ត ច ឧបោសថា ឯកា ច បវារណា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, ចត្តារោ ឧបោសថា អតិក្កន្តា, ទ្វេ ច ឧបោសថា ឯកា ច បវារណា អវសិដ្ឋា ។

( ៦- បើថ្ងៃ ១៥ កើតខែអស្សុជ ជាថ្ងៃបវារណា ត្រូវថា ) អយំ វស្សានឧតុ, អស្មឹ ឧតុម្ហិ សត្ត ច ឧបោសថា ឯកា ច បវារណា, ឥមិនា បក្ខេន បវារណាទិវសោ

សម្បត្តោ ( ឬថា បវារណា សម្បត្តា ក៏បាន ) បញ្ច ឧបោសថា អតិក្កន្តា, ទ្វេ ឧបោសថា អវសិដ្ឋា ។

(បើមិនធ្វើបវារណាទេ ដោយមានហេតុអ្វីមួយ ក៏ពន្យារឬបន្ថយបវារណាទៅធ្វើថ្ងៃណាមួយខាងមុខនោះ ថ្ងៃ ១៥ កើត ខែ អស្សុជ នេះ ទុកជាថ្ងៃធ្វើឧបោសថទី ៦ ក្នុងវស្សានរដូវ ) ។

( ៧- បើថ្ងៃ ១៤ រោច ខែអស្សុជ ត្រូវថា) អយំ វស្សានឧតុ, អស្មឹ ឧតុម្ហិ សត្ត ច ឧបោសថា ឯកា ច បវារណា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, បញ្ច ឧបោសថា ឯកា ច បវារណា អតិក្កន្តា, ឯកោ ឧបោសថោ អវសិដ្ឋោ ។

( ៨- បើថ្ងៃ ១៥ កើត ខែ កត្តិក ត្រូវថា ) អយំ វស្សានឧតុ, អស្មឹ ឧតុម្ហិ សត្ត ច ឧបោសថា ឯកា ច បវារណា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, ឆ ច ឧបោសថា ឯកា ច បវារណា អតិក្កន្តា, សត្ត ច ឧបោសថា ឯកា ច បវារណា បរិបុណ្ណា ។

( ចប់ ឧបោសថ ៧ និងបវារណា ១ ឬឧបោសថ ៨ ក្នុងវស្សានរដូវ )

( ភិក្ខុអ្នកសួរថា ) ភិក្ខុគណនា ច ។

( ភិក្ខុអ្នកឆ្លើយថា ) ឥមស្មឹ ឧបោសថគ្គេ សន្និបតិតានំ

ភិក្ខូនំ គណនា (បំផាប់អំពីនេះតទៅ ក្នុងរោងឧបោសថនោះ បើមានភិក្ខុ ៤ អង្គ ត្រូវថា) ចត្តារោ ភិក្ខូ សន្និបតិតា [១] ហោន្តិ ។

— ៥ — (បញ្ច) —

— ៦ — (ឆ) —

— ៧ — (សត្ត) —

— ៨ — (អដ្ឋ) —

— ៩ — (នវ) —

— ១០ — (ទស) —

— ១១ — (ឯកាទស) —

ឬ (ឯការស) —

— ១២ — (ទ្វាទស) —

ឬ (ទ្វារស) —

ឬ (ពារស) —

— ១៣ — (តេរស) —

— ១៤ — (ចតុទ្ទស) —

ឬ (ចុទ្ទស)

ឬ (ចោទ្ទស)

---

១ (ចត្តារោ) ភិក្ខូ ហោន្តិ ក៏បាន ។ ប្រទេសខ្លះលោកប្រើបាលីរាប់ចំនួនភិក្ខុថា តស្មឹ ឧបោសថគ្គេ ឆក្កា ភិក្ខូ សន្និបតិតា ភិក្ខូនំ គណនា តស្មឹ ឧបោសថ-គ្គេ (ចត្តារោ) ភិក្ខូ សន្និបតិតា ហោន្តិ ។

បើមានភិក្ខុ ១៥ អង្គត្រូវថា (បញ្ចទស) ភិក្ខូ សន្និបតិតា ហោន្តិ ។

— ឬ (បណ្ណរស)

— ១៦ — (សោឡស) —

— ១៧ — (សត្តរស) —

— ១៨ — (អដ្ឋារស) —

— ១៩ — (ឯកូនវីសតិ) —

— ឬ (ឯកូនវីស)

— ឬ (ឩនវីសតិ)

— ឬ (ឩនវីស)

— ២០ — (វីសតិ) —

— ឬ (វីស)

— ២១ — (ឯកវីសតិ) —

— ឬ (ឯកវីស)

— ២២ — (ពាវីសតិ) —

— ឬ (ពាវីស) —

— ២៣ — (តេវីសតិ) —

— ឬ (តេវីស) —

— ២៤ — (ចតុវីសតិ) —

— ឬ (ចតុវីស) —

បើមានភិក្ខុ ២៥ អង្គក្រៅថា) (បញ្ចវីសតិ) ភិក្ខូ សន្និបតិតា ហោន្តិ ។

ឬ (បញ្ចវីស)

— ២៦ — (ឆព្វីសតិ) —

ឬ (ឆព្វីស)

— ២៧ — (សត្តវីសតិ) —

ឬ (សត្តវីស)

— ២៨ — (អដ្ឋវីសតិ) —

ឬ (អដ្ឋវីស)

— ២៩ — (ឯកូនត្តឹសតិ) —

ឬ (ឯកូនត្តឹស)

ឬ (ឩនត្តឹសតិ)

ឬ (ឩនត្តឹស)

— ៣០ — (តឹសតិ) —

ឬ (តឹស)

— ៣១ — (ឯកត្តឹសតិ) —

ឬ (ឯកត្តឹស)

— ៣២ — (ទ្វត្តឹសតិ) —

ឬ (ទ្វត្តឹស)

ឬ (ពត្តឹសតិ)

ឬ (ពត្តឹស)

(បើមានភិក្ខុ ៣ ៣ អង្គត្រូវថា) (តេត្តឹសតិ) ភិក្ខូ សន្និបតិតា ហោន្តិ។

ឬ (តេត្តឹស)

— ៣៤ — (ចតុត្តឹសតិ)

ឬ (ចតុត្តឹស)

— ៣៥ — (បញ្ចត្តឹសតិ) —

ឬ (បញ្ចត្តឹស)

— ៣៦ — (ឆត្តឹសតិ) —

ឬ (ឆត្តឹស)

— ៣៧ — (សត្តត្តឹសតិ) —

ឬ (សត្តត្តឹស)

— ៣៨ — (អដ្ឋត្តឹសតិ) —

ឬ (អដ្ឋត្តឹស)

— ៣៩ — (ឯកូនចត្តាឡីស) —

ឬ (ឩនចត្តាឡីស)

ឬ (ឯកូនត្តាឡីស)

ឬ (ឩនត្តាឡីស)

— ៤០ — (ចត្តាឡីស) —

ឬ (តាឡីស)

— ៤១ — (ឯកចត្តាឡីស) —

ឬ (ឯកត្តាឡីស)

(បើបានភិក្ខុ ៤២ អង្គក្រៃថា)(ទ្វេចត្តាឡីស) ភិក្ខូ សន្និបតិតា ហោន្តិ។

ឬ (ទ្វេតាឡីស)

— ៤៣ — (តេចត្តាឡីស) —

ឬ (តេតាឡីស)

— ៤៤ — (ចតុច្ចត្តាឡីស) —

ឬ (ចតុត្តាឡីស)

— ៤៥ — (បញ្ចត្តាឡីស) —

ឬ (បញ្ចត្តាឡីស)

— ៤៦ — (ឆច្ចត្តាឡីស) —

ឬ (ឆត្តាឡីស)

— ៤៧ — (សត្តចត្តាឡីស) —

ឬ (សត្តត្តាឡីស)

— ៤៨ — (អដ្ឋចត្តាឡីស) —

ឬ (អដ្ឋត្តាឡីស)

— ៤៩ — (ឯកូនបញ្ញាស) —

ឬ (ឯកូនបណ្ណាស)

ឬ (ឩនបញ្ញាស)

ឬ (ឩនបណ្ណាស)

— ៥០ — (បញ្ញាស) —

ឬ (បណ្ណាស)

(បើមានភិក្ខុ ៥១ អង្គក្រថៃ) (ឯកបញ្ញាស) ភិក្ខូ សន្និបតិតា ហោន្តិ។

ឬ (ឯកបណ្ណាស)

— ៥២ — (ទ្វេបញ្ញាស) —

ឬ (ទ្វេបណ្ណាស)

— ៥៣ — (តេបញ្ញាស) —

ឬ (តេបណ្ណាស)

— ៥៤ — (ចតុប្បញ្ញាស) —

ឬ (ចតុប្បណ្ណាស)

— ៥៥ — (បញ្ចបញ្ញាស) —

ឬ (បញ្ចបណ្ណាស)

— ៥៦ — (ឆប្បញ្ញាស) —

ឬ (ឆប្បណ្ណាស)

— ៥៧ — (សត្តបញ្ញាស) —

ឬ (សត្តបណ្ណាស)

— ៥៨ — (អដ្ឋបញ្ញាស) —

ឬ (អដ្ឋបណ្ណាស)

— ៥៩ — (ឯកូនសដ្ឋី) —

ឬ (ឩនសដ្ឋី)

— ៦០ — (សដ្ឋី) —

( បើមានភិក្ខុ **៦១** អង្គ ត្រូវថា) (ឯកសដ្ឋី) ភិក្ខូ សន្និបតិតា ហោន្តិ ។

— ៦២ — (ទ្វេសដ្ឋី) —

ឬ (ទ្វាសដ្ឋី)

— ៦៣ — (តេសដ្ឋី) —

— ៦៤ — (ចតុស្សដ្ឋី) —

— ៦៥ — (បញ្ចសដ្ឋី) —

— ៦៦ — (ឆស្សដ្ឋី) —

— ៦៧ — (សត្តសដ្ឋី —

— ៦៨ — (អដ្ឋសដ្ឋី) —

— ៦៩ — (ឯកូនសត្តតិ) —

ឬ (ឯកូនសត្តរិ)

ឬ (ឩនសត្តតិ)

ឬ (ឩនសត្តរិ)

— ៧០ — (សត្តតិ) —

ឬ (សត្តរិ)

— ៧១ — (ឯកសត្តតិ) —

ឬ (ឯកសត្តរិ)

— ៧២ — (ទ្វេសត្តតិ) —

ឬ (ទ្វេសត្តរិ)

(បើមានភិក្ខុ **៧៣** អង្គត្រូវថា)(តេសត្តតិ) ភិក្ខូ សន្និបតិតា ហោន្តិ។

ឬ (តេសត្តរិ)

— ៧៤ — (ចតុស្សត្តតិ) —

ឬ (ចតុស្សត្តរិ)

— ៧៥ — (បញ្ចសត្តតិ) —

ឬ (បញ្ចសត្តរិ)

— ៧៦ — (ឆស្សត្តតិ) —

ឬ (ឆស្សត្តរិ)

— ៧៧ — (សត្តសត្តតិ)

ឬ (សត្តសត្តរិ)

— ៧៨ — (អដ្ឋសត្តតិ) —

ឬ (អដ្ឋសត្តរិ)

— ៧៩ — (ឯកូនអសីតិ) —

ឬ (ឯកូនាសីតិ)

ឬ (ឩនអសីតិ)

ឬ (ឩនាសីតិ)

— ៨០ — (អសីតិ) —

— ៨១ — (ឯកអសីតិ) —

ឬ (ឯកាសីតិ)

(បើមានភិក្ខុ៨២ អង្គត្រូវថា) (ទ្វេអសីតិ) ភិក្ខូ សន្និបតិតា ហោន្តិ។

ឬ (ទ្វាសីតិ)

— ៨៣ — (តេអសីតិ) —

ឬ (ត្យាសីតិ)

— ៨៤ — (ចតុអសីតិ) —

ឬ (ចតុរាសីតិ)

— ៨៥ — (បញ្ចអសីតិ) —

ឬ (បញ្ចាសីតិ)

— ៨៦ — (ឆអសីតិ) —

ឬ (ឆាសីតិ)

— ៨៧ — (សត្តអសីតិ) —

ឬ (សត្តាសីតិ)

— ៨៨ — (អដ្ឋអសីតិ) —

ឬ (អដ្ឋាសីតិ)

— ៨៩ — (ឯកូននវុតិ) —

ឬ (ឩននវុតិ)

— ៩០ — (នវុតិ) —

— ៩១ — (ឯកនវុតិ) —

— ៩២ — (ទ្វេនវុតិ) —

(បើមានភិក្ខុ ៩៣ អង្គត្រូវថា) (តេនវុតិ) ភិក្ខូ សន្និបតិតា ហោន្តិ។

— ៩៤ — (ចតុន្នវុតិ) —

— ៩៥ — (បញ្ចនវុតិ) —

— ៩៦ — (ឆន្នវុតិ) —

— ៩៧ — (សត្តនវុតិ) —

— ៩៨ — (អដ្ឋនវុតិ) —

— ៩៩ — (ឯកូនសត) —

ឬ (ឩនសត)

— ១០០ — (សត) —

— ១០១ — (ឯកុត្តរសត) —

— ១០២ — (ទ្វយុត្តរសត) —

— ១០៣ — (តយុត្តរសត) —

— ១០៤ — (ចតុរុត្តរសត) —

— ១០៥ — (បញ្ចុត្តរសត) —

— ១០៦ — (ឆរុត្តរសត) —

— ១០៧ — (សត្តុត្តរសត) —

— ១០៨ — (អដ្ឋុត្តរសត) —

— ១០៩ — (នវុត្តរសត) —

(បើមានភិក្ខុ ១១០ អង្គត្រូវថា)(ទសុត្តរសត) ភិក្ខូ សន្និបតិតា ហោន្តិ ។

— ១១១ — (ឯកាទសុត្តរសត —

ឬ (ឯការសុត្តរសត)

— ១១២ — (ទ្វាទសុត្តរសត) —

ឬ (ពារសុត្តរសត)

១១៣ — (តេរសុត្តរសត) —

— ១១៤ — (ចតុទ្ទសុត្តរសត) —

ឬ (ចុទ្ទសុត្តរសត)

ឬ (ចោទ្ទសុត្តរសត)

— ១១៥ — (បញ្ចទសុត្តរសត) —

ឬ (បណ្ណរសុត្តរសត)

— ១១៦ — (សោឡសុត្តរសត) —

— ១១៧ — (សត្តរសុត្តរសត) —

— ១១៨ — (អដ្ឋារសុត្តរសត) —

— ១១៩ — (ឯកូនវីសត្យុត្តរសត) —

ឬ (ឯកូនវីសុត្តរសត)

ឬ (ឩនវីសត្យុត្តរសត)

ឬ (ឩនវីសុត្តរសត)

(បើមានភិក្ខុ ១២០ អង្គ ត្រូវថា)(វីសត្យុត្តរសត) ភិក្ខូ សន្និបតិតា ហោន្តិ។

ឬ (វីសុត្តរសត)

។ល។ — ។ល។

— ២០០ — (ទ្វិសត) —

— ២០១ — (ឯកុត្តរទ្វិសត) —

— ២០២ — (ទ្វយុត្តរទ្វិសត) —

។ល។ ។ល។

— ៣០០ — (តិសត) —

— ៣០១ — (ឯកុត្តរតិសត) —

។ល។ ។ល។

— ៤០០ — (ចតុស្សត) —

៤០១ — (ឯកុត្តរចតុស្សត) —

។ល។ ។ល។

— ៥០០ — (បញ្ចសត) —

— ៥០១ — (ឯកុត្តរបញ្ចសត) —

។ល។ ។ល។

— ៦០០ — (ឆស្សត) —

— ៦០១ — (ឯកុត្តរឆស្សត) —

។ល។ ។ល។

(បើមានភិក្ខុ ៧០០ អង្គ ត្រូវថា)(សត្តសត)ភិក្ខូ សន្និបតិតា ហោន្តិ ។

— ៧០១— (ឯកុត្តរសត្តសត) —

។ល។ ។ល។

— ៨០០— (អដ្ឋសត) —

— ៨០១— (ឯកុត្តរអដ្ឋសត) —

។ល។ ។ល។

— ៩០០— (នវសត) —

— ៩០១— (ឯកុត្តរនវសត) —

។ល។ ។ល។

— ១០០០— (សហស្ស) —

— ១០០១— (ឯកុត្តរសហស្ស) —

។ល។ ។ល។

—១០.០០០(ហ្មឺន)— (ទសសហស្ស) —

— ១០.០០១— (ឯកុត្តរទសសហស្ស) -

។ល។ ។ល។

—១០០.០០០(សែន) (សតសហស្ស) —

—១០០.០០១ — (ឯកុត្តរសតសហស្ស) —

។ល។ ។ល។

—១.០០០.០០០(លាន) — (ទសសតសហស្ស) — ។

(ភិក្ខុអ្នកសួរថា) ឱវាទោ ។ (ភិក្ខុអ្នកឆ្លើយថា) ភិក្ខុនីនំ ឱវាទោ ទាតព្វោ, ឥទានិ បន តាសំ នត្ថិតាយ, សោ ច ឱវាទោ ឥធ នត្ថិ ។

(ភិក្ខុអ្នកសួរថា)ឧបោសថស្ស ឯតានិ បុព្វកិច្ចន្តិ វុច្ចតិ។

(ភិក្ខុអ្នកឆ្លើយថា) ឯតានិ បញ្ច កម្មានិ ឆន្ទាហរណាទីនិ បាតិមោក្ខុទ្ទេសតោ បឋមំ កត្តព្វត្តា, ឧបោសថស្ស ឧបោសថកម្មស្ស បុព្វកិច្ចន្តិ វុច្ចតិ , បុព្វកិច្ចានីតិ អក្ខាតានិ។

(ភិក្ខុអ្នកសួរថា) ឧបោសថោ យាវតិកា ច ភិក្ខូ កម្មប្បត្តា សភាគាបត្តិយោ ច ន វិជ្ជន្តិ, វជ្ជនីយា ច បុគ្គលា តស្មឹ ន ហោន្តិ, បត្តកល្លន្តិ វុច្ចតិ ។ ឧបោសថោ ។

(ភិក្ខុអ្នកឆ្លើយ បើឧបោសថថ្ងៃទី១៤ត្រូវថា) តីសុ ឧបោសថទិវសេសុ ចាតុទ្ទសីបណ្ណរសីសាមគ្គីសុ, អជ្ជុបោសថោ (ចាតុទ្ទសោ) ។

(បើឧបោសថថ្ងៃទី ១៥ ត្រូវថា) តីសុ ឧបោសថទិវសេសុ ចាតុទ្ទសីបណ្ណរសីសាមគ្គីសុ, អជ្ជុបោសថោ (បណ្ណរសោ) ។ (បើឧបោសថថ្ងៃសាមគ្គីត្រូវថា) តីសុ ឧបោសថទិវសេសុ ចាតុទ្ទសីបណ្ណរសីសាមគ្គីសុ អជ្ជុបោសថោ (សាមគ្គី) ។ (បើមានអធិករណ៍លើកថ្ងៃមួយ-

គោរទោចខែជេស្ឋបានពោលថាទី ១៥ ត្រង់ថ្ងៃ ១៥ រោច ខែជេស្ឋ ក្នុងឆ្នាំណាមួយ

ត្រូវថា ) តីសុ ឧបោសថទិវសេសុ ចាតុទ្ទសីបណ្ណរសី-សាមគ្គីសុ , អជ្ជុបោសថោ ( ឬថា អជ្ជ បន្នុបោសថោ) អធិកវារវសេន បណ្ណរសោ ។

(ភិក្ខុអ្នកសួរថា) យាវតិកា ច ភិក្ខូ កម្មប្បត្តា ។

(ភិក្ខុអ្នកឆ្លើយថា) យត្តកា ភិក្ខូ តស្ស ឧបោសថកម្មស្ស បត្តា យុត្តា អនុរូបា, សព្វន្តិមេន បរិច្ឆេទេន ចត្តារោ ភិក្ខូ បកតត្តា សង្ឃេន អនុក្ខិត្តា, តេ ច ខោ ហត្ថបាសំ អវិជ្ជហិត្វា ឯកសីមាយំ ឋិតា ។

(ភិក្ខុអ្នកសួរថា) សភាគាបត្តិយោ ច ន វិជ្ជន្តិ ។

(ភិក្ខុអ្នកឆ្លើយថា) វិកាលភោជនាទិវត្ថុសភាគាបត្តិយោ ច ន វិជ្ជន្តិ ។

(ភិក្ខុអ្នកសួរថា ) វជ្ជនីយា ច បុគ្គលា តស្មឹ ន ហោន្តិ ។

(ភិក្ខុអ្នកឆ្លើយថា ) គហដ្ឋបណ្ឌកាទយោ ឯកវីសតិ វជ្ជនីយបុគ្គលា, ហត្ថបាសតោ ពហិករណវសេន វជ្ជេតព្វា , តស្មឹ ន ហោន្តិ ។

(ភិក្ខុអ្នកសួរថា ) បត្តកល្លន្តិ វុច្ចតិ ។

(ភិក្ខុអ្នកឆ្លើយថា ) សង្ឃស្ស ឧបោសថកម្មំ ឥមេហិ

ចតូហិ លក្ខណេហិ សង្គហិតំ , បត្តកល្លន្តិ វុច្ចតិ , បត្តកាលវន្តន្តិ អត្ថោ ។

**បុព្វករណបុព្វកិច្ចានិ សមាបេត្វា ទេសិតាបត្តិកស្ស សមគ្គស្ស ភិក្ខុសង្ឃស្ស អនុមតិយា, បាតិមោក្ខំ ឧទ្ទិសិតុំ អារាធនំ(១) ករោមិ(២)។** បុព្វករណបុព្វកិច្ច ដែលបានធ្វើតាមរបៀបខាងលើនេះ ជាកិច្ចនៃសង្ឃុបោសថ ( ឧបោសថរបស់សង្ឃ ឬ ឧបោសថក្នុងសិទ្ធិរបស់សង្ឃ) ហេតុនោះ ភិក្ខុមានចំនួនយ៉ាងហោចត្រឹម ៤ អង្គឡើងទៅ ហៅថាសង្ឃ គឺមានតែសង្ឃនេះឯង ទើបអាចធ្វើសង្ឃុបោសថបាន។ រីភិក្ខុ ៣ អង្គ ឬ ២ អង្គ ហៅថា គណៈៗនេះ ធ្វើសង្ឃុបោសថមិនបានទេ ធ្វើបានតែគណុបោសថ (ឧបោសថរបស់គណៈ, ឧបោសថក្នុងសិទ្ធិរបស់គណៈ) គឺបារិសុទ្ធិឧបោសថ ។

ចំណែកឯភិក្ខុ ១ អង្គ ហៅថាបុគ្គល។ នេះឯង ធ្វើបានតែបុគ្គលុបោសថ (ឧបោសថរបស់បុគ្គល, ឧបោសថក្នុងសិទ្ធិរបស់បុគ្គល)គឺថាអធិដ្ឋានឧបោសថ ។

## ចប់របៀបធ្វើបុព្វករណបុព្វកិច្ច នៃសង្ឃុបោសថតែប៉ុណ្ណេះ ។

## របៀបធ្វើបុព្វករណបុព្វកិច្ច នៃសង្ឃប្បវារណា ( បវារណារបស់សង្ឃ)

របៀបធ្វើបុព្វករណបុព្វកិច្ច នៃសង្ឃប្បវារណានោះ ត្រូវធ្វើតាមពិធី

---

១ ថា អញ្ជើលទំ កំបាង ។ ២ កន្លែងខ្លះថា ករោម ដោយសំអាងថា អារាធនាទាំងរួស សព្វទាំងអស់ ។

ដូចតទៅនេះ ៖

ជាដំបូងភិក្ខុអ្នកសួរ (អ្នកជូនដើងបវារណា ឬ មេបវារណា) ត្រូវសូត្រប្រកាសប្រាប់សង្ឃសូត្រថា **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (៣ដង) ។ រួចសូត្រថា **សុណាតុ មេ ភន្តេ**[១] **សង្ឃោ, យទិ សង្ឃស្ស បត្តកល្លំ, អហំ អាយស្មន្តំ ឥត្ថន្នាមំ**[១] **វិនយំ បុច្ឆេយ្យំ ។**

ភិក្ខុអ្នកឆ្លើយ (អ្នកតាំងញត្តិ) ត្រូវសូត្រប្រកាសប្រាប់សង្ឃសូត្រថា **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (៣ដង)។ រួចសូត្រថា **សុណាតុ មេ ភន្តេ**[១] **សង្ឃោ,យទិ សង្ឃស្ស បត្តកល្លំ, អហំ អាយស្មតា ឥត្ថន្នាមេន**[១] **វិនយំ បុដ្ឋោ វិស្សជ្ជេយ្យំ ។**

បើភិក្ខុសួរឆ្លើយមិនបានសូត្រជាមុនទេ ហើយស្រាប់តែសួរឆ្លើយតែម្តង ត្រូវអាបត្តិទុក្កដ ។

(ភិក្ខុអ្នកសួរថា)

**សម្មជ្ជនី បទីបោ ច ឧទកំ អាសនេន ច**
**បវារណាយ ឯតានិ បុព្វករណន្តិ វុច្ចតិ ។**

**ឱកាស សម្មជ្ជនី ។** (ភិក្ខុអ្នកឆ្លើយថា) **សម្មជ្ជនករណញ្ច ។**
(ភិក្ខុអ្នកសួរថា) **បទីបោ ច ។** (បើក្នុងពេលយប់ ភិក្ខុអ្នកឆ្លើយថា)

---

១ ចូរមើលសេចក្តីពន្យល់ខាងចុងព័ត៌ត្រឹមទំព័រ ៣៦ តទៅ ។

បទីបុជ្ជលនញ្ច ឥទានិ សុរិយាលោកស្ស នត្ថិតាយ បទីបកិច្ចំ អត្ថិ ។ (បើក្នុងពេលថ្ងៃថា) បទីបុជ្ជលនញ្ច ឥទានិ សុរិយាលោកស្ស អត្ថិតាយ បទីបកិច្ចំ នត្ថិ ។ (ភិក្ខុអ្នកសួរថា) ឧទកំ អាសនេន ច ។ (ភិក្ខុអ្នកឆ្លើយថា) អាសនេន សហ បានីយបរិភោជនីយឧទកដ្ឋបនញ្ច ។ (ភិក្ខុអ្នកសួរថា) បវារណាយ ឯតានិ បុព្វករណន្តិ វុច្ចតិ ។ (ភិក្ខុអ្នកឆ្លើយថា) ឯតានិ ចត្តារិ វត្តានិ សម្មជ្ជនករណាទីនិ សង្ឃសន្និបាតតោ បឋមំ កត្តព្វត្តា, បវារណាយ បវារណាកម្មស្ស បុព្វករណន្តិ វុច្ចតិ, បុព្វករណានីតិ អក្ខាតានិ ។ (ភិក្ខុអ្នកសួរថា)

ឆន្ទប្បវារណា ឧតុក្ខានំ, ភិក្ខុគណនា ច ឱវាទោ,
បវារណាយ ឯតានិ, បុព្វកិច្ចន្តិ វុច្ចតិ ។

ឆន្ទប្បវារណា ។ (ភិក្ខុអ្នកឆ្លើយថា) ឆន្ទារហានំ ភិក្ខូនំ ឆន្ទប្បវារណាហរណញ្ច (១) ឥធ នត្ថិ ។

(ភិក្ខុអ្នកសួរថា) ឧតុក្ខានំ ។ (ភិក្ខុអ្នកឆ្លើយថា) ហេមន្តាទីនំ តិណ្ណំ ឧតូនំ ឯត្តកំ អតិក្កន្តំ, ឯត្តកំ អវសិដ្ឋន្តិ ឯវំ ឧតុអាចិក្ខនំ, ឧតូនីធ បន សាសនេ ហេមន្តគិម្ហវស្សា-

---

(១) ឆន្ទប្បវារណាហរណំ ច ឥធ នត្ថិ ក៏បាន ។

នានំ ទសេន តីណិ ហោន្តិ ។ អយំ វស្សានឧតុ អស្មឹ ឧតុម្ហិ សត្ត ច ឧបោសថា ឯកា ច បវារណា, ឥមិនា បក្ខេន បវារណា សម្បត្តា (ឬថា បវារណាទិវសោ សម្បត្តោ), បញ្ច ឧបោសថា អតិក្កន្តា, ទ្វេ ឧបោសថា អវសិដ្ឋា ។

(ភិក្ខុអ្នកសួរថា) ភិក្ខុគណនា ច ។ (ភិក្ខុអ្នកឆ្លើយថា) ឥមស្មឹ បវារណាគ្គេ សន្និបតិតានំ ភិក្ខូនំ គណនា បញ្ច[2] ភិក្ខូ សន្និបតិតា ហោន្តិ ។ (ភិក្ខុអ្នកសួរថា) ឱវាទោ ។ (ភិក្ខុអ្នកឆ្លើយថា) ភិក្ខុនីនំ ឱវាទោ ទាតព្វោ ឥទានិ បន តាសំ នត្ថិតាយ, សោ ច ឱវាទោ ឥធ នត្ថិ ។ (ភិក្ខុអ្នកសួរថា) បវារណាយ ឯតានិ បុព្វកិច្ចន្តិ វុច្ចតិ ។ (ភិក្ខុអ្នកឆ្លើយថា) ឯតានិ បញ្ច កម្មានិ ឆន្ទប្បវារណាទីនិ (ឬថា ឆន្ទាហរណាទីនិ) ញត្តិយា បឋមតោ បឋមំ កត្តព្វត្តា, បវារណាយ បវារណាកម្មស្ស បុព្វកិច្ចន្តិ វុច្ចតិ, បុព្វកិច្ចានីតិ អក្ខាតានិ ។ (ភិក្ខុអ្នកសួរថា) បវារណា, យាវតិកា ច ភិក្ខូ កម្មប្បត្តា សភាគាបត្តិយោ ច ន វិជ្ជន្តិ, វជ្ជនីយា ច បុគ្គលា តស្មឹ ន ហោន្តិ, បត្តកល្លន្តិ វុច្ចតិ ។ បវារណា ។ (ភិក្ខុអ្នកឆ្លើយថា)

---

២ ចូរមើលខាងដើមត្រង់ទំព័រទី ១៦ តទៅ ។

បវារណាទិវសេសុ ចាតុទ្ទសីបណ្ណរសីសាមគ្គីសុ ,
អជ្ជបវារណា បណ្ណរសី ។ (ភិក្ខុអ្នកសួរថា) យាវតិកា ច
ភិក្ខូ កម្មប្បត្តា ។ (ភិក្ខុអ្នកឆ្លើយថា) យត្តកា ភិក្ខូ តស្ស
បវារណាកម្មស្ស បត្តា យុត្តា អនុរូបា, សព្វន្តិមេន
បរិច្ឆេទេន បញ្ច ភិក្ខូ បកតត្តា សង្ឃេន អនុក្ខិត្តា,
តេ ច ខោ ហត្ថបាសំ អវិជហិត្វា ឯកសីមាយំ ឋិតា។
(ភិក្ខុអ្នកសួរថា) សភាគាបត្តិយោ ច ន វិជ្ជន្តិ។ (ភិក្ខុអ្នកឆ្លើយថា
វិកាលភោជនាទិវត្ថុកសភាគាបត្តិយោ ច ន វិជ្ជន្តិ ។
(ភិក្ខុអ្នកសួរថា) វជ្ជនីយា ច បុគ្គលា តស្មឹ ន ហោន្តិ ។
(ភិក្ខុអ្នកឆ្លើយថា) គហដ្ឋបណ្ឌកាទយោ ឯកវីសតិ វជ្ជនីយ
បុគ្គលា, ហត្ថបាសតោ ពហិករណវសេន វជ្ជេតព្វា
តស្មឹ ន ហោន្តិ ។ (ភិក្ខុអ្នកសួរថា) បត្តកល្លន្តិ វុច្ចតិ
(ភិក្ខុអ្នកឆ្លើយថា) សង្ឃស្ស បវារណាកម្មំ ឥមេហិ ចតូហិ
លក្ខណេហិ សង្គហិតំ, បត្តកល្លន្តិ វុច្ចតិ, បត្តកាល
វត្តន្តិ អក្ខាតំ ។

(ភិក្ខុអ្នកសួរអារាធនាថា) បុព្វករណបុព្វកិច្ចានិ សមាបេត្វា
ទេសិតាបត្តិកស្ស សមគ្គស្ស ភិក្ខុសង្ឃស្ស អនុមតិយា
ញត្តឹ ឋបេតុំ អជ្ឈេសនំ ករោមិ ។

បុព្វករណបុព្វកិច្ច ដែលបានធ្វើតាមរបៀបខាងលើនេះ ជាកិច្ចនៃសង្ឃប្បវារណា បវារណារបស់សង្ឃ, បវារណាក្នុងសិទ្ធិរបស់សង្ឃ ហេតុនោះភិក្ខុមានចំនួនយ៉ាងតិចបំផុតត្រឹម ៥ អង្គ ឡើងទៅហៅថាសង្ឃបញ្ចវគ្គ គឺបានតែសង្ឃដែលមានភិក្ខុចំនួន ៥ អង្គឡើងទៅទើបអាចធ្វើសង្ឃប្បវារណាបាន ។ ឯភិក្ខុ ៤ អង្គ ឬ ៣ អង្គ ឬថា ២ អង្គ ហៅថាគណៈ។ នេះធ្វើសង្ឃប្បវារណាមិនបានទេ ធ្វើបានតែគណប្បវារណា ) បវារណារបស់គណៈឬបវារណាក្នុងសិទ្ធិរបស់គណៈ ) ចំណែកឯភិក្ខុ ១ អង្គហៅថាបុគ្គល។នេះ ធ្វើបានតែបុគ្គលប្បវារណា ( បវារណារបស់បុគ្គល ឬ បវារណាក្នុងសិទ្ធិរបស់បុគ្គល ) ។

ចប់របៀបធ្វើបុព្វករណបុព្វកិច្ច

នៃសង្ឃប្បវារណា តែប៉ុណ្ណេះ ។

---

# សេចក្ដីពន្យល់

១. ត្រង់បាលីថា **ភន្តេ** បើភិក្ខុអ្នកសូត្រចាស់ជាងសង្ឃទាំងអស់ត្រូវថា **អាវុសោ** គឺត្រូវសូត្រថា **សុណាតុ មេ អាវុសោ សង្ឃោ។ល។**

២. ត្រង់បាលីថា **ឥត្ថន្នាមំ** នេះ សម្រាប់បញ្ចូលបព្វជិតនាមមកជំនួស, បើបព្វជិតនាម មានស្រៈ ឥ, ឧ នៅទីបំផុតដូចជា **មហាមុនិ, ធម្មគុរុ** ជាដើមត្រូវបន្ថែមនិគ្គហិត នៅទីបំផុតឲ្យទៅជា **មហាមុនិំ, ធម្មគុរុំ** ជាដើម, បើបព្វជិតនាមមានស្រៈ ឦ, ឩ, នៅទីបំផុត ដូចជា **សុមេធី, ធម្មញ្ញូ** ជាដើម ត្រូវធ្វើស្រៈ ឦ, ឩ, ទៅជា ឥ, ឧ ហើយបន្ថែមនិគ្គហិត នៅទីបំផុតឲ្យទៅជា **សុមេធិំ, ធម្មញ្ញុំ** ជាដើម, បើបព្វជិត

នាម ដែលមានស្រៈ េ - ា ( ឱ ) នៅទីបំផុតដូចជា អគ្គធីរោ បញ្ញាសារោ ជាដើម ត្រូវធ្វើឲ្យមានទីបំផុតជានិគ្គហិត ថា អគ្គធីរំ, បញ្ញាសារំ ជាដើម គឺភិក្ខុអ្នកសួរត្រូវសូធ្យថា អហំ អាយស្មន្តំ ( មហាមុនឹ ) ឬ ធម្មគរុំ ឬ សុមេធឹ ឬ ធម្មញ្ញុំ ឬ អគ្គធីរំ ឬថា បញ្ញាសារំ វិនយំ បុច្ឆេយ្យំ ។

៣. ត្រង់បាលីថា ឥត្ថន្នាមេន នេះក៏សម្រាប់បញ្ចូលបព្វជិតនាមមកជំនួសដែរ បើបព្វជិតនាមមានទីបំផុតជាស្រៈ ឥ, ឧ ដូចជា មហាមុនិ, ធម្មគរុ ជាដើម ត្រូវបន្ថែមអក្សរ នា នៅទីបំផុតឲ្យទៅជា មហាមុនិនា, ធម្មគរុនា ជាដើម, បើបព្វជិតនាមមាននាមទីបំផុតជាស្រៈ ឦ, ឩ, ដូចជា សុមេធី, ធម្មញ្ញូ ជាដើម ត្រូវធ្វើឲ្យទៅជាស្រៈ ឥ, ឧ វិញហើយបន្ថែមអក្សរ នា នៅទីបំផុតជា សុមេធិនា, ធម្មញ្ញុនា ជាដើម, បើបព្វជិតនាម មានទីបំផុតជាស្រៈ េ - ា (ឱ) ដូចជា អគ្គធីរោ បញ្ញាសារោ ជាដើម ត្រូវលុបស្រៈ េ - ា នោះចេញ ហើយបន្ថែម េ - ន ( ឯន ) មកជំនួសជា អគ្គធីរេន, បញ្ញាសារេន វិញ គឺភិក្ខុអ្នកឆ្លើយត្រូវសូធ្យថា អហំ អាយស្មតា ( មហាមុនិនា ឬ ធម្មគរុនា ឬ សុមេធិនា ឬ ធម្មញ្ញុនា ឬ អគ្គធីរេន ឬថា បញ្ញាសារេន ) វិនយំ បុដ្ឋោ វិស្សជ្ជេយ្យំ ។

៤. ត្រង់បាលីថា អាយស្មន្តំ, អាយស្មតា នេះជាពាក្យលំអុត

លំនឹង បើមិនបាច់ថា មិនជាការអ្វី ។ បើភិក្ខុមានវស្សាខ្ពស់ជាង ឬ ស្មើគ្នានឹងថា **ឥត្ថន្នាមំ ភិក្ខុំ, ឥត្ថន្នាមេន ភិក្ខុនា** មិនបាច់ថា **អាយស្មន្តំ, អាយស្មតា** ក៏បាន ។ បើភិក្ខុជាមហាថេរ មានបណ្ឌិតនាមថា **មហាមុនិ, ធម្មគរុ, សុមេធី, ធម្មញ្ញូ, អគ្គធីរោ, បញ្ញាសារោ** គ្រាន់តែបញ្ចូលពាក្យថា **មហាថេរំ, មហាថេរេន** ប៉ុណ្ណោះមកភ្ជាប់ខាងចុងបណ្ឌិតនាមនោះថា **មហាមុនិមហាថេរំ, មហាមុនិមហាថេរេន ធម្មគរុមហាថេរំ, ធម្មគរុមហាថេរេន, សុមេធិមហាថេរំ, សុមេធិមហាថេរេន, ធម្មញ្ញូមហាថេរំ, ធម្មញ្ញូមហាថេរេន, អគ្គធីរមហាថេរំ, អគ្គធីរមហាថេរេន បញ្ញាសារមហាថេរំ, បញ្ញាសារមហាថេរេន,** មិនបាច់ថា **អាយស្មន្តំ, អាយស្មតា** ក៏បាន ។

### បុព្វករណបុព្វកិច្ច

នៃសង្ឃឧបោសថ និង សង្ឃបវារណា ចប់ ។

ដោយព្រះធម្មឃោសាចារ្យ **សេខ នាង**

ផ្ដើម

# ភិក្ខុបាតិមោក្ខ

បាលី – ប្រែ

## នមោ តស្ស

ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។ ចប់ ។

សុណាតុ មេ ភន្តេ[1] សង្ឃោ, អជ្ជុបោសថោ (បណ្ណរសោ)[2], យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ ឧបោសថំ ករេយ្យ, បាតិមោក្ខំ ឧទ្ទិសេយ្យ ។

កឹ សង្ឃស្ស បុព្វកិច្ចំ ? បារិសុទ្ធឹ អាយស្មន្តោ អារោចេថ, បាតិមោក្ខំ ឧទ្ទិសិស្សាមិ, តំ សព្វេវ សន្តា សាធុកំ សុណោម មនសិករោម, យស្ស សិយា អាបត្តិ, សោ អាវិករេយ្យ, អសន្តិយា អាបត្តិយា តុណ្ហី ភវិតព្វំ; តុណ្ហីភាវេន ខោ បនាយស្មន្តេ បរិសុទ្ធាតិ វេទិស្សាមិ; យថា ខោ បន បច្ចេកបុដ្ឋស្ស វេយ្យាករណំ ហោតិ, ឯវមេវំ[3] ឯវរូបាយ បរិសាយ យាវតតិយំ អនុស្សាវិតំ ហោតិ, យោ បន ភិក្ខុ យាវតតិយំ អនុស្សាវិយមានេ សរមានោ សន្តឹ អាបត្តឹ នាវិករេយ្យ,

---

១ បើភិក្ខុអ្នកសម្ដែងបាតិមោក្ខនោះចាស់ជាងគេទាំងអស់ ត្រូវថា អាវុសោ ។ ២ បើថ្ងៃ ១៤ រោច ត្រូវថា ចាតុទ្ទសោ, បើថ្ងៃសាមគ្គីត្រូវថា សាមគ្គី ។ ៣ ឱ.ប. ឆាមេ ។

# ភិក្ខុបាតិមោក្ខប្រែ

សូមនមស្ការចំពោះព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។

បពិត្រព្រះសង្ឃដ៏ចម្រើន(១) សូមព្រះសង្ឃស្តាប់ខ្ញុំព្រះករុណា, ថ្ងៃនេះជាថ្ងៃឧបោសថ ទី (១៥)(២), បើឧបោសថកម្មនេះ មានកាលដ៏គួរដល់សង្ឃហើយ, សង្ឃគួរធ្វើឧបោសថ, គួរសម្តែងបាតិមោក្ខ ។

បុព្វកិច្ចរបស់សង្ឃ ( សង្ឃបានធ្វើហើយ ) ឬ ? បពិត្រលោកអ្នកមានអាយុទាំងឡាយ, សូមលោកទាំងឡាយប្រាប់នូវសេចក្តីបរិសុទ្ធិ, ខ្ញុំព្រះករុណានឹងសម្តែងបាតិមោក្ខ, យើងទាំងឡាយដែលមាននៅ ( ទីនេះ ) ទាំងអស់គ្នា គួរតាំងចិត្តស្តាប់បាតិមោក្ខនោះ ឲ្យបានសម្រេចប្រយោជន៍ លោកអង្គណាមានអាបត្តិ, លោកអង្គនោះគួរសម្តែងចេញ, បើពុំមានអាបត្តិទេ គួរនៅស្ងៀម, ខ្ញុំព្រះករុណានឹងដឹងថាលោកអ្នកមានអាយុទាំងឡាយ ជាអ្នកបរិសុទ្ធ ដោយកិរិយានៅស្ងៀមនុ៎ះឯង, ដូចជាបុគ្គលដែលគេសួរបញ្ហាចំពោះរូបម្នាក់ៗ តែងដោះស្រាយ យ៉ាងណាមិញ, ពាក្យដែលខ្ញុំព្រះករុណាប្រកាសឲ្យដឹង អស់កំណត់បីដងយ៉ាងនេះ ក្នុងបរិស័ទមានសភាពយ៉ាងនេះ ក៏ដូច្នោះដែរ, កាលបើខ្ញុំព្រះករុណាសូត្រប្រកាស គ្រប់បីដងហើយ, ភិក្ខុណាមួយ កាលរលឹកឃើញថាមានអាបត្តិហើយ មិនព្រមសម្តែងចេញទេ,

---

១ បើថា អាវុសោ គួរប្រែថា ម្នាលសង្ឃដ៏ចម្រើន ។ ២ បើថ្ងៃ ១៤ រោច គួរប្រែថា ទី ១៤ ។ បើថ្ងៃសាមគ្គី គួរប្រែថា ថ្ងៃសាមគ្គី ។

សម្បជានមុសាវាទស្ស ហោតិ. សម្បជានមុសាវាទោ ខោ បនាយស្មន្តោ អន្តរាយិកោ ធម្មោ វុត្តោ ភគវតា, តស្មា សរមានេន ភិក្ខុនា អាបន្នេន វិសុទ្ធាបេក្ខេន សន្តី អាបត្តិ អាវិកាតព្វា, អាវិកតា ហិស្ស ផាសុ ហោតិ ។

ឧទ្ទិដ្ឋំ ខោ បនាយស្មន្តោ និទានំ ។ តត្ថាយស្មន្តេ បុច្ឆាមិ, កច្ចិត្ថ បរិសុទ្ធា ? ទុតិយម្បិ បុច្ឆាមិ, កច្ចិត្ថ បរិសុទ្ធា ? តតិយម្បិ បុច្ឆាមិ, កច្ចិត្ថ បរិសុទ្ធា ? បរិសុទ្ធេត្ថាយស្មន្តោ, តស្មា តុណ្ហី ។ ឯវមេតំ ធារយាមិ ។

និទានុទ្ទេសោ និដ្ឋិតោ ។

# និទានុទ្ទេស

ភិក្ខុនោះត្រូវអាបត្តិឈ្មោះសម្បជានមុសាវាទទុក្កដ, បពិត្រលោកអ្នកមានអាយុទាំងឡាយ, ឯសម្បជានមុសាវាទហ្នឹង ព្រះមានព្រះភាគទ្រង់ត្រាស់ថា ជាអន្តរាយិកធម៌, ព្រោះហេតុនោះ ( បើ ) ភិក្ខុត្រូវអាបត្តិហើយ រលឹកឃើញបាន, មានបំណងចង់ឲ្យខ្លួនបរិសុទ្ធវិញ, ត្រូវតែសម្ដែងអាបត្តិដែលមាន ( នោះចេញ ), ដ្បិតភិក្ខុនោះរមែងមានសេចក្ដីសប្បាយ ព្រោះការសម្ដែងអាបត្តិនោះ ។

បពិត្រលោកអ្នកមានអាយុទាំងឡាយ, និទាន ខ្ញុំព្រះករុណាបានសម្ដែងរួចហើយ ។ ខ្ញុំព្រះករុណា សូមសួរលោកអ្នកមានអាយុទាំងឡាយ ក្នុងនិទាននេះ, លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំព្រះករុណាសូមសួរជាគម្រប់ពីរផងទៀត, លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំព្រះករុណាសូមសួរជាគម្រប់បីផងទៀត, លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? លោកអ្នកមានអាយុទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធក្នុងនិទាននុ៎ះហើយ, ព្រោះហេតុនោះបានជានៅស្ងៀម ។ ខ្ញុំព្រះករុណាសូមចាំទុកនូវហេតុនេះ ដោយកិរិយានៅស្ងៀមយ៉ាងនេះ ។

## ចប់និទានុទ្ទេស(•)។

---

• និទានប្រែថា "សេចក្ដីផ្ដើមឬពាក្យប្រារព្ធ" ឧទ្ទេសប្រែថា "បាលី ដែលសម្ដែងឡើង ទុកជាការតាំងដើមនៃសិក្ខាបទ" ។

តត្រិមេ ចត្តារោ បារាជិកា ធម្មា ឧទ្ទេសំ អា-
គច្ឆន្តិ ។

១- យោ បន ភិក្ខុ ភិក្ខូនំ សិក្ខាសាជីវសមា-
បន្នោ, សិក្ខំ អប្បច្ចក្ខាយ, ទុព្វល្យំ អនាវិកត្វា, មេ-
ថុនំ ធម្មំ បដិសេវេយ្យ អន្តមសោ តិរច្ឆានគតាយបិ,
បារាជិកោ ហោតិ អសំវាសោ ។

២- យោ បន ភិក្ខុ គាមា វា អរញ្ញា វា
អទិន្នំ ថេយ្យសង្ខាតំ អាទិយេយ្យ, យថារូបេ អទិន្នា-
ទានេ រាជានោ ចោរំ គហេត្វា ហនេយ្យុំ វា ពន្ធេ-
យ្យុំ វា បព្វាជេយ្យុំ វា : ចោរោសិ ពាលោសិ មូ-
ឡ្ហោសិ ថេនោសីតិ, តថារូបំ ភិក្ខុ អទិន្នំ អាទិយ-
មានោ, អយម្បិ បារាជិកោ ហោតិ អសំវាសោ ។

៣- យោ បន ភិក្ខុ សញ្ចិច្ច មនុស្សវិគ្គហំ
ជីវិតា វោរោបេយ្យ, សត្ថហារកំ វាស្ស បរិយេ-
សេយ្យ, មរណវណ្ណំ វា សំវណ្ណេយ្យ, មរណាយ
វា សមាទបេយ្យ : អម្ភោ បុរិស, កឹ តុយ្ហិមិនា បា-
បកេន ទុជ្ជីវិតេន? មតន្តេ ជីវិតា សេយ្យោតិ;
ឥតិ ចិត្តមនោ ចិត្តសង្កប្បោ

# ភិក្ខុបាតិមោក្ខប្រែ

អាបត្តិបារាជិកទាំងឡាយបួននេះ មកកាន់ឧទ្ទេសក្នុងបាតិមោក្ខនោះ ។

១-ភិក្ខុណាមួយដល់ព្រមដោយសិក្ខា និងសាជីវៈ(១) របស់ភិក្ខុទាំងឡាយហើយ, មិនពោលលាសិក្ខាចេញ, មិនធ្វើឲ្យជាក់ច្បាស់ ថាជាអ្នកមានកម្លាំងថយទេ, ហើយសេពមេថុនធម្ម, ដោយហោចទៅ សូម្បីតែនឹងសត្វតិរច្ឆានញី, ( ភិក្ខុនោះ ) ត្រូវអាបត្តិបារាជិក ជាបុគ្គលឥតសំវាស(២) ។

២-ភិក្ខុណាមួយកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ដោយចំណែកនៃចិត្តលួច អំពីស្រុកក្ដី, អំពីព្រៃក្ដី, ព្រះរាជាទាំងឡាយចាប់ចោរបានហើយ គប្បីសម្លាប់ក្ដី ឃុំឃាំងក្ដី និរទេសក្ដី ដោយព្រះរាជឱង្ការថា : " អាឯងជាចោរ, ជាមនុស្សពាលល្ងង់, ជាមនុស្សលួច " ព្រោះអទិន្នាទានមានសភាពយ៉ាងណា, ភិក្ខុកាលកាន់យកទ្រព្យដែលគេមិនបានឲ្យ មានសភាពយ៉ាងនោះ, ភិក្ខុនេះក៏ត្រូវអាបត្តិបារាជិក ជាបុគ្គលឥតសំវាសដែរ ។

៣-ភិក្ខុណាមួយ ក្លែងផ្ដាច់បង់រាងកាយរបស់មនុស្ស ឲ្យឃ្លាតចាកជីវិតក្ដី, ស្វែងរកសស្ត្រាវុធឲ្យគេសម្លាប់រាងកាយមនុស្សក្ដី, ពណ៌នាគុណនៃសេចក្ដីស្លាប់ក្ដី, ឬក៏និយាយណែនាំដើម្បីសេចក្ដីស្លាប់ថា : " ហៃបុរសដ៏ចម្រើន, ជីវិតអាក្រក់នេះមានប្រយោជន៍អ្វីដល់អ្នក ? អ្នកស្លាប់ទៅ ស្លាប់ទៅវិញប្រសើរជាងរស់នៅ " , ភិក្ខុមានចិត្តគិត មានសេចក្ដីត្រិះរិះក្នុងចិត្តដូច្នេះ ,

---

១ ពាក្យថាដល់ព្រមដោយសិក្ខា និងសាជីវៈ បានសេចក្ដីថា ភិក្ខុណាមួយជាអ្នកបានសិក្សា ក្នុងអធិសីលសិក្ខា និងសិក្ខាបទ ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តហើយ ។ ២ ឥតសំវាស គឺឥតធម៌ដែលជាហេតុឲ្យនៅរួមជាមួយនឹងភិក្ខុទាំងឡាយដទៃបាន ។

អនេកបរិយាយេន មរណវណ្ណំ វា សំវណ្ណេយ្យ, មរណាយ វា សមាទបេយ្យ, អយម្បិ បារាជិកោ ហោតិ អសំវាសោ ។

៤_ យោ បន ភិក្ខុ អនភិជានំ ឧត្តរិមនុស្សធម្មំ អត្តុបនាយិកំ អលមរិយញ្ញាណទស្សនំ សមុទាចរេយ្យៈ ឥតិ ជានាមិ, ឥតិ បស្សាមីតិៈ តតោ អបរេន ស_មយេន សមនុគ្គាហិយមានោ វា អសមនុគ្គាហិយ_មានោ វា អាបន្នោ, វិសុទ្ធាបេក្ខោ ឯវំ វទេយ្យៈ អជានមេវំ អាវុសោ អវចំ "ជានាមិ", អបស្សំ "បស្សាមិ" តុច្ឆំ មុសា វិលបិន្តិ, អញ្ញត្រ អធិមា_នា, អយម្បិ បារាជិកោ ហោតិ អសំវាសោ ។

ឧទ្ទិដ្ឋា ខោ អាយស្មន្តោ ចត្តារោ បារាជិកា ធម្មា, យេសំ ភិក្ខុ អញ្ញតរំ វា អញ្ញតរំ វា អាបជ្ជិ_ត្វា, ន លភតិ ភិក្ខូហិ សទ្ធឹ សំវាសំ, យថា បុរេ តថា បច្ឆា, បារាជិកោ ហោតិ អសំវាសោ ។

គប្បីពណ៌នាគុណនៃសេចក្តីស្លាប់ ឬគប្បីណែនាំ ដើម្បីសេចក្តីស្លាប់ដោយអនេកបរិយាយ, ភិក្ខុនេះ ក៏ត្រូវអាបត្តិបារាជិក ជាបុគ្គលឥតសំវាសផង ។

៤- ភិក្ខុណាមួយមិនដឹងជាក់ ហើយពោលអួតឧត្តរិមនុស្សធម៌ គឺញាណនិងទស្សនៈដ៏ប្រសើរ ជាគុណអាចកម្ចាត់បង់នូវកិលេស បង្អោនមកដាក់ក្នុងខ្លួនថា ៖ " ខ្ញុំដឹងដូច្នេះ, ខ្ញុំឃើញដូច្នេះ " , លុះដល់សម័យដទៃពីនោះមក នោះមានគេសាកសួរក្តី ឥតមានគេសាកសួរក្តី ក៏ពោលថា ត្រូវអាបត្តិបារាជិកហើយ, ( នោះបី ) មានប្រាថ្នាចង់ឲ្យបរិសុទ្ធ ( គឺឲ្យរួចទោស ) ហើយត្រឡប់ជានិយាយកែសំដីយ៉ាងនេះវិញថា " នែអាវុសោ, ខ្ញុំមិនដឹងយ៉ាងនេះទេ ប៉ុន្តែបានពោលថាដឹង, ខ្ញុំមិនឃើញយ៉ាងនេះទេ ប៉ុន្តែពោលថាឃើញ, ខ្ញុំពោលកុហកសោះទេ ", វៀរលែងតែសម្គាល់ ថាខ្លួនបានត្រាស់ដឹងពិត, ភិក្ខុនេះក៏ត្រូវអាបត្តិបារាជិក ជាបុគ្គលឥតសំវាសផង ។

បពិត្រលោកអ្នកមានអាយុទាំងឡាយ, អាបត្តិឈ្មោះបារាជិកទាំងបួន ខ្ញុំព្រះករុណាបានសម្តែងរួចហើយ, បណ្តាអាបត្តិទាំងបួននោះ ភិក្ខុណាត្រូវអាបត្តិណាមួយហើយ, ក៏មិនបាននូវការនៅរួម ជាមួយនឹងភិក្ខុទាំងឡាយដទៃទៀត, កាលពីមុនយ៉ាងណាមិញ, លុះខាងក្រោយមក ( ភិក្ខុនោះ ) ក៏ជាបារាជិកឥតសំវាសគ្នា យ៉ាងនោះដែរ ។

តត្ថាយស្មន្តេ បុច្ឆាមិ, កច្ចិត្ថ បរិសទ្ធា? ទុតិយម្បិ បុច្ឆាមិ, កច្ចិត្ថ បរិសុទ្ធា? តតិយម្បិ បុច្ឆាមិ, កច្ចិត្ថ បរិសុទ្ធា? បរិសុទ្ធេត្ថាយស្មន្តោ, តស្មា តុណ្ហី ។ ឯវមេតំ ធារយាមិ ។

បារាជិកុទ្ទេសោ និដ្ឋិតោ ។

# បារាជិកុទ្ទេស

ខ្ញុំព្រះករុណា សូមសួរលោកអ្នកមានអាយុទាំងឡាយ ក្នុងអាបត្តិបារាជិកទាំងបួននោះ, លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំព្រះករុណាសូមសួរជាគម្រប់ពីរផងទៀត, លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំព្រះករុណាសូមសួរជាគម្រប់បីផងទៀត, លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? លោកអ្នកមានអាយុទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធ ក្នុងបារាជិកាបត្តិទាំងបួននុ៎ះហើយ, ព្រោះហេតុនោះបានជានៅស្ងៀម ។

ខ្ញុំព្រះករុណាសូមចាំទុកនូវហេតុនេះ ដោយកិរិយានៅស្ងៀមយ៉ាងនេះ ។

ចប់បារាជិកុទ្ទេស ។

ឥមេ ខោ បនាយស្មន្តោ តេរស សង្ឃាទិសេសា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

១. សញ្ចេតនិកា សុក្កវិស្សដ្ឋិ. អញ្ញត្រ សុបិនន្តា សង្ឃាទិសេសោ ។

២. យោ បន ភិក្ខុ ឱតិណ្ណោ វិបរិណតេន ចិត្តេន, មាតុគ្គាមេន សទ្ធឹ កាយសំសគ្គំ សមាបជ្ជេយ្យ. ហត្ថគ្គាហំ វា វេណិគ្គាហំ វា អញ្ញតរស្ស វា អញ្ញតរស្ស វា អង្គស្ស បរាមសនំ. សង្ឃាទិសេសោ ។

៣. យោ បន ភិក្ខុ ឱតិណ្ណោ វិបរិណតេន ចិត្តេន, មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសេយ្យ យថាតំ យុវា យុវតឹ មេថុនុបសញ្ហិតាហិ. សង្ឃាទិសេសោ ។

៤. យោ បន ភិក្ខុ ឱតិណ្ណោ វិបរិណតេន ចិត្តេន, មាតុគ្គាមស្ស សន្តិកេ អត្តកាមបារិចរិយាយ វណ្ណំ ភាសេយ្យ: ឯតទគ្គំ ភគិនិ បារិចរិយានំ, យា មាទិសំ សីលវន្តំ កល្យាណធម្មំ ព្រហ្មចារឹ ឯតេន ធម្មេន បរិចរេយ្យាតិ មេថុនុបសញ្ហិតេន, សង្ឃាទិសេសោ ។

# សង្ឃាទិសេសសុទ្ធស

បពិត្រលោកអ្នកដ៏មានអាយុទាំងឡាយ, អាបត្តិឈ្មោះសង្ឃាទិសេសទាំង ១៣ នេះឯង មកកាន់ឧទ្ទេស ។

១– ភិក្ខុក្លែងញុំាងទឹកសុក្កៈឲ្យឃ្លាតចេញ, ត្រូវអាបត្តិសង្ឃាទិសេស, លើកលែងតែយល់សប្តិ ។

២– ភិក្ខុណាមួយ ដែលកាមរាគគ្របសង្កត់ មានចិត្តប្រែប្រួល, ដល់ព្រមនូវកាយសំសគ្គៈ មួយអន្លើដោយមាតុគ្រាម, ទោះចាប់ដៃក្តី ចាប់ផ្នួងសក់ក្តី ឬស្ទាបអង្អែលអវយវៈត្រង់ណាៗក្តី, ( ភិក្ខុនោះត្រូវ ) អាបត្តិសង្ឃាទិសេស ។

៣– ភិក្ខុណាមួយ ដែលកាមរាគគ្របសង្កត់ មានចិត្តប្រែប្រួល, និយាយចែចង់មាតុគ្រាមដោយសម្តីអាក្រក់ ។ , ដូចប្រុសកំលោះនិយាយចែចង់ស្រីក្រមុំ ដោយសម្តីដែលប្រកបដោយមេថុន,' ( ភិក្ខុនោះត្រូវ ) អាបត្តិសង្ឃាទិសេស ។

៤– ភិក្ខុណាមួយ ដែលកាមរាគគ្របសង្កត់ មានចិត្តប្រែប្រួល, និយាយសរសើរគុណនៃការបម្រើខ្លួនដោយកាម ក្នុងសំណាក់មាតុគ្រាម ដោយសេចក្តីប្រកបដោយមេថុនធម្មថា " ម្នាលប្អូនស្រី ! ស្រីណាបម្រើអ្នកប្រព្រឹត្តព្រហ្មចារ្យ មានសីល មានកល្យាណធម៌ ប្រហែលដូចអាត្មា ដោយមេថុនធម្មនុ៎ះ, ការបម្រើនេះរបស់ស្រីនោះ ឈ្មោះថាជាកំពូលនៃការបម្រើទាំងឡាយ ", ( ភិក្ខុនោះត្រូវ ) អាបត្តិសង្ឃាទិសេស ។

៥. យោ បន ភិក្ខុ សញ្ចរិត្តំ សមាបជ្ជេយ្យ, ឥត្ថិយា វា បុរិសមតឹ, បុរិសស្ស វា ឥត្ថិមតឹ ជាយត្តនេ វា ជារត្តនេ វា, អន្តមសោ តំខណិកាយបិ, សង្ឃាទិសេសោ ។

៦_ សញ្ញាចិកាយ បន ភិក្ខុនា កុដឹ ការយមានេន អស្សាមិកំ អត្តុទ្ទេសំ, បមាណិកា ការេតព្វា, តត្រិទំ បមាណំ : ទីឃសោ ទ្វាទសវិទត្ថិយោ សុគតវិទត្ថិយា, តិរិយំ សត្តន្តរា : ភិក្ខូ អភិនេតព្វា វត្ថុទេសនាយ: តេហិ ភិក្ខូហិ វត្ថុំ ទេសេតព្វំ អនារម្ភំ សបរិក្កមនំ: សារម្ភេ ចេ ភិក្ខុ វត្ថុស្មឹ អបរិក្កមនេ សញ្ញាចិកាយ កុដឹ ការេយ្យ, ភិក្ខូ វា អនភិនេយ្យ វត្ថុទេសនាយ, បមាណំ វា អតិក្កាមេយ្យ, សង្ឃាទិសេសោ ។

៥– ភិក្ខុណាមួយ ប្រព្រឹត្តនិយាយនាំ, (ប្រាប់) សេចក្តីប្រាថ្នារបស់បុរសដល់ស្ត្រីក្តី, (ប្រាប់) សេចក្តីប្រាថ្នារបស់ស្ត្រី ដល់បុរសក្តី, ឲ្យបានគ្នាជាប្តី ប្រពន្ធ ឬជាសាហាយស្មន់, ដោយហោចទៅ សូម្បីតែ (ប្រាប់) ដល់ស្ត្រីពេស្យា(១), (ភិក្ខុនោះត្រូវ) អាបត្តិសង្ឃាទិសេស ។

៦– កាលបើភិក្ខុឲ្យគេធ្វើកុដិដែលពុំមានទាយកជាម្ចាស់របស់ ចំពោះជាអី ទៅតែខ្លួន ដោយការសូមគ្រឿងឧបករណ៍គេយកខ្លួនឯង, ត្រូវធ្វើឲ្យប្រកបដោយប្រមាណ, ប្រមាណកុដិនោះគឺ បណ្តោយ ១២ ចំអាម ទទឹង ៧ ចំអាម, ដោយចំអាមព្រះសុគត វាស់ក្នុងខាងក្នុង, ត្រូវនាំភិក្ខុទាំងឡាយមកសម្តែងទីឲ្យ, ភិក្ខុទាំងនោះ គប្បីសម្តែងទីដែលមិនមានសេចក្តីរំខាន(២) មានឧបចារៈ(៣)ឲ្យ, បើភិក្ខុឲ្យគេធ្វើកុដិ ដោយការសូមគ្រឿងឧបករណ៍គេយកខ្លួនឯង ក្នុងទីដែលមានសេចក្តីរំខាន ទាំងមិនមានឧបចារៈក្តី, មិននាំភិក្ខុទាំងឡាយមកសម្តែងទីឲ្យក្តី, ធ្វើឲ្យកន្លងហួសប្រមាណក្តី, ត្រូវអាបត្តិសង្ឃាទិសេស ។

---

១ ប្រែតាមសព្ទថា ស្រីដែលបុរសគប្បីទៅរួមអស់មួយរំពេច, គឺស្រីអ្នកលេង, ស្រីពេស្យា, ស្រីផ្កាមាស ។ ២ ទីដែលមានសេចក្តីរំខាន គឺទីជាលំនៅនៃពួកស្រមោច, កណ្តៀរ កណ្តុរ, ពស់, ខ្លាឃ្មុំ...ដំរី, ខ្លា... ទីជាប់នឹងបុព្វណ្ណជាតិ ... វាលសម្រាប់លេង, ក៏ស្លាប់ផ្លូវដើរទៅមកនោះ ។ (មើល វិ.ក.២ប.២០៥,២០៨ ទំ.១៩៨,១៩៩) ។ ៣ ទីមិនមានឧបចារៈ គឺទីដែលរទេះទឹមហើយស្រឡះចូលមិនបាន ឬជណ្តើរបង្កាន់ជុំវិញមិនបាន ។

៧. មហល្លកំ បន ភិក្ខុនា វិហារំ ការយមានេន សស្សាមិកំ អត្តុទ្ទេសំ. ភិក្ខូ អភិនេតព្វា វត្ថុទេសនាយ: តេហិ ភិក្ខូហិ វត្ថុំ ទេសេតព្វំ អនារម្ភំ សបរិក្កមនំ: សារម្ភេ ចេ ភិក្ខុ វត្ថុស្មិំ អបរិក្កមនេ មហល្លកំ វិហារំ ការេយ្យ; ភិក្ខូ វា អនភិនេយ្យ វត្ថុទេសនាយ, សង្ឃាទិសេសោ ។

៨- យោ បន ភិក្ខុ ភិក្ខុំ ទុដ្ឋោ ទោសោ អប្បតីតោ, អមូលកេន បារាជិកេន ធម្មេន អនុទ្ធំសេយ្យ: អប្បេវ នាម នំ ឥមម្ហា ព្រហ្មចរិយា ចាវេយ្យន្តិ តតោ អបរេន សមយេន សមនុគ្គាហិយមានោ វា, អសមនុគ្គាហិយមានោ វា, អមូលកញ្ចេវ តំ អធិករណំ ហោតិ, ភិក្ខុ ច ទោសំ បតិដ្ឋាតិ, សង្ឃាទិសេសោ ។

# សង្ឃាទិសេសសុទ្ធស

៧– កាលបើភិក្ខុ ឲ្យគេធ្វើវិហារធំ (១) មានម្ចាស់ចំពោះជាទីនៅនៃខ្លួន, ត្រូវនាំភិក្ខុទាំងឡាយ មកសម្តែងទីឲ្យ, ភិក្ខុទាំងនោះ គប្បីសម្តែងទីដែលមិនមានសេចក្តីរង្កៀស មានឧបចារៈឲ្យ, បើភិក្ខុឲ្យគេធ្វើវិហារធំ ក្នុងទីដែលមានសេចក្តីរង្កៀស ទាំងមិនមានឧបចារៈក្តី មិននាំភិក្ខុទាំងឡាយមកសម្តែងទីឲ្យក្តី, ត្រូវអាបត្តិសង្ឃាទិសេស ។

៨– ភិក្ខុណាមួយ ក្រោធខឹង ប្រទូស្ត រកាំរអាំចិត្ត, ចោទកម្ចាត់ភិក្ខុផងគ្នា ដោយអាបត្តិបារាជិក មិនមានមូល ដោយបំណងថា : " ធ្វើដូចម្តេចហ្ន៎ ! អញនឹងញុំាងភិក្ខុនោះ ឲ្យឃ្លាតចាកព្រហ្មចរិយធម៌ (២)នេះបាន ", លុះដល់សម័យដទៃពីនោះមក ទោះមានគេសាកសួរក្តី ឥតមានគេសាកសួរក្តី, បើអធិករណ៍នោះប្រាកដជាពុំមានមូលមែនទាំងភិក្ខុក៏ថ្លែងថាទោសខ្លួនផង ( ភិក្ខុនោះត្រូវ ) អាបត្តិសង្ឃាទិសេស ។

---

១ វិហារធំ គឺកុដិដែលមានម្ចាស់ ដែលគេបូកបោចខាងក្នុងក្តី, ខាងក្រៅក្តី, ទាំងក្នុងទាំងក្រៅក្តី ( មើល វិ. ភ.២ ទ.២២២ ទំព័រ ២២៥ ) ។ ២ ព្រហ្មចរិយធម៌នេះ បានសេចក្តីថាព្រះពុទ្ធសាសនានេះ ។

៩_ យោ បន ភិក្ខុ ភិក្ខុំ ទុដ្ឋោ ទោសោ អប្បតីតោ. អញ្ញភាគិយស្ស អធិករណស្ស កញ្ចិ[1] ទេសំ លេសមត្តំ ឧបាទាយ, បារាជិកេន ធម្មេន អនុទ្ធំសេយ្យ : អប្បេវ នាម នំ ឥមម្ហា ព្រហ្មចរិយា ចាវេយ្យន្តិ: តតោ អបរេន សមយេន សមនុគ្គាហិយមានោ វា អសមនុគ្គាហិយមានោ វា, អញ្ញភាគិយញ្ចេវ តំ អធិករណំ ហោតិ, កោចិ ទេសោ លេសមត្តោ ឧបាទិន្នោ, ភិក្ខុ ច ទោសំ បតិដ្ឋាតិ, សង្ឃាទិសេសោ ។

១០_ យោ បន ភិក្ខុ សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមេយ្យ, ភេទនសំវត្តនិកំ វា អធិករណំ សមាទាយ បគ្គយ្ហ តិដ្ឋេយ្យ; សោ ភិក្ខុ ភិក្ខូហិ ឯវមស្ស វចនីយោ : មា អាយស្មា សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមិ, ភេទនសំវត្តនិកំ វា អធិករណំ សមាទាយ បគ្គយ្ហ អដ្ឋាសិ: សមេតាយស្មា សង្ឃេន, សមគ្គោ ហិ សង្ឃោ សម្មោទមានោ អវិវទមានោ ឯកុទ្ទេសោ ផាសុ វិហរតីតិ; ឯវញ្ច សោ ភិក្ខុ ភិក្ខូហិ វុច្ចមានោ, តថេវ បគ្គណ្ហេយ្យ; សោ ភិក្ខុ ភិក្ខូហិ យាវតតិយំ សមនុភាសិតព្វោ តស្ស បដិនិស្សគ្គាយ ។

---

១ ក្នុងបិដកបុរាណឃើញប្រើជាកិញ្ចិ (នបុំសកលិង្គ) ឯ "ទេស" ស័ព្ទនេះជា (បុំលិង្គ) ត្រូវប្រើជា កោចិ ទេសោ, កញ្ចិ ទេសំ ទើបត្រូវតាមបែបវេយ្យាករណ៍ ។

៩ – ភិក្ខុណាមួយ ក្រោធខឹង ប្រទូស្ត អាក់អន់ចិត្ត, ប្រកាន់យកហេតុបន្តិចបន្តួចនៃអធិករណ៍ ដែលជារឿងដទៃមកជាគ្រឿងអាង (១) ហើយចោទភិក្ខុដោយអាបត្តិបារាជិក ដោយបំណងថា : ធ្វើដូចម្តេចហ្ន៎! អញនឹងញុំាងភិក្ខុនោះឲ្យឃ្លាតចាកព្រហ្មចរិយធម៌នេះបាន”, លុះដល់សម័យដទៃពីនោះមក ទោះមានគេសាកសួរក្តី ឥតមានគេសាកសួរក្តី, បើអធិករណ៍នោះជារឿងដទៃទេ, ភិក្ខុប្រកាន់យកហេតុត្រឹមតែបន្តិចបន្តួច មកជាគ្រឿងអាង, ទាំងភិក្ខុក៏ប្តេជ្ញាទោសខ្លួនផង, ( ភិក្ខុនោះត្រូវ ) អាបត្តិសង្ឃាទិសេស ។

១០– ភិក្ខុណាមួយ ព្យាយាមដើម្បីបំបែកសង្ឃដែលព្រមព្រៀងគ្នា, ឬប្រកាន់ផ្គងឡើងនូវអធិករណ៍ ដែលនាំសង្ឃឲ្យបែកបាក់គ្នាហើយតាំងនៅ, ភិក្ខុទាំងឡាយត្រូវនិយាយនឹងភិក្ខុនោះ យ៉ាងនេះថា : “លោកអ្នកមានអាយុ កុំព្យាយាមបំបែកសង្ឃដែលព្រមព្រៀងគ្នាឡើយ, ទាំងកុំប្រកាន់ផ្គងឡើងនូវអធិករណ៍ ដែលនាំឲ្យសង្ឃបែកបាក់គ្នាហើយតាំងនៅឡើយ លោកអ្នកមានអាយុចូរព្រមព្រៀងជាមួយនឹងសង្ឃវិញទៅ, ព្រោះថា សង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា តែងតែនៅជាសុខសប្បាយ”, កាលដែលភិក្ខុទាំងឡាយនិយាយយ៉ាងនេះ, ភិក្ខុនោះនៅតែប្រកាន់ដូច្នោះដដែល, ត្រូវភិក្ខុទាំងឡាយ សូត្រសមនុភាសនកម្ម ហាមប្រាមភិក្ខុនោះ អស់កំណត់បីដង ដើម្បីឲ្យលះបង់សង្ឃភេទកម្មនោះចេញ ។

---

១ គ្រឿងអាងមាន ១០ យ៉ាងគឺ ជាតិ, នាម, គោត្រ, ភេទ, អាបត្តិ, បាត្រ, ចីវរ, ឧបជ្ឈាយ៍, អាចារ្យ និងសេនាសនៈ ។

យាវតតិយញ្ចេ សមនុភាសិយមានោ តំ បដិនិស្សជ្ជេយ្យ, ឥច្ចេតំ កុសលំ; នោ ចេ បដិនិស្សជ្ជេយ្យ, សង្ឃាទិសេសោ ។

១១- តស្សេវ ខោ បន ភិក្ខុស្ស ភិក្ខូ ហោន្តិ អនុវត្តកា វគ្គវាទកា, ឯកោ វា ទ្វេ វា តយោ វា, តេ ឯវំ វទេយ្យុំ : មា អាយស្មន្តោ ឯតំ ភិក្ខុំ កិញ្ចិ អវចុត្ថ, ធម្មវាទី ចេសោ ភិក្ខុ, វិនយវាទី ចេសោ ភិក្ខុ, អម្ហាកញ្ចេសោ ភិក្ខុ ឆន្ទញ្ច រុចិញ្ច អាទាយ វោហរតិ, ជានាតិ នោ ភាសតិ, អម្ហាកម្បេតំ ខមតីតិ។ តេ ភិក្ខូ ភិក្ខូហិ ឯវមស្សុ វចនីយា : មា អាយស្មន្តោ ឯវំ អវចុត្ថ, ន ចេសោ ភិក្ខុ ធម្មវាទី, ន ចេសោ ភិក្ខុ វិនយវាទី, មា អាយស្មន្តានម្បិ សង្ឃភេទោ រុចិត្ថ, សមេតាយស្មន្តានំ សង្ឃេន, សមគ្គោ ហិ សង្ឃោ សម្មោទមានោ អវិវទមានោ ឯកុទ្ទេសោ ផាសុ វិហរតីតិ; ឯវញ្ច តេ ភិក្ខូ ភិក្ខូហិ វុច្ចមានា, តថេវ បគ្គណ្ហេយ្យុំ, តេ ភិក្ខូ ភិក្ខូហិ យាវតតិយំ សមនុភាសិតព្វា តស្ស បដិនិស្សគ្គាយ ។

# សង្ឃាទិសេសសុះឆ្លុស

កាលបើភិក្ខុទាំងឡាយសូត្រសមនុភាសនកម្មហាមប្រាមគ្រប់បីដងហើយ ភិក្ខុនោះលះបង់សង្ឃភេទកម្មនោះចេញ, ការលះបង់នូវទោះនុះជាការប្រពៃ, បើពុំលះបង់ទេ, ត្រូវអាបត្តិសង្ឃាទិសេស ។

១១ – ភិក្ខុទាំងឡាយ ជាអ្នកប្រព្រឹត្តតាមភិក្ខុដែលបំបែកសង្ឃនោះផង ហើយជាអ្នកពោលប្រកាន់ពួក, ទោះមួយរូបក្តី ពីររូបក្តី បីរូបក្តី, ភិក្ខុទាំងនោះពោលហាម ( ភិក្ខុទាំងឡាយដែលជាអ្នកបរិសុទ្ធ ) យ៉ាងនេះថា : " សូមលោកអ្នកមានអាយុទាំងឡាយ កុំពោលពាក្យអ្វី ៗ នឹងភិក្ខុនោះឡើយ, ( ព្រោះភិក្ខុនេះ ជាអ្នកពោលត្រូវតាមធម៌ផង, ភិក្ខុនេះ ជាអ្នកពោលត្រូវតាមវិន័យផង , មួយវិញទៀតភិក្ខុនេះកាន់យកសេចក្តីពេញចិត្ត និងសេចក្តីគាប់ចិត្តរបស់ពួកយើង ទើបពោល , លោកដឹងសេចក្តីពេញចិត្តជាដើម របស់ពួកយើងទើបពោល, អំពើនេះ ក៏គាប់ចិត្តដល់យើងទាំងឡាយ ។ ភិក្ខុទាំងឡាយ ត្រូវនិយាយនឹងពួកភិក្ខុទាំងនោះយ៉ាងនេះថា : " លោកអ្នកមានអាយុទាំងឡាយ កុំពោលយ៉ាងហ្នឹងឡើយ , ( ព្រោះ ) ភិក្ខុនេះ មិនមែនជាអ្នកពោលត្រូវតាមធម៌ទេ, ភិក្ខុនេះ មិនមែនជាអ្នកពោលត្រូវតាមវិន័យទេ , លោកអ្នកមានអាយុទាំងឡាយ កុំគាប់ចិត្តនឹងសង្ឃភេទឡើយ, ចិត្តរបស់លោកអ្នកមានអាយុទាំងឡាយ ចូរព្រមព្រៀងជាមួយនឹងសង្ឃវិញទៅ, ព្រោះថា សង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា តែងតែនៅជាសុខសប្បាយ ", កាលដែលភិក្ខុទាំងឡាយនិយាយយ៉ាងនេះ, ភិក្ខុទាំងនោះនៅតែប្រកាន់នូវទោះដដែល, ត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្ម ហាមប្រាមភិក្ខុទាំងនោះអស់កំណត់បីដង ដើម្បីឱ្យលះបង់អំពើនោះចេញ ។

យាវតតិយញ្ចេ សមនុភាសិយមានា តំ បដិនិស្សជ្ជេយ្យ, ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យ, សង្ឃាទិសេសោ ។

១២- ភិក្ខុ បនេវ ទុព្វចជាតិកោ ហោតិ, ឧទ្ទេសបរិយាបន្នេសុ សិក្ខាបទេសុ ភិក្ខូហិ សហធម្មិកំ វុច្ចមានោ, អត្តានំ អវចនីយំ ករោតិ: មា មំ អាយស្មន្តោ កិញ្ចិ អវចុត្ថ កល្យាណំ វា បាបកំ វា, អហម្បាយស្មន្តេ ន កិញ្ចិ វក្ខាមិ កល្យាណំ វា បាបកំ វា, វិរមថាយស្មន្តោ មម វចនាយាតិ ។ សោ ភិក្ខុ ភិក្ខូហិ ឯវមស្ស វចនីយោ : មា អាយស្មា អត្តានំ អវចនីយំ អកាសិ, វចនីយមេវ អាយស្មា អត្តានំ ករោតុ, អាយស្មាបិ ភិក្ខូ វទេតុ សហធម្មេន, ភិក្ខូបិ អាយស្មន្តំ វក្ខន្តិ សហធម្មេន; ឯវំ សំវឌ្ឍាហិ តស្ស ភគវតោ បរិសា, យទិទំ អញ្ញមញ្ញវចនេន អញ្ញមញ្ញវុដ្ឋាបនេនាតិ ។

កាលបើភិក្ខុទាំងឡាយ សូត្រសមនុភាសនកម្ម ហាមប្រាមគ្រប់បីដងហើយ ភិក្ខុទាំងនោះលះបង់អំពើនោះចេញ, ការលះបង់បានដូច្នេះនុ៎ះជាការប្រពៃ, បើពុំលះបង់ទេ, ត្រូវអាបត្តិសង្ឃាទិសេស ។

១២- បើភិក្ខុ មានភាពជាអ្នកដែលគេពិបាកស្តីថា, កាលបើភិក្ខុទាំងឡាយពោលប្រដៅតាមធម៌ ក្នុងសិក្ខាបទទាំងឡាយដែលរាប់ចូលក្នុងឧទ្ទេស (បាតិ-មោក្ខ), ក៏ធ្វើខ្លួនឲ្យគេប្រដៅផងពុំបាន ដោយពាក្យថា : "សូមលោកអ្នកមានអាយុទាំងឡាយ កុំនិយាយពាក្យអ្វីៗ ទោះល្អក្តី អាក្រក់ក្តី នឹងខ្ញុំឡើយ, ចំណែកខ្ញុំ ក៏មិនពោលពាក្យអ្វីៗ ទោះល្អក្តី អាក្រក់ក្តី នឹងលោកអ្នកមានអាយុទាំងឡាយដែរ, សូមលោកអ្នកមានអាយុទាំងឡាយ លែងនិយាយប្រដៅខ្ញុំទៅ" ។ ភិក្ខុទាំងឡាយ ត្រូវនិយាយនឹងភិក្ខុនោះ យ៉ាងនេះថា : "លោកអ្នកមានអាយុ កុំធ្វើខ្លួនឲ្យគេប្រដៅពុំបាន (ដូច្នេះ) ឡើយ, លោកអ្នកមានអាយុ ចូរធ្វើខ្លួនឲ្យគេស្តីប្រដៅបានផង, ចំណែកលោកអ្នកមានអាយុ ចូរនិយាយស្តី (ទៅរក) ភិក្ខុទាំងឡាយ តាមសហធម៌ គឺពុទ្ធបញ្ញត្តិទៅ, ទាំងពួកភិក្ខុក៏នឹងនិយាយស្តី មករកលោកអ្នកមានអាយុ តាមសហធម៌ដែរ, ព្រោះថា បរិស័ទរបស់ព្រះមានព្រះភាគនោះ តែងចម្រើនឡើងដោយអាការៈយ៉ាងនេះ, គឺដោយពាក្យជាប្រយោជន៍ដល់គ្នានឹងគ្នា និងដោយការញ៉ាំងគ្នានឹងគ្នា ឲ្យចេញចាកអាបត្តិ" ។

ឯវញ្ច សោ ភិក្ខុ ភិក្ខូហិ វុច្ចមានោ តថេវ បគ្គណ្ហេយ្យ, សោ ភិក្ខុ ភិក្ខូហិ យាវតតិយំ សមនុភាសិតព្វោ តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ សមនុភាសិយមានោ តំ បដិនិស្សជ្ជេយ្យ, ឥច្ចេតំ កុសលំ, នោ ចេ បដិនិស្សជ្ជេយ្យ, សង្ឃាទិសេសោ ។

១៣ ភិក្ខុ បនេវ អញ្ញតរំ គាមំ វា និគមំ វា ឧបនិស្សាយ វិហរតិ កុលទូសកោ បាបសមាចារោ ។ តស្ស ខោ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច, កុលានិ ច តេន ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច, ។ សោ ភិក្ខុ ភិក្ខូហិ ឯវមស្ស វចនីយោ: អាយស្មា ខោ កុលទូសកោ បាបសមាចារោ, អាយស្មតោ ខោ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច, កុលានិ ចាយស្មតា ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច, បក្កមតាយស្មា ឥមម្ហា អាវាសា, អលំ តេ ឥធ វាសេនាតិ ។ ឯវញ្ច សោ ភិក្ខុ ភិក្ខូហិ វុច្ចមានោ, តេ ភិក្ខូ ឯវំ វទេយ្យ: ឆន្ទគាមិនោ ច ភិក្ខូ, ទោសគាមិនោ ច ភិក្ខូ, មោហគាមិនោ ច ភិក្ខូ, ភយគាមិនោ ច ភិក្ខូ, តាទិសិកាយ អាបត្តិយា ឯកច្ចំ បព្វាជេន្តិ ឯកច្ចំ ន បព្វាជេន្តីតិ ។

# សង្ឃាទិសេស សុរខ្លួស

កាលដែលភិក្ខុទាំងឡាយនិយាយយ៉ាងនេះ, ភិក្ខុនោះនៅតែប្រកាន់ដូច្នេះដដែល, ត្រូវភិក្ខុទាំងឡាយ ស្មូត្រសមនុភាសនកម្ម ហាមប្រាមភិក្ខុនោះអស់គំណត់បីដង ដើម្បីឲ្យលះបង់អំពើនោះចេញ ។ កាលបើភិក្ខុទាំងឡាយស្មូត្រសមនុភាសនកម្ម ហាមប្រាមគ្រប់បីដងហើយ ភិក្ខុនោះលះបង់អំពើនោះចេញ, ការលះបង់បានដូច្នេះនុ៎ះជាការប្រពៃ, បើពុំលះបង់ទេ, ត្រូវអាបត្តិសង្ឃាទិសេស។

១៣ – ភិក្ខុចូលទៅនៅអាស្រ័យនឹងស្រុកណាមួយ ឬនិគមណាមួយ ជាអ្នកទូស្តត្រកូល មានការប្រព្រឹត្តអាក្រក់ ។ ការប្រព្រឹត្តអាក្រក់របស់ភិក្ខុនោះផង ប្រាកដជាគេឃើញផង គេឮផង, ទាំងត្រកូលទាំងឡាយ ដែលភិក្ខុនោះទូស្ត ហើយ ក៏ប្រាកដជាគេឃើញផង គេឮផងដែរ ។ ភិក្ខុទាំងឡាយត្រូវនិយាយនឹងភិក្ខុនោះយ៉ាងនេះថា : “ លោកអ្នកមានអាយុជាអ្នកទូស្តត្រកូល ជាអ្នកមានការប្រព្រឹត្តអាក្រក់ពិត, ការប្រព្រឹត្តអាក្រក់របស់លោកអ្នកមានអាយុ ប្រាកដជាគេឃើញផង គេឮផង, ទាំងត្រកូលទាំងឡាយដែលលោកអ្នកមានអាយុទូស្ត ហើយ ក៏ប្រាកដជាគេឃើញផង គេឮផងដែរ, លោកអ្នកមានអាយុចូរចេញចាកអាវាសនេះទៅ ! លោកពុំគួរនឹងនៅក្នុងទីនេះទេ ។ កាលបើដែលភិក្ខុទាំងឡាយនិយាយយ៉ាងនេះ ភិក្ខុនោះត្រឡប់ជាថាឲ្យភិក្ខុទាំងឡាយនោះយ៉ាងនេះវិញថា : ភិក្ខុទាំងឡាយសុទ្ធតែលុះក្នុងសេចក្ដីស្រឡាញ់ផង , ភិក្ខុទាំងឡាយសុទ្ធតែលុះក្នុងសេចក្ដីស្អប់ផង, ភិក្ខុទាំងឡាយសុទ្ធតែលុះក្នុងសេចក្ដីល្ងង់ខ្លៅផង, ភិក្ខុទាំងឡាយសុទ្ធតែលុះក្នុងសេចក្ដីខ្លាចផង, ព្រោះភិក្ខុទាំងឡាយ បណ្ដេញភិក្ខុពួកខ្លះ មិនបណ្ដេញភិក្ខុពួកខ្លះ ដោយអាបត្តិដូចតែគ្នា ។

សោ ភិក្ខុ ភិក្ខូហិ ឯវមស្ស វចនីយោ : មា អាយស្មា ឯវំ អវច, ន ច ភិក្ខូ ឆន្ទគាមិនោ, ន ច ភិក្ខូ ទោសគាមិនោ, ន ច ភិក្ខូ មោហគាមិនោ, ន ច ភិក្ខូ ភយគាមិនោ, អាយស្មា ខោ កុលទូសកោ បាបសមាចារោ អាយស្មតោ ខោ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច, កុលានិ ចាយស្មតា ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច, បក្កមតាយស្មា ឥមម្ហា អាវាសា, អលន្តេ ឥធ វាសេនាតិ ។ ឯវញ្ច សោ ភិក្ខុ ភិក្ខូហិ វុច្ចមានោ, តថេវ បគ្គណ្ហេយ្យ, សោ ភិក្ខុ ភិក្ខូហិ យាវតតិយំ សមនុភាសិតព្វោ តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ សមនុភាសិយមានោ តំ បដិនិស្សជ្ជេយ្យ, ឥច្ចេតំ កុសលំ, នោ ចេ បដិនិស្សជ្ជេយ្យ, សង្ឃាទិសេសោ ។

# សង្ឃាទិសេសុទ្ទេស

ភិក្ខុនោះត្រឡប់ជាថា ឲ្យភិក្ខុទាំងឡាយនោះយ៉ាងនេះវិញថា : " ភិក្ខុទាំងឡាយ សុទ្ធតែលុះក្នុងសេចក្តីស្រឡាញ់ផង, ភិក្ខុទាំងឡាយសុទ្ធតែលុះក្នុងសេចក្តីស្អប់ផង, ភិក្ខុទាំងឡាយ សុទ្ធតែលុះក្នុងសេចក្តីល្ងង់ខ្លៅផង , ភិក្ខុទាំងឡាយ សុទ្ធតែលុះក្នុងសេចក្តីខ្លាចផង, ព្រោះភិក្ខុទាំងឡាយ បណ្តេញភិក្ខុពួកខ្លះ មិនបណ្តេញភិក្ខុពួកខ្លះ ដោយអាបត្តិដូចតែគ្នា " ។ ភិក្ខុទាំងឡាយ ត្រូវនិយាយនឹងភិក្ខុនោះ យ៉ាងនេះថា : " លោកអ្នកមានអាយុ កុំនិយាយយ៉ាងនេះឡើយ , ភិក្ខុទាំងឡាយ មិនមែនលុះក្នុងសេចក្តីស្រឡាញ់ទេ, ភិក្ខុទាំងឡាយមិនមែនលុះក្នុងសេចក្តីស្អប់ទេ, ភិក្ខុទាំងឡាយ មិនមែនលុះក្នុងសេចក្តីល្ងង់ខ្លៅទេ , ភិក្ខុទាំងឡាយមិនមែនលុះក្នុងសេចក្តីខ្លាចទេ, លោកអ្នកមានអាយុ ជាអ្នកទ្រុស្តត្រកូល ជាអ្នកមានការប្រព្រឹត្តអាក្រក់ពិត, ការប្រព្រឹត្តអាក្រក់របស់លោកអ្នកមានអាយុ ប្រាកដជាគេឃើញផង គេឮផង, ទាំងត្រកូលទាំងឡាយ ដែលលោកអ្នកមានអាយុទ្រុស្តហើយ ក៏ប្រាកដជាគេឃើញផង គេឮផងដែរ, លោកអ្នកមានអាយុ ចូរចេញចាកអាវាសនេះទៅ ! លោកពុំគួរនឹងនៅក្នុងទីនេះទេ " ។ កាលដែលភិក្ខុទាំងឡាយនិយាយយ៉ាងនេះ ភិក្ខុនោះនៅតែប្រកាន់ដូច្នោះដដែល, ត្រូវភិក្ខុទាំងឡាយសូត្រសមនុ-ភាសនកម្ម ហាមប្រាមភិក្ខុនោះ អស់កំណត់បីដង ដើម្បីឲ្យលះបង់អំពើអាក្រក់នោះចេញ ។ កាលបើភិក្ខុទាំងឡាយ សូត្រសមនុភាសនកម្មហាមប្រាមគ្រប់បីដងហើយ ភិក្ខុនោះលះបង់អំពើនោះចេញ , ការលះបង់បានដូច្នេះនុ៎ះជាការប្រពៃ, បើពុំលះបង់ទេ, ត្រូវអាបត្តិសង្ឃាទិសេស ។

ឧទិដ្ឋា ខោ អាយស្មន្តោ តេរស សង្ឃាទិសេសា ធម្មា, នវ បឋមាបត្តិកា, ចត្តារោ យាវតតិយកា; យេសំ ភិក្ខុ អញ្ញតរំ វា អញ្ញតរំ វា អាបជ្ជិត្វា យាវតិហំ ជានំ បដិច្ឆាទេតិ, តាវតិហំ តេន ភិក្ខុនា អកាមា បរិវត្ថព្វំ ។ បរិវុត្ថបរិវាសេន ភិក្ខុនា ឧត្តរិ ឆារត្តំ ភិក្ខុមានត្តាយ បដិបជ្ជិតព្វំ ។ ចិណ្ណមានត្តោ ភិក្ខុ, យត្ថ សិយា វីសតិគណោ ភិក្ខុសង្ឃោ, តត្ថ សោ ភិក្ខុ អព្ភេតព្វោ ។ ឯកេនបិ ចេ ឩនោ វីសតិគណោ ភិក្ខុសង្ឃោ តំ ភិក្ខុំ អព្ភេយ្យ, សោ ច ភិក្ខុ អនព្ភិតោ, តេ ច ភិក្ខូ គារយ្ហា ។ អយំ តត្ថ សាមីចិ ។

# ភិក្ខុបាតិមោក្ខប្រែ

បពិត្រលោកអ្នកមានអាយុទាំងឡាយ អាបត្តិឈ្មោះសង្ឃាទិសេសទាំង ១៣ ខ្ញុំព្រះករុណាបានសំដែងរួចហើយ, អាបត្តិ ៩ ហៅថា " បឋមាបត្តិកា " ( គឺត្រូវអាបត្តិក្នុងវេលាធ្វើឲ្យកន្លងបញ្ញត្តិជាដំបូង ) , អាបត្តិ ៤ ហៅថា " យាវតតិយ-កា " ( គឺត្រូវអាបត្តិក្នុងវេលាដែលសង្ឃសូធ្យប្រកាសហាមគ្រប់បីដងហើយ ក៏នៅតែពុំព្រមលះបង់អំពើអាក្រក់នោះចេញ ) , បណ្ដាអាបត្តិទាំង ១៣ នោះ, បើភិក្ខុណាត្រូវអាបត្តិណាមួយហើយ ដឹងច្បាស់បិទបាំងទុកអស់ប៉ុន្មានថ្ងៃ , ភិក្ខុនោះត្រូវនៅបរិវាសអស់ប៉ុណ្ណោះថ្ងៃដោយផាច់ខាត (១) ភិក្ខុអ្នកនៅបរិវាស គ្រប់កំណត់ថ្ងៃដែលបិទបាំងហើយ ត្រូវប្រព្រឹត្តភិក្ខុមានត្ត(២) អស់ ៦ រាត្រី តទៅទៀត ។ ភិក្ខុប្រព្រឹត្តមានត្តហើយ, ភិក្ខុសង្ឃពួក ២០ រូប មានក្នុងទីណា , ភិក្ខុនោះ ត្រូវភិក្ខុសង្ឃចំនួន ២០ រូប ឲ្យអព្ភានកម្ម (៣) ក្នុងទីនោះ ។ បើភិក្ខុសង្ឃមិនគ្រប់ ២០ រូបទេ សូម្បីខ្វះតែមួយរូប ហើយឲ្យអព្ភានកម្មដល់ភិក្ខុនោះ , ភិក្ខុនោះមិនបានឈ្មោះថា ភិក្ខុសង្ឃឲ្យអព្ភានកម្មផង, ទាំងពួកការកភិក្ខុនោះ ក៏ឈ្មោះថាត្រូវព្រះពុទ្ធជាម្ចាស់តិះដៀលផង(៤) សេចក្ដីប្រតិបត្តិនេះ ជាការសមគួរក្នុងកម្មនោះ ។

---

១ បើទុកជាភិក្ខុនោះមិនចង់នៅបរិវាសក៏ដោយ ត្រូវតែនៅទាល់តែបាន ។ ២ ភិក្ខុមានត្ត ប្រែថា កម្មជាគ្រឿងប្រព្រឹត្ត ដើម្បីឲ្យបានជាទីរាប់អាន របស់ភិក្ខុផងគ្នា ។ ៣ អព្ភានកម្ម ប្រែថា កម្មដែលសង្ឃសូធ្យប្រកាសហៅភិក្ខុដែលបាននៅបរិវាសព្រមទាំងមានត្តរួចហើយនោះ មកបញ្ចូលជាពួកវិញ ។ ៤ គឺថា ភិក្ខុជាការកសង្ឃនោះត្រូវអាបត្តិទុក្កដទាំងអស់គ្នា ។

សង្ឃាទិសេសុទ្ទេសោ

តត្ថាយស្មន្តេ បុច្ឆាមិ.

កច្ចិត្ថ បរិសុទ្ធា ?

ទុតិយម្បិ បុច្ឆាមិ,

កច្ចិត្ថ បរិសុទ្ធា ?

តតិយម្បិ បុច្ឆាមិ,

កច្ចិត្ថ បរិសុទ្ធា ?

បរិសុទ្ធេត្ថាយស្មន្តោ,

តស្មា តុណ្ហី ។

ឯវមេតំ ធារយាមិ ។

សង្ឃាទិសេសុទ្ទេសោ និដ្ឋិតោ ។

# សង្ឃាទិសេសុទ្ទេស

ខ្ញុំព្រះករុណា សូមសួរលោកអ្នកមានអាយុទាំងឡាយ ក្នុងសង្ឃាទិសេសាបត្តិទាំង ១៣ នោះ,

លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ?

ខ្ញុំព្រះករុណា សូមសួរជាគម្រប់ពីរដងទៀត .

លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ?

ខ្ញុំព្រះករុណា សូមសួរជាគម្រប់បីដងទៀត .

លោកទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ ?

លោកអ្នកមានអាយុទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធ ក្នុងសង្ឃាទិសេសាបត្តិទាំង ១៣ នោះហើយ, ព្រោះហេតុនោះបានជានៅស្ងៀម ។ ខ្ញុំព្រះករុណា សូមចាំទុកនូវហេតុនេះ ដោយកិរិយានៅស្ងៀមយ៉ាងនេះ ។

ចប់សង្ឃាទិសេសុទ្ទេស

ឥមេ ខោ បនាយស្មន្តោ ទ្វេ អនិយតា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

១- យោ បន ភិក្ខុ មាតុគ្គាមេន សទ្ធឹ ឯកោ ឯកាយ រហោ បដិច្ឆន្នេ អាសនេ អលំកម្មនិយេ និសជ្ជំ កប្បេយ្យ តមេនំ សទ្ធេយ្យវចសា ឧបាសិកា ទិស្វា តិណ្ណំ ធម្មានំ អញ្ញតរេន វទេយ្យ បារាជិកេន វា សង្ឃាទិសេសេន វា បាចិត្តិយេន វា.និសជ្ជំ ភិក្ខុ បដិជានមានោ តិណ្ណំ ធម្មានំ អញ្ញតរេន ការេតព្វោ បារាជិកេន វា សង្ឃាទិសេសេន វា បាចិត្តិយេន វា, យេន វា សា សទ្ធេយ្យវចសា ឧបាសិកា វទេយ្យ, តេន សោ ភិក្ខុ ការេតព្វោ ។ អយំ ធម្មោ អនិយតោ ។

២- ន ហេវ ខោ បន បដិច្ឆន្នំ អាសនំ ហោតិ នាលំកម្មនិយំ, អលញ្ច ខោ ហោតិ មាតុគ្គាមំ ទុដ្ឋុល្លាហិ វាចាហិ ឱភាសិតុំ ។

# ភិក្ខុប្បាតិមោក្ខប្រែ

បពិត្រលោកអ្នកមានអាយុទាំងឡាយ, ធម៌ឈ្មោះអនិយតទាំងឡាយ ពីរ នេះឯង មកកាន់ឧទ្ទេស ។

១- ភិក្ខុណាមួយ តែម្នាក់និងម្នាក់ អង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើមេថុនកិច្ចបានជាមួយនឹងមាតុគ្រាម , ឧបាសិកាដែលមានវាចាគួរជឿបាន ឃើញភិក្ខុនោះហើយ គប្បីចោទដោយអាបត្តិបីយ៉ាង ចំពោះអាបត្តិណាមួយ គឺអាបត្តិបារាជិកក៏ សង្ឃាទិសេសក្តី បាចិត្តិយក្តី , កាលបើភិក្ខុទទួលប្តេជ្ញាការអង្គុយមែន , វិន័យធរត្រូវវិនិច្ឆ័យដោយអាបត្តិបីយ៉ាង ចំពោះអាបត្តិណាមួយ គឺអាបត្តិបារាជិកក្តី សង្ឃាទិសេសក្តី បាចិត្តិយក្តី , ម្យ៉ាងទៀត ឧបាសិកាដែលមានវាចាគួរជឿបាននោះ ចោទដោយអាបត្តិណា , វិន័យធរត្រូវវិនិច្ឆ័យដោយអាបត្តិនោះចំពោះភិក្ខុនោះ ។

ធម៌នេះ ឈ្មោះថា អនិយត ( មិនទៀង ) ។

២- បើអាសនៈជាទីដែលគេមិនបានបិទបាំង មិនល្មមនឹងធ្វើមេថុនកិច្ចបានក៏ពិតមែន, ប៉ុន្តែថា ជាទីគួរនឹងនិយាយពេចន៍មាតុគ្រាម ដោយពាក្យអាក្រក់ៗបាន ។

យោ បន ភិក្ខុ តថារូបេ អាសនេ មាតុគ្គាមេន សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេយ្យ, តមេនំ សទ្ធេយ្យវចសា ឧបាសិកា ទិស្វា តិណ្ណំ ធម្មានំ អញ្ញតរេន វទេយ្យ សង្ឃាទិសេសេន វា បាចិត្តិយេន វា, និសជ្ជំ ភិក្ខុ បដិជានមានោ តិណ្ណំ ធម្មានំ អញ្ញតរេន ការេតព្វោ សង្ឃាទិសេសេន វា បាចិត្តិយេន វា, យេន វា សា សទ្ធេយ្យវចសា ឧបាសិកា វទេយ្យ, តេន សោ ភិក្ខុ ការេតព្វោ ។ អយម្បិ ធម្មោ អនិយតោ ។

ឧទ្ទិដ្ឋា ខោ អាយស្មន្តោ ទ្វេ អនិយតា ធម្មា ។ តត្ថាយស្មន្តេ បុច្ឆាមិ, កច្ចិត្ថ បរិសុទ្ធា? ទុតិយម្បិ បុច្ឆាមិ, កច្ចិត្ថ បរិសុទ្ធា? តតិយម្បិ បុច្ឆាមិ, កច្ចិត្ថ បរិសុទ្ធា? បរិសុទ្ធេត្ថាយស្មន្តោ, តស្មា តុណ្ហី ។ ឯវមេតំ ធារយាមិ ។

អនិយតុទ្ទេសោ និដ្ឋិតោ ។

# អនិយតុទ្ទេស

ភិក្ខុណាមួយ តែម្នាក់និងម្នាក់ អង្គុយក្នុងទីស្ងាត់ លើអាសនៈ មានសភាពដូច្នោះ ជាមួយនឹងមាតុគ្រាម, ឧបាសិកាដែលមានវាចាគួរជឿបាន ឃើញភិក្ខុនោះហើយ គប្បីចោទដោយអាបត្តិពីរយ៉ាង ចំពោះអាបត្តិណាមួយ គឺអាបត្តិសង្ឃាទិសេសក្តី បាចិត្តិយក្តី, កាលបើភិក្ខុទទួលប្តេជ្ញាការអង្គុយមែន វិន័យធរត្រូវវិនិច្ឆ័យដោយអាបត្តិពីរយ៉ាង ចំពោះអាបត្តិណាមួយ គឺអាបត្តិសង្ឃាទិសេសក្តី បាចិត្តិយក្តី, មួយទៀតឧបាសិកាដែលមានវាចាគួរជឿបាននោះ ចោទដោយអាបត្តិណា, វិន័យធរត្រូវវិនិច្ឆ័យ ដោយអាបត្តិនោះ ចំពោះភិក្ខុនោះ ។ ទាំងធម៌នេះ ក៏ឈ្មោះថា អនិយតដែរ ។

បពិត្រលោកអ្នកមានអាយុទាំងឡាយ, ធម៌ឈ្មោះអនិយតទាំងពីរ ខ្ញុំព្រះករុណា បានសម្តែងរួចហើយ ។ ខ្ញុំព្រះករុណា សូមសួរលោកអ្នកមានអាយុទាំងឡាយ ក្នុងអាបត្តិទាំងនោះ, លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ? ខ្ញុំព្រះករុណា សូមសួរជាគម្រប់ពីរផងទៀត, លោកទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ? ខ្ញុំព្រះករុណា សូមសួរជាគម្រប់បីផងទៀត, លោកទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ? លោកអ្នកមានអាយុទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធ ក្នុងអាបត្តិទាំងនុ៎ះហើយ, ព្រោះហេតុនោះ បានជានៅស្ងៀម ។ ខ្ញុំព្រះករុណាសូមចាំទុកនូវហេតុនេះ ដោយកិរិយានៅស្ងៀមយ៉ាងនេះ ។

ចប់អនិយតុទ្ទេស

ឥមេ ខោ បនាយស្មន្តោ តឹស និស្សគ្គិយា បាចិត្តិយា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

១- និដ្ឋិតចីវរស្មឹ ភិក្ខុនា ឧព្ភតស្មឹ កឋិនេ, ទសាហបរមំ អតិរេកចីវរំ ធារេតព្វំ, តំ អតិក្កាមយតោ, និស្សគ្គិយំ បាចិត្តិយំ ។១។(១)

២- និដ្ឋិតចីវរស្មឹ ភិក្ខុនា ឧព្ភតស្មឹ កឋិនេ, ឯករត្តម្បិ ចេ ភិក្ខុ តិចីវរេន វិប្បវសេយ្យ, អញ្ញត្រ ភិក្ខុសម្មតិយា, និស្សគ្គិយំ បាចិត្តិយំ ។២។

៣- និដ្ឋិតចីវរស្មឹ ភិក្ខុនា ឧព្ភតស្មឹ កឋិនេ, ភិក្ខុនោ បនេវ អកាលចីវរំ ឧប្បជ្ជេយ្យ, អាកង្ខមានេន ភិក្ខុនា បដិគ្គហេតព្វំ, បដិគ្គហេត្វា ខិប្បមេវ ការេតព្វំ, នោ ចស្ស បារិបូរិ, មាសបរមំ តេន ភិក្ខុនា តំ ចីវរំ និក្ខិបិតព្វំ, ឧនស្ស បារិបូរិយា សតិយា បច្ចាសាយ, តតោ ចេ ឧត្តរី និក្ខិបេយ្យ, សតិយាបិ បច្ចាសាយ, និស្សគ្គិយំ បាចិត្តិយំ ។៣។

---

១ លេខរៀងខាងដើមប្រាប់ចំនួនសិក្ខាបទក្នុងកណ្ឌមួយៗ, លេខរៀងខាងចុងប្រាប់ចំនួនសិក្ខាបទក្នុងវគ្គមួយៗ ។

# ភិក្ខុបាតិមោក្ខប្រែ

បពិត្រលោកអ្នកមានអាយុទាំងឡាយ, អាបត្តិនិស្សគ្គិយបាចិត្តិយទាំងឡាយ ៣០ នេះឯង មកកាន់ឧទ្ទេស ( គឺបាតិមោក្ខដែលសង្ឃ ត្រូវសម្តែងរាល់កន្លះខែ )។

១- កាលបើចីវរសម្រេចហើយ កឋិនដោះហើយ, ភិក្ខុត្រូវទុកដាក់អតិរេកចីវរ យ៉ាងយូរបំផុតបានត្រឹម ១០ ថ្ងៃ ( បើទុក ) ឲ្យកន្លងហួសពីនោះទៅ, ចីវរនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

២- កាលបើចីវរសម្រេចហើយ កឋិនដោះហើយ , បើភិក្ខុនៅប្រាសចាកត្រៃចីវរ សូម្បីតែមួយយប់, វៀរលែងតែភិក្ខុដែលបានអវិប្បវាសសម្មតិអំពីសង្ឃ, ចីវរនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

៣- កាលបើចីវរសម្រេចហើយ កឋិនដោះហើយ, បើអកាលចីវរ កើតឡើងដល់ភិក្ខុ, កាលបើភិក្ខុមានសេចក្តីត្រូវការ ក៏គប្បីទទួលចុះ , លុះទទួលហើយ ត្រូវរៀបរៀងធ្វើឲ្យឆាប់, បើសំពត់នោះនៅខ្វះ ធ្វើមិនគ្រប់គ្រាន់ទេ, ភិក្ខុនោះត្រូវទុកសំពត់នោះ យ៉ាងយូរបំផុតបានត្រឹម ១ ខែ, បើមានបំណងថា នឹងរកសំពត់មកបំពេញចីវរខ្វះនោះ , បើទុកឲ្យលើសពីមួយខែនោះទៅ , បើទុកដាមានបំណងតទៅទៀតក៏ដោយ , ចីវរនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

៤- យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា បុរាណចីវរំ ធោវាបេយ្យ វា រជាបេយ្យ វា អាកោ-ដាបេយ្យ វា និស្សគ្គិយំ បាចិត្តិយំ ។ ៤ ។

៥- យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា ហត្ថតោ ចីវរំ បដិគ្គណ្ហេយ្យ, អញ្ញត្រ បារិវត្តកា, និស្សគ្គិយំ បាចិត្តិយំ ។ ៥ ។

៦- យោ បន ភិក្ខុ អញ្ញាតកំ គហបតឹ វា គហបតានឹ វា ចីវរំ វិញ្ញាបេយ្យ, អញ្ញត្រ សមយា, និស្សគ្គិយំ បាចិត្តិយំ, តត្ថាយំ សមយោ: អច្ឆិន្នចីវរោ វា ហោតិ ភិក្ខុ នដ្ឋចីវរោ វា, អយំ តត្ថ សមយោ ។ ៦ ។

៧- តញ្ចេ អញ្ញាតកោ គហបតិ វា គហបតានី វា ពហូហិ ចីវរេហិ អភិហដ្ឋុំ បវារេយ្យ, សន្តរុត្តរបរមន្តេន ភិក្ខុនា តតោ ចីវរំ សាទិតព្វំ, តតោ ចេ ឧត្តរឹ សាទិយេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។ ៧ ។

# ចីវរវគ្គ ក្នុងនិស្សគ្គិយ

៤- ភិក្ខុណាមួយ ប្រើភិក្ខុនី មិនមែនជាញាតិ ឲ្យលាងក្តី ឲ្យជ្រលក់ក្តី ឲ្យគោះគក់ក្តី នូវចីវរចាស់, ចីវរនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៥. ភិក្ខុណាមួយ ទទួលយកចីវរអំពីដៃភិក្ខុនី មិនមែនជាញាតិ, វៀរលែងតែប្តូរគ្នា, ចីវរនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៦. ភិក្ខុណាមួយ សូមចីវរចំពោះគហបតី(១)ក្តី គហបតានី(២)ក្តី មិនមែនជាញាតិ, វៀរលែងតែមានសម័យ, ចីវរនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ, នេះជាសម័យក្នុងសិក្ខាបទនោះគឺ : ភិក្ខុមានចីវរដែលចោរដណ្តើមយកទៅ ឬមានចីវរខូច, នេះជាសម័យ ក្នុងសិក្ខាបទនោះ ។

៧. បើគហបតីក្តី គហបតានីក្តី មិនមែនជាញាតិ គេបវារណាភិក្ខុនោះ ដើម្បីនាំយកចីវរជាច្រើនមកប្រគេន , ភិក្ខុនោះត្រូវត្រេកអរតែនឹងចីវរដែលមានកំណត់យ៉ាងច្រើនបំផុត បានត្រឹមអន្តរវាសក និងឧត្តរាសង្គប៉ុណ្ណោះ អំពីចីវរដែលគេនាំមកនោះ , បើត្រេកអរលើសអំពីកំណត់នោះទៅ , ចីវរនោះជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

---

១ បុរសជាម្ចាស់ផ្ទះ ។ ២ ស្ត្រីជាម្ចាស់ផ្ទះ ។

៨. ភិក្ខុំ បនេវ ឧទ្ទិស្ស អញ្ញាតកស្ស គហបតិស្ស វា គហបតានិយា វា ចីវរចេតាបនំ ឧបក្ខដំ ហោតិ៖ ឥមិនា ចីវរចេតាបនេន ចីវរំ ចេតាបេត្វា ឥត្ថន្នាមំ ភិក្ខុំ ចីវរេន អច្ឆាទេស្សាមីតិ ។ តត្រ ចេ សោ ភិក្ខុ បុព្វេ អប្បវារិតោ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជេយ្យ៖ សាធុ វត មំ អាយស្មា ឥមិនា ចីវរចេតាបនេន ឯវរូបំ វា ឯវរូបំ វា ចីវរំ ចេតាបេត្វា អច្ឆាទេហីតិ, កល្យាណកម្យតំ ឧបាទាយ, និស្សគ្គិយំ បាចិត្តិយំ ។៨។

៩- ភិក្ខុំ បនេវ ឧទ្ទិស្ស ឧភិន្នំ អញ្ញាតកានំ គហបតីនំ វា គហបតានីនំ វា បច្ចេកចីវរចេតាបនា ឧបក្ខដា ហោន្តិ៖ ឥមេហិ មយំ បច្ចេកចីវរចេតាបនេហិ បច្ចេកចីវរានិ ចេតាបេត្វា ឥត្ថន្នាមំ ភិក្ខុំ ចីវរេហិ អច្ឆាទេស្សាមាតិ ។

៨. បើមានគហបតិក្តី គហបតានីក្តី មិនមែនជាញាតិ គេបម្រុងតម្លៃសម្រាប់ទិញចីវរ ចំពោះភិក្ខុថា :

" ខ្ញុំនឹងទិញចីវរ ដោយតម្លៃចីវរនេះហើយ នឹងឲ្យភិក្ខុឈ្មោះនេះ ស្លៀកដណ្តប់ចីវរ " ។ បើភិក្ខុដែលគេមិនបានបវារណាជាមុននោះ ចូលទៅក្នុងទីនោះហើយ កំណត់ចីវរដោយពាក្យថា : " ល្អហើយអ្នកមានអាយុ ! អ្នកចូរទិញចីវរមានបែបយ៉ាងនេះៗ ដោយតម្លៃចីវរនេះហើយ ចូរឲ្យមកអាត្មាស្លៀកដណ្តប់ចុះ ", ព្រោះអាស្រ័យសេចក្តីចង់បានចីវរល្អ , ចីវរនោះ ជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

៩. បើមានតម្លៃចីវរផ្សេងគ្នា ដែលគហបតីក្តី គហបតានីក្តី ពីរនាក់ មិនមែនជាញាតិ គេឧទ្ទិសចំពោះភិក្ខុមួយរូបហើយ តម្កល់ទុកថា :

"យើងនឹងទិញចីវរផ្សេងគ្នា ដោយតម្លៃចីវរផ្សេងគ្នាទាំងនេះហើយ នឹងឲ្យភិក្ខុឈ្មោះនេះ ស្លៀកដណ្តប់ចីវរទាំងឡាយ "

តត្រ ចេ សោ ភិក្ខុ បុព្វេ អប្បវារិតោ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជេយ្យ : សាធុ វត មំ អាយស្មន្តោ ឥមេហិ បច្ចេកចីវរចេតាបនេហិ ឯវរូបំ វា ឯវរូបំ វា ចីវរំ ចេតាបេត្វា អច្ឆាទេថ ឧភោវ សន្តា ឯកេនាតិ, កល្យាណកម្យតំ ឧបាទាយ, និស្សគ្គិយំ បាចិត្តិយំ ។៩។

១០ ភិក្ខុំ បនេវ ឧទ្ទិស្ស រាជា វា រាជភោគ្គោ វា ព្រាហ្មណោ វា គហបតិកោ វា ទូតេន ចីវរេតាបនំ បហិណេយ្យ : ឥមិនា ចីវរចេតាបនេន ចីវរំ ចេតាបេត្វា ឥត្ថន្នាមំ ភិក្ខុំ ចីវរេន អច្ឆាទេហីតិ ។ សោ ចេ ទូតោ តំ ភិក្ខុំ ឧបសង្កមិត្វា ឯវំ វទេយ្យ : ឥទំ ខោ ភន្តេ អាយស្មន្តំ ឧទ្ទិស្ស ចីវរចេតាបនំ អាភតំ, បដិគ្គណ្ហាតុ អាយស្មា ចីវរចេតាបនន្តិ ។ តេន ភិក្ខុនា សោ ទូតោ ឯវមស្ស វចនីយោ : ន ខោ មយំ អាវុសោ ចីវរចេតាបនំ បដិគ្គណ្ហាម, ចីវរញ្ច ខោ មយំ បដិគ្គណ្ហាម កាលេន កប្បិយន្តិ ។

បើភិក្ខុដែលគេមិនបានបវារណាជាមុននោះ ចូលទៅក្នុងទីនោះ ហើយកំណត់ចីវរដោយពាក្យថា : " ល្អហើយ អ្នកមានអាយុទាំងឡាយ ! អ្នកទាំងពីរចូររួបរួមជាមួយគ្នា ទិញចីវរបែបយ៉ាងនេះៗ ដោយតម្លៃចីវរផ្សេងគ្នាទាំងនេះហើយ ចូរនាំយកមកអាត្មាស្លៀកដណ្តប់ចុះ " ព្រោះអាស្រ័យសេចក្តីចង់បាននូវចីវរល្អ, ចីវរនោះជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

១០- ព្រះរាជាក្តី រាជអាមាត្យក្តី ព្រាហ្មណ៍ក្តី គហបតីក្តី បានឧទ្ទិសចំពោះភិក្ខុមួយរូបហើយ បញ្ជូនតម្លៃចីវរទៅប្រគេនដោយអ្នកបម្រើថា : " អ្នកឯងចូរទិញចីវរ ដោយតម្លៃចីវរនេះហើយ ចូរប្រគេនភិក្ខុឈ្មោះនេះ ឲ្យស្លៀកដណ្តប់ចីវរចុះ " ។ បើបម្រើនោះ ចូលទៅរកភិក្ខុនោះហើយ និយាយយ៉ាងនេះថា : " លោកម្ចាស់ ! តម្លៃចីវរនេះ ខ្ញុំព្រះករុណានាំមក ចំពោះលោកអ្នកមានអាយុ, សូមលោកអ្នកមានអាយុ ទទួលយកតម្លៃចីវរចុះ " ។ ភិក្ខុនោះត្រូវនិយាយនឹងបម្រើនោះ យ៉ាងនេះថា : " ម្នាលអាវុសោ ! យើងទទួលយកតម្លៃចីវរពុំបានទេ, យើងទទួលបានតែចីវរដែលគួរ ដោយកាលគួរ " ។

សោ ចេ ទូតោ តំ ភិក្ខុំ ឯវំ វទេយ្យ : អត្ថិ បនាយស្មតោ កោចិ វេយ្យាវច្ចករោតិ ។ ចីវរត្ថិកេន ភិក្ខវេ ភិក្ខុនា វេយ្យាវច្ចករោ និទ្ទិសិតព្វោ អារាមិកោ វា ឧបាសកោ វា : ឯសោ ខោ អាវុសោ ភិក្ខូនំ វេយ្យាវច្ចករោតិ ។ សោ ចេ ទូតោ តំ វេយ្យាវច្ចករំ សញ្ញាបេត្វា, តំ ភិក្ខុំ ឧបសង្កមិត្វា, ឯវំ វទេយ្យ: យំ ខោ ភន្តេ អាយស្មា វេយ្យាវច្ចករំ និទ្ទិសិ, សញ្ញត្តោ សោ មយា, ឧបសង្កមតុ អាយស្មា, កាលេន ចីវរេន តំ អច្ឆាទេស្សតីតិ ។ ចីវរត្ថិកេន ភិក្ខវេ ភិក្ខុនា វេយ្យាវច្ចករោ ឧបសង្កមិត្វា ទ្វិត្តិក្ខត្តុំ ចោទេតព្វោ សារេតព្វោ អត្ថោ មេ អាវុសោ ចីវរេនាតិ ។ ទ្វិត្តិក្ខត្តុំ ចោទយមានោ សារយមានោ តំ ចីវរំ អភិនិប្ផាទេយ្យ, ឥច្ចេតំ កុសលំ; នោ ចេ អភិនិប្ផាទេយ្យ ចតុក្ខត្តុំ បញ្ចក្ខត្តុំ ឆក្ខត្តុបរមំ តុណ្ហីភូតេន ឧទ្ទិស្ស ឋាតព្វំ; ចតុក្ខត្តុំ បញ្ចក្ខត្តុំ ឆក្ខត្តុបរមំ តុណ្ហីភូតោ ឧទ្ទិស្ស តិដ្ឋមានោ តំ ចីវរំ អភិនិប្ផាទេយ្យ,

# ភិក្ខុប្បាតិមោក្ខប្រែ

បើចម្រើនោះ សួរភិក្ខុនោះយ៉ាងនេះថា : លោកអ្នកមានអាយុមានវេយ្យាវច្ចករណាមួយដែរឬ" ។ ម្នាលភិក្ខុទាំងឡាយ ! ភិក្ខុអ្នកត្រូវការចីវរ គប្បីបង្ហាញប្រាប់វេយ្យាវច្ចករ គឺញោមវត្តឬឧបាសកថា : " ម្នាលអាវុសោ ! អ្នកនេះឯងហើយជាវេយ្យាវច្ចកររបស់ភិក្ខុទាំងឡាយ " ។

បើចម្រើនោះ បាននិយាយពន្យល់វេយ្យាវច្ចករនោះ ឲ្យចូលចិត្តហើយ ក៏ចូលទៅរកភិក្ខុនោះ ពោលយ៉ាងនេះថា : " បពិត្រលោកដ៏ចម្រើន ! លោកអ្នកមានអាយុ បង្ហាញប្រាប់នូវវេយ្យាវច្ចករណា," វេយ្យាវច្ចករនោះ ខ្ញុំព្រះករុណាបានពន្យល់ឲ្យចូលចិត្តហើយ , សូមលោកអ្នកមានអាយុ ចូលទៅរកគេចុះ , គេនឹងឲ្យលោកស្លៀកដណ្តប់ចីវរតាមកាល ។ ម្នាលភិក្ខុទាំងឡាយ ! ភិក្ខុអ្នកត្រូវការចីវរ គប្បីចូលទៅគៀនទារ រំលឹកវេយ្យាវច្ចករ ពីរបីលើកថា : "ម្នាលអាវុសោ ! អាត្មាត្រូវការចីវរ ។ កាលបើភិក្ខុទៅតៀនទាររំលឹកអស់ពីរបីលើក ក៏ញុំាងចីវរនោះឲ្យសម្រេចបាន , ការបានសម្រេចដូច្នេះនុ៎ះ ជាការប្រពៃ, បើពុំបានសម្រេចទេ, ភិក្ខុគប្បីទៅឈរស្ងៀមចំពោះមុខ បួនលើក ប្រាំលើក ប្រាំមួយលើកយ៉ាងច្រើន, កាលបើភិក្ខុឈរស្ងៀមចំពោះមុខ បួនលើកប្រាំលើកប្រាំមួយលើក យ៉ាងច្រើនបំផុតហើយ ក៏ញុំាងចីវរនោះ អោយសម្រេចបាន ,

ឥច្ចេតំ កុសលំ; នោ ចេ អភិនិប្ផាទេយ្យ, តតោ ចេ ឧត្តរឹ វាយមមានោ តំ ចីវរំ អភិនិប្ផាទេយ្យ, និស្សគ្គិយំ បាចិត្តិយំ, នោ ចេ អភិនិប្ផាទេយ្យ, យតស្ស ចីវរចេតាបនំ អាភតំ, តត្ថ សាមំ វា គន្តព្វំ ទូតោ វា បាហេតព្វោ យំ ខោ តុម្ហេ អាយស្មន្តោ ភិក្ខុំ ឧទ្ទិស្ស ចីវរចេតាបនំ បហិណិត្ថ, ន តំ តស្ស ភិក្ខុនោ កិញ្ចិ អត្ថំ អនុភោតិ, យុញ្ជន្តាយស្មន្តោ សកំ, មា វោ សកំ វិនស្សាតិ ។ អយំ តត្ថ សាមីចិ ។១០។

## ចីវរវគ្គោ បឋមោ ។

១១- យោ បន ភិក្ខុ កោសិយមិស្សកំ សន្ថតំ ការាបេយ្យ និស្សគ្គិយំ បាចិត្តិយំ ។១១។

១២- យោ បន ភិក្ខុ សុទ្ធកាឡកានំ ឯឡកលោមានំ សន្ថតំ ការាបេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។១២។

១៣- នវំ បន ភិក្ខុនា សន្ថតំ ការយមានេន ទ្វេ ភាគា សុទ្ធកាឡកានំ ឯឡកលោមានំ អាទាតព្វា, តតិយំ ឱទាតានំ ចតុត្ថំ គោចរិយានំ ។

ការបានសម្រេចផ្តេកផ្តួលទុំ ជាការប្រពៃ, បើពុំបានសម្រេចទេ, កាលបើភិក្ខុនោះ ចេះតែព្យាយាម ឲ្យលើសពីកំណត់នោះ ទាល់តែបានសម្រេចចីវរនោះមក, ចីវរនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ, បើពុំបានសម្រេចទេ, ថាប្រើនោះ នាំតម្លៃចីវរមកដើម្បីភិក្ខុនោះ អំពីសំណាក់អ្នកណា, ភិក្ខុគប្បីទៅខ្លួនឯង ឬប្រើ បម្រើឲ្យទៅក្នុងសំណាក់អ្នកនោះថា : " ម្នាលអ្នកមានអាយុទាំងឡាយ ! អ្នក ទាំងឡាយបញ្ជូនតម្លៃចីវរទៅ ចំពោះភិក្ខុរូបណា, តម្លៃចីវរនោះ ពុំសម្រេច ប្រយោជន៍បន្តិចបន្តួចដល់ភិក្ខុរូបនោះទេ, អ្នកមានអាយុទាំងឡាយ ចូរទារយក របស់អ្នកវិញចុះ, ទ្រព្យរបស់អ្នកទាំងឡាយ ចូរកុំវិនាសខូចឡើយ " ។ នេះជា សាមីចិកម្ម គឺសេចក្តីប្រព្រឹត្តិដ៏សមគួរ ក្នុងសិក្ខាបទនោះ ។

ចីវរវគ្គទីមួយ ( ចប់ ) ។

១១. ភិក្ខុណាមួយ ឲ្យគេធ្វើសន្ថត លាយដោយសូត្រ, សន្ថតនោះជា និស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

១២. ភិក្ខុណាមួយ ឲ្យគេធ្វើសន្ថត ដោយរោមចៀមខ្មៅសុទ្ធ, សន្ថតនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

១៣. កាលបើភិក្ខុឲ្យគេធ្វើសន្ថតថ្មី គប្បីយករោមចៀមខ្មៅសុទ្ធពីរភាគ, រោមចៀមស (មួយភាគ) ជាភាគទីបី, រោមចៀមក្រហម (មួយភាគ) ជាភាគទីបួន ។

អនាទា ចេ ភិក្ខុ ទ្វេ ភាគេ សុទ្ធកាឡកានំ ឯឡក-លោមានំ តតិយំ ឱទាតានំ ចតុត្ថំ គោចរិយានំ នវំ សន្ថតំ ការាបេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។១៣។

១៤- នវំ បន ភិក្ខុនា សន្ថតំ ការាបេត្វា ឆព្វស្សានិ ធារេតព្វំ ។ ឱរេន ចេ ឆន្នំ វស្សានំ តំ សន្ថតំ វិស្សជ្ជេត្វា វា អវិស្សជ្ជេត្វា វា អញ្ញំ នវំ សន្ថតំ ការាបេយ្យ, អញ្ញត្រ ភិក្ខុសម្មតិយា, និស្សគ្គិយំ បាចិត្តិយំ ។១៤។

១៥- និសីទនសន្ថតំ បន ភិក្ខុនា ការយមានេន បុរាណសន្ថតស្ស សាមន្តា សុគតវិទត្ថិ អាទាតព្វា ទុព្វណ្ណករណាយ ។ អនាទា ចេ ភិក្ខុ បុរាណសន្ថតស្ស សាមន្តា សុគតវិទត្ថឹ នវំ និសីទនសន្ថតំ ការាបេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។១៥។

១៦- ភិក្ខុនោ បនេវ អទ្ធានមគ្គប្បដិបន្នស្ស ឯឡកលោមានិ ឧប្បជ្ជេយ្យុំ, អាកង្ខមានេន ភិក្ខុនា បដិគ្គហេតព្វានិ, បដិគ្គហេត្វា តិយោជនបរមំ សហត្ថា ហារេតព្វានិ អសន្តេ ហារកេ, តតោ ចេ ឧត្តរឹ ហរេយ្យ អសន្តេបិ ហារកេ, និស្សគ្គិយំ បាចិត្តិយំ ។១៦។

បើភិក្ខុមិនយករោមចៀមខ្មៅសុទ្ធពីរភាគ រោមចៀមសជាភាគទីបី រោមចៀមក្រហមជាភាគទីបួនទេ , ហើយឲ្យគេធ្វើសន្ថតថ្មី , សន្ថតនោះជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

១៤.បើភិក្ខុឲ្យគេធ្វើសន្ថតថ្មី គប្បីប្រើប្រាស់ឲ្យដល់ប្រាំមួយឆ្នាំ ។ បើមិនទាន់ដល់ប្រាំមួយឆ្នាំទេ ភិក្ខុលះចោលសន្ថតនោះក្តី មិនលះក្តី ហើយឲ្យគេធ្វើសន្ថតថ្មីដទៃទៀត , វៀរលែងតែភិក្ខុដែលបានសម្មតអំពីសង្ឃ , សន្ថតនោះជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

១៥.កាលបើភិក្ខុឲ្យគេធ្វើសន្ថតសម្រាប់អង្គុយ គប្បីយកសន្ថតចាស់ មួយចំអាមព្រះសុគត ដោយជុំវិញមកផ្សំផង ដើម្បីនឹងធ្វើសន្ថតថ្មីនោះឲ្យអន់ព័ណ៌។ បើភិក្ខុឲ្យគេធ្វើនិសីទនសន្ថតថ្មី មិនយកសន្ថតចាស់មួយចំអាមព្រះសុគតដោយជុំវិញមកផ្សំលាយនឹងសន្ថតថ្មីផងទេ , សន្ថតនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

១៦.បើមានរោមចៀមទាំងឡាយ កើតឡើងដល់ភិក្ខុអ្នកដើរផ្លូវឆ្ងាយ, កាលបើភិក្ខុចង់បាន ក៏គប្បីទទួលយកចុះ , លុះទទួលហើយ , បើមិនមានអ្នកនាំយកទៅឲ្យទេ , គប្បីនាំយកទៅដោយដៃខ្លួនឯង យ៉ាងឆ្ងាយបំផុតបានត្រឹមបីយោជន៍, បើនាំយកឲ្យលើសពីកំណត់នោះទៅ , ទាំងអ្នកនាំយកទៅឲ្យក៏គ្មាន , រោមចៀមនោះជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

១៧- យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា ឯឡកលោមានិ ធោវាបេយ្យ វា រជាបេយ្យ វា វិជដាបេយ្យ វា, និស្សគ្គិយំ បាចិត្តិយំ ។ ៧ ។

១៨- យោ បន ភិក្ខុ ជាតរូបរជតំ ឧគ្គណ្ហេយ្យ វា ឧគ្គណ្ហាបេយ្យ វា ឧបនិក្ខិត្តំ វា សាទិយេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។ ៨ ។

១៩- យោ បន ភិក្ខុ នានប្បការកំ រូបិយសំវោហារំ សមាបជ្ជេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។៩។

២០- យោ បន ភិក្ខុ នានប្បការកំ កយវិក្កយំ សមាបជ្ជេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។ ១០ ។

កោសិយវគ្គោ ទុតិយោ ។

២១- ទសាហបរមំ អតិរេកបត្តោ ធារេតព្វោ. តំ អតិក្កាមយតោ, និស្សគ្គិយំ បាចិត្តិយំ ។ ១ ។

២២- យោ បន ភិក្ខុ ឩនបញ្ចពន្ធនេន បត្តេន អញ្ញំ នវំ បត្តំ ចេតាបេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។ តេន ភិក្ខុនា សោ បត្តោ ភិក្ខុបរិសាយ និស្សជ្ជិតព្វោ ។ យោ ច តស្សា ភិក្ខុបរិសាយ បត្តបរិយន្តោ, សោ ច តស្ស ភិក្ខុនោ បទាតព្វោ:

# សិក្ខាបទ ក្នុងនិស្សគ្គិយ

១៧_ ភិក្ខុណាមួយ ប្រើភិក្ខុនី មិនមែនជាញាតិ ឲ្យលាងក្តី ឲ្យជ្រលក់ក្តី ឲ្យសិតឬព្រផោះក្តី នូវរោមចៀមទាំងឡាយ, រោមចៀមនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

១៨_ ភិក្ខុណាមួយ ទទួលខ្លួនឯងក្តី ប្រើគេឲ្យទទួលក្តី នូវមាសប្រាក់ ឬមួយត្រេកអរ ចំពោះមាសប្រាក់ ដែលគេទុកដាក់ឲ្យ, មាសប្រាក់នោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

១៩_ ភិក្ខុណាមួយ ប្រព្រឹត្តទិញដូរដោយរូបិយៈ មានប្រការផ្សេងៗ, វត្ថុដែលទិញដូរមកនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

២០_ ភិក្ខុណាមួយ ប្រព្រឹត្តទិញដូររបស់ចាស់ មានប្រការផ្សេងៗ, របស់នោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

កោសិយវគ្គទីពីរ ( ចប់ )

២១_ ភិក្ខុត្រូវទុកអតិរេកបាត្រ យ៉ាងយូរបំផុតបានត្រឹមដប់ថ្ងៃ, ( បើទុក ) ឲ្យកន្លងហួសពីនោះទៅ, បាត្រនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។

២២_ ភិក្ខុណាមួយ មានបាត្រមានចំណងតិស្នាមប្រេះ មិនទាន់គ្រប់ ៥ អន្លើ ឲ្យគេរកបាត្រថ្មីទៀត, បាត្រនោះជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនោះ ត្រូវលះបង់បាត្រនោះ ក្នុងភិក្ខុបរិស័ទ ។ បាត្រណាជាទីបំផុត របស់ភិក្ខុបរិស័ទនោះ, ភិក្ខុដែលសង្ឃបានសន្មត ត្រូវប្រគល់បាត្រនោះ ឲ្យដល់ភិក្ខុនោះដោយពាក្យថា :

អយន្តេ ភិក្ខុ បត្តោ, យាវ ភេទនាយ ធារេតព្វោតិ។ អយំ តត្ថ សាមីចិ ។ ២ ។

២៣- យានិ ខោ បន តានិ គិលានានំ ភិក្ខូនំ បដិសាយនីយានិ ភេសជ្ជានិ, សេយ្យថីទំ : សប្បិ នវនីតំ តេលំ មធុ ផាណិតំ ។ តានិ បដិគ្គហេត្វា សត្តាហបរមំ សន្និធិការកំ បរិភុញ្ជិតព្វានិ, តំ អតិក្កាមយតោ, និស្សគ្គិយំ បាចិត្តិយំ ។ ៣ ។

២៤- មាសោ សេសោ គិម្ហានន្តិ ភិក្ខុនា វស្សិកសាដិកចីវរំ បរិយេសិតព្វំ ។ អឌ្ឍមាសោ សេសោ គិម្ហានន្តិ កត្វា និវាសេតព្វំ ។ ឱរេន ចេ មាសោ សេសោ គិម្ហានន្តិ វស្សិកសាដិកចីវរំ បរិយេសេយ្យ, ឱរេនឌ្ឍមាសោ សេសោ គិម្ហានន្តិ កត្វានិវាសេយ្យ; និស្សគ្គិយំ បាចិត្តិយំ ។ ៤ ។

២៥- យោ បន ភិក្ខុ ភិក្ខុស្ស សាមំ ចីវរំ ទត្វា, កុបិតោ អនត្តមនោ អច្ឆិន្ទេយ្យ វា អច្ឆិន្ទាបេយ្យ វា, និស្សគ្គិយំ បាចិត្តិយំ ។ ៥ ។

"ម្នាលភិក្ខុ ! នេះជាបាត្ររបស់លោកហើយ , លោកត្រូវប្រើប្រាស់ ត្រាតែបែកពុះ" ។ នេះជាសាមីចិកម្ម ក្នុងការលះបង់បាត្រនោះ ។

២៣-ភេសជ្ជៈណាមួយ ដែលពួកភិក្ខុមានជំងឺគប្បីឆាន់បាន , ភេសជ្ជៈទាំងនោះគឺ ទឹកដោះរាវ , ទឹកដោះខាប់ , ប្រេង , ទឹកឃ្មុំ , ស្ករអំពៅ ។ ភិក្ខុទទួលភេសជ្ជៈទាំងនោះហើយ ត្រូវទុកឆាន់យ៉ាងយូរបំផុត បានត្រឹមប្រាំពីរថ្ងៃ, (បើទុក) ឲ្យកន្លងហួសពីនោះទៅ , ភេសជ្ជៈទាំងនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

២៤- ភិក្ខុ (ដឹង) ថា គិម្ហរដូវនៅសល់មួយខែទៀត គប្បីស្វែងរក សាដកចីវរ សម្រាប់ងូតទឹកភ្លៀងបាន ។ (ដឹង) ថា គិម្ហរដូវនៅសល់កន្លះខែទៀត គប្បីធ្វើឲ្យស្រេចហើយប្រើប្រាស់ ។ បើភិក្ខុ (ដឹង) ថា នៅមិនទាន់ដល់ខែមួយ ជាខាងចុងនៃគិម្ហរដូវទេ ហើយស្វែងរកសាដកចីវរសម្រាប់ងូតទឹកភ្លៀង , (ដឹង) ថា មិនទាន់ដល់កន្លះខែ ជាខាងចុងនៃគិម្ហរដូវទេ ក៏ធ្វើឲ្យសម្រេចហើយប្រើប្រាស់, សាដកចីវរនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

២៥-ភិក្ខុណាមួយ ឲ្យចីវរដល់ភិក្ខុដទៃ ដោយខ្លួនឯងហើយ ខឹងអន់ចិត្ត ដណ្តើមយកមកវិញក្តី ប្រើគេឲ្យដណ្តើមយកមកវិញក្តី , ចីវរនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

២៦- យោ បន ភិក្ខុ សាមំ សុត្តំ វិញ្ញាបេត្វា តន្តវាយេហិ ចីវរំ វាយាបេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។ ៦ ។

២៧- ភិក្ខុំ បនេវ ឧទ្ទិស្ស អញ្ញាតកោ គហបតិ វា គហបតានី វា តន្តវាយេហិ ចីវរំ វាយាបេយ្យ ។ តត្រ ចេ សោ ភិក្ខុ បុព្វេ អប្បវារិតោ តន្តវាយេ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជេយ្យ; ឥទំ ខោ អាវុសោ ចីវរំ មំ ឧទ្ទិស្ស វីយតិ អាយតញ្ច ករោថ, វិត្ថតញ្ច, អប្បិតញ្ច, សុវីតញ្ច, សុប្បវាយិតញ្ច, សុវិលេខិតញ្ច, សុវិតច្ឆិតញ្ច ករោថ, អប្បេវ នាម មយម្បិ អាយស្មន្តានំ កិញ្ចិ មត្តំ អនុបទជ្ជេយ្យាមាតិ ។ ឯវញ្ច សោ ភិក្ខុ វត្វា កិញ្ចិ មត្តំ អនុបទជ្ជេយ្យ អន្តមសោ បិណ្ឌបាតមត្តម្បិ, និស្សគ្គិយំ បាចិត្តិយំ ។៧។

# ចិត្តារុទ្ទេស ក្នុងនិស្សគ្គិយ

២៦- ភិក្ខុណាមួយ សូមអំបោះមក ដោយខ្លួនឯងហើយ ឲ្យពួកជាងតម្បាញត្បាញចីវរឲ្យ , ចីវរនោះជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

២៧. គហបតិក្តី គហបតានីក្តី មិនមែនជាញាតិ គេឲ្យពួកជាងតម្បាញត្បាញចីវរចំពោះភិក្ខុ ។ បើភិក្ខុនោះ ដែលអ្នកម្ចាស់ចីវរ គេពុំបានបវារណាមកពីមុនក្នុងរឿងចីវរនោះទេ អាចហ៊ានចូលទៅរកពួកជាងតម្បាញហើយ ជំរាបនូវកិរិយាកំណត់ក្នុងចីវរ(១) ថា : " ម្នាលអ្នកមានអាយុទាំងឡាយ ! ចីវរនេះគេឲ្យត្បាញចំពោះអាត្មា , អ្នកទាំងឡាយចូរធ្វើឲ្យវែងផង , ឲ្យទូលាយផង , ឲ្យមានសាច់ញឹកផង , ឲ្យស្មើល្អផង , រវៃឲ្យតឹងល្អផង , ចូរក្រវោះកូតឲ្យល្អផង , ចូរសិតឲ្យល្អផង , សឹមអាត្មានឹងថែមរង្វាន់បន្តិចបន្តួចឲ្យដល់អ្នកទាំងឡាយ ។ ភិក្ខុនោះ លុះនិយាយយ៉ាងនេះហើយ ក៏ថែមរង្វាន់បន្តិចបន្តួចឲ្យគេ ដោយហោចទៅ សូម្បីត្រឹមតែអាហារបិណ្ឌបាត, ចីវរនោះជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

---

១ គឺរិះគន់ផង់ឲ្យបានល្អហួសហេតុ។

២៨- ទសាហានាគតំ កត្តិកតេមាសិបុណ្ណមំ, ភិក្ខុនោ បនេវ អច្ចេកចីវរំ ឧប្បជ្ជេយ្យ, អច្ចេកំ មញ្ញមានេន ភិក្ខុនា បដិគ្គហេតព្វំ, បដិគ្គហេត្វា យាវចីវរកាលសមយំ និក្ខិបិតព្វំ, តតោ ចេ ឧត្តរឹ និក្ខិបេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។ ៨ ។

២៩- ឧបវស្សំ ខោ បន កត្តិកបុណ្ណមំ ។ យានិ ខោ បន តានិ អារញ្ញកានិ សេនាសនានិ សាសង្កសម្មតានិ សប្បដិភយានិ, តថារូបេសុ ភិក្ខុ សេនាសនេសុ វិហរន្តោ, អាកង្ខមានោ តិណ្ណំ ចីវរានំ អញ្ញតរំ ចីវរំ អន្តរឃរេ និក្ខិបេយ្យ ។

២៨-នៅ១០ៈដប់ថ្ងៃទៀត នឹងដល់ថ្ងៃពេញបូណ៌មីខែកត្តិក ដែលជាខែទីបីនៃវស្សានរដូវ (១) បើអច្ចេកចីវរ (២) កើតឡើងដល់ភិក្ខុ , ភិក្ខុសម្គាល់ថា ជាអច្ចេកចីវរ គប្បីទទួលទុកបាន លុះទទួលហើយ គប្បីទុកដាក់ដរាបដល់អស់សម័យនៃចីវរកាល (៣) បើទុកឲ្យហួសកំណត់នោះទៅ , ចីវរនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

២៩-កាលបើភិក្ខុនៅចាំវស្សារួចហើយ លុះដល់មកថ្ងៃពេញបូណ៌មីខែកត្តិក ( ដែលជាខែទីបំផុតនៃវស្សានរដូវ ) ។ សេនាសនៈទាំងឡាយណាមួយ ដែលតាំងនៅក្នុងព្រៃដែលគេសន្មតថាជាទីមានសេចក្ដីរង្កៀស , ដែលមានភ័យចំពោះមុខ , កាលបើភិក្ខុនៅក្នុងសេនាសនៈទាំងឡាយ មានសភាពដូច្នេះ , (បើ) មានបំណង គប្បីទុកបណ្ដាចីវរទាំងបី ចីវរណាមួយ ក្នុងចន្លោះផ្ទះបាន ។

---

១ ថ្ងៃពេញបូណ៌មីបឋមកត្តិក គឺថ្ងៃ ១៥ កើតខែអស្សុជ ។ ២ សំពត់ដែលបុគ្គលណាមួយក្រោកចេញទៅក្នុងគងទ័ពក្ដី , ទៅកាន់និវាសស្ថានក្ដី , មានជម្ងឺក្ដី , ស្រីមានគភ៌ក្ដី , បុគ្គលឥតមានសទ្ធាជ្រះថ្លាហើយត្រឡប់ជាមានសទ្ធាជ្រះថ្លាក្ដាកើតឡើងក្ដី យកមកប្រគេន , គឺចីវរដែលបុគ្គលផ្ញើដោយប្រញាប់ ។ ៣ បើភិក្ខុមិនបានទទួលអានិសង្សកឋិនទេ ចីវរកាលមានតែ ១ ខែ បើបានទទួលអានិសង្សកឋិន ចីវរកាលមាន ៥ ខែ គិតតាំងពីថ្ងៃចេញវស្សាទៅ ។

សិយា ច តស្ស ភិក្ខុនោ កោចិទេវ បច្ចយោ តេន ចីវរេន វិប្បវាសាយ, ឆារត្តបរមន្តេន ភិក្ខុនា តេន ចីវរេន វិប្បវសិតព្វំ ។ តតោ ចេ ឧត្តរិ វិប្បវសេយ្យ, អញ្ញត្រ ភិក្ខុសម្មតិយា, និស្សគ្គិយំ បាចិត្តិយំ ។ ៩ ។

៣០- យោ បន ភិក្ខុ ជានំ សង្ឃិកំ លាភំ បរិណតំ អត្តនោ បរិណាមេយ្យ, និស្សគ្គិយំ បាចិត្តិយំ ។១០។

បត្តវគ្គោ តតិយោ ។

ឧទ្ទិដ្ឋា ខោ អាយស្មន្តោ តឹស និស្សគ្គិយា បាចិត្តិយា ធម្មា ។ តត្ថាយស្មន្តេ បុច្ឆាមិ,
កច្ចិត្ថ បរិសុទ្ធា ? ទុតិយម្បិ បុច្ឆាមិ,
កច្ចិត្ថ បរិសុទ្ធា ? តតិយម្បិ បុច្ឆាមិ,
កច្ចិត្ថ បរិសុទ្ធា ? បរិសុទ្ធេត្ថាយស្មន្តោ,
តស្មា តុណ្ហី ។ ឯវមេតំ ធារយាមិ ។

និស្សគ្គិយា បាចិត្តិយា និដ្ឋិតា ។

# ចិត្តារម្មស ក្នុងនិស្សគ្គិយ

ប្រសិនបើ ភិក្ខុមានហេតុអ្វីមួយល្មមឲ្យនៅប្រាសចាកចីវរនោះ, ភិក្ខុនោះត្រូវនៅប្រាសចាកចីវរនោះ យ៉ាងយូរបំផុតបានត្រឹមប្រាំមួយរាត្រី ។ បើនៅប្រាសចាកឲ្យហួសពីកំណត់នោះទៅ, វៀរលែងតែភិក្ខុដែលបានសន្មតអំពីសង្ឃ ចីវរនោះជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៣០. ភិក្ខុណាមួយ កាលដឹងហើយ បង្អោននូវលាភដែលគេប្រុងនឹង បង្អោនទៅដើម្បីសង្ឃមកដើម្បីខ្លួនវិញ, លាភនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ

បត្តវគ្គទី ៣ ( ចប់ ) ។

បពិត្រលោកអ្នកមានអាយុទាំងឡាយ អាបត្តិឈ្មោះនិស្សគ្គិយបាចិត្តិយទាំង ៣០ ខ្ញុំព្រះករុណាបានសំដែងរួចហើយ ខ្ញុំព្រះករុណាសូមសួរលោកអ្នកមានអាយុទាំងឡាយ ក្នុងអាបត្តិទាំងនោះ, លោកទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ? ខ្ញុំព្រះករុណា សូមសួរជាគម្រប់ពីរដងទៀត, លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ? ខ្ញុំព្រះករុណា សូមសួរជាគម្រប់បីដងទៀត, លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ? លោកអ្នកមានអាយុទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធក្នុងអាបត្តិទាំងនុ៎ះហើយ, ព្រោះហេតុនោះបានជានៅស្ងៀម ។ ខ្ញុំព្រះករុណា សូមចាំទុកនូវហេតុនេះ ដោយកិរិយានៅស្ងៀមយ៉ាងនេះ ។

ចប់អាបត្តិឈ្មោះនិស្សគ្គិយបាចិត្តិយ ។

ឥមេ ខោ បនាយស្មន្តោ ទ្វេនវុតិ បាចិត្តិយា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

១- សម្បជានមុសាវាទេ បាចិត្តិយំ ។ ១ ។

២- ឱមសវាទេ បាចិត្តិយំ ។ ២ ។

៣- ភិក្ខុបេសុញ្ញេ បាចិត្តិយំ ។ ៣ ។

៤- យោ បន ភិក្ខុ អនុបសម្បន្នំ បទសោ ធម្មំ វាចេយ្យ, បាចិត្តិយំ ។ ៤ ។

៥- យោ បន ភិក្ខុ អនុបសម្បន្នេន ឧត្តរិទិរត្តតិរត្តំ សហ សេយ្យំ កប្បេយ្យ, បាចិត្តិយំ ។ ៥ ។

៦- យោ បន ភិក្ខុ មាតុគ្គាមេន សហ សេយ្យំ កប្បេយ្យ, បាចិត្តិយំ ។ ៦ ។

៧- យោ បន ភិក្ខុ មាតុគ្គាមស្ស ឧត្តរិឆប្បញ្ច-វាចាហិ ធម្មំ ទេសេយ្យ, អញ្ញត្រ វិញ្ញុនា បុរិស-វិគ្គហេន, បាចិត្តិយំ ។៧។

៨- យោ បន ភិក្ខុ អនុបសម្បន្នស្ស ឧត្តរិមនុស្ស-ធម្មំ អារោចេយ្យ, ភូតស្មឹ, បាចិត្តិយំ ។៨។

បតិត្រលោកអ្នកមានអាយុទាំងឡាយ អាបត្តិបាចិត្តិយទាំងឡាយ ៩២ នេះឯង មកកាន់ឧទ្ទេស ។

១-ភិក្ខុពោលពាក្យកុហកដោយដឹងខ្លួន ត្រូវអាបត្តិបាចិត្តិយ ។

២-ភិក្ខុពោលពាក្យចាក់ដោត ត្រូវអាបត្តិបាចិត្តិយ ។

៣-ភិក្ខុពោលពាក្យញុះញង់ភិក្ខុផងគ្នា ត្រូវអាបត្តិបាចិត្តិយ ។

៤-ភិក្ខុណាមួយ បង្រៀនធម៌ជាបទចំពោះអនុបសម្បន្ន, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ (១) ។

៥-ភិក្ខុណាមួយ សម្រេចការដេក ជាមួយនឹងអនុបសម្បន្ន លើសពីពីរយប់ ឬបីយប់ឡើងទៅ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៦-ភិក្ខុណាមួយ សម្រេចការដេក ជាមួយនឹងមាតុគ្រាម, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៧-ភិក្ខុណាមួយ សម្ដែងធម៌ ដល់មាតុគ្រាម លើសពីប្រាំឬប្រាំមួយម៉ាត់ឡើងទៅ, វៀរលែងតែមានបុរសដែលដឹងក្ដី (នៅជាមួយផង) ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៨-ភិក្ខុណាមួយ ប្រាប់ឧត្តរិមនុស្សធម្ម ដល់អនុបសម្បន្ន ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ព្រោះមានពិតមែន ។

---

១ ចូរមើលក្រង់អនាបត្តិ ក្នុងវិន័យបិដក មហាវិភង្គភាគទី ៣ ទំព័រ ២៥៥ ផង ។

៩- យោ បន ភិក្ខុ ភិក្ខុស្ស ទុដ្ឋុល្លំ អាបត្តឹ អនុបសម្បន្នស្ស អារោចេយ្យ, អញ្ញត្រ ភិក្ខុសម្មតិយា, បាចិត្តិយំ ។ ៩ ។

១០- យោ បន ភិក្ខុ បឋវឹ ខណេយ្យ វា ខណាបេយ្យ វា, បាចិត្តិយំ ។ ១០ ។

មុសាវាទវគ្គោ បឋមោ ។

១១- ភូតគាមបាតព្យតាយ បាចិត្តិយំ ។ ១ ។

១២- អញ្ញវាទកេ វិហេសកេ បាចិត្តិយំ ។ ២ ។

១៣- ឧជ្ឈាបនកេ ខិយនកេ បាចិត្តិយំ ។ ៣ ។

១៤- យោ បន ភិក្ខុ សង្ឃិកំ មញ្ចំ វា បីឋំ វា ភិសឹ វា កោច្ឆំ វា អជ្ឈោកាសេ សន្ថរិត្វា វា សន្ថរាបេត្វា វា, តំ បក្កមន្តោ នេវ ឧទ្ធរេយ្យ ន ឧទ្ធរាបេយ្យ អនាបុច្ឆំ វា គច្ឆេយ្យ, បាចិត្តិយំ ។៤។

១៥- យោ បន ភិក្ខុ សង្ឃិកេ វិហារេ សេយ្យំ សន្ថរិត្វា វា សន្ថរាបេត្វា វា, តំ បក្កមន្តោ នេវ ឧទ្ធរេយ្យ ន ឧទ្ធរាបេយ្យ អនាបុច្ឆំ វា គច្ឆេយ្យ, បាចិត្តិយំ ។ ៥ ។

# សិក្ខាបទខ្លះ ក្នុងបាចិត្តិយ

៩ - ភិក្ខុណាមួយ ប្រាប់ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នា ដល់អនុបសម្បន្ន, វៀរលែងតែភិក្ខុដែលសង្ឃសន្មតឲ្យប្រាប់, ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

១០. ភិក្ខុណា មួយ ជីកខ្លួនឯង ឬ ប្រើអ្នកដទៃឲ្យជីកនូវផែនដី, ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

មុសាវាទ វគ្គទី១ ( ចប់ ) ។

១១. ភិក្ខុធ្វើភូតគាម (១) ឲ្យវិនាស ត្រូវអាបត្តិបាចិត្តិយ ។

១២ ភិក្ខុពោលនូវពាក្យដទៃ ឬធ្វើឲ្យសង្ឃបានសេចក្តីលំបាក ត្រូវអាបត្តិបាចិត្តិយ ។

១៣. ភិក្ខុបង្គាប់ភិក្ខុដទៃ ឲ្យពោលទោសភិក្ខុផងគ្នា ឬតិះដៀលភិក្ខុផងគ្នាខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។

១៤. ភិក្ខុណាមួយ លាតសន្ធឹងខ្លួនឯង ឬ ឲ្យគេលាតសន្ធឹងនូវគ្រែក្តី តាំងក្តី ពូកក្តី កៅអីក្តី ដែលជារបស់សង្ឃ ក្នុងទីវាលហើយ, កាលនឹងដើរចេញទៅមិនបានរើបទុកដាក់ មិនបានប្រើគេឲ្យរើបទុកដាក់ នូវគ្រឿងសេនាសនៈនោះ ឬឥតបានប្រាប់អ្នកដទៃ ស្រាប់តែដើរចេញទៅ, ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

១៥. ភិក្ខុណាមួយក្រាល ឬប្រើគេឲ្យក្រាល នូវកម្រាលសម្រាប់ដេក ក្នុងវិហារជារបស់សង្ឃហើយ, កាលនឹងដើរចេញទៅ មិនបានរើបទុកដាក់ មិនបានប្រើគេឲ្យរើបទុកដាក់ នូវគ្រឿងសេនាសនៈនោះ ឬឥតបានប្រាប់អ្នកដទៃ ស្រាប់តែដើរចេញទៅ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

---

១ សំដៅយកស្មៅ, វល្លិ និងដើមឈើស្រស់ដែលមានពូជប្រាំយ៉ាង ណាមួយតាំងនៈ លូតលាស់តទៅទៀតបានជាដើម ។

១៦- យោ បន ភិក្ខុ សង្ឃិកេ វិហារេ ជានំ បុព្វុបគតំ ភិក្ខុំ អនុបខជ្ជ(១) សេយ្យំ កប្បេយ្យៈ យស្ស សម្ពាធោ ភវិស្សតិ, សោ បក្កមិស្សតីតិ; ឯតទេវ បច្ចយំ ករិត្វា អនញ្ញំ, បាចិត្តិយំ ។ ៦ ។

១៧- យោ បន ភិក្ខុ ភិក្ខុំ កុបិតោ អនត្តមនោ សង្ឃិកា វិហារា និក្កឌ្ឍេយ្យ វា និក្កឌ្ឍាបេយ្យ វា, បាចិត្តិយំ ។ ៧ ។

១៨- យោ បន ភិក្ខុ សង្ឃិកេ វិហារេ ឧបរិវេហាសកុដិយា អាហច្ចបាទកំ មញ្ចំ វា បីឋំ វា អភិនិសីទេយ្យ វា អភិនិបជ្ជេយ្យ វា, បាចិត្តិយំ ។៨។

១៩- មហល្លកំ បន ភិក្ខុនា វិហារំ ការយមានេន, យាវ ទ្វារកោសា អគ្គឡដ្ឋបនាយ អាលោកសន្ធិបរិកម្មាយ ទ្វិត្តិច្ឆទនស្ស បរិយាយំ អបហរិតេ ឋិតេន អធិដ្ឋាតព្វំ, តតោ ចេ ឧត្តរឹ អបហរិតេបិ ឋិតោ អធិដ្ឋហេយ្យ, បាចិត្តិយំ ។ ៩ ។

---

១ ក្នុងច្បាប់ដទៃថា អនុបខជ្ជ ឬ អនុបខជ្ជ (កកាយដែលបានពិនិត្យមើលគេឃើញថា អនុប្បខជ្ជ ទើបត្រូវ ព្រោះមកពី: អនុ + ប + ខទ + ត្វា» អនុប្បខជ្ជ ប្រែថា ច្រៀតចូល, គេហៅ (សំស្រ្កឹតថា: អនុប្រស្កន្ទ្យ) ។

១៦.ភិក្ខុណាមួយ កាលដឹង ហើយចូលទៅច្រៀតបៀតភិក្ខុដែលចូលទៅនៅមុនហើយ សម្រេចនូវទីដេកក្នុងវិហារ របស់សង្ឃ ដោយគិតថា : "ភិក្ខុណាមានសេចក្ដីចង្អៀតចង្អល់ , ភិក្ខុនោះនឹងចេញទៅចុះ"; ធ្វើនូវសេចក្ដីច្រៀតបៀតនោះឯង ឲ្យជាបច្ច័យ ពុំមែនហេតុដទៃឡើយ , ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។

១៧.ភិក្ខុណាមួយ មានចិត្តក្រោធ ខឹង នឹងភិក្ខុផងគ្នាហើយ ទង់ទាញខ្លួនឯង ឬ ប្រើគេឲ្យទង់ទាញ ចេញចាកវិហាររបស់សង្ឃ , ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

១៨ . ភិក្ខុណាមួយ អង្គុយសង្កត់ ឬ ដេកសង្កត់ដោយរហ័ស នូវគ្រែក្ដី តាំងក្ដី ដែលមានជើងគ្រាន់តែសិកទុកជាបណ្ដោះអាសន្ន លើថ្នាក់ក្នុងវិហាររបស់សង្ឃ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

១៩ – កាលបើភិក្ខុឲ្យគេធ្វើវិហារធំ ( គឺកុដិធំដែលមានម្ចាស់ ) , គប្បី ( លាបបូកញយាបាន ) កំណត់ទីមានឱកាសត្រឹមតែសន្ទឹកទ្វារ(១) និងសន្ទឹកបង្អួច ដើម្បីទុកប្រើប្រាស់នូវទ្វារ(២) និងដើម្បីបរិកម្មនូវសន្ទឹកបង្អួច(៣) ឯដំបូលភិក្ខុត្រូវស្ថិតនៅក្នុងទីដែលគ្មានដំណាំ ទើបប្រក់បានត្រឹមពីរបីជាន់, បើភិក្ខុប្រក់ឲ្យច្រើនលើសពីកំណត់នោះទៅ ទុកជាស្ថិតនៅក្នុងទីដែលគ្មានដំណាំ , ក៏គង់ត្រូវអាបត្តិបាចិត្តិយ ។

---

១ កំណត់ត្រឹមហត្ថបាសដោយជុំវិញនៃក្របទ្វារ ។ ២ គឺដើម្បីបើកបិទទ្វារ ។ ៣ សេចក្ដីថា ព្រះតថាគតអនុញ្ញាតវត្ថុពណ៌ស, ពណ៌ខ្មៅ, ពណ៌ង្គ និងក្បាច់ក្រវៀងកា ដើម្បីបរិកម្មនូវសន្ទឹកបង្អួច . . . ។

២០- យោ បន ភិក្ខុ ជាន់ សប្បាណក់ ឧទក់ តិណំ វា មត្តិកំ វា សិញ្ចេយ្យ វា សិញ្ចាបេយ្យ វា, បាចិត្តិយំ ។ ១០ ។

ភូតគាមវគ្គោ ទុតិយោ ។

២១- យោ បន ភិក្ខុ អសម្មតោ ភិក្ខុនិយោ ឱវទេយ្យ, បាចិត្តិយំ ។ ១ ។

២២- សម្មតោបិ ចេ ភិក្ខុ, អត្ថង្គតេ សុរិយេ, ភិក្ខុនិយោ ឱវទេយ្យ បាចិត្តិយំ ។ ២ ។

២៣- យោ បន ភិក្ខុ ភិក្ខុនូបស្សយំ ឧបសង្កមិត្វា ភិក្ខុនិយោ ឱវទេយ្យ, អញ្ញត្រ សមយា, បាចិត្តិយំ ។ តត្ថាយំ សមយោ: គិលានា ហោតិ ភិក្ខុនី, អយំ តត្ថ សមយោ ។ ៣ ។

២៤- យោ បន ភិក្ខុ ឯវំ វទេយ្យ: អាមិសហេតុ ភិក្ខូ ភិក្ខុនិយោ ឱវទន្តីតិ, បាចិត្តិយំ ។ ៤ ។

២៥- យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា ចីវរំ ទទេយ្យ, អញ្ញត្រ បារិវដ្តកា, បាចិត្តិយំ ។ ៥ ។

២៦- យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា ចីវរំ សិព្វេយ្យ វា សិព្វាបេយ្យ វា, បាចិត្តិយំ ។ ៦ ។

# ចិត្តាវរគ្គ ភ្លួចបាចិត្តិយ

២០. ភិក្ខុណាមួយ កាលដឹងថាទឹកមានសត្វហើយ ស្រោចខ្លួនឯង ឬ ប្រើគេឲ្យស្រោចនូវស្មៅឬដី, ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

ភូតគាម វគ្គទី ២ (ចប់) ។

២១. ភិក្ខុណាមួយ ដែលសង្ឃមិនបានសន្មតហើយ ទៅប្រដៅពួកភិក្ខុនី, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

២២. ភិក្ខុ បើទុកជាសង្ឃបានសន្មតហើយក៏ដោយ, កាលបើព្រះអាទិត្យអស្តង្គតហើយ, ទៅប្រដៅពួកភិក្ខុនី, ត្រូវអាបត្តិបាចិត្តិយ ។

២៣. ភិក្ខុណាមួយ ចូលទៅកាន់លំនៅរបស់ភិក្ខុនីហើយ ប្រដៅពួកភិក្ខុនី, វៀរលែងតែមានសម័យ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ នេះជាសម័យ ក្នុងសិក្ខាបទនោះ គឺ ភិក្ខុនីមានជំងឺ, នេះជាសម័យ ក្នុងសិក្ខាបទនោះ ។

២៤. ភិក្ខុណាមួយ ពោលយ៉ាងនេះថា : " ភិក្ខុទាំងឡាយ ប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស ", ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

២៥. ភិក្ខុណាមួយ ឲ្យចីវរដល់ភិក្ខុនី មិនមែនជាញាតិ, វៀរលែងតែប្តូរគ្នា, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

២៦. ភិក្ខុណាមួយ ដេរខ្លួនឯង ឬប្រើគេឲ្យដេរចីវរ ឲ្យភិក្ខុនី មិនមែនជាញាតិ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

២៧- យោ បន ភិក្ខុ ភិក្ខុនិយា សទ្ធឹ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជេយ្យ, អន្តមសោ គាមន្តរម្បិ, អញ្ញត្រ សមយា, បាចិត្តិយំ ។ តត្ថាយំ សមយោ : សត្ថគមនីយោ ហោតិ មគ្គោ សាសង្កសម្មតោ សប្បដិភយោ, អយំ តត្ថ សមយោ ។ ៧ ។

២៨- យោ បន ភិក្ខុ ភិក្ខុនិយា សទ្ធឹ សំវិធាយ ឯកនាវំ អភិរុហេយ្យ, ឧទ្ធង្គាមិនឹ វា អធោគាមិនឹ វា, អញ្ញត្រ តិរិយន្តរណាយ, បាចិត្តិយំ ។ ៨ ។

២៩- យោ បន ភិក្ខុ ជានំ ភិក្ខុនិបរិបាចិតំ បិណ្ឌបាតំ ភុញ្ជេយ្យ, អញ្ញត្រ បុព្វេ គិហិសមារម្ភា, បាចិត្តិយំ ។ ៩ ។

៣០- យោ បន ភិក្ខុ ភិក្ខុនិយា សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេយ្យ, បាចិត្តិយំ ។ ៣០ ។

ឱវាទវគ្គោ តតិយោ ។

២៧. ភិក្ខុណាមួយ បបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយ ជាមួយគ្នា, ដោយហោចទៅសូម្បីចន្លោះស្រុកមួយ, វៀរលែងតែមានសម័យ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ នេះជាសម័យក្នុងសិក្ខាបទនោះ គឺផ្លូវដែលគួរទីងទៅដោយមានគ្នីគ្នាជាពួក ១ ដែលគេសន្មតថា ប្រកបដោយសេចក្តីរង្កៀស ១ ដែលប្រកបដោយភ័យចំពោះមុខ ១, នេះជាសម័យក្នុងសិក្ខាបទនោះ ។

២៨. ភិក្ខុណាមួយ បបួលភិក្ខុនី ឡើងជិះទូកមួយជាមួយគ្នា, ទៅច្រាសទឹកក្តី ទៅបណ្តោយទឹកក្តី, វៀរលែងតែឆ្លងទទឹង, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

២៩. ភិក្ខុណាមួយ កាលដឹង ហើយឆាន់ចង្ហាន់បិណ្ឌបាត ដែលភិក្ខុនីចាត់ចែងឲ្យ, វៀរលែងតែចង្ហាន់ ដែលគ្រហស្ថបានប្រារព្ធជាមុន, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៣០. ភិក្ខុណាមួយ សម្រេច ការអង្គុយ ក្នុងទីស្ងាត់ជាមួយនឹងភិក្ខុនី តែម្នាក់និងម្នាក់ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

ឱវាទវគ្គទី ៣ ( ចប់ )

៣១- អគិលានេន[១] ភិក្ខុនា ឯកោ អាវសថបិណ្ឌោ ភុញ្ជិតព្វោ, តតោ ចេ ឧត្តរិ ភុញ្ជេយ្យ, បាចិត្តិយំ ។១។

៣២- គណភោជនេ អញ្ញត្រ សមយា, បាចិត្តិយំ ។ តត្ថាយំ សមយោ : គិលានសមយោ, ចីវរទានសមយោ, ចីវរការសមយោ, អទ្ធានគមនសមយោ, នាវាភិរុហនសមយោ, មហាសមយោ, សមណភត្តសមយោ; អយំ តត្ថ សមយោ ។ ២ ។

៣៣- បរម្បរភោជនេ អញ្ញត្រ សមយា, បាចិត្តិយំ ។ តត្ថាយំ សមយោ : គិលានសមយោ, ចីវរទានសមយោ, ចីវរការសមយោ; អយំ តត្ថ សមយោ ។៣។

---

១ មើលការសំយោគវិធាន ក្រុមគម្រូត «គ» ជាអគិលានេន ។

# ចិត្តាវគ្គ ភួនបាចិត្តិយ

៣១- ភិក្ខុ មិនមានជំងឺ ត្រូវឆាន់ចង្ហាន់បិណ្ឌបាតក្នុងរោងទានបានតែម្តង. បើឆាន់ឲ្យលើសពីកំណត់នោះទៅ, ត្រូវអាបត្តិបាចិត្តិយ ។

៣២. ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះ ( ទទួល ) គណភោជន (១) ( ព្រមគ្នា ) វៀរលែងតែមានសម័យ ។ នេះជាសម័យ ក្នុងសិក្ខាបទនោះគឺ សម័យដែលមានជំងឺ (២) ១ សម័យដែលគេឲ្យចីវរ (៣) ១ សម័យដែលធ្វើចីវរ (៤) ១ សម័យដែលដើរផ្លូវឆ្ងាយ(៥) ១ សម័យដែលជិះទូក(៦) ១ សម័យដែលមានភិក្ខុច្រើនអន្លើ(៧) ១ សម័យនៃសមណភត្ត(៨) ១, នេះជាសម័យ ក្នុងសិក្ខាបទនោះ ។

៣៣. ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់បរម្បរភោជន ( គឺភោជនដែលគេនិមន្តខាងក្រោយ ), វៀរលែងតែមានសម័យ ។ នេះជាសម័យ ក្នុងសិក្ខាបទនោះគឺ សម័យដែលមានជំងឺ(៩)១ សម័យដែលគេឲ្យចីវរ ១ សម័យដែលធ្វើចីវរ ១, នេះជាសម័យក្នុងសិក្ខាបទនោះ ។

---

១ គឺភិក្ខុបួនរូបឡើងទៅ ទទួលនិមន្តឆាន់ភោជនជាយ៉ាងណាមួយដែលគេចេញឈ្មោះ, ភោជននោះឈ្មោះជាគណភោជន ។ ២ សូម្បីតែជើងបែកបាក់ផ្តៅក៏ហៅថាមានជំងឺ ។ ៣ គឺក្នុងវេលាចីវរកាល១ខែឬ៥ខែបើបានក្រាលកឋិន ។ ៤ កាលដែលភិក្ខុកំពុងធ្វើចីវរ ។ ៥ ពេលដែលភិក្ខុកំពុងដើរផ្លូវឆ្ងាយកន្លះយោជន៍ឡើងទៅ ឬត្រឡប់មកវិញ ។ ៦ ពេលដែលភិក្ខុរៀបនឹងជិះទូក, កំពុងជិះឬចុះទូក ។ ៧ ភិក្ខុជួបជុំគ្នាច្រើនជាងកំណត់ បិណ្ឌបាតឆាន់មិនឆ្អែត ។ ៨ គឺអ្នកដែលចូលទៅក្រៅព្រះពុទ្ធសាសនាបព្វជិត ។ ៩ គឺភិក្ខុ មិនអាចនឹងអង្គុយឆាន់ ជាប់ទាល់ឆ្អែតលើអាសនៈមួយបាន ។

៣៤- ភិក្ខុំ បនេវ កុលំ ឧបគតំ បូវេហិ វា មន្ថេហិ វា អភិហដ្ឋុំ បវារេយ្យ ។ អាកង្ខមានេន ភិក្ខុនា ទ្វិត្តិបត្តបូរា បដិគ្គហេតព្វា ។ តតោ ចេ ឧត្តរឹ បដិគ្គណ្ហេយ្យ, បាចិត្តិយំ ។ ទ្វិត្តិបត្តបូរេ បដិគ្គហេត្វា តតោ នីហរិត្វា ភិក្ខូហិ សទ្ធឹ សំវិភជិតព្វំ អយំ តត្ថ សាមីចិ ។ ៤ ។

៣៥- យោ បន ភិក្ខុ ភុត្តាវី បវារិតោ អនតិរិត្តំ ខាទនីយំ វា ភោជនីយំ វា ខាទេយ្យ វា ភុញ្ជេយ្យ វា, បាចិត្តិយំ ។ ៥ ។

៣៦- យោ បន ភិក្ខុ ភិក្ខុំ ភុត្តាវឹ បវារិតំ អនតិរិត្តេន ខាទនីយេន វា ភោជនីយេន វា អភិហដ្ឋុំ បវារេយ្យ, ហន្ទ ភិក្ខុ ខាទ វា ភុញ្ជ វាតិ, ជានំ អាសាទនាបេក្ខោ, ភុត្តស្មឹ, បាចិត្តិយំ ។ ៦ ។

៣៧- យោ បន ភិក្ខុ វិកាលេ ខាទនីយំ វា ភោជនីយំ វា ខាទេយ្យ វា ភុញ្ជេយ្យ វា បាចិត្តិយំ ។៧។

៣៤_ ជនបវារណា នូវភិក្ខុដែលចូលទៅកាន់ត្រកូល ដោយនំទាំងឡាយក្តី ដោយសត្តុទាំងឡាយក្តី ដើម្បីនាំទៅបានតាមប្រាថ្នា ។ ភិក្ខុមានសេចក្តីត្រូវការ ត្រូវទទួលត្រឹមពេញពីរបីបាត្របាន ។ បើទទួលឲ្យលើសពីកំណត់នោះទៅ, ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុដែលបានទទួលនំ ឬសត្តុកំណត់ត្រឹមពីរបីបាត្រហើយ ត្រូវនាំយកអំពីទីនោះ មកចែកជាមួយនឹងភិក្ខុទាំងឡាយ, ការចែកនំឬសត្តុនេះ ជាសាមីចិកម្ម ក្នុងសិក្ខាបទនោះ ។

៣៥_ ភិក្ខុណាមួយ ឆាន់ហើយ បានហាមភោជនហើយ ទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយាហារ ឬ ភោជនីយាហារ ដែលជាអនតិរិត្ត(១), ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៣៦_ ភិក្ខុណាមួយ នាំភត្តទៅបវារណាបង្ខំភិក្ខុដែលឆាន់ហើយ ហាមភត្តហើយ ដោយខាទនីយាហារ ឬភោជនីយាហារ ដែលជាអនតិរិត្ត ដោយពាក្យថា "ហ៏! ភិក្ខុ, លោកចូរទំពាស៊ីក្តី ចូរបរិភោគក្តី" កាលបើដឹងហើយ រំពៃរកទោស, និមិត្តតែភិក្ខុនោះឆាន់រួចហើយ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៣៧- ភិក្ខុណាមួយ ទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយាហារ ឬភោជនីយាហារ ក្នុងពេលវិកាល, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

---

១ អនតិរិត្តភោជន បានដល់ភោជនដែលមិនគួរដល់អាការនៃវិនយកម្ម ៧ យ៉ាង និងវត្ថុដែលមិនមែនជារបស់សល់ អំពីភិក្ខុឈឺ ។

៣៨- យោ បន ភិក្ខុ សន្និធិការកំ ខាទនីយំ វា ភោជនីយំ វា ខាទេយ្យ វា ភុញ្ជេយ្យ វា, បាចិត្តិយំ ។ ៨ ។

៣៩- យានិ ខោ បន តានិ បណីតភោជនានិ, សេយ្យថីទំ : សប្បិ នវនីតំ តេលំ មធុ ផាណិតំ មច្ឆោ មំសំ ខីរំ ទធិ ។ យោ បន ភិក្ខុ ឯវរូបានិ បណីតភោជនានិ អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជេយ្យ, បាចិត្តិយំ ។ ៩ ។

៤០- យោ បន ភិក្ខុ អទិន្នំ មុខទ្វារំ អាហារំ អាហរេយ្យ, អញ្ញត្រ ឧទកទន្តបោណា, បាចិត្តិយំ ។ ១០ ។

ភោជនវគ្គោ ចតុត្ថោ ។

៤១- យោ បន ភិក្ខុ អចេលកស្ស វា បរិព្វាជកស្ស វា បរិព្វាជិកាយ វា សហត្ថា ខាទនីយំ វា ភោជនីយំ វា ទទេយ្យ, បាចិត្តិយំ ។ ១ ។

៤២- យោ បន ភិក្ខុ ភិក្ខុំ ឯវំ វទេយ្យ : ឯហាវុសោ, គាមំ វា និគមំ វា បិណ្ឌាយ បវិសិស្សាមាតិ; តស្ស ទាបេត្វា វា អទាបេត្វា វា ឧយ្យោជេយ្យ :

# ចិន្តារុរទ្ទស ក្នុងបាចិត្តិយ

៣៨. ភិក្ខុណាមួយ ទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយាហារ ឬភោជនីយាហារ ដែលខ្លួនទុកដាក់ឲ្យកន្លងរាត្រី, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៣៩. បណីតភោជនទាំងឡាយ ណាមួយ, បណីតភោជនទាំងនោះ គឺ ទឹកដោះថ្លា, ទឹកដោះខាប់, ប្រេង, ទឹកឃ្មុំ, ស្ករអំពៅ, ត្រី, សាច់, ទឹកដោះស្រស់, ទឹកដោះជូរ ។ ភិក្ខុណាមួយ គ្មានជំងឺ សូមបណីតភោជនទាំងឡាយមានសភាពយ៉ាងនេះ ដើម្បីប្រយោជន៍ខ្លួនហើយឆាន់, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៤០. ភិក្ខុណាមួយ លេបនូវអទិន្នាហារ(១) តាមទ្វារមាត់ វៀរលែងតែទឹកនិងឈើស្ទន់, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

## ភោជនវគ្គទី៤ (ចប់) ។

៤១. ភិក្ខុណាមួយ ឲ្យខាទនីយាហារ ឬភោជនីយាហារ ដល់អចេលកក្តី បរិញ្វាជកក្តី បរិញ្វាជិកាក្តី ដោយដៃរបស់ខ្លួន, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៤២. ភិក្ខុណាមួយ និយាយនឹងភិក្ខុផងគ្នា យ៉ាងនេះថា " ម្នាលអាវុសោ, លោកចូរមក, យើងទាំងឡាយ នឹងចូលទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត" ហើយឲ្យគេឲ្យ ឬមិនឲ្យគេឲ្យអ្វីៗ ដល់ភិក្ខុនោះហើយ បញ្ជូនឲ្យត្រឡប់ទៅវិញ ដោយពាក្យថា

---

១ អាហារដែលគេមិនបានប្រគេន ។

គច្ឆាវុសោ, ន មេ តយា សទ្ធឹ កថា វា និសជ្ជា វា ផាសុ ហោតិ. ឯកកស្ស មេ កថា វា និសជ្ជា វា ផាសុ ហោតីតិ; ឯតទេវ បច្ចយំ ករិត្វា អនញ្ញំ, បាចិត្តិយំ ។ ២ ។

៤៣- យោ បន ភិក្ខុ សភោជនេ កុលេ អនុប្បខជ្ជ និសជ្ជំ កប្បេយ្យ, បាចិត្តិយំ ។ ៣ ។

៤៤- យោ បន ភិក្ខុ មាតុគ្គាមេន សទ្ធឹ រហោ បដិច្ឆន្នេ អាសនេ និសជ្ជំ កប្បេយ្យ, បាចិត្តិយំ ។ ៤ ។

៤៥- យោ បន ភិក្ខុ មាតុគ្គាមេន សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេយ្យ, បាចិត្តិយំ ។ ៥ ។

៤៦- យោ បន ភិក្ខុ និមន្តិតោ សភត្តោ សមានោ, សន្តំ ភិក្ខុំ អនាបុច្ឆា, បុរេភត្តំ វា បច្ឆាភត្តំ វា កុលេសុ ចារិត្តំ អាបជ្ជេយ្យ, អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ ៖ ចីវរទានសមយោ, ចីវរការសមយោ; អយំ តត្ថ សមយោ ។ ៦ ។

៤៧- អគិលានេន ភិក្ខុនា ចាតុម្មាសប្បច្ចយប្បវារណា សាទិតព្វា, អញ្ញត្រ បុនប្បវារណាយ, អញ្ញត្រ និច្ចប្បវារណាយ, តតោ ចេ ឧត្តរឹ សាទិយេយ្យ, បាចិត្តិយំ ។ ៧ ។

ម្នាលអាវុសោ លោកចូរទៅវិញចុះ, ខ្ញុំនិយាយឬអង្គុយ ជាមួយនឹងលោកមិនសប្បាយទេ. ខ្ញុំនិយាយឬអង្គុយតែម្នាក់ឯងស្រួលជាង ; ធ្វើនូវហេតុនុះឯងឲ្យជាបច្ច័យ ពុំមែនហេតុដទៃឡើយ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៤៣. ភិក្ខុណាមួយ ចូលទៅកាន់ ទៅសម្រេចការអង្គុយនៅ ក្នុងត្រកូលដែលមានតែជនពីរនាក់គឺប្តីនិងប្រពន្ធ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៤៤. ភិក្ខុណាមួយ សម្រេចការអង្គុយ លើអាសនៈ ជាទីស្ងាត់កំបាំងជាមួយនឹងមាតុគ្រាម, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៤៥. ភិក្ខុណាមួយ សម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងមាតុគ្រាមតែម្នាក់និងម្នាក់, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៤៦. ភិក្ខុណាមួយ បានទទួលនិមន្តគេហើយ ជាអ្នកមានភត្តហើយ, មិនបានលាឬប្រាប់ភិក្ខុផងគ្នា ដែលមាននៅ, ហើយដល់នូវការត្រាច់ទៅ ក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី, វៀរលែងតែមានសម័យ, ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ នេះជាសម័យក្នុងសិក្ខាបទនោះគឺ សម័យដែលគេឲ្យចីវរ ១ សម័យដែលធ្វើចីវរ១, នេះជាសម័យ ក្នុងសិក្ខាបទនោះ ។

៤៧. ភិក្ខុមិនមានជំងឺ ត្រូវត្រេកអរនឹងការបវារណា ដោយបច្ច័យកំណត់ត្រឹមបួនខែ, វៀរលែងតែគេបានបវារណាថែមទៀត, វៀរលែងតែគេបានបវារណាជានិច្ច, បើត្រេកអរឲ្យលើសពីកំណត់នោះទៅ, ត្រូវអាបត្តិបាចិត្តិយ ។

៤៨- យោ បន ភិក្ខុ ឧយ្យុត្តំ សេនំ ទស្សនាយ គច្ឆេយ្យ, អញ្ញត្រ តថារូបប្បច្ចយា, បាចិត្តិយំ ។ ៨ ។

៤៩- សិយា ច តស្ស ភិក្ខុនោ កោចិទេវ បច្ចយោ សេនំ គមនាយ, ទិរត្តតិរត្តំ តេន ភិក្ខុនា សេនាយ វសិតព្វំ ។ តតោ ចេ ឧត្តរឹ វសេយ្យ, បាចិត្តិយំ ។ ៩ ។

៥០- ទិរត្តតិរត្តញ្ចេ ភិក្ខុ សេនាយ វសមានោ, ឧយ្យោធិកំ វា ពលគ្គំ វា សេនាព្យូហំ វា អនីក-ទស្សនំ វា គច្ឆេយ្យ, បាចិត្តិយំ ។ ១០ ។

អចេលកវគ្គោ បញ្ចមោ ។

៥១- សុរាមេរយបានេ បាចិត្តិយំ ។ ១ ។

៥២- អង្គុលិប្បតោទកេ បាចិត្តិយំ ។ ២ ។

៥៣- ឧទកេ ហស្សធម្មេ បាចិត្តិយំ ។ ៣ ។

៥៤- អនាទរិយេ បាចិត្តិយំ ។ ៤ ។

៥៥- យោ បន ភិក្ខុ ភិក្ខុំ ភឹសាបេយ្យ, បាចិត្តិយំ ។ ៥ ។

៥៦- យោ បន ភិក្ខុ អគិលានោ វិសិព្វនាបេ-ក្ខោ, ជោតឹ សមាទហេយ្យ វា សមាទហាបេយ្យ វា, អញ្ញត្រ តថារូបប្បច្ចយា, បាចិត្តិយំ ។ ៦ ។

# ចិត្តាររុក្ខស ក្នុងបាចិត្តិយ

៤៨. ភិក្ខុណាមួយ ទៅដើម្បីមើលកងទ័ពគេលើកចេញទៅ, វៀរលែងតែមានហេតុមានសភាពដូច្នោះ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៤៩. បើភិក្ខុនោះ មានហេតុអ្វីមួយ គួរនឹងទៅកាន់កងទ័ព, ភិក្ខុនោះត្រូវទៅនៅក្នុងទ័ពបាន ត្រឹមពីររាត្រីឬបីរាត្រី ។ បើនៅឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។

៥០. កាលបើភិក្ខុនៅក្នុងកងទ័ព កំណត់ពីររាត្រី ឬបីរាត្រី ហើយទៅកាន់ទីដែលគេច្បាំងគ្នាក្តី ទីដែលគេត្រួតពលក្តី ទីតាំងនៅនៃកងទ័ពក្តី ទីសម្រាប់ចាត់ក្បួនទ័ពក្តី, ត្រូវអាបត្តិបាចិត្តិយ ។

## អចេលកវគ្គទី ៥ (ចប់) ។

៥១. ភិក្ខុ ផឹកសុរានិងមេរ័យ ត្រូវអាបត្តិបាចិត្តិយ ។

៥២. ភិក្ខុ ចាក់ក្រលេកប្រលែងគ្នា ដោយចន្ទ្រញីម្រាមដៃ ត្រូវអាបត្តិបាចិត្តិយ ។

៥៣. ភិក្ខុ លេងទឹក ត្រូវអាបត្តិបាចិត្តិយ ។

៥៤. ភិក្ខុ មិនអើពើ(១) ត្រូវអាបត្តិបាចិត្តិយ ។

៥៥. ភិក្ខុណាមួយ បន្លាចភិក្ខុផងគ្នា, ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

៥៦. ភិក្ខុណាមួយ មិនមានជំងឺ មានបំណងនឹងអាំងភ្លើងហើយ បង្កាត់ភ្លើងខ្លួនឯងក្តី ប្រើគេឲ្យបង្កាត់ក្តី, វៀរលែងតែមានហេតុ មានសភាពដូច្នោះ(២) ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

---

១ គឺភិក្ខុមិនអើពើនឹងភិក្ខុអ្នករំលឹកដាស់តឿន ឬនឹងសិក្ខាបទដែលព្រះសុគតបញ្ញត្តទុកហើយ

២ គឺការតុតប្រទីបនិងការដុតចាក្រជាដើម ។

៥៧ យោ បន ភិក្ខុ ឱរេនឌ្ឍមាសំ នហាយេយ្យ អញ្ញត្រ សមយា, បាចិត្តិយំ ។ តត្ថាយំ សមយោ ទិយឌ្ឍោ មាសោ សេសោ គិម្ហានន្តិ. វស្សានស្ស បឋមោ មាសោ. ឥច្ចេតេ អឌ្ឍតេយ្យមាសា. ឧណ្ហសមយោ. បរិឡាហសមយោ. គិលានសមយោ. កម្មសមយោ. អទ្ធានគមនសមយោ, វាតវុដ្ឋិសមយោ, អយំ តត្ថ សមយោ ។៧។

៥៨- នវំ បន ភិក្ខុនា ចីវរលាភេន តិណ្ណំ ទុព្វណ្ណករណានំ អញ្ញតរំ ទុព្វណ្ណករណំ អាទាតព្វំ នីលំ វា កទ្ទមំ វា កាឡសាមំ វា ។ អនាទា ចេ ភិក្ខុ តិណ្ណំ ទុព្វណ្ណករណានំ អញ្ញតរំ ទុព្វណ្ណករណំ, នវំ ចីវរំ បរិភុញ្ជេយ្យ, បាចិត្តិយំ ។៨។

៥៩- យោ បន ភិក្ខុ ភិក្ខុស្ស វា ភិក្ខុនិយា វា សិក្ខមានាយ វា សាមណេរស្ស វា សាមណេរិយា វា សាមំ ចីវរំ វិកប្បេត្វា អប្បច្ចុទ្ធារកំ បរិភុញ្ជេយ្យ, បាចិត្តិយំ ។៩។

# ភិក្ខុបាតិមោក្ខប្រែ

៥៧ - ភិក្ខុណាមួយ មិនទាន់ដល់កំណត់កន្លះខែហើយងូតទឹក, វៀរលែងតែមានសម័យ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ នេះជាសម័យ ក្នុងសិក្ខាបទនោះគឺ មួយខែកន្លះដ៏សេសខាងចុងនៃគិម្ហរដូវ(១), មួយខែខាងដើមនៃវស្សានរដូវ(២), រួមខែទាំងនេះត្រូវជាពីរខែកន្លះ, ហៅថាសម័យក្តៅ, សម័យស្អុះស្អាប់, សម័យដែលមានជំងឺ, សម័យដែលធ្វើការងារ, សម័យដែលដើរផ្លូវឆ្ងាយ, សម័យដែលមានខ្យល់និងភ្លៀង, នេះជាសម័យក្នុងសិក្ខាបទនោះ(៣) ។

៥៨- ភិក្ខុបានចីវរថ្មីមកហើយ គប្បីកាន់យកនូវវត្ថុសម្រាប់ធ្វើឲ្យខូចពណ៌បីយ៉ាង វត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ណាមួយ គឺ ពណ៌ខៀវក្តី ពណ៌ភក់ក្តី ពណ៌ខ្មៅក្តី ។ បើភិក្ខុមិនកាន់យក នូវវត្ថុសម្រាប់ធ្វើឲ្យខូចពណ៌បីយ៉ាង វត្ថុសម្រាប់ធ្វើអោយខូចពណ៌ណាមួយទេ, ហើយប្រើប្រាស់ចីវរថ្មី, ត្រូវអាបត្តិបាចិត្តិយ ។

៥៩- ភិក្ខុណាមួយ បានវិកប្បចីវរដោយខ្លួនឯង ចំពោះភិក្ខុផងគ្នាក្តី ភិក្ខុនីក្តី សិក្ខមានាក្តី សាមណេរក្តី សាមណេរីក្តី ហើយប្រើប្រាស់ចីវរដែលមិនទាន់ឲ្យគេដកវិកប្បចេញ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

---

១ គឺចាប់តាំងពី ១ កើត ខែ ជេស្ឋ ទៅដល់ ១៥ កើត ខែ អាសាឍ ។ ២ គឺចាប់តាំងពី១ រោច ខែ អាសាឍ ទៅដល់ ១៥ កើត ខែស្រាពណ៍ ។ ៣ សិក្ខាបទនេះជាបទេសបញ្ញត្តិព្រះសាស្តាទ្រង់បញ្ញត្តចំពោះតែភិក្ខុ អ្នកនៅក្នុងមជ្ឈិមប្រទេសប៉ុណ្ណោះ ; ក្រៅពីនោះ ដូចនៅប្រទេសយើងជាដើម ភិក្ខុអាចងូតទឹកបានជានិច្ច ។

៦០- យោ បន ភិក្ខុ ភិក្ខុស្ស បត្តំ វា ចីវរំ វា និសីទនំ វា សូចិឃរំ វា កាយពន្ធនំ វា អបនិធេយ្យ វា អបនិធាបេយ្យ វា, អន្តមសោ ហស្សាបេក្ខោបិ បាចិត្តិយំ ។១០។

សុរាបានវគ្គោ ឆដ្ឋោ ។

៦១- យោ បន ភិក្ខុ សញ្ចិច្ច បាណំ ជីវិតា វោរោបេយ្យ. បាចិត្តិយំ ។១១។

៦២- យោ បន ភិក្ខុ ជានំ សប្បាណកំ ឧទកំ បរិភុញ្ជេយ្យ, បាចិត្តិយំ ។១២។

៦៣- យោ បន ភិក្ខុ ជានំ យថាធម្មំ និហតាធិក-រណំ បុនកម្មាយ ឧក្កោដេយ្យ. បាចិត្តិយំ ។១៣។

៦៤- យោ បន ភិក្ខុ ភិក្ខុស្ស ជានំ ទុដ្ឋុល្លំ អាបត្តឹ បដិច្ឆាទេយ្យ. បាចិត្តិយំ ។១៤។

៦៥- យោ បន ភិក្ខុ ជានំ ឩនវីសតិវស្សំ បុគ្គលំ ឧបសម្បាទេយ្យ, សោ ច បុគ្គលោ អនុបសម្បន្នោ តេ ច ភិក្ខូ គារយ្ហា, ឥទំ តស្មឹ បាចិត្តិយំ ។១៥។

៦៦- យោ បន ភិក្ខុ ជានំ ថេយ្យសត្ថេន សទ្ធឹ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជេយ្យ, អន្តមសោ គាមន្តរម្បិ, បាចិត្តិយំ ។១៦។

# សិក្ខាបទទោស ក្នុងបាចិត្តិយ

៦០. ភិក្ខុណាមួយ លាក់ទុកខ្លួនឯង ឬប្រើគេឲ្យលាក់ទុក នូវបាត្រក្តី ចីវរក្តី និស័ទនៈក្តី បំពង់ម្ជុលក្តី វត្ថុពន្ធចង្កេះក្តី របស់ភិក្ខុផងគ្នា ដោយហោចទៅ សូម្បីគ្រាន់តែបានបំណងនឹងសើចលេង, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

សុរាបានវគ្គទី ៦ (ចប់) ។

៦១. ភិក្ខុណាមួយ ក្លែងផ្តាច់បង់សត្វ ចាកជីវិត, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៦២. ភិក្ខុណាមួយ កាលដឹងហើយប្រើប្រាស់ទឹកដែលមានសត្វ មានជីវិត, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៦៣. ភិក្ខុណាមួយ កាលដឹងថា អធិករណ៍ ដែលសង្ឃរម្ងាប់សមគួរតាមធម៌ហើយ សើរើដើម្បីធ្វើជាថ្មីទៀត, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៦៤. ភិក្ខុណាមួយ កាលដឹង ហើយបិទបាំងទុកនូវទុដ្ឋុល្លាបត្តិ របស់ភិក្ខុផងគ្នា, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៦៥. ភិក្ខុណាមួយ កាលដឹងហើយ ឲ្យឧបសម្បទាដល់បុគ្គលដែលមានអាយុមិនទាន់គ្រប់ម្ភៃឆ្នាំ, បុគ្គលនោះ ក៏នៅពុំមែនជាឧបសម្បន្នផង, ទាំងពួកភិក្ខុនោះ ក៏ឈ្មោះថាត្រូវព្រះពុទ្ធជាម្ចាស់តិះដៀលផង, នេះជាអាបត្តិបាចិត្តិយ ក្នុងសិក្ខាបទនោះ ។

៦៦. ភិក្ខុណាមួយ កាលដឹងហើយ បបួលពួកឈ្មួញជាចោរ ដើរទៅកាន់ផ្លូវឆ្ងាយមួយ ជាមួយគ្នា, ដោយហោចទៅ សូម្បីចន្លោះស្រុកមួយ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៦៧- យោ បន ភិក្ខុ មាតុគ្គាមេន សទ្ធឹ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជេយ្យ, អន្តមសោ គាមន្តរម្បិ, បាចិត្តិយំ ។៧។

៦៨- យោ បន ភិក្ខុ ឯវំ វទេយ្យ, តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ, យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា, តេ បដិសេវតោ នាលំ អន្តរាយាយាតិ។ សោ ភិក្ខុ ភិក្ខូហិ ឯវមស្ស វចនីយោ: មា អាយស្មា ឯវំ អវច, មា ភគវន្តំ អព្ភាចិក្ខិ, ន ហិ សាធុ ភគវតោ អព្ភក្ខានំ, ន ហិ ភគវា ឯវំ វទេយ្យ : អនេកបរិយាយេន អាវុសោ អន្តរាយិកា ធម្មា វុត្តា ភគវតា, អលញ្ច បន តេ បដិសេវតោ អន្តរាយាយាតិ ។ ឯវញ្ច សោ ភិក្ខុ ភិក្ខូហិ វុច្ចមានោ, តថេវ បគ្គណ្ហេយ្យ, សោ ភិក្ខុ ភិក្ខូហិ យាវតតិយំ សមនុភាសិតព្វោ តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ សមនុភាសិយមានោ តំ បដិនិស្សជ្ជេយ្យ, ឥច្ចេតំ កុសលំ: នោ ចេ បដិនិស្សជ្ជេយ្យ, បាចិត្តិយំ ។៨។

# ភិក្ខុបាតិមោក្ខប្រែ

៦៧. ភិក្ខុណាមួយ បបួលមាតុគ្រាម ដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នា, ដោយហោចទៅ សូម្បីចន្លោះស្រុកមួយ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៦៨. ភិក្ខុណាមួយ ពោលយ៉ាងនេះថា " ខ្ញុំដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ដោយប្រការថា " អន្តរាយិកធម៌ទាំងឡាយណា ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយ, អន្តរាយិកធម៌ទាំងឡាយនោះ មិនមែនអាចនឹងធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពទេ" ។ ភិក្ខុទាំងឡាយ ត្រូវនិយាយនឹងភិក្ខុនោះ យ៉ាងនេះថា " លោកអ្នកមានអាយុ កុំនិយាយយ៉ាងនេះឡើយ, កុំពោលបង្កាច់ ព្រះមានព្រះភាគឡើយ, ការពោលបង្កាច់ព្រះមានព្រះភាគ មិនល្អទេ, ព្រះមានព្រះភាគពុំមែនពោលយ៉ាងនេះទេ, ម្នាលអាវុសោ ! ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយ នូវអន្តរាយិកធម៌ទាំងឡាយ ដោយអនេកបរិយាយ, អន្តរាយិកធម៌ទាំងនោះសោត ក៏អាចធ្វើនូវសេចក្តីអន្តរាយដល់អ្នកសេព បានមែនពិត " ។

កាលបើដែលភិក្ខុទាំងឡាយ និយាយយ៉ាងនេះ, ភិក្ខុនោះ នៅតែប្រកាន់ដូច្នោះដដែល ត្រូវភិក្ខុទាំងឡាយ សូត្រសមនុភាសនកម្ម ហាមប្រាមភិក្ខុនោះ អស់កំណត់បីដង ដើម្បីឱ្យលះបង់ទិដ្ឋិនោះចេញ ។ កាលបើភិក្ខុទាំងឡាយ សូត្រសមនុភាសនកម្ម ហាមប្រាមគ្រប់បីដងហើយ ភិក្ខុនោះ លះបង់នូវទិដ្ឋិនោះចេញ ការលះបង់ បានដូច្នោះនុ៎ះ ជាការប្រពៃ, បើពុំលះបង់ទេ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៦៩- យោ បន ភិក្ខុ ជានំ តថាវាទិនា ភិក្ខុនា អកដានុធម្មេន តំ ទិដ្ឋឹ អប្បដិនិស្សដ្ឋេន សទ្ធឹ សម្ភុញ្ជេយ្យ វា សំវសេយ្យ វា សហ វា សេយ្យំ កប្បេយ្យ, បាចិត្តិយំ ។៦៩។

៧០- សមណុទ្ទេសោបិ ចេ ឯវំ វទេយ្យ : តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ : យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា, តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ សោ សមណុទ្ទេសោ ភិក្ខូហិ ឯវមស្ស វចនីយោ : មា អាវុសោ សមណុទ្ទេស, ឯវំ អវច, មា ភគវន្តំ អព្ភាចិក្ខិ : ន ហិ សាធុ ភគវតោ អព្ភក្ខានំ, ន ហិ ភគវា ឯវំ វទេយ្យ ; អនេកបរិយាយេន អាវុសោ សមណុទ្ទេស, អន្តរាយិកា ធម្មា វុត្តា ភគវតា, អលញ្ច បន តេ បដិសេវតោ អន្តរាយាយាតិ ។ ឯវញ្ច សោ សមណុទ្ទេសោ ភិក្ខូហិ វុច្ចមានោ, តថេវ បគ្គណ្ហេយ្យ, សោ សមណុទ្ទេសោ ភិក្ខូហិ ឯវមស្ស វចនីយោ ; អជ្ជតគ្គេ តេ អាវុសោ សមណុទ្ទេស, ន ចេវ សោ ភគវា សត្ថា អបទិសិតព្វោ ;

# ទិក្ខារុទ្ទស ភ្លុចបាចិត្តិយ

៦៩. ភិក្ខុណាមួយ កាលដឹង ហើយបរិភោគរួមក្តី នៅរួមក្តី សម្រេចការដេករួមក្តី ជាមួយនឹងភិក្ខុ ដែលមានការពោលផ្ទុយ្ទោះជាប្រក្រតី, ជាអ្នកមិនធ្វើតាមធម៌, ជាអ្នកមិនលះបង់ទិដ្ឋិនោះ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៧០. បើសមណុទ្ទេស ពោលយ៉ាងនេះថា " ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយ ដោយបការៈថា " អន្តរាយិកធម៌ទាំងឡាយណាដែលព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងហើយ, អន្តរាយិកធម៌ទាំងឡាយនោះ មិនមែនអាចនឹងធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពទេ " ។ ភិក្ខុទាំងឡាយត្រូវនិយាយនឹងសមណុទ្ទេសនោះ យ៉ាងនេះថា នែ! អាវុសោសមណុទ្ទេស, ឯងកុំនិយាយយ៉ាងនេះឡើយ, កុំពោលបង្កាច់ព្រះមានព្រះភាគឡើយ, ការពោលបង្កាច់ព្រះមានព្រះភាគ មិនល្អទេ, ព្រះមានព្រះភាគពុំមែនពោលយ៉ាងនេះទេ, នែ! អាវុសោសមណុទ្ទេស, ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងហើយនូវអន្តរាយិកធម៌ទាំងឡាយ ដោយអនេកបរិយាយ, អន្តរាយិកធម៌ទាំងនោះសោត ក៏អាចធ្វើនូវសេចក្តីអន្តរាយ ដល់អ្នកសេព បានពិតមែន ។ កាលដែលភិក្ខុទាំងឡាយ និយាយយ៉ាងនេះ, សមណុទ្ទេសនោះ នៅតែប្រកាន់ផ្ទុយ្ទោះដដែល, ភិក្ខុទាំងឡាយ ត្រូវនិយាយនឹងសមណុទ្ទេសនោះយ៉ាងនេះថា " នែ! អាវុសោសមណុទ្ទេស, ចាប់តាំងពីថ្ងៃនេះទៅ ឯងមិនត្រូវអាង ព្រះមានព្រះភាគអង្គនោះ ថាជាសាស្តារបស់ឯងទៀតឡើយ

យម្បិ ចញ្ញេ សមណុទ្ទេសា លភន្តិ ភិក្ខូហិ សទ្ធឹ ទិរត្តតិរត្តំ សហសេយ្យំ, សាបិ តេ នត្ថិ; ចរ បិរេ វិនស្សាតិ ។ យោ បន ភិក្ខុ ជានំ តថានាសិតំ សមណុទ្ទេសំ ឧបលាបេយ្យ វា ឧបដ្ឋាបេយ្យ វា សម្ភុញ្ជេយ្យ វា សហ វា សេយ្យំ កប្បេយ្យ, បាចិត្តិយំ ។១០។

## សប្បាណកវគ្គោ សត្តមោ ។

៧១- យោ បន ភិក្ខុ ភិក្ខូហិ សហធម្មិកំ វុច្ចមានោ, ឯវំ វទេយ្យៈ ន តាវាហំ អាវុសោ, ឯតស្មឹ សិក្ខាបទេ សិក្ខិស្សាមិ, យាវ នញ្ញំ ភិក្ខុំ ព្យត្តំ វិនយធរំ បរិបុច្ឆាមីតិ, បាចិត្តិយំ ។ សិក្ខមានេន ភិក្ខវេ ភិក្ខុនា អញ្ញាតព្វំ បរិបុច្ឆិតព្វំ បរិបញ្ហិតព្វំ ។ អយំ តត្ថ សាមីចិ ។១។

៧២- យោ បន ភិក្ខុ, បាតិមោក្ខេ ឧទ្ទិស្សមានេ, ឯវំ វទេយ្យៈ កិម្បនិមេហិ ខុទ្ទានុខុទ្ទកេហិ សិក្ខាបទេហិ ឧទ្ទិដ្ឋេហិ, យាវទេវ កុក្កុច្ចាយ វិហេសាយ វិលេខាយ សំវត្តន្តីតិ, សិក្ខាបទវិវណ្ណនកេ បាចិត្តិយំ ។២។

ក៏សាមណេរទាំងឡាយដទៃ តែងបាននូវការដេករួមឯណា អស់ពីររាត្រី ឬបីរាត្រី ជាមួយនឹងភិក្ខុទាំងឡាយ, ការដេករួមនោះ មិនមានដល់ឯងទេ, នែ! មនុស្សឥតគេរាប់ ឯងចូរចេញទៅ, ចូរវិនាសទៅ " ។ ភិក្ខុណាមួយកាល ដឹងហើយ បញ្ចុះបញ្ចូលសមណុទ្ទេស ដែលសង្ឃបានឲ្យវិនាស យ៉ាងនោះ ហើយក្តី, ឲ្យបម្រើក្តី, បរិភោគរួមក្តី, សម្រេចឥរិយាបថដេករួម, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

## សប្បាណកវគ្គទី៧ ( ចប់ ) ។

៧១. ភិក្ខុណាមួយ កាលដែលភិក្ខុទាំងឡាយពោលពាក្យប្រកបដោយធម៌ ហើយពោលយ៉ាងនេះថា " ម្នាលអាវុសោទាំងឡាយ, ខ្ញុំមិនទាន់សាកសួរ ភិក្ខុដទៃដែលឈ្លាស ដែលទ្រទ្រង់វិន័យដរាបណា, ខ្ញុំនឹងមិនសិក្សាសិក្ខាបទ នេះដរាបនោះ ", ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ ម្នាលភិក្ខុទាំងឡាយ, ភិក្ខុ អ្នកសិក្សាគួរតែដឹងច្បាស់, គួរតែសាកសួរ គួរតែពិចារណា ។ នេះជាសាមីចិកម្ម ក្នុងសិក្ខាបទនោះ ។

៧២. ភិក្ខុណាមួយ, កាលភិក្ខុកំពុងសម្តែង នូវបាតិមោក្ខ ពោលយ៉ាងនេះថា " ប្រយោជន៍អ្វី ដោយសិក្ខាបទតូចតាច ដែលសម្តែងហើយទាំងនេះ សិក្ខាបទទាំងនេះ, ប្រព្រឹត្តទៅគ្រាន់តែ ដើម្បីសេចក្តីក្តៅក្រហាយចិត្ត សេចក្តីលំបាកចិត្ត និងសេចក្តីសៅរសាយចិត្តប៉ុណ្ណោះឯង", ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ព្រោះពោលបន្ទាប់សិក្ខាបទ ។

៧៣- យោ បន ភិក្ខុ អន្វឌ្ឍមាសំ បាតិមោក្ខេ ឧទ្ទិស្សមានេ, ឯវំ វទេយ្យ: ឥទានេវ ខោ អហំ ជានាមិ: អយម្បិ កិរ ធម្មោ សុត្តាគតោ សុត្តបរិយាបន្នោ អន្វឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតីតិ: តញ្ចេ ភិក្ខុំ អញ្ញេ ភិក្ខូ ជានេយ្យុំ និសិន្នបុព្វំ ឥមិនា ភិក្ខុនា ទ្វិត្តិក្ខត្តុំ បាតិមោក្ខេ ឧទ្ទិស្សមានេ, កោ បន វាទោ ភិយ្យោតិ, ន ច តស្ស ភិក្ខុនោ អញ្ញាណកេន មុត្តិ អត្ថិ, យញ្ច តត្ថ អាបត្តិំ អាបន្នោ, តញ្ច យថាធម្មោ ការេតព្វោ; ឧត្តរិញ្ចស្ស មោហោ អារោបេតព្វោ: តស្ស តេ អាវុសោ អលាភា, តស្ស តេ ទុល្លទ្ធំ, យំ ត្វំ បាតិមោក្ខេ ឧទ្ទិស្សមានេ, ន សាធុកំ អដ្ឋិកត្វា មនសិករោសីតិ ; ឥទំ តស្មិំ មោហនកេ បាចិត្តិយំ ។៣។

៧៤- យោ បន ភិក្ខុ ភិក្ខុស្ស កុបិតោ អនត្តមនោ បហារំ ទទេយ្យ, បាចិត្តិយំ ។៤។

៧៥- យោ បន ភិក្ខុ ភិក្ខុស្ស កុបិតោ អនត្តមនោ តលសត្តិកំ ឧគ្គិរេយ្យ, បាចិត្តិយំ ។៥។

# សិក្ខាបទខ្លះ ក្នុងបាចិត្តិយ

៧៣. ភិក្ខុណាមួយ , កាលភិក្ខុកំពុងសម្តែង នូវបាតិមោក្ខ រាល់កន្លះខែ ពោលយ៉ាងនេះថា " ខ្ញុំទើបតែនឹងដឹង ក្នុងកាលឥឡូវនេះឯង ថា " ពួចាសិក្ខាបទនេះ មកហើយក្នុងសូត្រ រាប់បញ្ចូលក្នុងសូត្រ មកកាន់ឧទ្ទេស រាល់កន្លះខែ " ។ បើភិក្ខុទាំងឡាយដទៃ ដឹងនូវភិក្ខុនោះថា " ភិក្ខុនេះ ធ្លាប់អង្គុយស្តាប់បាតិមោក្ខ ដែលភិក្ខុសម្តែង អស់វារៈពីរបីផងហើយ នឹងបាច់និយាយថ្វី ដល់ការស្តាប់ច្រើនផង ", ភិក្ខុនោះ មិនមានការរួចចាកអាបត្តិ ដោយសារការៈដែលមិនដឹងទេ, ភិក្ខុនោះ ត្រូវអាបត្តិណា ក្នុងអនាចារនោះ សង្ឃត្រូវឲ្យភិក្ខុនោះ ធ្វើអាបត្តិនោះដោយសមគួរតាមធម៌, មួយាំងទៀតត្រូវលើកមោហារោបនកម្ម ចំពោះភិក្ខុនោះថែមទៀតថា " ម្នាលអាវុសោ ការនេះមិនជាលាភ របស់អ្នកឯងទេ, អ្នកឯងនេះ បាននូវរបស់អាក្រក់ហើយ ដោយហេតុថា កាលភិក្ខុកំពុងសម្តែងនូវបាតិមោក្ខ, អ្នកឯងមិនបានធ្វើទុកក្នុងចិត្ត ឲ្យសម្រេចប្រយោជន៍ល្អឡើយ ។ នេះជាអាបត្តិបាចិត្តិយ ព្រោះតែធ្វើវង្វេង (តើ ) នោះ ។

៧៤. ភិក្ខុណាមួយ ក្រោធខឹង ហើយឲ្យប្រហារដល់ភិក្ខុផងគ្នា, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៧៥. ភិក្ខុណាមួយ ក្រោធខឹង ហើយងាឡើងនូវលំពែងគឺបាតដៃសំដៅភិក្ខុផងគ្នា, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៧៦- យោ បន ភិក្ខុ ភិក្ខុំ អមូលកេន សង្ឃា-ទិសេសេន អនុទ្ធំសេយ្យ, បាចិត្តិយំ ៕៦៕

៧៧- យោ បន ភិក្ខុ ភិក្ខុស្ស សញ្ចិច្ច កុក្កុច្ចំ ឧបទហេយ្យ ៖ ឥតិស្ស មុហុត្តម្បិ អផាសុ ភវិស្សតីតិ, ឯតទេវ បច្ចយំ ករិត្វា អនញ្ញំ, បាចិត្តិយំ ៕៧៕

៧៨- យោ បន ភិក្ខុ ភិក្ខូនំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ, ឧបស្សុតឹ តិដ្ឋេយ្យ ៖ យំ ឥមេ ភណិស្សន្តិ, តំ សោស្សាមីតិ, ឯតទេវ បច្ចយំ ករិត្វា អនញ្ញំ, បាចិត្តិយំ ៕៨៕

៧៩- យោ បន ភិក្ខុ ធម្មិកានំ កម្មានំ ឆន្ទំ ទត្វា, បច្ឆា ខីយនធម្មំ អាបជ្ជេយ្យ, បាចិត្តិយំ ៕៩៕

៨០- យោ បន ភិក្ខុ, សង្ឃេ វិនិច្ឆយកថាយំ វត្តមានាយ, ឆន្ទំ អទត្វា, ឧដ្ឋាយាសនា បក្កមេយ្យ, បាចិត្តិយំ ៕១០៕

# ភិក្ខុបាតិមោក្ខប្រែ

៧៦. ភិក្ខុណាមួយ ចោទភិក្ខុផងគ្នា ដោយអាបត្តិសង្ឃាទិសេស ឥតមានមូល, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៧៧. ភិក្ខុណាមួយ ក្លែងបង្កហេតុឲ្យមានសេចក្ដីស្ដៀសសង្ស័យដល់ភិក្ខុផងគ្នា ដោយគិតថា " ភិក្ខុនោះ នឹងមានសេចក្ដីមិនសប្បាយចិត្តមួយរំពេចដោយហេតុនេះ ពុំខានឡើយ ", ធ្វើនូវសេចក្ដីសង្ស័យនោះឯងឲ្យជាបច្ច័យ ពុំមែនហេតុដទៃឡើយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៧៨. ភិក្ខុណាមួយ កាលដែលភិក្ខុទាំងឡាយបង្កហេតុប្រកួតប្រកាន់ឈ្លោះទាស់ទែងគ្នា, ទៅឈរលែបចាំស្ដាប់ ដោយគិតថា " ភិក្ខុទាំងនេះ នឹងពោលនូវពាក្យណា, អញនឹងស្ដាប់នូវពាក្យនោះ ", ធ្វើនូវកិរិយាឈរលែបចាំស្ដាប់នោះឯង ឲ្យជាបច្ច័យ ពុំមែនហេតុដទៃឡើយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៧៩. ភិក្ខុណាមួយ ឲ្យឆន្ទៈដើម្បីកម្មទាំងឡាយ ដែលប្រកបដោយធម៌ហើយ(១) ក៏ដល់នូវធម៌តិកិរិយាតិះដៀល ជាខាងក្រោយវិញ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៨០. ភិក្ខុណាមួយ កាលដែលពាក្យវិនិច្ឆ័យកំពុងប្រព្រឹត្តទៅក្នុងសង្ឃ មិនឲ្យឆន្ទៈ, ហើយក្រោកចាកអាសនៈ ចេញទៅ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ

---

១ បានដល់កម្មទាំង៤យ៉ាងគឺ អបលោកនកម្ម១ ញត្តិកម្ម១ ញត្តិទុតិយកម្ម១ ញត្តិចតុត្ថកម្ម ១ ដែលសង្ឃធ្វើតាមធម៌ តាមវិន័យ ។

៨១- យោ បន ភិក្ខុ សមគ្គេន សង្ឃេន ចីវរំ ទត្វា, បច្ឆា ខីយនធម្មំ អាបជ្ជេយ្យ : យថាសន្ថុតំ ភិក្ខូ សង្ឃិកំ លាភំ បរិណាមេន្តីតិ, បាចិត្តិយំ ។ ១១ ។

៨២- យោ បន ភិក្ខុ ជានំ សង្ឃិកំ លាភំ បរិណតំ បុគ្គលស្ស បរិណាមេយ្យ, បាចិត្តិយំ ។ ១២ ។

សហធម្មិកវគ្គោ អដ្ឋមោ ។

៨៣- យោ បន ភិក្ខុ, រញ្ញោ ខត្តិយស្ស មុទ្ធាភិ-សិត្តស្ស អនិក្ខន្តរាជកេ អនិគ្គតរតនកេ បុព្វេ អប្បដិ-សំវិទិតោ, ឥន្ទខីលំ អតិក្កាមេយ្យ, បាចិត្តិយំ ។ ១ ។

៨៤- យោ បន ភិក្ខុ រតនំ វា រតនសម្មតំ វា, អញ្ញត្រ អជ្ឈារាមា វា អជ្ឈាវសថា វា ឧគ្គណ្ហេយ្យ វា ឧគ្គណ្ហាបេយ្យ វា, បាចិត្តិយំ ។ រតនំ វា បន ភិក្ខុនា រតនសម្មតំ វា អជ្ឈារាមេ វា អជ្ឈាវសថេ វា ឧគ្គហេត្វា វា ឧគ្គហាបេត្វា វា និក្ខិបិតព្វំ : យស្ស ភវិស្សតិ, សោ ហរិស្សតីតិ ។ អយំ តត្ថ សាមីចិ ។ ២ ។

# សិក្ខាវុធ្ធស ក្នុងបាចិត្តិយ

៨១. ភិក្ខុណាមួយ ឲ្យចីវរ ( ដល់ភិក្ខុ ជាមួយ ) នឹងសង្ឃ ដែលព្រមព្រៀងគ្នាហើយ, ក៏ដល់នូវកិរិយាតិះដៀល ជាខាងក្រោយវិញថា " ភិក្ខុទាំងឡាយបង្អោនលាភរបស់សង្ឃ ទៅតាមសេចក្ដីគាប់ចិត្ត ", ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៨២. ភិក្ខុណាមួយ កាលដឹងហើយ បង្អោនលាភដែលគេប្រុងនឹងបង្អោនទៅ ដើម្បីសង្ឃ ឲ្យត្រឡប់មកដើម្បីបុគ្គលវិញ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

## សហធម្មិកវគ្គទី ៨ (ចប់) ។

៨៣- ភិក្ខុណាមួយ, កាលព្រះរាជាក្សត្រិយ៍ បានមុទ្ធាភិសេកហើយ ទ្រង់ពុំទាន់ជ្រាបជាមុន, ឈានកន្លងធរណី(១) ចូលទៅក្នុងក្រឡាព្រះបន្ទំ ដែលព្រះរាជាមិនទាន់ស្ដេចចេញ ទាំងស្រ្តីកែវគឺព្រះមហេសី ក៏មិនទាន់ស្ដេចចេញដែរ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៨៤. ភិក្ខុណាមួយ រើសខ្លួនឯងក្ដី ឲ្យគេរើសក្ដី នូវរតនៈក្ដី នូវវត្ថុដែលសន្មតជារតនៈក្ដី, វៀរលែងតែខាងក្នុងអារាម ឬខាងក្នុងទីស្នាក់, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ តែថាភិក្ខុត្រូវរើសខ្លួនឯង ឬឲ្យគេរើស នូវរតនៈក្ដី នូវវត្ថុដែលគេសន្មតជារតនៈក្ដី ខាងក្នុងអារាម ឬខាងក្នុងទីស្នាក់ហើយទុកដាក់ ដោយគិតថា " រតនៈរបស់អ្នកណា អ្នកនោះនឹងនាំយកទៅ " ។ នេះជាសាមីចិកម្មក្នុងសិក្ខាបទនោះ ។

---

១ សំដៅយកក្រូបទ្វារខាងក្រោមនៃក្រឡាបន្ទំ ។

៨១- យោ បន ភិក្ខុ សមគ្គេន សង្ឃេន ចីវរំ ទត្វា, បច្ឆា ខីយនធម្មំ អាបជ្ជេយ្យ: យថាសន្ថុតំ ភិក្ខូ សង្ឃិកំ លាភំ បរិណាមេន្តីតិ, បាចិត្តិយំ ។ ១១ ។

៨២- យោ បន ភិក្ខុ ជានំ សង្ឃិកំ លាភំ បរិណតំ បុគ្គលស្ស បរិណាមេយ្យ, បាចិត្តិយំ ។ ១២ ។

សហធម្មិកវគ្គោ អដ្ឋមោ ។

៨៣- យោ បន ភិក្ខុ, រញ្ញោ ខត្តិយស្ស មុទ្ធាភិសិត្តស្ស អនិក្ខន្តរាជកេ អនិគ្គតរតនកេ បុព្វេ អប្បដិសំវិទិតោ, ឥន្ទខីលំ អតិក្កាមេយ្យ, បាចិត្តិយំ ។ ១ ។

៨៤- យោ បន ភិក្ខុ រតនំ វា រតនសម្មតំ វា, អញ្ញត្រ អជ្ឈារាមា វា អជ្ឈាវសថា វា ឧគ្គណ្ហេយ្យ វា ឧគ្គណ្ហាបេយ្យ វា, បាចិត្តិយំ ។ រតនំ វា បន ភិក្ខុនា រតនសម្មតំ វា អជ្ឈារាមេ វា អជ្ឈាវសថេ វា ឧគ្គហេត្វា វា ឧគ្គហាបេត្វា វា និក្ខិបិតព្វំ: យស្ស ភវិស្សតិ, សោ ហរិស្សតីតិ ។ អយំ តត្ថ សាមីចិ ។ ២ ។

# វិត្ថារទោស ក្នុងបាចិត្តិយ

៨១. ភិក្ខុណាមួយ ឲ្យចីវរ ( ដល់ភិក្ខុ ជាមួយ ) នឹងសង្ឃ ដែលព្រមព្រៀងគ្នាហើយ, ក៏ដល់នូវកិរិយាតិះដៀល ជាខាងក្រោយវិញថា “ ភិក្ខុទាំងឡាយបង្អោនលាភរបស់សង្ឃ ទៅតាមសេចក្តីគាប់ចិត្ត ”, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៨២. ភិក្ខុណាមួយ កាលដឹងហើយ បង្អោនលាភដែលគេប្រុងនឹងបង្អោនទៅ ដើម្បីសង្ឃ ឲ្យត្រឡប់មកដើម្បីបុគ្គលវិញ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

## សហធម្មិកវគ្គទី ៨ (ចប់) ។

៨៣- ភិក្ខុណាមួយ, កាលព្រះរាជាក្សត្រិយ៍ បានមុទ្ធាភិសេកហើយ ទ្រង់ពុំទាន់ជ្រាបជាមុន, ឈានកន្លងធរណី(១) ចូលទៅក្នុងក្រឡាព្រះបន្ទំ ដែលព្រះរាជាមិនទាន់ស្តេចចេញ ទាំងស្រ្តីកែវគឺព្រះមហេសី ក៏មិនទាន់ស្តេចចេញដែរ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។

៨៤. ភិក្ខុណាមួយ រើសខ្លួនឯងក្តី ឲ្យគេរើសក្តី នូវរតនៈក្តី នូវវត្ថុដែលសន្មតជារតនៈក្តី, វៀរលែងតែខាងក្នុងអារាម ឬខាងក្នុងទីស្នាក់, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ តែថាភិក្ខុត្រូវរើសខ្លួនឯង ឬឲ្យគេរើស នូវរតនៈក្តី នូវវត្ថុដែលគេសន្មតជារតនៈក្តី ខាងក្នុងអារាម ឬខាងក្នុងទីស្នាក់ហើយទុកដាក់ ដោយគិតថា “ រតនៈរបស់អ្នកណា អ្នកនោះនឹងនាំយកទៅ ” ។ នេះជាសាមីចិកម្មក្នុងសិក្ខាបទនោះ ។

---

១ សំដៅយកគ្រឿងទ្វារខាងក្រោមនៃក្រឡាបន្ទំ ។

៨៥- យោ បន ភិក្ខុ សន្តំ ភិក្ខុំ អនាបុច្ឆា វិកាលេ គាមំ បវិសេយ្យ, អញ្ញត្រ តថារូបា អច្ចាយិកា ករ-ណីយា, បាចិត្តិយំ ។៣។

៨៦- យោ បន ភិក្ខុ អដ្ឋិមយំ វា ទន្តមយំ វា វិសាណមយំ វា សូចិឃរំ ការាបេយ្យ, ភេទនកំ បាចិត្តិយំ ។ ៤ ។

៨៧- នវំ បន ភិក្ខុនា មញ្ចំ វា បីឋំ វា ការយមានេន, អដ្ឋង្គុលបាទកំ ការេតព្វំ សុគតង្គុលេន អញ្ញត្រ ហេដ្ឋិមាយ អដនិយា, តំ អតិក្កាមយតោ; ឆេទនកំ បាចិត្តិយំ ។ ៥ ។

៨៨- យោ បន ភិក្ខុ មញ្ចំ វា បីឋំ វា តូលោនទ្ធំ ការាបេយ្យ, ឧទ្ទាលនកំ បាចិត្តិយំ ។ ៦ ។

៨៩- និសីទនំ បន ភិក្ខុនា ការយមានេន បមាណិកំ ការេតព្វំ, តត្រិទំ បមាណំ: ទីឃសោ ទ្វេ វិទត្ថិយោ សុគតវិទត្ថិយា តិរិយំ ទិយឌ្ឍំ ទសា វិទត្ថិ ។ តំ អតិក្កាមយតោ, ឆេទនកំ បាចិត្តិយំ ។៧។

# ភិក្ខុបាតិមោក្ខប្រែ

៨៥ - ភិក្ខុណាមួយ ពុំបានលាភិក្ខុដែលមាននៅ ហើយចូលទៅកាន់ស្រុកក្នុងវេលាវិកាល, វៀរលែងតែមានកិច្ចប្រញាប់ មានសភាពដូច្នោះ, ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

៨៦ - ភិក្ខុណាមួយ ឲ្យគេធ្វើចំពង់ម្ជុល ជាវិការៈនៃឆ្អឹងក្ដី ជាវិការៈនៃភ្លុកក្ដី ជាវិការៈនៃស្នែងក្ដី ភិក្ខុនោះ ត្រូវអាបត្តិភេទនកបាចិត្តិយ(១) ។

៨៧ - បើភិក្ខុឲ្យគេធ្វើគ្រែថ្មីក្ដី តាំងថ្មីក្ដី ត្រូវឲ្យធ្វើឲ្យមានជើង ៨ ធ្នាប់ ដោយធ្នាប់ព្រះសុគត វាស់ពីត្រឹមមែគ្រែខាងក្រោមចុះទៅ, (បើធ្វើ) ឲ្យកន្លងហួសពីនោះទៅ, ត្រូវឆេទនកបាចិត្តិយ(២) ។

៨៨ - ភិក្ខុណាមួយ ឲ្យគេធ្វើគ្រែក្ដី តាំងក្ដី ញាត់ដោយសំឡី, ភិក្ខុនោះ ត្រូវអាបត្តិឧទ្ទាលនកបាចិត្តិយ(៣) ។

៨៩ - បើភិក្ខុឲ្យគេធ្វើសំពត់និសីទនៈ ត្រូវឲ្យគេធ្វើឲ្យត្រូវនឹងប្រមាណ, ឯប្រមាណក្នុងសំពត់និសីទនៈនោះយ៉ាងនេះគឺ បណ្ដោយពីរចំអាម, ទទឹង ១ ចំអាមកន្លះ និងជាយ ១ ចំអាម ដោយចំអាមព្រះសុគត ។ (បើធ្វើ) ឲ្យកន្លងហួសពីនោះទៅ, ត្រូវអាបត្តិឆេទនកបាចិត្តិយ ។

---

១ អាបត្តិបាចិត្តិយនេះ មានកិច្ចត្រូវបំបែកចំពង់ម្ជុលនោះ ជាវិនយកម្មសិនទើបសម្ដែងបាន, បើមិនបានធ្វើវិនយកម្មទេ, សម្ដែងមិនដាច់ឡើយ ។

២ អាបត្តិបាចិត្តិយនេះ មានកិច្ចត្រូវកាត់ជើងគ្រែ ឬតាំងនោះ ជាវិនយកម្មសិន ទើបសម្ដែងបាន, បើមិនបានធ្វើវិនយកម្មទេ សម្ដែងពុំដាច់ឡើយ ។ ៣ អាបត្តិបាចិត្តិយនេះ មានកិច្ចត្រូវរោយសំឡីនោះចោល ជាវិនយកម្មសិន ទើបសម្ដែងបាន, បើមិនបានធ្វើវិនយកម្មទេ សម្ដែងពុំដាច់ឡើយ ។

៩០- កណ្ឌុប្បដិច្ឆាទឹ(១) បន ភិក្ខុនា ការយមានេន បមាណិកា ការេតព្វា, តត្រិទំ បមាណំ: ទីឃសោ ចតស្សោ វិទត្ថិយោ សុគតវិទត្ថិយា តិរិយំ ទ្វេ វិទត្ថិយោ តំ អតិក្កាមយតោ, ឆេទនកំ បាចិត្តិយំ ។ ៨ ។

៩១- វស្សិកសាដិកំ(២) បន ភិក្ខុនា ការយមានេន បមាណិកា ការេតព្វា, តត្រិទំ បមាណំ: ទីឃសោ ឆ វិទត្ថិយោ សុគតវិទត្ថិយា តិរិយំ អឌ្ឍតេយ្យា ។ តំ អតិក្កាមយតោ, ឆេទនកំ បាចិត្តិយំ ។ ៩ ។

៩២- យោ បន ភិក្ខុ សុគតចីវរប្បមាណំ ចីវរំ ការាបេយ្យ អតិរេកំ វា, ឆេទនកំ បាចិត្តិយំ ។ តត្រិទំ សុគតស្ស សុគតចីវរប្បមាណំ: ទីឃសោ នវ វិទត្ថិយោ សុគតវិទត្ថិយា តិរិយំ ឆ វិទត្ថិយោ ។

ឥទំ សុគតស្ស សុគតចីវរប្បមាណំ ។ ១០ ។

រតនវគ្គោ នវមោ ។

---

១ ច្បាប់ខ្លះថា កណ្ឌុប្បដិច្ឆាទិ ។ ខ្លះថា កណ្ឌុប្បដិច្ឆាទិ ។ ២ ច្បាប់ខ្លះថា វស្សិកសាដិកា ។

## និស្សគ្គិយ បាចិត្តិយ

៩០- បើភិក្ខុឲ្យគេធ្វើសំពត់សម្រាប់គ្របកម ត្រូវឲ្យគេធ្វើ ឲ្យត្រូវនឹងប្រមាណ, ឯប្រមាណ ក្នុងសំពត់សម្រាប់គ្របកមនោះ យ៉ាងនេះគឺ បណ្ដោយបួនចំអាម, ទទឹងពីរចំអាម ដោយចំអាមព្រះសុគត ។ ( បើធ្វើ ) ឲ្យកន្លងហួសពីនោះទៅ, ត្រូវអាបត្តិនេះទនកបាចិត្តិយ ។

៩១- បើភិក្ខុឲ្យគេធ្វើសំពត់ស្បៀកសាដិកា(១) ត្រូវឲ្យគេធ្វើឲ្យត្រូវនឹងប្រមាណ, ឯប្រមាណ ក្នុងសំពត់ស្បៀកសាដិកានោះ យ៉ាងនេះគឺ បណ្ដោយប្រាំមួយចំអាម, ទទឹងពីរចំអាមកន្លះ ដោយចំអាមព្រះសុគត ។ ( បើធ្វើ ) ឲ្យកន្លងហួសពីនោះទៅ, ត្រូវអាបត្តិនេះទនកបាចិត្តិយ ។

៩២- ភិក្ខុណាមួយ ឲ្យគេធ្វើចីវរ ប៉ុនចីវរព្រះសុគតឬធំជាង, ភិក្ខុនោះត្រូវអាបត្តិនេះទនកបាចិត្តិយ ។ ឯប្រមាណ នៃសុគតចីវររបស់ព្រះសុគតនោះ យ៉ាងនេះគឺ បណ្ដោយប្រាំបួនចំអាម, ទទឹងប្រាំមួយចំអាម ដោយចំអាមព្រះសុគត ។

នេះជាប្រមាណ នៃសុគតចីវរ របស់ព្រះសុគត ។

### រតនវគ្គទី ៩ (ចប់) ។

---

១ គឺសំពត់ដែលភិក្ខុធ្វើ សម្រាប់ងូតទឹកភ្លៀងគស់៤ខែ នៃរដូវវស្សា ។

ឧទ្ទិដ្ឋា ខោ អាយស្មន្តោ ទ្វេនវុតិ បាចិត្តិយា
ធម្មា ។ តត្ថាយស្មន្តេ បុច្ឆាមិ, កច្ចិត្ថ បរិសុទ្ធា ?
ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ?
តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ?
បរិសុទ្ធេត្ថាយស្មន្តោ, តស្មា តុណ្ហី ។
ឯវមេតំ ធារយាមិ ។

បាចិត្តិយា និដ្ឋិតា ។

# ភិក្ខុបាតិមោក្ខប្រែ

បពិត្រលោកអ្នកមានអាយុទាំងឡាយ , អាបត្តិបាចិត្តិយទាំងកៅសិបពីរ ខ្ញុំព្រះករុណាបានសម្ដែងរួចហើយ ។ ខ្ញុំព្រះករុណាសូមសួរលោកអ្នកមានអាយុទាំងឡាយក្នុងអាបត្តិទាំងនោះ, លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ?

ខ្ញុំព្រះករុណា សូមសួរជាគម្រប់ពីរផងទៀត, លោកទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ ?

ខ្ញុំព្រះករុណា សូមសួរជាគម្រប់បីផងទៀត, លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ?

លោកអ្នកមានអាយុទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធក្នុងអាបត្តិទាំងនុ៎ះហើយ, ព្រោះហេតុនោះបានជានៅស្ងៀម ។

ខ្ញុំព្រះករុណា សូមចាំទុកនូវហេតុនេះ ដោយកិរិយានៅស្ងៀមយ៉ាងនេះ ។

ចប់អាបត្តិបាចិត្តិយ ។

ឥមេ ខោ បនាយស្មន្តោ, ចត្តារោ បាដិទេសនីយា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

១- យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា អន្តរឃរំ បវិដ្ឋាយ ហត្ថតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទេយ្យ វា ភុញ្ជេយ្យ វា, បដិទេសេតព្វំ តេន ភិក្ខុនា: គារយ្ហំ អាវុសោ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេសនីយំ, តំ បដិទេសេមីតិ ។

២- ភិក្ខូ បនេវ កុលេសុ និមន្តិតា ភុញ្ជន្តិ ។ តត្រ ចេ ភិក្ខុនី វោសាសមានរូបា ឋិតា ហោតិ: ឥធ សូបំ ទេថ, ឥធ ឱទនំ ទេថាតិ ។ តេហិ ភិក្ខូហិ សា ភិក្ខុនី អបសាទេតព្វា: អបសក្ក តាវ ភគិនិ, យាវ ភិក្ខូ ភុញ្ជន្តីតិ ។ ឯកស្សបិ ចេ ភិក្ខុនោ នប្បដិភាសេយ្យ តំ ភិក្ខុនឹ អបសាទេតុំ: អបសក្ក តាវ ភគិនិ, យាវ ភិក្ខូ ភុញ្ជន្តីតិ, បដិទេសេតព្វំ តេហិ ភិក្ខូហិ: គារយ្ហំ អាវុសោ ធម្មំ អាបជ្ជិម្ហា អសប្បាយំ បាដិទេសនីយំ, តំ បដិទេសេមាតិ ។

# សិក្ខាបទុទ្ទេស ក្នុងបាដិទេសនីយ

បពិត្រលោកអ្នកមានអាយុទាំងឡាយ, អាបត្តិបាដិទេសនីយទាំងឡាយ បួននេះឯង មកកាន់ឧទ្ទេស ។

១-ភិក្ខុណាមួយ ទទួលយកខាទនីយាហារ ឬ ភោជនីយាហារដោយដៃរបស់ខ្លួន អំពីដៃភិក្ខុនី មិនមែនជាញាតិដែលចូលទៅកាន់ចន្លោះផ្ទះហើយ ទំពាស៊ីក្តី បរិភោគក្តី, ភិក្ខុនោះត្រូវសម្តែង ( អាបត្តិបាដិទេសនីយ ) ថា “ម្នាលអាវុសោ! ខ្ញុំត្រូវហើយ នូវអាបត្តិបាដិទេសនីយ ដែលព្រះមានព្រះភាគទ្រង់តិះដៀល មិនជាទីសប្បាយ, ខ្ញុំសូមសម្តែងនូវអាបត្តិនោះចេញ” ។

២- ភិក្ខុទាំងឡាយ ដែលគេបាននិមន្តហើយ កំពុងឆាន់ក្នុងត្រកូលទាំងឡាយ ។ បើមានភិក្ខុនីមកឈរបង្គាប់គេជិតទីនោះថា “អ្នកទាំងឡាយចូរមកប្រគេនសម្លក្នុងទីនេះ, ចូរមកប្រគេនបាយក្នុងទីនេះ” ។ ភិក្ខុទាំងនោះត្រូវបណ្តេញភិក្ខុនីនោះចេញ ដោយពាក្យថា “នែនាង! នាងចូរថយចេញទៅសិនទម្រាំតែពួកភិក្ខុឆាន់រួច” ។ សូម្បីភិក្ខុមួយរូប បើមិនបានបណ្តេញភិក្ខុនីនោះ ដោយពាក្យថា “នែនាង! នាងចូរថយចេញទៅសិនទម្រាំតែពួកភិក្ខុឆាន់រួច” ដូច្នេះទេ, ភិក្ខុទាំងនោះត្រូវសម្តែង ( អាបត្តិបាដិទេសនីយ ) ថា “ម្នាលអាវុសោ! យើងត្រូវហើយ នូវអាបត្តិឈ្មោះបាដិទេសនីយ ដែលព្រះមានព្រះភាគ ទ្រង់តិះដៀលមិនជាទីសប្បាយ, យើងសូមសម្តែងនូវអាបត្តិនោះចេញ” ។

៣- យានិ ខោ បន តានិ សេក្ខសម្មតានិ កុលានិ, យោ បន ភិក្ខុ តថារូបេសុ សេក្ខសម្មតេសុ កុលេសុ បុព្វេ អនិមន្តិតោ អគិលានោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទេយ្យ វា ភុញ្ជេយ្យ វា, បដិទេសេតព្វំ តេន ភិក្ខុនា: គារយ្ហំ អាវុសោ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេសនីយំ, តំ បដិទេសេមីតិ ។

៤- យានិ ខោ បន តានិ អារញ្ញកានិ សេនាសនានិ សាសង្កសម្មតានិ សប្បដិភយានិ, យោ បន ភិក្ខុ តថារូបេសុ សេនាសនេសុ វិហរន្តោ បុព្វេ អប្បដិសំវិទិតំ ខាទនីយំ វា ភោជនីយំ វា អជ្ឈារាមេ សហត្ថា បដិគ្គហេត្វា អគិលានោ ខាទេយ្យ វា ភុញ្ជេយ្យ វា, បដិទេសេតព្វំ តេន ភិក្ខុនា: គារយ្ហំ អាវុសោ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេសនីយំ, តំ បដិទេសេមីតិ ។

៣ - ត្រកូលទាំងឡាយណា ដែលសង្ឃបានសន្មតថា ជាសេក្ខត្រកូលហើយ , បើភិក្ខុណាមួយ ឥតបានគេនិមន្តមុនហើយឥតទាំងមានជំងឺ បានទទួលយកខាទនីយាហារ ឬ ភោជនីយាហារដោយដៃរបស់ខ្លួន អំពីពួកត្រកូលដែលសង្ឃបានសន្មតថាជាសេក្ខត្រកូលបែបនោះហើយ យកមកទំពាស៊ីឬបរិភោគ, ភិក្ខុនោះត្រូវសម្តែង (អាបត្តិបាដិទេសនីយ) ថា “ ម្នាលអាវុសោ! ខ្ញុំត្រូវហើយនូវអាបត្តិបាដិទេសនីយ ដែលព្រះមានព្រះភាគទ្រង់តិះដៀលមិនជាទីសប្បាយៈ, ខ្ញុំសូមសម្តែងនូវអាបត្តិនោះចេញ ” ។

៤ - ទីសេនាសនៈទាំងឡាយណា ដែលមាននៅក្នុងព្រៃ ដែលគេសន្មតថាជាទីប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខ, ភិក្ខុណាមួយនៅក្នុងទីសេនាសនៈទាំងឡាយ បែបនោះមិនមានជំងឺ បានទទួលយកខាទនីយាហារឬភោជនីយាហារ ដែលគេមិនបានឲ្យដំណឹងជាមុន ដោយដៃរបស់ខ្លួនក្នុងអារាមយកមកទំពា ស៊ី ឬបរិភោគ , ភិក្ខុនោះត្រូវសម្តែង ( អាបត្តិបាដិទេសនីយ ) ថា “ម្នាលអាវុសោ! ខ្ញុំត្រូវហើយ នូវអាបត្តិបាដិទេសនីយ ដែលព្រះមានព្រះភាគទ្រង់តិះដៀល មិនជាទីសប្បាយ , ខ្ញុំសូមសម្តែងនូវអាបត្តិនោះចេញ ” ។

ឧទ្ទិដ្ឋា ខោ អាយស្មន្តោ ចត្តារោ បាដិទេស-
នីយា ធម្មា ។

តត្ថាយស្មន្តេ បុច្ឆាមិ, កច្ចិត្ថ បរិសុទ្ធា ?
ទុតិយម្បិ បុច្ឆាមិ, កច្ចិត្ថ បរិសុទ្ធា ?
តតិយម្បិ បុច្ឆាមិ, កច្ចិត្ថ បរិសុទ្ធា ?
បរិសុទ្ធេត្ថាយស្មន្តោ, តស្មា តុណ្ហី ។
ឯវមេតំ ធារយាមិ ។

បាដិទេសនីយា និដ្ឋិតា ។

# និក្ការុទ្ទេស ក្នុងបាដិទេសនីយ

បពិត្រលោកអ្នកមានអាយុទាំងឡាយ, អាបត្តិបាដិទេសនីយទាំងបួន ខ្ញុំព្រះករុណាបានសម្តែងរួចហើយ ។

ខ្ញុំព្រះករុណា សូមសួរលោកអ្នកមានអាយុទាំងឡាយ ក្នុងអាបត្តិទាំងនោះ, លោកទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំព្រះករុណា សូមសួរជាគម្រប់ពីរផងទៀត, លោកទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំព្រះករុណា សូមសួរជាគម្រប់បីផងទៀត, លោកទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ ? លោកអ្នកមានអាយុទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធ ក្នុងអាបត្តិទាំងនុ៎ះហើយ, ព្រោះហេតុនោះបានជានៅស្ងៀម ។

ខ្ញុំព្រះករុណា សូមចាំទុកនូវហេតុនេះ ដោយកិរិយានៅស្ងៀមយ៉ាងនេះ ។

ចប់អាបត្តិបាដិទេសនីយ ។

ឥមេ ខោ បនាយស្មន្តោ ( បញ្ចសត្តតិ [១] ) សេខិយា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

១- បរិមណ្ឌលំ និវាសេស្សាមីតិ សិក្ខា ករណីយា ។១។

២- បរិមណ្ឌលំ បារុបិស្សាមីតិ សិក្ខា ករណីយា។២។

៣- សុប្បដិច្ឆន្នោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។៣។

៤- សុប្បដិច្ឆន្នោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។៤។

៥- សុសំវុតោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។៥។

៦- សុសំវុតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។៦។

៧- ឱក្ខិត្តចក្ខុ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។៧។

៨- ឱក្ខិត្តចក្ខុ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។៨។

---

១ បាលីក្នុងវង់ក្រចកនេះ បញ្ចូលថ្មីដើម្បីប្រាប់ឲ្យដឹងចំនួន សេខិយសិក្ខាបទ ៧៥, ក្នុងវិនយបិដកមិនមានបាលីនេះទេ ។

# ភិក្ខុបាតិមោក្ខប្រែ

បពិត្រលោកអ្នកមានអាយុទាំងឡាយ ! វត្តដែលគប្បីសិក្សាទាំងឡាយ (បិក្ខសិបព្រាំ) នេះឯង មកកាន់ឧទ្ទេស (គឺការសម្ដែងឡើង) ។

១- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សា(១) ថា " អាត្មាអញ នឹងស្លៀកស្បង់ឲ្យជាបរិមណ្ឌល " ។

២. ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងដណ្ដប់ (គឺគ្រង) ចីវរឲ្យជាបរិមណ្ឌល " ។

៣. ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងបិទបាំងកាយ (គឺឃ្លុំ) ឲ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ " ។

៤- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងបិទបាំងកាយ (គឺឃ្លុំ) ឲ្យល្អ អង្គុយក្នុងចន្លោះផ្ទះ " ។

៥- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងសង្រួមឲ្យល្អដើរទៅក្នុងចន្លោះផ្ទះ" ។

៦- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងសង្រួមឲ្យល្អ អង្គុយក្នុងចន្លោះផ្ទះ " ។

៧- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមានភ្នែកសំឡឹងចុះដើរទៅក្នុងចន្លោះផ្ទះ " ។

៨- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមានភ្នែកសំឡឹងចុះអង្គុយក្នុងចន្លោះផ្ទះ " ។

---

១. ពាក្យនេះជាសេចក្ដីថា បើភិក្ខុណាមួយមិនអើពើ មិនប្រព្រឹត្តតាមទេ, ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

៩- ន ឧក្ខិត្តកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។៩។

១០- ន ឧក្ខិត្តកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។១០។

បរិមណ្ឌលវគ្គោ បឋមោ ។

១១- ន ឧជ្ជគ្ឃិកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។១។

១២- ន ឧជ្ជគ្ឃិកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។២។

១៣- អប្បសទ្ទោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។៣។

១៤- អប្បសទ្ទោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។៤។

១៥- ន កាយប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។៥។

១៦- ន កាយប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។៦។

# វិន្ទាវរទ្ធស ក្ដុខសេខិយ

៩- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនសើចសើចធំៗ ដើរទៅក្នុងចន្លោះផ្ទះ " ។

១០ . ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនសើចធំៗ អង្គុយក្នុងចន្លោះផ្ទះ " ។

## បរិមណ្ឌលវគ្គទី ១ ( ចប់ )

១១. ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនសើចខ្លាំងដើរទៅក្នុងចន្លោះផ្ទះ " ។

១២ . ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនសើចខ្លាំងអង្គុយក្នុងចន្លោះផ្ទះ " ។

១៣. ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងនិយាយសម្លេងតិចដើរទៅក្នុងចន្លោះផ្ទះ " ។

១៤. ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងនិយាយសម្លេងតិចអង្គុយក្នុងចន្លោះផ្ទះ " ។

១៥. ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនគ្រវែងកាយ ដើរទៅក្នុងចន្លោះផ្ទះ " ។

១៦. ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនគ្រវែងកាយ អង្គុយក្នុងចន្លោះផ្ទះ " ។

១៧- ន ពាហុប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។ ៧ ។

១៨- ន ពាហុប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។ ៨ ។

១៩- ន សីសប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។ ៩ ។

២០- ន សីសប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។ ១០ ។

ឧជ្ជគ្ឃិកវគ្គោ ទុតិយោ ។

២១- ន ខម្ភកតោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។ ១ ។

២២- ន ខម្ភកតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។ ២ ។

២៣- ន ឱគុណ្ឋិតោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។ ៣ ។

២៤- ន ឱគុណ្ឋិតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។ ៤ ។

១៧- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនយោលដៃដើរទៅក្នុងចន្លោះផ្ទះ " ។

១៨- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនគ្រវាដៃអង្គុយ ក្នុងចន្លោះផ្ទះ " ។

១៩- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនអង្រួនក្បាល ដើរទៅក្នុងចន្លោះផ្ទះ " ។

២០- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនអង្រួនក្បាល អង្គុយក្នុងចន្លោះផ្ទះ " ។

## ឧជ្ជគ្ឃិកវគ្គទី ២ ( ចប់ ) ។

២១- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនយកដៃស្ទឹមចង្កេះ ដើរទៅក្នុងចន្លោះផ្ទះ " ។

២២- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនយកដៃស្ទឹមចង្កេះ អង្គុយក្នុងចន្លោះផ្ទះ " ។

២៣- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនទទូរក្បាល ដើរទៅក្នុងចន្លោះផ្ទះ " ។

២៤- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនទទូរក្បាល អង្គុយក្នុងចន្លោះផ្ទះ " ។

២៥- ន ឧក្កុដិកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។ ៥ ។

២៦- ន បល្លត្ថិកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។ ៦ ។

ឆព្វីសតិ សារុប្បា ។

១- សក្កច្ចំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។ ៧ ។

២- បត្តសញ្ញី បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។ ៨ ។

៣- សមសូបកំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។ ៩ ។

៤- សមតិត្តិកំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។ ១០ ។

ខម្ភកតវគ្គោ តតិយោ ។

៥- សក្កច្ចំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។ ១ ។

៦- បត្តសញ្ញី បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។ ២ ។

២៥_ ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា " អាត្មាអញ នឹងមិនចំណេតជើង ដើរទៅក្នុងចន្លោះផ្ទះ " ។

២៦_ ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា " អាត្មាអញ នឹងមិនអង្គុយស្រពោមក្បាលផង ក្នុងចន្លោះផ្ទះ " ។

## ( ចប់ ) សារុប្បវគ្គប្រាំមួយ ។

១_ ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា " អាត្មាអញ នឹងទទួលអាហារបិណ្ឌបាតដោយគោរព " ។

២_ ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា " អាត្មាអញ នឹងសម្គាល់តែក្នុងបាត្រទទួលបិណ្ឌបាត ។

៣- ភិក្ខុគប្បីធ្វើសេចក្តីសិក្សា " អាត្មាអញ នឹងទទួលបិណ្ឌបាត ឲ្យល្មមគ្នានឹងសម្ល " ។

៤_ ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា " អាត្មាអញ នឹងទទួលបិណ្ឌបាត ឲ្យស្មើត្រឹមកណ្តាប់មាត់បាត្រ " ។

## ខមុក្កវគ្គទី ៣ ( ចប់ ) ។

៥_ ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា " អាត្មាអញ នឹងឆាន់បិណ្ឌបាតដោយគោរព " ។

៦_ ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា " អាត្មាអញ នឹងសម្គាល់តែក្នុងបាត្រឆាន់បិណ្ឌបាត ។

៧- សបទានំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។៣។

៨- សមសូបកំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។៤។

៩- ន ថូបកតោ ឱមទ្ទិត្វា បិណ្ឌបាតំ ភុញ្ជិស្សា-មីតិ សិក្ខា ករណីយា ។៥។

១០- ន សូបំ វា ព្យញ្ជនំ វា ឱទនេន បដិច្ឆាទេស្សា-មិ ភិយ្យោកម្យតំ ឧបាទាយាតិ សិក្ខា ករណីយា ។៦។

១១- ន សូបំ វា ឱទនំ វា អគិលានោ អត្ត-នោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។៧។

១២- ន ឧជ្ឈានសញ្ញី បរេសំ បត្តំ ឱលោកេ-ស្សាមីតិ សិក្ខា ករណីយា ។៨។

១៣- នាតិមហន្តំ កពឡំ ករិស្សាមីតិ សិក្ខា ករណីយា ។៩។

១៤- បរិមណ្ឌលំ អាលោបំ ករិស្សាមីតិ សិក្ខា ករណីយា ។១០។

សក្កច្ចវគ្គោ ចតុត្ថោ ។

៧- ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា “ អាត្មាអញ នឹងឆាន់បិណ្ឌបាត រាប ឲ្យស្មើ ” ។

៨- ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា “ អាត្មាអញ នឹងឆាន់បិណ្ឌបាតឲ្យល្មម គ្នានឹងសម្ល ” ។

៩- ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា “ អាត្មាអញ នឹងមិនប្រមូលត្រង់កំពូលបាយ ហើយឆាន់បិណ្ឌបាត ” ។

១០- ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា “ អាត្មាអញ នឹងមិនកកាយបាយលុប សម្ល ឬ ម្ហូប ព្រោះអាស្រ័យសេចក្តីល្មោភច្រើន ” ។

១១- ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា “ អាត្មាអញ ឥតមានជំងឺនឹងមិនសុំសម្ល ឬបាយ ដើម្បីប្រយោជន៍ខ្លួនឯងហើយឆាន់ ” ។

១២- ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា “ អាត្មាអញ នឹងមិនប្រុងលើកទោស ហើយ សម្លឹងមើលបាត្រពួកភិក្ខុដទៃ ” ។

១៣- ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា “ អាត្មាអញ នឹងមិនធ្វើពំនូតបាយ ឲ្យធំពេក ” ។

១៤- ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា “ អាត្មាអញ នឹងធ្វើពំនូតបាយ ឲ្យជាបរិ-មណ្ឌលគឺឲ្យមូល ” ។

សក្កច្ចវគ្គទី ៤ ( ចប់ ) ។

១៥- ន អនាហដេ កពឡេ[១]មុខទ្វារំ វិវរិស្សាមីតិ សិក្ខា ករណីយា ។ ១ ។

១៦- ន ភុញ្ជមានោ សព្វំ ហត្ថំ មុខេ បក្ខិបិស្សាមីតិ សិក្ខា ករណីយា ។ ២ ។

១៧- ន សកពឡេន មុខេន ព្យាហរិស្សាមីតិ សិក្ខា ករណីយា ។ ៣ ។

១៨- ន បិណ្ឌុក្ខេបកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។ ៤ ។

១៩- ន កពឡាវច្ឆេទកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។ ៥ ។

២០- ន អវគណ្ឌការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។ ៦ ។

២១- ន ហត្ថនិទ្ធុនកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។ ៧ ។

២២- ន សិត្ថាវការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។ ៨ ។

២៣- ន ជិវ្ហានិច្ឆារកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។ ៩ ។

២៤- ន ចបុចបុការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។ ១០ ។

កពឡវគ្គោ បញ្ចមោ ។

---

[១] ជា កពឡេ ក៏មាន ។ កពឡនិង កពឡ ប្រើបានដូចគ្នា ។

# សិក្ខាបទ ក្នុងសេខិយ

១៥. ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា "អាត្មាអញ, កាលពំនូតបាយមិនទាន់មកដល់, នឹងមិនបើកទ្វារមាត់ចាំ" ។

១៦. ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា "អាត្មាអញ កាលឆាន់នឹងមិនញាត់ម្រាមដៃទាំងអស់ ចូលទៅក្នុងមាត់" ។

១៧. ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា "អាត្មាអញ នឹងមិននិយាយទាំងពំនូតបាយនៅក្នុងមាត់" ។

១៨. ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា "អាត្មាអញនឹងមិនឆាន់ បោះដុំបាយទៅក្នុងមាត់" ។

១៩. ភិក្ខុគប្បីធ្វើសេក្តីសិក្សាថា "អាត្មាអញ នឹងមិនឆាន់កាត់ពំនូតបាយ" ។

២០. ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា "អាត្មាអញ នឹងមិនឆាន់បៀមពំនូតបាយក្នុងថ្ពាល់" ។

២១. ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា "អាត្មាអញ នឹងមិនឆាន់រលាស់ដៃ" ។

២២. ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា "អាត្មាអញ នឹងមិនឆាន់ធ្វើគ្រាប់បាយឲ្យជ្រុះរោយរាយ" ។

២៣. ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា "អាត្មាអញ នឹងមិនឆាន់លៀនអណ្ដាត" ។

២៤. ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា "អាត្មាអញ នឹងមិនឆាន់ធ្វើសូរឲ្យឮផ្ចប់ៗ" ។

កពឡវគ្គទី ៥ (ចប់) ។

២៥- ន សុរុសុរុការកំ ភុញ្ជិស្សាមីតិ សិក្ខា
ករណីយា ។ ១ ។

២៦- ន ហត្ថនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា
ករណីយា ។ ២ ។

២៧- ន បត្តនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា
ករណីយា ។ ៣ ។

២៨- ន ឱដ្ឋនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា
ករណីយា ។ ៤ ។

២៩- ន សាមិសេន ហត្ថេន បានីយថាលកំ
បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។ ៥ ។

៣០- ន សសិត្ថកំ បត្តធោវនំ អន្តរឃរេ ឆឌ្ឌេ-
ស្សាមីតិ សិក្ខា ករណីយា ។ ៦ ។

សមត្តឹស ភោជនប្បដិសំយុត្តា ។

១- ន ឆត្តបាណិស្ស អគិលានស្ស ធម្មំ ទេសិ-
ស្សាមីតិ សិក្ខា ករណីយា ។ ៧ ។

២- ន ទណ្ឌបាណិស្ស អគិលានស្ស ធម្មំ ទេសិ-
ស្សាមីតិ សិក្ខា ករណីយា ។ ៨ ។

២៥. ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា "អាត្មាអញ នឹងមិនឆាន់ ធ្វើសូរឡឺ ឮក្រុកៗ" ។

២៦. ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា "អាត្មាអញ នឹងមិនឆាន់លិទ្ធដៃ" ។

២៧. ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា "អាត្មាអញ នឹងមិនឆាន់លិទ្ធបាត្រ" ។

២៨. ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា "អាត្មាអញ នឹងមិនឆាន់លិទ្ធបបូរមាត់" ។

២៩. ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា "អាត្មាអញ មានដៃប្រឡាក់ដោយអាមិស នឹងមិនទទួលភាជនៈទឹកសម្រាប់ឆាន់" ។

៣០. ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា "អាត្មាអញ នឹងមិនចាក់ទឹកលាងបាត្រ ទាំងគ្រាប់បាយ ក្នុងចន្លោះផ្ទះ" ។

(ចប់) ភោជនប្បដិសំយុត្ត ៣០ គត់ ។

១. ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា "អាត្មាអញ នឹងមិនសម្តែងធម៌ដល់មនុស្ស គ្មានជំងឺ មានឆត្រក្នុងដៃ" ។

២. ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា "អាត្មាអញ នឹងមិនសម្តែងធម៌ដល់មនុស្ស គ្មានជំងឺ មានដំបងក្នុងដៃ" ។

៣- ន សត្ថបាណិស្ស អគ្គិលានស្ស ធម្មំ ទេសិ-ស្សាមីតិ សិក្ខា ករណីយា ។៩។

៤- ន អាវុធបាណិស្ស អគ្គិលានស្ស ធម្មំ ទេសិ-ស្សាមីតិ សិក្ខា ករណីយា ។១០។

សុរុសុរុវគ្គោ ឆដ្ឋោ ។

៥- ន បាទុការុឡ្ហស្ស អគ្គិលានស្ស ធម្មំ ទេសិ-ស្សាមីតិ សិក្ខា ករណីយា ។១។

៦- ន ឧបាហនារុឡ្ហស្ស អគ្គិលានស្ស ធម្មំ ទេ-សិស្សាមីតិ សិក្ខា ករណីយា ។២។

៧- ន យានគតស្ស អគ្គិលានស្ស ធម្មំ ទេសិ-ស្សាមីតិ សិក្ខា ករណីយា ។៣។

៨- ន សយនគតស្ស អគ្គិលានស្ស ធម្មំ ទេសិ-ស្សាមីតិ សិក្ខា ករណីយា ។៤។

៩- ន បល្លត្ថិកាយ និសិន្នស្ស អគ្គិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។៥។

១០- ន វេឋិតសីសស្ស អគ្គិលានស្ស ធម្មំ ទេ-សិស្សាមីតិ សិក្ខា ករណីយា ។៦។

៣- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា "អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្ស គ្មានជំងឺ មានគ្រឿងសស្ត្រាក្នុងដៃ " ។

៤- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា "អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្ស គ្មានជំងឺ មានគ្រឿងអាវុធក្នុងដៃ " ។

## សុរុសុរវគ្គទី ៦ (ចប់) ។

៥- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្ស គ្មានជំងឺ ពាក់ទ្រនាប់ជើង " ។

៦- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្ស គ្មានជំងឺ ពាក់ស្បែកជើង " ។

៧- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្ស គ្មានជំងឺ នៅលើយាន " ។

៨- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនសម្ដែងធម៌ ដល់មនុស្សគ្មានជំងឺ នៅលើដំណេក " ។

៩- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនសម្ដែងធម៌ ដល់មនុស្សគ្មានជំងឺ អង្គុយក្រហោមក្បាលជង្គង់ " ។

១០- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញ នឹងមិនសម្ដែងធម៌ ដល់មនុស្សគ្មានជំងឺ ពួកក្បាល " ។

១១- ន ឱគុណ្ឋិតសីសស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។៧។

១២- ន ឆមាយំ និសីទិត្វា អាសនេ និសិន្នស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា។៨។

១៣- ន នីចេ អាសនេ និសីទិត្វា ឧច្ចេ អាសនេ និសិន្នស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។៩។

១៤- ន ឋិតោ និសិន្នស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។១០។

១៥- ន បច្ឆតោ គច្ឆន្តោ បុរតោ គច្ឆន្តស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។១១។

១៦- ន ឧប្បថេន គច្ឆន្តោ បថេន គច្ឆន្តស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា។១២។

សោឡស ធម្មទេសនាបដិសំយុត្តា ។

១- ន ឋិតោ អគិលានោ ឧច្ចារំ វា បស្សាវំ វា ករិស្សាមីតិ សិក្ខា ករណីយា ។ ១៣ ។

២- ន ហរិតេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករិស្សាមីតិ សិក្ខា ករណីយា។១៤។

១១- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា “ អាត្មាអញនឹងមិនសម្ដែងធម៌ ដល់មនុស្សគ្មានជំងឺ ទទ្បរក្បាល ” ។

១២- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា “ អាត្មាអញនឹងមិនអង្គុយផ្ទាល់ នឹងផែនដី ហើយសម្ដែងធម៌ ដល់មនុស្សគ្មានជំងឺ អង្គុយលើអាសនៈ ” ។

១៣- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា “ អាត្មាអញ នឹងមិនអង្គុយលើអាសនៈទាប ហើយសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ អង្គុយលើអាសនៈខ្ពស់ ” ។

១៤- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា “ អាត្មាអញនឹងមិនឈរសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ ដែលអង្គុយ ” ។

១៥- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា “ អាត្មាអញ នឹងមិនដើរខាងក្រោយ សម្ដែងធម៌ដល់មនុស្សគ្មានជំងឺ ដើរខាងមុខ ” ។

១៦- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា “ អាត្មាអញនឹងមិនដើរក្រៅផ្លូវ សម្ដែងធម៌ដល់មនុស្សគ្មានជំងឺ ដើរតាមផ្លូវ ” ។

## (ចប់) ទេសនាបដិសំយុត្ត ១៦ ។

១- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា “ អាត្មាអញគ្មានជំងឺ នឹងមិនឈរបន្ទោបង់ឧច្ចារៈឬបស្សាវៈ ” ។

២- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា “ អាត្មាអញគ្មានជំងឺ នឹងមិនបន្ទោបង់ឧច្ចារៈឬបស្សាវៈ ឬក៏ស្ដោះទឹកមាត់លើស្មៅស្រស់ ឬឈើស្រស់ ” ។

៣- ន ឧទកេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករិស្សាមីតិ សិក្ខា ករណីយា ។១៥។

តយោ បកិណ្ណកា និដ្ឋិតា ។

បាទុកាវគ្គោ សត្តមោ ។

ឧទ្ទិដ្ឋា ខោ អាយស្មន្តោ ( បញ្ចសត្តតិ ) សេខិយា ធម្មា ។

តត្ថាយស្មន្តេ បុច្ឆាមិ , កច្ចិត្ថ បរិសុទ្ធា ?
ទុតិយម្បិ បុច្ឆាមិ , កច្ចិត្ថ បរិសុទ្ធា ?
តតិយម្បិ បុច្ឆាមិ , កច្ចិត្ថ បរិសុទ្ធា ?
បរិសុទ្ធេត្ថាយស្មន្តោ , តស្មា តុណ្ហី ។
ឯវមេតំ ធារយាមិ ។

សេខិយា និដ្ឋិតា ។

៣- ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា " អាត្មាអញគ្មានជំងឺ នឹងមិនបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬក៏ស្ដោះទឹកមាត់លើទឹក " ។

## ចប់បកិណ្ណកៈ ៣

## បាទុកាវគ្គទី ៧ (ចប់) ។

បពិត្រលោកអ្នកមានអាយុទាំងឡាយ, វត្ថុដែលគប្បីសិក្សាទាំង ( ចិតសិបប្រាំ ) ខ្ញុំព្រះករុណាបានសម្ដែងរួចហើយ ។ ខ្ញុំព្រះករុណាសូមសួរលោកអ្នកមានអាយុទាំងឡាយក្នុងសេខិយវត្ថុទាំងនោះ, លោកទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំព្រះករុណាសូមសួរជាគម្រប់ពីរដងទៀត, លោកទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ? ខ្ញុំព្រះករុណា សូមសួរជាគម្រប់បីដងទៀត, លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? លោកអ្នកមានអាយុទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធ ក្នុងសេខិយវត្ថុទាំងនុ៎ះហើយ, ព្រោះហេតុនោះ បានជានៅស្ងៀម ។ ខ្ញុំព្រះករុណា សូមចាំទុកនូវហេតុនេះ ដោយកិរិយានៅស្ងៀមយ៉ាងនេះ ។

## ចប់សេខិយវគ្គ ។

ឥមេ ខោ បនាយស្មន្តោ សត្ត អធិករណសមថា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

ឧប្បន្នុប្បន្នានំ អធិករណានំ សមថាយ វូបសមាយ សម្មុខាវិនយោ ទាតព្វោ, សតិវិនយោ ទាតព្វោ, អមូឡ្ហវិនយោ ទាតព្វោ, បដិញ្ញាយ ការេតព្វំ, យេភុយ្យសិកា, តស្ស បាបិយសិកា, តិណវត្ថារកោតិ ។

ឧទ្ទិដ្ឋា ខោ អាយស្មន្តោ សត្ត អធិករណសមថា ធម្មា ។

# ចិត្តារុទ្ទេសក្នុងអធិករណសមថៈ

បពិត្រលោកអ្នកមានអាយុទាំងឡាយ , ធម៌សម្រាប់រម្ងាប់ នូវអធិករណ៍ទាំងឡាយប្រាំពីរយ៉ាងនេះឯង មកកាន់ឧទ្ទេស ។

ដើម្បីរម្ងាប់ ដើម្បីផ្សះផ្សារ នូវអធិករណ៍ទាំងឡាយដែលកើតឡើងហើយ សង្ឃត្រូវឲ្យសម្មុខាវិន័យ ១,[១] សង្ឃត្រូវអោយសតិវិន័យ ១,[២] សង្ឃត្រូវឲ្យអមូឡ្ហវិន័យ ១,[៣] សង្ឃត្រូវវិនិច្ឆ័យ តាមពាក្យថ្លែងជារបស់ភិក្ខុអ្នកឆ្លើយ ១, សង្ឃត្រូវវិនិច្ឆ័យ តាមពាក្យខាងច្រើនជាប្រមាណ ១, សង្ឃត្រូវធ្វើទោសតាមកម្មរបស់ភិក្ខុដែលប្រព្រឹត្តលាមក ១, សង្ឃត្រូវវិនិច្ឆ័យឲ្យពួកភិក្ខុដែលវិវាទទាស់ទែងគ្នា លុបលាងចំពោះ ហើយអត់ឱនគ្នាទៅវិញទៅមក ដូចជាគ្របម្រុក លាមកដោយស្មៅ ១ ។

បពិត្រលោកអ្នកមានអាយុទាំងឡាយ, ធម៌សម្រាប់រម្ងាប់ នូវអធិករណ៍ទាំងប្រាំពីរយ៉ាង ខ្ញុំព្រះករុណាបានសម្ដែងរួចហើយ ។

---

១-ធម្មវាទីកឲ្យល់ច្បាស់អធម្មវាទីថា "នេះជាធម៌, នេះជាវិន័យ, នេះជាសត្ថុសាសនៈ, លោកចូរកាន់តាមធម៌វិន័យនេះចុះ" ការរម្ងាប់អធិករណ៍នេះឈ្មោះសម្មុខាវិន័យ ។ ២- សង្ឃត្រូវឲ្យសតិវិន័យ ដល់ភិក្ខុដែលជាព្រះខីណាស្រព បរិសុទ្ធចាកអាបត្តិដែលមានភិក្ខុដទៃចោទ ។ ៣- សង្ឃត្រូវឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុដែលជាឆ្កួតហើយ ដោយញត្តិចតុត្ថកម្មវាចា ដើម្បីមិនឲ្យភិក្ខុណាមួយចោទភិក្ខុនោះ ដោយអាបត្តិអ្វីឡើយ ។

(មានសេចក្ដីពិស្ដារក្នុងសមថក្ខន្ធកចុល្លវគ្គវិន័យបិដកភាគទី ១០)

តត្ថាយស្មន្តេ បុច្ឆាមិ , កច្ចិត្ថ បរិសុទ្ធា ?

ទុតិយម្បិ បុច្ឆាមិ , កច្ចិត្ថ បរិសុទ្ធា ?

តតិយម្បិ បុច្ឆាមិ , កច្ចិត្ថ បរិសុទ្ធា ?

បរិសុទ្ធេត្ថាយស្មន្តោ , តស្មា តុណ្ហី ។

ឯវមេតំ ធារយាមិ ។

**អធិករណសមថា ធម្មា និដ្ឋិតា ។**

# ភិក្ខុបាតិមោក្ខប្រែ

ខ្ញុំព្រះករុណា សូមសួរលោកអ្នកមានអាយុទាំងឡាយ ក្នុងធម៌ទាំងនោះ, លោកទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ ?

ខ្ញុំព្រះករុណា សូមសួរជាគម្រប់ពីរផងទៀត, លោកទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ ?

ខ្ញុំព្រះករុណា សូមសួរជាគម្រប់បីផងទៀត , លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? លោកអ្នកមានអាយុទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធក្នុងធម៌ទាំងនុ៎ះហើយ ។

ព្រោះហេតុនោះ បានជានៅស្ងៀម ។

ខ្ញុំព្រះករុណាសូមចាំទុក នូវហេតុនេះ ដោយកិរិយានៅស្ងៀមយ៉ាងនេះ ។

ចប់ធម៌សម្រាប់រម្ងាប់នូវអធិករណ៍ ។

ឧទ្ទិដ្ឋំ ខោ អាយស្មន្តោ និទានំ,

ឧទ្ទិដ្ឋា ចត្តារោ បារាជិកា ធម្មា,

ឧទ្ទិដ្ឋា តេរស សង្ឃាទិសេសា ធម្មា,

ឧទ្ទិដ្ឋា ទ្វេ អនិយតា ធម្មា,

ឧទ្ទិដ្ឋា តឹស និស្សគ្គិយា បាចិត្តិយា ធម្មា,

ឧទ្ទិដ្ឋា ទ្វេនវុតិ បាចិត្តិយា ធម្មា,

ឧទ្ទិដ្ឋា ចត្តារោ បាដិទេសនីយា ធម្មា,

ឧទ្ទិដ្ឋា ( បញ្ចសត្តតិ ) សេខិយា ធម្មា,

ឧទ្ទិដ្ឋា សត្ត អធិករណសមថា ធម្មា ។

ឯត្តកំ តស្ស ភគវតោ សុត្តាគតំ សុត្តបរិយាបន្នំ អន្វឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតិ ។ តត្ថ សព្វេហេវ សមគ្គេហិ សម្មោទមានេហិ អវិវទមានេហិ សិក្ខិតព្វន្តិ ។

វិត្ថារុទ្ទេសោ និដ្ឋិតោ (១) ។

ភិក្ខុបាតិមោក្ខំ និដ្ឋិតំ ។

---

១ បាលីនេះ ល្បាប់ខ្លះមាន ខ្លះគ្មាន, ក្រកោរសូធ្យក៏បាន មិនបាច់សូធ្យក៏បាន ។

# និគ្គមនុទ្ទេស ក្នុងភិក្ខុឧទ្ទេស

បពិត្រលោកអ្នកមានអាយុទាំងឡាយ, និទានខ្ញុំព្រះករុណាបានសម្ដែងរួចហើយ, អាបត្តិបារាជិកទាំង ៤ ខ្ញុំព្រះករុណាបានសម្ដែងរួចហើយ, អាបត្តិសង្ឃាទិសេសទាំង ១៣ ខ្ញុំព្រះករុណាបានសម្ដែងរួចហើយ, ធម៌ឈ្មោះអនិយតទាំង ២ ខ្ញុំព្រះករុណាបានសម្ដែងរួចហើយ, អាបត្តិនិស្សគ្គិយបាចិត្តិយទាំង ៣០ ខ្ញុំព្រះករុណាបានសម្ដែងរួចហើយ, អាបត្តិបាចិត្តិយ(១) ទាំង ៩២ ខ្ញុំព្រះករុណា បានសម្ដែងរួចហើយ, អាបត្តិបាដិទេសនីយទាំង ៤ ខ្ញុំព្រះករុណា បានសម្ដែងរួចហើយ, សេខិយវត្តទាំង (៧៥) ខ្ញុំព្រះករុណា បានសម្ដែងរួចហើយ, ធម៌សម្រាប់រម្ងាប់នូវអធិករណ៍ទាំង ៧ យ៉ាង ខ្ញុំព្រះករុណាបានសម្ដែងរួចហើយ ។ សិក្ខាបទមានប្រមាណប៉ុណ្ណោះ របស់ព្រះមានព្រះភាគអង្គនោះមកហើយក្នុងសូត្រ (មាតិកា) រាប់បញ្ចូលហើយក្នុងសូត្រ មកកាន់ឧទ្ទេស (គឺការសម្ដែងបាតិមោក្ខ) រាល់កន្លះខែ ។ លោកអ្នកមានអាយុគ្រប់អង្គ គប្បីព្រមព្រៀងគ្នា គប្បីរីករាយនឹងគ្នា កុំវិវាទទាស់ទែងគ្នា គប្បីសិក្សាក្នុងសិក្ខាបទទាំងឡាយនោះ ។

ចប់ និគ្គមនុទ្ទេស ។

ចប់ ភិក្ខុបាតិមោក្ខ ។

---

១ សុទ្ធិកបាចិត្តិយ ។

# ការសម្តែងបាតិមោក្ខសង្ខេប

# សង្ខិត្តេន បាតិមោក្ខុទ្ទេសោ

## ការសម្តែងបាតិមោក្ខសង្ខេប

ព្រះបរមសាស្តាសម្មាសម្ពុទ្ធ ទ្រង់ត្រាស់អនុញ្ញាតដល់ភិក្ខុទាំងឡាយ មានសេចក្តីក្នុងឧបោសថក្ខន្ធកៈ ( មហាវគ្គ ) ថា

" ម្នាលភិក្ខុទាំងឡាយ! បាតិមោក្ខុទ្ទេសទាំងនេះមាន ៥ គឺ

ភិក្ខុត្រូវសម្តែង នូវនិទានហើយ សូត្រនូវឧទ្ទេសដ៏សេសសល់ដោយសុតបទ នេះជាបាតិមោក្ខុទ្ទេសទី ១ ។

ភិក្ខុត្រូវ សម្តែងនូវនិទានហើយ សម្តែងនូវបារាជិកទាំង ៤ ហើយសូត្រនូវឧទ្ទេសដ៏សេសសល់ ដោយសុតបទ នេះជាបាតិមោក្ខុទ្ទេសទី ២ ។

ភិក្ខុត្រូវសម្តែង នូវនិទានហើយ សម្តែងនូវបារាជិកទាំង៤ សង្ឃាទិសេសទាំង ១៣ ហើយ សូត្រនូវឧទ្ទេសដ៏សេសសល់ ដោយសុតបទ នេះជាបាតិមោក្ខុទ្ទេសទី ៣ ។

ភិក្ខុត្រូវសម្តែង នូវនិទានហើយ សម្តែងបារាជិកទាំង៤ សង្ឃាទិសេសទាំង ១៣ អនិយតទាំង ២ ហើយ សូត្រឧទ្ទេសដ៏សេសសល់ ដោយសុតបទ នេះជាបាតិមោក្ខុទ្ទេសទី ៤ ។ ឧទ្ទេសដោយពិស្តារ ជាបាតិមោក្ខុទ្ទេសទី ៥ " ។

ទោះបីមានបែបបាតិមោក្ខុទ្ទេសដល់ទៅប្រាំដូច្នេះ ក៏ភិក្ខុទាំងឡាយ ពុំត្រូវសម្តែងបាតិមោក្ខសង្ខេប តាមបែបបាតិមោក្ខុទ្ទេស ៤ យ៉ាងខាងដើម រាល់ថ្ងៃ

# ការសំដែងបាតិមោក្ខសង្ខេប

ឧទ្ទេសថយឡើយ ព្រោះមានព្រះពុទ្ធដីកាថា

" ម្នាលភិក្ខុទាំងឡាយ ! ភិក្ខុមិនត្រូវសំដែងបាតិមោក្ខ ដោយសង្ខេបទេ, ភិក្ខុណាសំដែងត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ! តថាគតអនុញ្ញាតឲ្យភិក្ខុសំដែងបាតិមោក្ខដោយសង្ខេប បានតែក្នុងពេលដែលមានអន្តរាយ ។ ឯអន្តរាយក្នុងពេលដែលសំដែងបាតិមោក្ខនោះ មាន ១០ យ៉ាងគឺ អន្តរាយអំពីព្រះរាជា គឺមានស្តេចយាងចូលមក ១, អន្តរាយអំពីចោរ គឺមានចោរចូលមកលុកលុយ ១, អន្តរាយអំពីភ្លើង គឺមានភ្លើងព្រៃឆេះរាលមក ឬភ្លើងឆេះផ្ទះជាដើមកើតឡើង ១, អន្តរាយអំពីទឹក គឺមានភ្លៀងខ្លាំងឬជំនន់ហូរមក ១, អន្តរាយអំពីមនុស្សគឺ មានមនុស្សច្រើនចូលមក ១, អន្តរាយអំពីអមនុស្ស គឺខ្មោចចូលភិក្ខុ ១,អន្តរាយអំពីសត្វសាហាវ ១, អន្តរាយអំពីសត្វទីឃជាតិ គឺសត្វលូនវារ ១, អន្តរាយដល់ជីវិត គឺភិក្ខុកើតជំងឺស្លាប់ ឬមានមនុស្សមានពៀរចង់សម្លាប់ភិក្ខុ ១, អន្តរាយដល់ព្រហ្មចារ្យ គឺមានមនុស្សមកចាប់ភិក្ខុផ្សឹក ១ ។

ម្នាលភិក្ខុទាំងឡាយ ! កាលបើពុំមានអន្តរាយបែបយ៉ាងនេះទេ , ត្រូវតែភិក្ខុសំដែងបាតិមោក្ខ ដោយពិស្តារ " ។

ការសំដែងបាតិមោក្ខសង្ខេប តាមបែបបាតិមោក្ខឧទ្ទេសទី ២ ដូច្នេះគឺ

ឧទ្ទិដ្ឋំ ខោ អាយស្មន្តោ និទានំ,

ឧទ្ទិដ្ឋា ចត្តារោ បារាជិកា ធម្មា, សុតា ខោ បនាយស្មន្តេហិ តេរស សង្ឃាទិសេសា ធម្មា, ទ្វេ អនិយតា ធម្មា, តឹស និស្សគ្គិយា បាចិត្តិយា ធម្មា, ទ្វេនវុតិ បាចិត្តិយា ធម្មា, ចត្តារោ បាដិទេសនីយា ធម្មា, (បញ្ចសត្តតិ) សេខិយា ធម្មា, សត្ត អធិករណ-សមថា ធម្មា ។

ឯត្តកំ តស្ស ភគវតោ សុត្តាគតំ សុត្តបរិយាបន្នំ អន្វឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតិ ។ តត្ថ សព្វេហេវ សមគ្គេហិ សម្មោទមានេហិ អវិវទមានេហិ សិក្ខិតព្វន្តិ ។

ភិក្ខុបាតិមោក្ខំ និដ្ឋិតំ ។

# ភិក្ខុប្បាតិមោក្ខប្រែ

បពិត្រលោកអ្នកមានអាយុទាំងឡាយ! និទាន ខ្ញុំព្រះករុណាបានសម្ដែងរួចហើយ, អាបត្តិបារាជិកទាំង ៤ ខ្ញុំព្រះករុណា បានសម្ដែងរួចហើយ, ចំណែកខាងអាបត្តិសង្ឃាទិសេសទាំង ១៣ , ធម៌ឈ្មោះអនិយតទាំង ២, អាបត្តិនិស្សគ្គិយបាចិត្តិយទាំង ៣០ , អាបត្តិបាចិត្តិយទាំង ៩២, អាបត្តិបាដិទេសនីយទាំង ៤, សេខិយវត្តទាំង (៧៥), ធម៌សម្រាប់រម្ងាប់នូវអធិករណ៍ទាំង ៧ យ៉ាង លោកអ្នកមានអាយុទាំងឡាយ សឹងធ្លាប់បានស្ដាប់ហើយ ។

សិក្ខាបទមានប្រមាណប៉ុណ្ណេះ របស់ព្រះមានព្រះភាគអង្គនោះ មកហើយក្នុងសុត្តៈ រាប់បញ្ចូលហើយក្នុងសុត្តៈ មកកាន់ឧទ្ទេស រាល់កន្លះខែ ។ លោកអ្នកមានអាយុគ្រប់អង្គ គប្បីព្រមព្រៀងគ្នា គប្បីរីករាយរកគ្នា កុំវិវាទទាស់ទែងគ្នា គប្បីសិក្សាក្នុងសិក្ខាបទទាំងឡាយនោះ ។

ចប់ ភិក្ខុប្បាតិមោក្ខ ។

# តិណ្ណន្នំ អញ្ញមញ្ញំ បារិសុទ្ធិឧបោសថោ

ព្រះមានព្រះភាគទ្រង់ត្រាស់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ, តថាគតអនុញ្ញាតឲ្យភិក្ខុបីរូបធ្វើបារិសុទ្ធិឧបោសថយ៉ាងនេះ គឺត្រូវភិក្ខុដែលឈ្លាសប្រតិពលញ៉ាំងភិក្ខុទាំងឡាយនោះ ឲ្យដឹងដោយពាក្យថា

**សុណន្តុ មេ អាយស្មន្តា, អជ្ជុបោសថោ បណ្ណរសោ[១] យទាយស្មន្តានំ បត្តកល្លំ, មយំ អញ្ញមញ្ញំ បារិសុទ្ធិឧបោសថំ ករេយ្យាម ។**

ត្រូវភិក្ខុចាស់ជាង ធ្វើឧត្តរាសង្គឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលនឹងភិក្ខុទាំងពីររូបនោះថា

**បរិសុទ្ធោ អហំ អាវុសោ! "បរិសុទ្ធោតិ" មំ ធារេថ។**

ត្រូវភិក្ខុខ្ចីជាងគ្នាជាលំដាប់ ធ្វើឧត្តរាសង្គឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលនឹងភិក្ខុទាំងពីររូបនោះ ថា

**បរិសុទ្ធោ អហំ ភន្តេ! "បរិសុទ្ធោតិ" មំ ធារេថ។**

ឯភិក្ខុដែលខ្ចីជាងគេបង្អស់ ក៏ត្រូវធ្វើអាការៈ ហើយពោលនឹងភិក្ខុទាំងពីររូបនោះ ដូចពាក្យភិក្ខុទី២នោះដែរ ។

---

១ បើថ្ងៃទី ១៤ រោច ត្រូវថា " ចាតុទ្ទសោ " ។

# បារិសុទ្ធិឧបោសថ

## ភិក្ខុបីរូប (ធ្វើ) បារិសុទ្ធិឧបោសថដល់គ្នានឹងគ្នា

សូមលោកអ្នកមានអាយុទាំងឡាយ ស្តាប់ខ្ញុំព្រះករុណា, ថ្ងៃនេះ ជាថ្ងៃឧបោសថទី ១៥(១) បើឧបោសថកម្មនេះមានកាលគួរ ដល់លោកអ្នកមានអាយុទាំងឡាយហើយ; យើងទាំងឡាយ ត្រូវធ្វើបារិសុទ្ធិឧបោសថដល់គ្នា នឹងគ្នា ។

ម្នាលអាវុសោទាំងឡាយ ! ខ្ញុំករុណាជាបុគ្គលបរិសុទ្ធ, ចូរលោកទាំងឡាយចាំទុកនូវខ្ញុំករុណា ថាជាបុគ្គលបរិសុទ្ធ ( ត្រូវថា ៣ ដង ) ។

ទាន ប្រោស ! ខ្ញុំព្រះករុណាជាបុគ្គលបរិសុទ្ធ, សូមលោកទាំងឡាយចាំទុកនូវខ្ញុំព្រះករុណា ថាជាបុគ្គលបរិសុទ្ធ ( ត្រូវថា ៣ ដង ) ។

---

១ បើថ្ងៃទី ១៤ រោច ត្រូវប្រែថាទី ១៤ ។

# ទ្វិន្នំ អញ្ញមញ្ញំ បារិសុទ្ធិឧបោសថោ

ព្រះមានព្រះភាគទ្រង់ត្រាស់អនុញ្ញាតថា "ម្នាលភិក្ខុទាំងឡាយ! តថាគតអនុញ្ញាតឲ្យភិក្ខុពីររូប ធ្វើបារិសុទ្ធិឧបោសថយ៉ាងនេះ គឺត្រូវភិក្ខុចាស់ជាង ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលនឹងភិក្ខុខ្ចីជាងថា

**បរិសុទ្ធោ អហំ អាវុសោ! "បរិសុទ្ធោតិ" មំ ធារេហិ ។**

ត្រូវភិក្ខុខ្ចីជាង ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលនឹងភិក្ខុចាស់ជាង ថា

**បរិសុទ្ធោ អហំ ភន្តេ! "បរិសុទ្ធោតិ" មំ ធារេថ ។**

# បារិសុទ្ធិឧបោសថ

ភិក្ខុពីររូប ( ធ្វើ ) បារិសុទ្ធិឧបោសថដល់គ្នា នឹងគ្នា

ម្នាលអាវុសោ! ខ្ញុំករុណាជាបុគ្គលបរិសុទ្ធ, ចូរលោកចាំទុក នូវខ្ញុំករុណាថាជាបុគ្គលបរិសុទ្ធ ( គ្រាវថា ៣ ដង ) ។

ទានព្រោស ! ខ្ញុំព្រះករុណា ជាបុគ្គលបរិសុទ្ធ, សូមលោកចាំទុក នូវខ្ញុំព្រះករុណាថា ជាបុគ្គលបរិសុទ្ធ ( គ្រាវថា ៣ ដង ) ។

# អធិដ្ឋានឧបោសថ

## អធិដ្ឋាន ឧបោសថោ

## ឧបោសថដោយអធិដ្ឋាន

ព្រះមានបុណ្យទ្រង់ត្រាស់អនុញ្ញាតថា “ម្នាលភិក្ខុទាំងឡាយ, ក្នុងសាសនានេះ ភិក្ខុតែ ១ រូប នៅក្នុងអាវាសមួយ ក្នុងថ្ងៃឧបោសថនោះ ត្រូវភិក្ខុនោះ បោសសម្អាតទីកន្លែង ដែលភិក្ខុទាំងឡាយតែងត្រឡប់មកនៅអាស្រ័យ គឺ ឧដ្ឋាបនសាលាក្តី មណ្ឌបក្តី គល់ឈើក្តី រួចត្រូវចូលទៅតម្កល់ទឹកឆាន់, ទឹកប្រើប្រាស់ , ក្រាលអាសនៈ , អុជប្រទីបហើយត្រូវអង្គុយចាំ ។ បើភិក្ខុទាំងឡាយដទៃមក, ត្រូវភិក្ខុនោះ ធ្វើឧបោសថជាមួយនឹងភិក្ខុទាំងឡាយនោះ, បើភិក្ខុទាំងឡាយដទៃមិនមកទេ, ត្រូវភិក្ខុនោះអធិដ្ឋានឧបោសថ ថា :

**“ អជ្ជ មេ ឧបោសថោ”**

ប្រែថា “ ថ្ងៃនេះ ជាថ្ងៃឧបោសថ របស់អញ ” ។

បើមិនអធិដ្ឋានដូច្នេះទេ, ត្រូវអាបត្តិទុក្កដ ។

# សង្ឃប្បវារណា

## តេវាចិកា បវារណា

លុះធ្វើបុព្វករណៈ និងបុព្វកិច្ច ដូចបានពោលខាងដើមរួចហើយ ត្រូវភិក្ខុ ដែលឈ្លាសប្រតិពល សូត្រញត្តិ ឲ្យសង្ឃដែលមានភិក្ខុតាំងពី ៥ រូបឡើងទៅ ដឹង ដោយពាក្យថា

សុណាតុ មេ ភន្តេ សង្ឃោ, អជ្ជ បវារណា (បណ្ណរសី) ។ យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ តេវាចិកំ បវារេយ្យ ។

បន្ទាប់មក ត្រូវភិក្ខុជាថេរៈ មានវស្សាចាស់ជាងសង្ឃ ធ្វើឧត្តរាសង្គឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលបីដងនឹងសង្ឃថា

សង្ឃំ អាវុសោ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។

ទុតិយម្បិ អាវុសោ សង្ឃំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។

# បវារណានៃសង្ឃ
## បវារណាបីដងៗ មួយរូប

បពិត្រព្រះសង្ឃដ៏ចម្រើន! សូមព្រះសង្ឃស្ដាប់ខ្ញុំព្រះករុណា, ថ្ងៃនេះជាថ្ងៃបវារណា ( ទីដប់ប្រាំ ) ។ បើបវារណាកម្មមានកាលគួរ ដល់សង្ឃហើយ, សង្ឃត្រូវបវារណាបីដងៗ មួយរូប ។

ម្នាលអាវុសោទាំងឡាយ! ខ្ញុំករុណាសូមបវារណា (១) នឹងសង្ឃដោយឃើញក្ដី ឮក្ដី រង្កៀសក្ដី, ចូរលោកអ្នកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្ដីអនុគ្រោះហើយ ពោលចំពោះខ្ញុំករុណា, កាលបើខ្ញុំករុណាឃើញ នឹងធ្វើតាម ។

ម្នាលអាវុសោទាំងឡាយ! ខ្ញុំករុណាសូមបវារណានឹងសង្ឃ ជាគម្រប់ពីរដងទៀត ដោយឃើញក្ដី ឮក្ដី រង្កៀសក្ដី, ចូរលោកអ្នកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្ដីអនុគ្រោះហើយ ពោលចំពោះខ្ញុំករុណា, កាលបើខ្ញុំករុណាឃើញ នឹងធ្វើតាម ។

---

១ ពាក្យថាបវារណាក្នុងទីនេះ សំដៅសេចក្ដីថា បើកឱកាសឲ្យសង្ឃពោលថាបាន ដោយហេតុ ៣ យ៉ាង ។

តតិយម្បិ អាវុសោ សង្ឃំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។

លុះព្រះថេរៈបវារណារួចហើយ, ត្រូវភិក្ខុដែលមានវស្សាខ្ចីជាបន្ទាប់ ចុះមកធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលប័ផង ។ មួយរូបនឹងសង្ឃ ដរាបដល់ភិក្ខុដែលខ្ចីវស្សាជាងគេបំផុត យ៉ាងនេះថា

សង្ឃំ ភន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។

ទុតិយម្បិ ភន្តេ សង្ឃំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។

តតិយម្បិ ភន្តេ សង្ឃំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។

---

ក្នុងពេលដែលភិក្ខុជាថេរៈទាំងឡាយ កំពុងអង្គុយច្រហោងបវារណា ភិក្ខុមិនត្រូវអង្គុយរាបលើអាសនៈទេ, ភិក្ខុណាអង្គុយរាប ត្រូវអាបត្តិទុក្កដ, ភិក្ខុត្រូវតែអង្គុយច្រហោង ដរាបដល់ពេលដែលខ្លួនត្រូវបវារណា លុះបវារណារួចហើយ ទើបអង្គុយរាបលើអាសនៈបាន ។

# បវារណានៃសង្ឃ

ម្នាលអាវុសោទាំងឡាយ ! ខ្ញុំករុណាសូមបវារណានឹងសង្ឃ ជាគម្រប់បីផងទៀត ដោយឃើញក្តី ឮក្តី រង្កៀសក្តី, ចូរលោកអ្នកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះហើយ ពោលចំពោះខ្ញុំករុណា, កាលបើខ្ញុំករុណាឃើញ នឹងធ្វើតាម ។

បពិត្រព្រះសង្ឃដ៏ចម្រើន ! ខ្ញុំព្រះករុណា សូមបវារណានឹងសង្ឃ ដោយឃើញក្តី ឮក្តី រង្កៀសក្តី, សូមលោកអ្នកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះហើយ ពោលចំពោះខ្ញុំព្រះករុណា, កាលបើខ្ញុំព្រះករុណាឃើញ នឹងធ្វើតាម ។

បពិត្រព្រះសង្ឃដ៏ចម្រើន ! ខ្ញុំព្រះករុណា សូមបវារណានឹងសង្ឃ ជាគម្រប់ពីរផងទៀត ដោយឃើញក្តី ឮក្តី រង្កៀសក្តី, សូមលោកអ្នកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះហើយ ពោលចំពោះខ្ញុំព្រះករុណា, បើខ្ញុំព្រះករុណាឃើញ នឹងធ្វើតាម ។

បពិត្រព្រះសង្ឃដ៏ចម្រើន ! ខ្ញុំព្រះករុណាសូមបវារណានឹងសង្ឃ ជាគម្រប់បីផងទៀត ដោយឃើញក្តី ឮក្តី រង្កៀសក្តី, សូមលោកអ្នកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះហើយ ពោលចំពោះខ្ញុំព្រះករុណា , កាលបើខ្ញុំព្រះ-ករុណាឃើញ នឹងធ្វើតាម ។

# បវារណាវិធីសង្ឃ

## វគ្គទាចិកាធិកា បវារណា

## បវារណាពីរដងៗមួយរូបជាដើម

កាលបើមានសញ្ចារភ័យ គឺភ័យដែលកើតពីមនុស្សនៅក្នុងព្រៃក្តី មានពួកមនុស្សមកឡូទាន ក្នុងថ្ងៃបវារណានោះអស់យប់យូរក្តី ពួកភិក្ខុផ្តៀងផ្ទាត់ព្រះ-សូត្រក្តី វិនិច្ឆ័យវិន័យក្តី សាកច្ឆាធម៌ក្តី ឈ្លោះគ្នាក្តី សង្ឃប្រជុំគ្នាច្រើនមានទីដែលតត់ភ្លៀងតិច ហើយភ្លៀងធំរៀបនឹងបង្អុរចុះមកក្តី ឬមានអន្តរាយ ១០ យ៉ាងណាមួយ ដូចបានពោលហើយ ក្នុងការសម្តែងបាតិមោក្ខសង្ខេបនោះក្តី ក្នុងថ្ងៃបវារណានោះ, បើសង្ឃនឹងបវារណាជាតេវាចិកាបវារណាទៅ ឃើញថាមិនហើយជាប្រាកដ ហើយមុខជានឹងមានអន្តរាយពុំខាន, ព្រះសម្ពុទ្ធមានព្រះភាគទ្រង់ត្រាស់អនុញ្ញាត ឲ្យបវារណាជាវេទ្វាចិកា ( គឺបវារណាពីរដងៗមួយរូប ) បានបើ ហេតុនោះប្រញឹកខ្វាំង នឹងបវារណាជាឯកវាចិកា ( គឺបវារណាតែម្តងៗមួយរូប ) ឬបវារណាជាសមានវស្សិកា ( គឺឲ្យភិក្ខុដែលមានវស្សាស្មើៗគ្នាបវារណាព្រមគ្នា ) ក៏បាន ។

ត្រូវភិក្ខុដែលឈ្លាសប្រតិពលផ្តៀងសង្ឃឲ្យដឹងថា

សុណាតុ មេ ភន្តេ សង្ឃោ, មនុស្សេហិ ទានំ ទេន្តេហិ យេភុយ្យេន រត្តិ ខេបិតា ។

សចេ សង្ឃោ តេវាចិកំ បវារេស្សតិ, អប្បវារិតោ ច សង្ឃោ ភវិស្សតិ, អថាយំ រត្តិ វិភាយិស្សតិ ។ យទិ សង្ឃស្ស បត្តកល្លំ,

សង្ឃោ { ទ្វេវាចិកំ(១) / ឯកវាចិកំ / សមានវស្សិកំ } បវារេយ្យ ។

(សេចក្តីនេះ សំដៅចំពោះហេតុដែលមានមនុស្សច្រើនឲ្យទានអស់យប់ជ្រៅពេក)

សុណាតុ មេ ភន្តេ សង្ឃោ, អយំ ព្រហ្មចរិយន្តរាយោ, សចេ សង្ឃោ តេវាចិកំ បវារេស្សតិ, អប្បវារិតោ ច សង្ឃោ ភវិស្សតិ ។ អថាយំ ព្រហ្មចរិយន្តរាយោ ភវិស្សតិ ។ យទិ សង្ឃស្ស បត្តកល្លំ,

សង្ឃោ { ទ្វេវាចិកំ(១) / ឯកវាចិកំ / សមានវស្សិកំ } បវារេយ្យ ។

(សេចក្តីនេះ សំដៅចំពោះអន្តរាយដល់ព្រហ្មចារ្យ, បើមានហេតុ ឬ អន្តរាយដទៃ, បណ្ឌិតគួរសន្និដ្ឋានតាមន័យនេះចុះ) ។

---

១ ត្រូវថាពាក្យណាមួយ តាមសមគួរដល់កាល ។

# បវារណានៃសង្ឃ

បពិត្រព្រះសង្ឃដ៏ចម្រើន! សូមព្រះសង្ឃស្តាប់ខ្ញុំព្រះករុណា, (ផ្សិតមាន) ពួកមនុស្សឱ្យទានអស់រាត្រីជាច្រើន ។

បើសង្ឃនឹងបវារណាជាតេវាចិកា, សង្ឃនឹងបវារណាមិនហើយជាប្រាកដ, កាលបើដូច្នេះ, រាត្រីនេះមុខជានឹងភ្លឺពុំខាន ។ បើបវារណាកម្មមានកាលគួរដល់សង្ឃហើយ,

សង្ឃត្រូវបវារណា { ជាទ្វេវាចិកា ។<br>ជាឯកវាចិកា ។<br>ជាសមានវស្សិកា ។ }

បពិត្រព្រះសង្ឃដ៏ចម្រើន! សូមព្រះសង្ឃស្តាប់ខ្ញុំព្រះករុណា, នេះជាអន្តរាយដល់ព្រហ្មចារ្យ, បើសង្ឃនឹងបវារណាជាតេវាចិកា, សង្ឃនឹងបវារណាមិនហើយជាប្រាកដ, កាលបើដូច្នេះ, អន្តរាយដល់ព្រហ្មចារ្យនេះ មុខជានឹងកើតឡើងមិនខាន ។

បើបវារណាកម្មមានកាលគួរ ដល់សង្ឃហើយ,

សង្ឃត្រូវបវារណា { ជាទ្វេចិកា ។<br>ជាឯកវាចិកា ។<br>ជាសមានវស្សិកា ។ }

# គណបវារណា

ព្រះមានបុណ្យទ្រង់អនុញ្ញាត ឲ្យភិក្ខុបួនរូបបវារណាដល់គ្នានឹងគ្នាបាន ។ គ្រូភិក្ខុដែលឈ្លាសប្រតិពល ញុំាងភិក្ខុទាំងឡាយនោះ ឲ្យដឹងដោយពាក្យថា

សុណន្តុ មេ អាយស្មន្តា, អជ្ជ បវារណា (បណ្ណរសី) ។ យទាយស្មន្តានំ បត្តកល្លំ, មយំ អញ្ញមញ្ញំ តេវាចិកំ បវារេយ្យាម ។

គ្រូភិក្ខុចាស់ជាង ធ្វើចីពរឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលនឹងភិក្ខុទាំងបីរូបនោះថា

អហំ អាវុសោ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។

ទុតិយម្បិ អាវុសោ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។

តតិយម្បិ អាវុសោ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។

# បវារណានៃគណៈ

## បវារណានៃគណៈគឺភិក្ខុបួនរូប

សូមលោកអ្នកមានអាយុទាំងឡាយ ស្ដាប់ខ្ញុំព្រះករុណា, ថ្ងៃនេះជាថ្ងៃបវារណា ( ទីដប់ប្រាំ ) ។ បើបវារណាកម្ម មានកាលគួរ ដល់លោកអ្នកមានអាយុទាំងឡាយហើយ, យើងទាំងឡាយ ត្រូវបវារណាទៅវិញទៅមកពិសគា មួយរូប ។

ម្នាលអាវុសោទាំងឡាយ ! ខ្ញុំករុណា សូមបវារណា នឹងលោកអ្នកមានអាយុទាំងឡាយ ដោយឃើញក្ដី ឮក្ដី រង្កៀសក្ដី, ចូរលោកអ្នកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្ដីអនុគ្រោះហើយ ពោលចំពោះខ្ញុំករុណា, កាលបើខ្ញុំករុណាឃើញនឹងធ្វើតាម ។

ម្នាលអាវុសោទាំងឡាយ ! ខ្ញុំករុណាសូមបវារណានឹងលោកអ្នកមានអាយុទាំងឡាយ ជាគម្រប់ពីរដងទៀត ដោយឃើញក្ដី ឮក្ដី រង្កៀសក្ដី, ចូរលោកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្ដីអនុគ្រោះហើយ ពោលចំពោះខ្ញុំករុណា កាលបើខ្ញុំករុណាឃើញ នឹងធ្វើតាម ។

ម្នាលអាវុសោទាំងឡាយ ! ខ្ញុំករុណាសូមបវារណានឹងលោកអ្នកមានអាយុទាំងឡាយ ជាគម្រប់បីដងទៀត ដោយឃើញក្ដី ឮក្ដី រង្កៀសក្ដី, ចូរលោកអ្នកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្ដីអនុគ្រោះហើយ ពោលចំពោះខ្ញុំករុណា, កាលបើខ្ញុំករុណាឃើញ នឹងធ្វើតាម ។

# តិណ្ណន្នំ អញ្ញមញ្ញំ បវារណា

ត្រូវភិក្ខុដែលឈ្លាសប្រតិពល ញុំាងភិក្ខុទាំងឡាយនោះ ឲ្យដឹងដោយពាក្យថា

សុណន្តុ មេ អាយស្មន្តា, អជ្ជ បវារណា (បណ្ណរសី) ។ យទាយស្មន្តានំ បត្តកល្លំ, មយំ អញ្ញមញ្ញំ តេវាចិកំ បវារេយ្យាម ។

ត្រូវភិក្ខុចាស់ជាង ធ្វើឧត្តរាសង្គឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលនឹងភិក្ខុទាំងពីររូបនោះថា

អហំ អាវុសោ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទន្តុ មំ អាយស្មន្តា អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។

ទុតិយម្បិ អាវុសោ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទន្តុ មំ អាយស្មន្តា អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។

តតិយម្បិ អាវុសោ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទន្តុ មំ អាយស្មន្តា អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។

# បវារណានៃភិក្ខុបីរូប
## ភិក្ខុបីរូបបវារណាទឹងគ្នាទៅវិញទៅមក

សូមលោកអ្នកមានអាយុទាំងឡាយស្តាប់ខ្ញុំព្រះករុណា, ថ្ងៃនេះ ជាថ្ងៃបវារណា ( ទីដប់ប្រាំ ) ។ បើបវារណាកម្ម មានកាលគួរ ដល់លោកអ្នកមានអាយុទាំងឡាយហើយ, យើងទាំងឡាយត្រូវបវារណាទៅវិញទៅមក បីដងៗ ១ រូប ។

ម្នាលអាវុសោទាំងឡាយ! ខ្ញុំករុណាសូមបវារណានឹងលោកអ្នកមានអាយុទាំងឡាយ ដោយឃើញក្តី ឮក្តី រង្កៀសក្តី, ចូរលោកអ្នកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះហើយ ពោលចំពោះខ្ញុំករុណា, កាលបើខ្ញុំករុណាឃើញ នឹងធ្វើតាម ។

ម្នាលអាវុសោទាំងឡាយ! ខ្ញុំករុណាសូមបវារណានឹងលោកអ្នកមានអាយុទាំងឡាយ ជាគម្រប់ពីរដងទៀត ដោយឃើញក្តី ឮក្តី រង្កៀសក្តី, ចូរលោកអ្នកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះហើយពោលចំពោះខ្ញុំករុណា, កាលបើខ្ញុំករុណាឃើញ នឹងធ្វើតាម ។

ម្នាលអាវុសោទាំងឡាយ ! ខ្ញុំករុណាសូមបវារណានឹងលោកអ្នកមានអាយុទាំងឡាយ ជាគម្រប់បីដងទៀត ដោយឃើញក្តី ឮក្តី រង្កៀសក្តី, ចូរលោកអ្នកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះហើយ ពោលចំពោះខ្ញុំករុណា, កាលបើខ្ញុំករុណាឃើញ នឹងធ្វើតាម ។

ត្រូវភិក្ខុទី២ និង ទីបី ធ្វើអាការដូចបានពោលហើយ រួចពោលមួយរូបបីដងៗ យ៉ាងនេះថា

**អហំ ភន្តេ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។**

**ទុតិយម្បិ ភន្តេ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។**

**តតិយម្បិ ភន្តេ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។**

# បវារណានៃភិក្ខុបីរូប

មានប្រោស ! ខ្ញុំព្រះករុណាសូមបវារណា នឹងលោកអ្នកមានអាយុទាំងឡាយ ដោយឃើញក្តី ឮក្តី រង្កៀសក្តី, សូមលោកអ្នកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះហើយ ពោលចំពោះខ្ញុំព្រះករុណា, កាលបើខ្ញុំព្រះករុណាឃើញ នឹងធ្វើតាម ។

មានប្រោស ! ខ្ញុំព្រះករុណាសូមបវារណា នឹងលោកអ្នកមានអាយុទាំងឡាយជាគម្រប់ពីរដងទៀត ដោយឃើញក្តី ឮក្តី រង្កៀសក្តី, សូមលោកអ្នកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះហើយ ពោលចំពោះខ្ញុំព្រះករុណា, កាលបើខ្ញុំព្រះករុណាឃើញ នឹងធ្វើតាម ។

មានប្រោស ! ខ្ញុំព្រះករុណាសូមបវារណា នឹងលោកអ្នកមានអាយុទាំងឡាយជាគម្រប់បីដងទៀត ដោយឃើញក្តី ឮក្តី រង្កៀសក្តី, សូមលោកអ្នកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះហើយ ពោលចំពោះខ្ញុំព្រះករុណា, កាលបើខ្ញុំព្រះករុណាឃើញ នឹងធ្វើតាម ។

## ទ្វិន្នំ អញ្ញមញ្ញំ បវារណា

ត្រូវភិក្ខុចាស់ជាង ធ្វើឧត្តរាសង្គឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលនឹងភិក្ខុខ្ចីជាងថា

អហំ អាវុសោ អាយស្មន្តំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទតុ មំ អាយស្មា អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។

ទុតិយម្បិ អាវុសោ អាយស្មន្តំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទតុ មំ អាយស្មា អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។

តតិយម្បិ អាវុសោ អាយស្មន្តំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទតុ មំ អាយស្មា អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។

ត្រូវភិក្ខុខ្ចីជាង ធ្វើឧត្តរាសង្គឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលនឹងភិក្ខុចាស់ជាងថា

អហំ ភន្តេ អាយស្មន្តំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទតុ មំ អាយស្មា អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។

## បវារណានៃភិក្ខុពីររូប

## ភិក្ខុពីររូបបវារណានឹងគ្នាទៅវិញទៅមក

ម្នាលអាវុសោ ! ខ្ញុំករុណាសូមបវារណានឹងលោកអ្នកមានអាយុ ដោយឃើញក្តី ឮក្តី រង្កៀសក្តី, ចូរលោកអ្នកមានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះហើយ ពោលចំពោះខ្ញុំព្រះករុណា, កាលបើខ្ញុំព្រះករុណាឃើញ នឹងធ្វើតាម ។

ម្នាលអាវុសោ ! ខ្ញុំករុណាសូមបវារណា នឹងលោកអ្នកមានអាយុ ជាគម្រប់ពីរដងទៀត ដោយឃើញក្តី ឮក្តី រង្កៀសក្តី, ចូរលោកអ្នកមានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះហើយ ពោលចំពោះខ្ញុំព្រះករុណា, កាលបើខ្ញុំព្រះករុណាឃើញ នឹងធ្វើតាម ។

ម្នាលអាវុសោ ! ខ្ញុំករុណាសូមបវារណា នឹងលោកអ្នកមានអាយុ ជាគម្រប់បីដងទៀត ដោយឃើញក្តី ឮក្តី រង្កៀសក្តី, ចូរលោកអ្នកមានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះហើយ ពោលចំពោះខ្ញុំករុណា, កាលបើខ្ញុំករុណាឃើញ នឹងធ្វើតាម ។

ខានព្រោស ! ខ្ញុំព្រះករុណាសូមបវារណា នឹងលោកអ្នកមានអាយុ ដោយឃើញក្តី ឮក្តី រង្កៀសក្តី, សូមលោកអ្នកមានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះហើយ ពោលចំពោះខ្ញុំព្រះករុណា, កាលបើខ្ញុំព្រះករុណាឃើញ នឹងធ្វើតាម ។

ទុតិយម្បិ ភន្តេ អាយស្មន្តំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទតុ មំ អាយស្មា អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។

តតិយម្បិ ភន្តេ អាយស្មន្តំ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា; វទតុ មំ អាយស្មា អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ[១] ។

---

១ ការបវារណា របស់ភិក្ខុបួនរូប, បីរូប, ពីររូប មិនមានអនុញ្ញាតឲ្យពោល ជាទ្វេវាចិកា, ឯកវាចិកា និង សមានវស្សិកាឡើយ ព្រោះមានគ្នាតិច ។

# បវារណានៃភិក្ខុពីររូប

មានប្រោស! ខ្ញុំព្រះករុណាសូមបវារណា នឹងលោកអ្នកមានអាយុ ជាគម្រប់ពីរផងទៀត ដោយឃើញក្តី ឮក្តី រង្កៀសក្តី, សូមលោកអ្នកមានអាយុអាស្រ័យនូវសេចក្តីអនុគ្រោះហើយ ពោលចំពោះខ្ញុំព្រះករុណា, កាលបើខ្ញុំព្រះ-ករុណាឃើញ នឹងធ្វើតាម ។

មានប្រោស! ខ្ញុំព្រះករុណាសូមបវារណា នឹងលោកអ្នកមានអាយុ ជាគម្រប់បីផងទៀត ដោយឃើញក្តី ឮក្តី រង្កៀសក្តី, សូមលោកអ្នកមានអាយុអាស្រ័យនូវសេចក្តីអនុគ្រោះហើយ ពោលចំពោះខ្ញុំព្រះករុណា, កាលបើខ្ញុំព្រះ-ករុណាឃើញ នឹងធ្វើតាម ។

# អធិដ្ឋានប្បវារណា

# អធិដ្ឋានប្បវារណា

## បវារណាដោយអធិដ្ឋាន

បើភិក្ខុនៅក្នុងអាវាសមួយ តែម្នាក់ឯង ក្នុងថ្ងៃបវារណានោះ ត្រូវធ្វើតាមរបៀបដូចបានពោលក្នុង " អធិដ្ឋានឧបោសថ " ហើយត្រូវអធិដ្ឋានបវារណា ថា

"អជ្ជ មេ បវារណា" ។

ប្រែថា " ថ្ងៃនេះ ជាថ្ងៃបវារណារបស់អញ " ។

ចំណេះជាការស្រេច ។

## សមានវស្សិកា បវារណា

## សមានវស្សិកា បវារណាកម្ម

កាលបើភិក្ខុសង្ឃមានចំនួនច្រើនពេក បើបវារណាមួយរូបៗ ដោយឧទ្ទេ ទៅនឹងយូរណាស់ មិនងាយនឹងហើយ, ឃើញថាព្រះថេរៈចាស់ៗ នឹងធន់ទ្រាំ ចាំគ្នាមិនកើត⁄ ត្រូវតាំងញត្តិជាសមានវស្សិកាថា

**សុណាតុ មេ ភន្តេ សង្ឃោ, អជ្ជ បវារណា បណ្ណរសី, អយញ្ច ភិក្ខុសង្ឃសន្និបាតោ ពហុត— រោ ហោតិ, សចេ ឯកេកោ ភិក្ខុ បច្ចេកំ បច្ចេកំ បវារេស្សតិ,**

អម្ហាកំ(១) បវារណាកម្មំ អតិចិរំ បវត្តិស្សតិ មហល្លកា ច ថេរា ចិរំ និសីទិតុំ ន សក្ខិស្សន្តិ, យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ សមានវស្សិកំ បវារេយ្យ ។

“ បពិត្រព្រះសង្ឃដ៏ចម្រើន , សូមព្រះសង្ឃស្តាប់ខ្ញុំព្រះករុណា , ថ្ងៃនេះ ជាថ្ងៃបវារណាទី ១៥ កើត, ក៏ប្រជុំភិក្ខុសង្ឃនេះ ច្រើនហួសពេក, បើភិក្ខុមួយរូប ៗ នឹងបវារណាដោយខ្លួនៗទៅ, បវារណាកម្មរបស់យើង មុខជានឹងយូរណាស់ (ក្រហើយ), ទាំងព្រះថេរៈចាស់ៗទាំងឡាយ ក៏នឹងពុំអាចគង់យូរបានឡើយ, បើបវារណាកម្មមានកាលសមគួរដល់សង្ឃហើយ, សង្ឃត្រូវបវារណាជាសមានវស្សិកា ” ។ ( សូធ្យពាក្យ៣ដងក៏បាន, សូធ្យបាលី តែម្តងហើយប្រែជាសម្រាយផង ឲ្យសង្ឃស្តាប់បានរាល់គ្នាក៏បាន ) ។

លុះតាំងញត្តិយ៉ាងនេះរួចហើយ , ត្រូវព្រះថេរៈចាស់ៗ បវារណាមួយរូប ៗ ដោយខ្លួនៗឲ្យបាន ៤ រូបសិន ឬឲ្យបានច្រើនរូបជាងនោះក៏បាន, រួចហើយ ត្រូវភិក្ខុទាំងឡាយ បវារណាដោយពួកៗ តាមលំដាប់វស្សាតាមទៅ ដរាបដល់គ្រប់រូប ។ ក្នុងមួយពួក ៗ បវារណាបានតាំងពីបីដង ៗ រហូតដល់ម្តង ៗ ក៏បាន ។ បើឃើញគួរបវារណា ៣ ដង ៗ បាន ក៏ត្រូវបវារណាតាមសមគួរដល់វេលាចុះ(២)។

---

១ ប្រើជាសង្ឃស្ស ក៏បាន, ប្រែថា របស់សង្ឃ ។

២ បើជំនុំសង្ឃមានភិក្ខុសង្ឃ ច្រើនពេក , ក៏គប្បីប្រើញត្តិតាមបែបនេះ ។ នេះជាមតិរបស់ សម្តេច ព្រះមហាសុមេធាធិបតី ជ.ណ. ជោតញ្ញាណោ ។

# អំពីការចូលវស្សា

តាមទំនៀមក្នុងព្រះពុទ្ធសាសនា, តែដល់វស្សានរដូវហើយ ចាប់តាំងពីថ្ងៃ ១ រោច ខែ អាសាឍ ( ឬខែទុតិយាសាឍ, បើឆ្នាំនោះមានអធិកមាស ) រហូតទៅទល់នឹងថ្ងៃ ១៥ កើត ខែ កត្តិក គឺក្នុងរយៈកាលនៃរដូវភ្លៀង ៤ ខែ, ភិក្ខុទាំងអស់ ពុំត្រូវចេះតែត្រាច់ចររហេតរហូត ទៅកាន់ទីផ្សេងៗឡើយ, ត្រូវរកទីលំនៅឈប់សម្រាកនៅទីឯកន្លែងមួយអស់កំណត់ ៣ ខែ ដែលលោកហៅថា ចាំវស្សា ។

ដោយហេតុរដូវភ្លៀងមានដល់ទៅ ៤ ខែ ហើយការចាំវស្សា មានត្រឹមតែ ៣ ខែ នេះហើយ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់អនុញ្ញាតឲ្យមានការចូល-ចេញវស្សា ពីរបែបឬពីរលើក តាមបំណងរបស់ភិក្ខុ ។

ការចាំវស្សាលើកដំបូង, ភិក្ខុត្រូវចូលវស្សាពីថ្ងៃ ១ រោច ខែ អាសាឍ ( ឬខែ ទុតិយាសាឍ ) រហូតទៅទល់នឹង ថ្ងៃ ១៥ កើត ខែ អស្សុជ ទើបចេញវិញ, លោកហៅថា " **បុរិមិកាវស្សា** " ។

ការចាំវស្សាលើកក្រោយ, ភិក្ខុត្រូវចូលវស្សាពី ថ្ងៃ ១ រោច ខែ ស្រាពណ៍ រហូតទៅទល់នឹងថ្ងៃ ១៥ កើត ខែ កត្តិក, លោកហៅថា "**បច្ឆិមិកាវស្សា**"

នៅថ្ងៃចូលវស្សា ត្រូវភិក្ខុបោសព្រោស សម្អាតទីសេនាសនៈ និងទីបរិវេណ រៀបចំឲ្យមានរបៀបរៀបរយល្អ, តម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ឲ្យហើយស្រេច រួចត្រូវចូលទៅប្រជុំគ្នា ក្នុងឧបោសថាគារ ( វិហារ ) អធិដ្ឋានចូលវស្សាព្រមគ្នាថា

## របៀបចូលវស្សា

**"ឥមស្មឹំ អាវាសេ ឥមំ តេមាសំ វស្សំ ឧបេម "**(១)

ប្រែថា "យើងទាំងឡាយនៅចាំវស្សាអស់បីខែនេះ ក្នុងអាវាសនេះ" ។

ក្នុងពេលអធិដ្ឋាន ត្រូវតាំងចិត្តថានឹងនៅក្នុងវេលារាត្រី រក្សាអរុណ ឲ្យរះឡើងតែក្នុងពេលដែលខ្លួននៅ ក្នុងខេត្តនៃអាវាស រហូតដល់គ្រប់កំណត់បីខែ ។

បើភិក្ខុនៅចាំវស្សាក្នុងទីសេនាសនៈណាមួយ, ត្រូវកំណត់ខេត្ត នឹងបរិវេណទីសេនាសនៈនោះ , បើនៅច្រើនគ្នា, ត្រូវអធិដ្ឋានចូលវស្សា ថា

**"ឥមស្មឹំ សេនាសនេ ឥមំ តេមាសំ វស្សំ ឧបេម "**

ប្រែថា "យើងទាំងឡាយនៅចាំវស្សា អស់បីខែនេះ ក្នុងទីសេនាសនៈនេះ" ។

បើនៅតែម្នាក់ឯង , ត្រូវអធិដ្ឋាន ថា

**"ឥមស្មឹំ សេនាសនេ ឥមំ តេមាសំ វស្សំ ឧបេមិ "**

ប្រែដូចគ្នា, ប្លែកតែត្រង់ពាក្យថា "យើងទាំងឡាយ ឲ្យផ្លាស់ជា "អញ ឬ "អាត្មាអញ" វិញ ។

បើនៅក្នុងកុដិធំ ច្រើនគ្នា ឲ្យថា

**"ឥមស្មឹំ វិហារេ ឥមំ តេមាសំ វស្សំ ឧបេម "** ប្រែថា "យើងទាំងឡាយនៅចាំវស្សា អស់បីខែនេះ ក្នុងវិហារនេះ" ។ បើនៅតែម្នាក់ឯង , ឲ្យថា **"ឧបេមិ"** ត្រង់ពាក្យថា **"ឧបេម"** ប្រែដូចគ្នា ។

## របៀបចូលវស្សា

ប្តូរតែពាក្យថា "យើងទាំងឡាយ" ជា "អញ" ឬ "អាត្មាអញ" វិញ ។

បើនៅក្នុងតូប ឬ កុដិតូចៗម្នាក់ៗឯណាក្នុងព្រៃ, ត្រូវកំណត់ខេត្តនិងទីបរិវេណ របស់តូប ឬកុដិនោះៗ ហើយអធិដ្ឋានថា

**" ឥមិស្មឹំ ឬ ឥមាយំ កុដិយំ ឥមំ តេមាសំ វស្សំ ឧបេមិ "**

ប្រែថា " អាត្មាអញនៅចាំវស្សា អស់បីខែនេះ ក្នុងតូបនេះ " ។

ក្នុងអាវាសមួយៗ នៅពេលដែលភិក្ខុសង្ឃ បានអធិដ្ឋានចូលវស្សារួចហើយ, គួរភិក្ខុចៅអាវាស ឬមហាថេរ ប្រកាសប្រាប់ខេត្តនៃអាវាស គឺកំណត់ព្រំប្រទល់វត្ត គ្រប់ទិសទាំងបួន ឱ្យភិក្ខុសាមណេរគ្រប់រូបបានដឹងទូទៅ ដើម្បីនឹងបានចៀសវាងអំពីការដាច់វស្សា ព្រោះការបណ្តោយឱ្យអរុណរះឡើង ក្នុងពេលដែលខ្លួនស្ថិតនៅខាងក្រៅខេត្តនៃអាវាសនោះ ។

ដល់ថ្ងៃចូលវស្សាហើយ បើភិក្ខុនៅតែត្រាច់ទៅមក ឬតែអង់វង់ពុំចូលវស្សានៅទីណាមួយនោះ ឃើញថាមិនសមគួរឡើយ លោកថា ត្រូវអាបត្តិទុក្កដ ភិក្ខុចូលវស្សាក្នុងទីណាហើយ ត្រូវតែរក្សារាត្រីនៅក្នុងទីនោះរហូតដល់គ្រប់កំណត់បីខែ, បើមានធុរៈកើតឡើង នាំឱ្យភិក្ខុចេញចាកទីនោះ ក៏គប្បីប្រញាប់ប្រញាល់ត្រឡប់វិលមកកាន់ទីនោះវិញ ឱ្យទាន់មុនពេលអរុណរះ ។ តែបើមានធុរៈចំពោះមាតា-បិតា និងភិក្ខុ-សាមណេរ ដែលខ្លួនបានដឹងហើយ, ភិក្ខុត្រូវទៅដោយ **សត្តាហករណីយ** ដោយមិនចាំបាច់មានការមកនិមន្ត, បើឧបាសក ឧបាសិកា បងប្អូន ប្រុស-ស្រី ញាតិ ឬបុរសអ្នកធ្វើការ

របស់ភិក្ខុនោះអាពាធ: ហើយបានបញ្ជូនបម្រើមកនិមន្ត ឲ្យទៅកាន់ទីកន្លែងរបស់ខ្លួន ដែលនៅឆ្ងាយ ពុំគួរដល់ការត្រឡប់មកកាន់អាវាស ក្នុងថ្ងៃនោះវិញទាន់ ឬបើមានគេនិមន្ត ចំពោះសង្ឃករណីយកិច្ចណាមួយ ( ដូចមានសេចក្តីពិស្តារ ក្នុងវស្សូបនាយិកក្ខន្ធកៈ ) ភិក្ខុអាចទៅដោយ **សត្តាហករណីយ** បាន, មុននឹងចេញផុតអំពីអាវាសទៅ ( តាមច្បាប់ ) ត្រូវអធិដ្ឋាន ថា

**"សចេ មេ អន្តរាយោ នត្ថិ , សត្តាហព្ភន្តរេយេវ បុន និវត្តិស្សាមិ" ។**

**" ទុតិយម្បិ... "តតិយម្បិ...**

ប្រែថា " បើមិនមានអន្តរាយ (ឧបសគ្គ) ដល់អាត្មាអញទេ, អាត្មាអញនឹងត្រឡប់មកវិញ ក្នុងចន្លោះសត្តាហៈពុំខាន" ។

... ជាគម្រប់ពីរដងផង " ។...ជាគម្រប់បីដងផង " ។

ភិក្ខុលើកសត្តាហៈចេញទៅអំពីវត្តហើយ ត្រូវត្រឡប់មកវត្ត ខាងក្នុងអរុណនៃថ្ងៃទីប្រាំពីរវិញ (គឺត្រូវទៅនៅក្រៅវត្តបានពេញ ៦ យប់), កុំទៅនៅក្រៅ ឲ្យហួសអរុណនៃថ្ងៃទីប្រាំពីរឡើយ, បើធ្វេសប្រហែស ទេះតែទៅក្រៅវត្តឲ្យកន្លងហួសទៅ នឹងដាច់វស្សា ត្រូវអាបត្តិទុក្កដ ហើយខានបានទទួលអានិសង្សកឋិន ព្រមទាំងសង្ឃលាភផ្សេងៗ ដែលនឹងកើតឡើងក្នុងវត្តនោះផង ។

ការចូលវស្សានេះមិនចំពោះតែភិក្ខុទេ ទាំងសាមណេរក៏ត្រូវចូលវស្សាដែរ ទើបត្រូវតាមពុទ្ធានុញ្ញាតឲ្យចែកសង្ឃលាភ , ប៉ុន្តែសាមណេរមិនមានកិច្ចដោយការបវារណាឡើយ , គ្រាន់តែឲ្យអធិដ្ឋានចូលវស្សាប៉ុណ្ណោះ ។

# សីលុទ្ទេសបាឋោ

## ឧទ្ទេសបាឋសារេន សជ្ឈាយិតព្វោ

ភាសិតមិទំ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន : " សម្បន្នសីលា ភិក្ខវេ! វិហរថ សម្បន្នបាតិមោក្ខា, បាតិមោក្ខសំវរសំវុតា វិហរថ អាចារគោចរសម្បន្នា, អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខថ សិក្ខាបទេសូតិ[១] " តស្មាតិហម្ហេហិ សិក្ខិតព្វំ :

សម្បន្នសីលា វិហរិស្សាម សម្បន្នបាតិមោក្ខា, បាតិមោក្ខសំវរសំវុតា វិហរិស្សាម អាចារគោចរ-សម្បន្នា, អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខិស្សាម សិក្ខាបទេសូតិ " ។ ឯវញ្ហិ នោ សិក្ខិតព្វំ ។

បាតិមោក្ខំ វិសោធេន្តោ អប្បេវ ជីវិតំ ជហេ
បញ្ញត្តំ លោកនាថេន ន ភិន្ទេ សីលសំវរំ[២] ។

កិកីវ អណ្ឌំ ចមរីវ វាលធឹ
បិយំវ បុត្តំ នយនំវ ឯកកំ
តថេវ សីលំ អនុរក្ខមានកា
សុបេសលា ហោថ សទា សគារវា[៣] ។

---

១ ២ ៣ វិសុទ្ធិមគ្គ សីលនិទ្ទេស ។

# បាលីសម្តែងប្រារព្ធសីល

# បាលីសម្តែងប្រារព្ធសីល

## ដែលឃើញថាសង្ឃគួរស្វាធ្យាយក្នុងទីបំផុតនៃឧបោសថកម្ម

សម្តេចព្រះមានព្រះភាគ ព្រះអង្គនោះ ទ្រង់ជ្រាប ទ្រង់ឃើញ ទ្រង់ជាអរហន្តសម្មាសម្ពុទ្ធ បានត្រាស់សម្តែងពាក្យនេះថា " ម្នាលភិក្ខុទាំងឡាយ ! អ្នកទាំងឡាយចូរជាអ្នកមានសីលដល់ព្រមហើយ មានបាតិមោក្ខដល់ព្រមហើយ នោះចុះ, ចូរជាអ្នកសង្រួម ដោយការសង្រួមក្នុងបាតិមោក្ខ ប្រកបដោយអាចារៈ (គឺមារយាទ) និងគោចរ (គឺទីត្រាច់ទៅ) ហើយនោះចុះ, ចូរជាអ្នកឃើញភ័យជាប្រក្រតី ក្នុងទោសបន្តិចបន្តួចហើយសិក្សាម៉ឺងម៉ាត់ ក្នុងសិក្ខាបទទាំងឡាយ! " ព្រោះហេតុនោះ យើងទាំងឡាយ (ជាបព្វជិត) ក្នុងព្រះពុទ្ធសាសនានេះ គួរសិក្សា ថា "យើងនឹងជាអ្នកមានសីលដល់ព្រមហើយ មានបាតិមោក្ខដល់ព្រមហើយទៅ, យើងនឹងជាអ្នកសង្រួម ដោយការសង្រួមក្នុងបាតិមោក្ខ ប្រកបដោយអាចារៈ និងគោចរហើយទៅ, យើងនឹងជាអ្នកឃើញភ័យជាប្រក្រតី ក្នុងទោសបន្តិចបន្តួច ហើយសិក្សាម៉ឺងម៉ាត់ ក្នុងសិក្ខាបទទាំងឡាយ " ។ យើងត្រូវសិក្សាយ៉ាងនេះឯង ។

សទ្ធាបព្វជិត កាលជម្រះបាតិមោក្ខសំវរសីល ស៊ូប្រថុយលះបង់ជីវិតរបស់ខ្លួន ពុំទម្លាយនូវសីលសំវរៈ ដែលព្រះបរមលោកនាថ ទ្រង់ត្រាស់បញ្ញត្តទុកមកនោះឡើយ ។

មេក្រពើរវៀចខំរក្សាស៊ុត, មេទ្រីគចាមរីខំរក្សារោម ស៊ូប្រថុយជីវិត យ៉ាងណាមិញ, កុដុម្ពិកៈខំរក្សាកូនប្រុសសម្លាញ់តែមួយ, បុរសពិការភ្នែកម្ខាង ខំរក្សាភ្នែកតែមួយ យ៉ាងណាមិញ, យើងចូររក្សាសីលយើង ឲ្យបានដូចជាមេក្រពើរវៀចជាដើម យ៉ាងនោះឯង ឲ្យបានជាអ្នកមានសីល ជាទីស្រឡាញ់ ប្រកបដោយសេចក្តីគោរពសព្វវេលា ។

សត្ថា សាវកានំ សិក្ខាបទំ បញ្ញាបេតិ ទស អត្ថវសេ បដិច្ច ៖

សង្ឃសុដ្ឋុតាយ, សង្ឃផាសុតាយ, ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ, បេសលានំ ភិក្ខូនំ ផាសុវិហារាយ, ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ. សម្បរាយិកានំ អាសវានំ បដិឃាតាយ. អប្បសន្នានំ បសាទាយ, បសន្នានំ ភិយ្យោភាវាយ. សទ្ធម្មដ្ឋិតិយា, វិនយានុគ្គហាយ ។

វិនយម្ហិ មហត្ថេសុ បេសលានំ សុខាវហេ
និគ្គហានញ្ច បាបិច្ឆេ លជ្ជីនំ បគ្គហេសុ ច,
សាសនាធារណេ ចេវ សព្វញ្ញុជិនគោចរេ
អនញ្ញវិសយេ ខេមេ សុប្បញ្ញត្តេ អសំសយេ,
ខន្ធកេ វិនយេ ចេវ បរិវារេ ច មាតិកេ
យថាត្ថការី កុសលោ បដិបជ្ជតិ យោនិសោ ។
យោ គវំ ន ជានាតិ, ន សោ រក្ខតិ គោគណំ,
ឯវំ សីលំ អជានន្តោ កឹ សោ រក្ខេយ្យ សំវរំ[១]។
បមុដ្ឋម្ហិ ច សុត្តន្តេ អភិធម្មេ ច តាវទេ,
វិនយេ អវិនដ្ឋម្ហិ បុន តិដ្ឋតិ សាសនំ ។

១ វិនយបិដក មហាវគ្គ ។

# ប្រយោជន៍នៃវិន័យ

ព្រះបរមសាស្តា ទ្រង់ក្រាស់បញ្ញត្តសិក្ខាបទ ដល់សាវ័កទាំងឡាយ ព្រោះអាស្រ័យប្រយោជន៍ ១០ យ៉ាង គឺ

ដើម្បីសេចក្តីល្អ ដល់សង្ឃ១, ដើម្បីការនៅសប្បាយ ដល់សង្ឃ១, ដើម្បីសង្កត់សង្កិន នូវបុគ្គលទាំងឡាយដែលទ្រុស្តសីល១, ដើម្បីកិរិយានៅជាសុខស្រួលដល់ភិក្ខុទាំងឡាយ អ្នកមានសីលជាទីស្រឡាញ់ ១, ដើម្បីរារាំងអាសវធម៌ទាំងឡាយ ក្នុងបច្ចុប្បន្ន១, ដើម្បីកម្ចាត់បង់អាសវធម៌ទាំងឡាយ ក្នុងបរលោក ១, ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង១, ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង ១, ដើម្បីឲ្យព្រះសទ្ធម្ម តម្កល់នៅមាំ ១, (និង) ដើម្បីអនុគ្រោះ ដល់ព្រះវិន័យ ១ ។

កាលបើព្រះវិន័យ មានប្រយោជន៍ដ៏ធំ នាំមកនូវសេចក្តីសុខដល់ពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ផង, សង្កត់សង្កិននូវពួកភិក្ខុ ដែលមានសេចក្តីប្រាថ្នាលាមកផង, តម្កល់តម្កើងនូវពួកភិក្ខុដែលមានសេចក្តីខ្មាសផង, ជាសភាវៈទ្រទ្រង់ទុកនូវសាសនាផង, ជាទីគោចររបស់ព្រះជិនស្រី ជាសព្វញ្ញូផង, មិនមែនជាវិស័យនៃបុគ្គលដទៃផង, ជាទីក្សេមក្សាន្តផង, គឺព្រះមានព្រះភាគទ្រង់បញ្ញត្តហើយដោយប្រពៃ ដោយឥតសង្ស័យ, អ្នកប្រាជ្ញដែលមានប្រក្រតីធ្វើនូវប្រយោជន៍ដ៏សមគួរតែងប្រតិបត្តិដោយឧបាយក្នុងខន្ធកវិន័យផង ក្នុងបរិវារៈផង ក្នុងមាតិកាផង ។

បុគ្គលណាមិនស្គាល់គោ, បុគ្គលនោះនឹងរក្សាហ្វូងគោដូចម្តេចបាន យ៉ាងណាមិញ, ភិក្ខុណាមិនស្គាល់សីល, ភិក្ខុនោះនឹងរក្សាសេចក្តីសង្រួមក្នុងសីលដូចម្តេចបាន យ៉ាងនោះដែរ ។

បើទុកជាព្រះសូត្រ និងព្រះអភិធម្ម សាបសូន្យអស់ទៅហើយ, តែបើព្រះវិន័យ មិនទាន់វិនាសនៅឡើយទេ, ព្រះពុទ្ធសាសនាឈ្មោះថាស្ថិតនៅតទៅទៀតបាន ។

## អភិណ្ហប្បច្ចវេក្ខណធម្មា

១- ជរាធម្មោម្ហិ ជរំ អនតីតោ;

២- ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោ;

៣- មរណធម្មោម្ហិ មរណំ អនតីតោ;

៤- សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ

៥- កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ, យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមិ ។

---

## ទសធម្មសុត្តបាឋោ

១- វេវណ្ណិយម្ហិ អជ្ឈុបគតោ;

២- បរប្បដិពទ្ធា មេ ជីវិកា;

៣- អញ្ញោ មេ អាកប្បោ ករណីយោ;

៤- កច្ចិ នុ ខោ អត្តា សីលតោ ន ឧបវទតិ?

៥- កច្ចិ នុ ខោ មំ អនុវិច្ច វិញ្ញូ សព្រហ្មចារី សីលតោ ន ឧបវទន្តិ ?

៦- សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ;

## អភិណ្ហបច្ចវេក្ខណៈ

## ធម៌គួរពិចារណារឿយៗ

១- អាត្មាអញ មានការចាស់ជរាជាធម្មតា នឹងកន្លងការចាស់ជរាទៅពុំបានឡើយ;

២- អាត្មាអញ មានការឈឺថ្កាត់ជាធម្មតា នឹងកន្លងការឈឺថ្កាត់ទៅពុំបានឡើយ;

៣- អាត្មាអញ មានសេចក្ដីស្លាប់ជាធម្មតា នឹងកន្លងសេចក្ដីស្លាប់ទៅពុំបានឡើយ,

៤- អាត្មាអញ គង់តែព្រាត់ប្រាសនិរាស ចាកសត្វនិងសង្ខារ ជាទីស្រឡាញ់ពេញចិត្តទាំងអស់ពុំខាន,

៥- អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាអ្នកឲ្យផល មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពំនាក់អាស្រ័យ, អាត្មាអញនឹងធ្វើកម្មណា ជាកម្មល្អក្ដី អាក្រក់ក្ដី អាត្មាអញនឹងត្រូវជាអ្នកទទួល នូវផល នៃកម្មនោះពុំខាន ។

## បាលីទសធម្មសូត្រ

១. អាត្មាអញមានភេទផ្សេងអំពីគ្រហស្ថ,

២. ការចិញ្ចឹមជីវិតរបស់អាត្មាអញ ជាប់ដោយសារអ្នកដទៃ,

៣. អាត្មាអញត្រូវធ្វើអាកប្បកិរិយា (អំពើដោយកាយនិងវាចា) ផ្សេងដទៃប្លែកពីគ្រហស្ថ;

៤. ចិត្តរបស់អាត្មាអញមិនតិះដៀលខ្លួនឯងព្រោះសីល (មិនបរិបូណ៌) ទេឬ?

៥. ពួកសព្រហ្មចារីជាអ្នកប្រាជ្ញពិចារណាហើយ មិនតិះដៀលអាត្មាអញព្រោះសីល (មិនបរិបូណ៌) ទេឬ?

៦- អាត្មាអញគង់តែព្រាត់ប្រាសនិរាស ចាកសត្វនិងសង្ខារជាទីស្រឡាញ់ពេញចិត្តទាំងអស់ពុំខាន,

៧- កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ, យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមិ;

៨- កថម្ភូតស្ស មេ រត្តិន្ទិវា វីតិបតន្តិ ?

៩- កច្ចិ នុ ខោហំ សុញ្ញាគារេ អភិរមាមិ ?

១០- អត្ថិ នុ ខោ មេ ឧត្តរិមនុស្សធម្មា អលមរិយញ្ញាណទស្សនវិសេសោ អធិគតោ ? សោហំ បច្ឆិមេ កាលេ សព្រហ្មចារីហិ បុដ្ឋោ ន មង្កុ ភវិស្សាមិ ។

៧.អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាអ្នកឲ្យផល មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពំនាក់អាស្រ័យ, អាត្មាអញនឹងធ្វើកម្មណា ជាកម្មល្អក្តី អាក្រក់ក្តី អាត្មាអញនឹងត្រូវជាអ្នកទទួល នូវផលនៃកម្មនោះពុំខាន ,

៨.យប់និងថ្ងៃកន្លងទៅ អាត្មាអញបានធ្វើអ្វីខ្លះ ?

៩.អាត្មាអញត្រេកអរ ក្នុងផ្ទះស្ងាត់ឬទេ ?

១០.អាត្មាអញមានឧត្តរិមនុស្សធម៌ដែរឬទេ ?អាត្មាអញបានលុះគុណវិសេស គឺញាណនិងទស្សនៈដ៏ប្រសើរ ជាធម៌អាចកម្ចាត់បង់នូវកិលេសដែរឬទេ? បើពួកសព្រហ្មចារីមកសួរក្នុងបច្ឆិមកាល អាត្មាអញឯង នឹងមិនអៀនខ្មាសឡើយ ។

គម្ពីរដែលជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះគឺ

១– គណចារបាលី

២– សមន្តបាសាទិកា (អដ្ឋកថាវិន័យ )

៣– កង្ខាវិតរណី ( អដ្ឋកថាបាតិមោក្ខ )

៤– វិនយត្ថមញ្ជុសា ( ដីកាបាតិមោក្ខ )

៥– វិនយបិដក ( មហាវិភង្គ )

៦– វិនយបិដក (ឧបោសថក្ខន្ធក )

៧– វិនយបិដក ( បារាណាខន្ធក )

ភិក្ខុ ធម្មារាមោ បុណ្យ.សុម្ពាជ ម.ឧ

# សីមាវិធី

មុនដំបូង ត្រូវយកដុំថ្ម ដែលមានទម្ងន់ល្មមធ្វើនិមិត្តសីមា ហែប្រទក្សិណរោងឧបោសថ ៣ ជុំ រួចវេរប្រគេនភិក្ខុសង្ឃ ដែលនិមន្តចូលរួម ក្នុងពិធីនោះ ។

### បាលីវេរដុំថ្មជានិមិត្តសីមា

ឱកាស មយំ ភន្តេ ឥមេ មហន្តេ បាសាណបិណ្ឌេ សីមាយ និមិត្តករណត្ថាយ ភិក្ខុសង្ឃស្ស ទេម សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមេ បាសាណបិណ្ឌេ បដិគ្គណ្ហាតុ បដិគ្គហិត្វាន ឥមេហិ បាសាណបិណ្ឌេហិ និមិត្តំ កិត្តេត្វា ខណ្ឌសីមំ សម្មន្នតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

សូមគោរព បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន យើងខ្ញុំទាំងឡាយ សូមវេរនូវដុំថ្មធំ ៗ ទាំងឡាយនេះ ប្រគេនចំពោះព្រះសង្ឃ ដើម្បីប្រយោជន៍ដល់កិរិយាធ្វើ ជានិមិត្តសីមា បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយកនូវដុំថ្មទាំងឡាយនេះ ហើយសន្មត នូវខណ្ឌសីមាចុះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ បន្ទាប់មកនិមន្តព្រះសង្ឃចម្រើនព្រះបរិត្ត ចប់ហើយវេររោងឧបោសថប្រគេនព្រះភិក្ខុសង្ឃ ដែលនិមន្តមកទាំង ៨ ទិស ។

### បាលីវេររោងឧបោសថ

មយំ ភន្តេ ឥមំ (ឧបោសថាគារំ) ការេត្វា ឧបោសថប្បវារណាទិកម្មករណត្ថាយ ចាតុទ្ទិសស្ស ភិក្ខុសង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមំ

(ឧរបាសថាគារំ) បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ តតិយម្បិ ។

បពិត្រព្រះគម្លងសង្ឃដ៏ចម្រើន យើងខ្ញុំទាំងឡាយ បានចាត់ចែងធ្វើ នូវ (រោងសម្រាប់ធ្វើឧបោសថ) នេះ ហើយសូមវេរប្រគេន ដល់ព្រះភិក្ខុសង្ឃ ដែលមកអំពីទិសទាំង ៨ ដើម្បីប្រយោជន៍ដល់កិរិយាធ្វើ នូវសង្ឃកម្ម មានឧបោសថ-កម្ម និង បវារណាកម្មជាដើម បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះភិក្ខុសង្ឃទទួលយក នូវរោងសម្រាប់ធ្វើឧបោសថនេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ អស់វារៈពីរផងផង ។ អស់វារៈបីផងផង ។

រួចលើកដុំថ្មយកទៅដាក់នៅមាត់រណ្ដៅ គ្រប់ទិសទាំង ៨ ។ បន្ទាប់មក រៀបចំធ្វើសីមាសង្ឃកម្ម ។

## របៀបធ្វើសីមាសង្ឃកម្ម

មុនដំបូង ត្រូវព្រះសង្ឃទាំងអស់ សំដែងអាបត្តិ រួចទៅប្រជុំនៅជុំវិញរណ្ដៅសីមាឥន្ទខីល, ត្រូវព្រះមហាថេរ ១ អង្គ ដែលឈ្លាសប្រតិពល (ធ្វើជាវិសុំគាម) ឈរឡើងប្រកាសប្រាប់សង្ឃថា អយំ ភូមិប្បទេសោ ទិសំ គាមោ វហាតុ ប្រទេសនេះ នូវជាប្រទេសផ្សេងអំពីស្រុក ។ រួចហើយព្រះសង្ឃជាវិសុំគាម នាំព្រះសង្ឃគ្រប់អង្គសូត្រ សព្វេ ពុទ្ធា ពលប្បត្តា បច្ចេកានញ្ច យំ ពលំ អរហន្តានញ្ច តេជេន រក្ខំ ពន្ធាមិ សព្វសោ ។ សូត្រ ៣ ចប់ហើយ ទើបផ្ដើមសូត្រដកសីមា ។ ត្រូវដកអវិប្បវាសសីមាមុន សឹមសូត្រដក សមានសំវាសសីមាក្រោយ ។ សូត្រដករួចហើយ ត្រូវសួរនិមិត្តសីមាទាំង ៨ ទិស ចាប់ពីទិសខាងកើត ទិសបន្ទាប់ ទិសខាងត្បូង ខាងបន្ទាប់ ខាងលិច ខាងបន្ទាប់ ខាងជើង ខាងបន្ទាប់ រួចហើយ សួរ

ទិសខាងកើតម្ដងទៀត ។ លុះសូត្រនិមិត្តរួចហើយ ត្រូវព្រះសង្ឃទាំងអស់ មកជួបជុំគ្នា ក្នុងរោងឧបោសថ រួចសូត្រចង, សូត្រចង ត្រូវសូត្រ សមានសំវាសសីមាមុន ទើបសូត្រចង អវិប្បវាសសីមាក្រោយ រួចហើយទើបសូត្រសន្មតរោងឧបោសថ ។ ប៉ុន្តែ មុននឹងសូត្រសន្មត ត្រូវព្រះសង្ឃត្រួតពិនិត្យមើល បើវត្តនោះ មានឧបោសថាគារ ២ កន្លែង ដែលសង្ឃសូត្រសន្មតមុនរួចហើយ ត្រូវសង្ឃសូត្រដកមួយចេញ ហើយសូត្រសន្មតតែមួយ ។ ពីព្រោះក្នុងឧបោសថក្ខន្ធកៈ ដែលមានពុទ្ធានុញ្ញាតឱ្យសង្ឃសន្មតឧបោសថាគារ គឺរោងឧបោសថក្នុងសីមា មានពុទ្ធបញ្ញត្តិ ហាមមិនឱ្យសង្ឃសន្មតឧបោសថាគារ ២ កន្លែងក្នុងមហាសីមាមួយ ឬ ក្នុងវត្តមួយឡើយ បើមាន ត្រូវសូត្រញត្តិទុតិយកម្មវាចា ដកឧបោសថាគារមួយខាងចេញ ។

## ពិធីសូត្រដកឧបោសថាគារ

សុណាតុ មេ ភន្តេ សង្ឃោ, យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ (....)(១) ឧបោសថាគារំ សមូហនេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ, សង្ឃោ (....)(២) ឧបោសថាគារំ សមូហនតិ ។ យស្សាយស្មតោ ខមតិ, (....)(៣) ឧបោសថាគារស្ស សមុគ្ឃាតោ, សោ តុណ្ហស្ស, យស្ស នក្ខមតិ, សោ ភាសេយ្យ ។ សមូហតំ សង្ឃេន (...)(៤) ឧបោសថាគារំ ។ ខមតិ សង្ឃស្ស, តស្មា តុណ្ហី ។ ឯវមេតំ ធារយាមិ ។ រួចហើយទើបសូត្រសន្មត ។

---

១-២-៣-៤ ក្នុងវង់ក្រចកទាំង ៤ នេះសម្រាប់បញ្ចូលឈ្មោះវត្ត

ឧទាហរណ៍ ៖ វត្តឧណ្ណាលោមថា ឧណ្ណាលោមំ ។ល។

## ពិធីសូធ្យសន្មតិឧបោសថាគារ

សង្ឃត្រូវប្រជុំគ្នាក្នុងវិហារ ឲ្យបានត្រឹមត្រូវតាមលក្ខណៈសង្ឃកម្ម ហើយត្រូវចាត់ភិក្ខុ ១ រូប អ្នកឈ្លាសប្រតិពល ឲ្យសូធ្យបាលីញត្តិទុតិយកម្មវាចា សន្មតឧបោសថាគារ ដោយយកនាមវត្តជាភាសាបាលីបញ្ចូលផងថា

**សុណាតុ មេ ភន្តេ សង្ឃោ, យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ (.....)(១) វិហារំ ឧបោសថាគារំ សម្មន្នេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ (.....)(២) វិហារំ ឧបោសថាគារំ សម្មន្នតិ ។ យស្សាយស្មតោ ខមតិ, (.....)(៣) វិហារស្ស ឧបោសថាគារស្ស សម្មតិ, សោ តុណ្ហស្ស, យស្ស នក្ខមតិ, សោ ភាសេយ្យ ។ សម្មតោ សង្ឃេន (.....) ៤) វិហារោ ឧបោសថាគារំ ។ ខមតិ សង្ឃស្ស, តស្មា តុណ្ហី ។ ឯវមេតំ ធារយាមិ ។** កាលបើសង្ឃ បានសន្មតដូច្នេះហើយ វិហារនោះក៏បានឡើងជាឧបោសថាគារ តាមពុទ្ធានុញ្ញាត ។

---

១-២-៣-៤ ក្នុងវង់ក្រចកទាំង ៤ នេះសម្រាប់បញ្ចូលឈ្មោះវត្ត
ឧទាហរណ៍ : វត្តឧណ្ណាលោមថា ឧណ្ណាលោមំ ។ ល ។

# សីមាវិនិច្ឆ័យសង្ខេប

ដើមហេតុដែលកើតមានពុទ្ធានុញ្ញាត ឲ្យមានសីមានោះ សេចក្ដីថា ក្នុងសម័យ ១ ព្រះបរមគ្រូជាម្ចាស់ ទ្រង់គង់នៅទៀបភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ទ្រង់អនុញ្ញាតឲ្យភិក្ខុសង្ឃ ប្រជុំគ្នាសម្ដែងបាតិមោក្ខ ក្នុងថ្ងៃ ១៤ ឬ ១៥ ក្នុង ១ បក្ស(១) ម្ដង។ក្នុងកាលនោះ ឆព្វគ្គិយភិក្ខុទាំងឡាយ ក៏នាំគ្នាសម្ដែងបាតិមោក្ខតែក្នុងពួកភិក្ខុជាបរិស័ទរបស់ខ្លួន ៗ ព្រះសម្មាសម្ពុទ្ធទ្រង់បានជ្រាបដំណើរនោះហើយ ទើបទ្រង់បញ្ញត្តហាមដោយទុក្កដវារៈ ហើយទ្រង់អនុញ្ញាតឲ្យសម្ដែងបាតិមោក្ខ ដល់ភិក្ខុសង្ឃដែលមកព្រមព្រៀងគ្នាក្នុងទី ១ ។

ភិក្ខុសង្ឃទាំងពួង ក៏មានសេចក្ដីត្រិះរិះថា “ព្រះមហាករុណាទ្រង់អនុញ្ញាតឲ្យសម្ដែងបាតិមោក្ខដល់ភិក្ខុសង្ឃ ដែលមកព្រមព្រៀងគ្នាក្នុងទី ១ នោះ គឺព្រមព្រៀងគ្នាតែក្នុងអាវាសមួយ ៗ ទេ ឬ ក៏ត្រូវឲ្យភិក្ខុសង្ឃមកពីអាវាសទាំងអស់លើផែនដីមកប្រជុំព្រមព្រៀងគ្នា ក្នុងទី ១ ដែរ ?” ទើបនាំគ្នាទៅក្រាបបង្គំទូលសួរព្រះដ៏មានបុណ្យ ព្រះអង្គក៏អនុញ្ញាតទីដែលភិក្ខុសង្ឃត្រូវមកប្រជុំព្រមព្រៀងគ្នានោះតែក្នុងអាវាសមួយ ៗ ។ ភិក្ខុទាំងឡាយក៏ទូលទៀតថា “ទីអាវាសមួយ ៗ នោះនឹងកំណត់ខេត្តដែនទទឹង, បណ្ដោយប៉ុន្មាន ?” ហើយនាំគ្នាចូលទៅទូលសួរព្រះដ៏មានបុណ្យ ទើបព្រះអង្គអនុញ្ញាតឲ្យសន្មតសីមា ដើម្បីនឹងកំណត់ឲ្យដឹងនូវទីអាវាសរបស់សង្ឃមួយ ៗថា “**អនុជានាមិ ភិក្ខវេ សីមំ សម្មន្និតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុសង្ឃ សន្មតនូវសីមា” ។

(មានសេចក្ដីសម្ដែងដោយពិស្ដារ ក្នុងឧបោសថក្ខន្ធកៈ ក្នុងគម្ពីរមហាវគ្គព្រមទាំងអដ្ឋកថា ។ ដែលសម្ដែងខាងលើនេះដោយសេចក្ដីសង្ខេប ដើម្បីឲ្យតែបុព្វហេតុដែលព្រះសម្មាសម្ពុទ្ធ ទ្រង់អនុញ្ញាតឲ្យសន្មតសីមាប៉ុណ្ណោះ តអំពីនេះទៅ

---

១ គឺក្នុង សុក្កបក្ខ (ខាងខ្នើត) ម្ដង ក្នុងកាឡបក្ខ (ខាងរនោច) ម្ដង ។

នឹងសម្ដែងចំពោះដំណើរសីមាតែម្ដង តាមសមគួរដល់សេចក្ដីក្នុងបាលី និងអដ្ឋកថា ដែលព្រះអដ្ឋកថាចារ្យលោកបានវិនិច្ឆ័យហើយ ដោយសេចក្ដីសង្ខេបដូចមានតទៅក្នុងខាងក្រោមនេះ ) ។

សីមា មានពីរយ៉ាងគឺ

ពទ្ធសីមា  សីមាដែលសង្ឃបានសូត្រចង ១

អពទ្ធសីមា  សីមាដែលសង្ឃមិនបានសូត្រចង ១ ។

## ពទ្ធសីមា

សីមាឯណា ដែលសង្ឃបានធ្វើឲ្យផុតចាកសីមាវិបត្តិទាំង ១១ យ៉ាង និងឲ្យប្រកបដោយសម្បត្តិទាំង ៣ យ៉ាង ហើយចងនូវនិមិត្តដោយនិមិត្ត ហើយបានសូត្រសម្មត សីមានោះ ឈ្មោះថា ពទ្ធសីមា ។

សីមាវិបត្តិ ១១ យ៉ាងគឺ

១- **អតិខុទ្ទកា** សីមាតូចពេក មិនល្មមភិក្ខុ ២១ រូបអង្គុយបាន ។

២- **អតិមហតី** សីមាធំពេក កន្លងទី ៣ យោជន៍ឡើងទៅ ។

៣- **ខណ្ឌនិមិត្តា** សីមាមាននិមិត្តដាច់ គឺមាននិមិត្តមិនតគ្នា គឺថាកំណត់និមិត្តទិសខាងកើតរួចហើយ ក៏កំណត់និមិត្តក្នុងទិសជាលំដាប់ ទៅដល់ទិសខាងជើង ឬទិសណាមួយ ក៏ឈប់នៅទិសនោះទៅ មិនបានកំណត់និមិត្តទិសខាងកើតត្រួតថែមម្ដងទៀត, ពុំនោះយករបស់ណាមួយ ដែលមិនគួរនឹងធ្វើជានិមិត្តបាន មានដើមដូង ត្នោត ឬ ដង្គត់ឈើណាមួយជាដើម ធ្វើជានិមិត្ត ។

៤- **ឆាយា និមិត្តា** យកស្រមោលអ្វីមួយ មានស្រមោលភ្នំជាដើម ធ្វើជានិមិត្ត ។

៥- **អនិមិត្តា** ឥតមានអ្វីមួយជានិមិត្តឡើយ ។

**៦- ពហិ សីមេ ឋិតសម្មតា** កំណត់និមិត្តរួចហើយ ឈរក្រៅនិមិត្តសន្មតសីមា ។

**៧- នទិយា សម្មតា** សន្មតសីមាក្នុងស្ទឹង ឬ ទន្លេ ។

**៨- សមុទ្ទេ សម្មតា** សន្មតសីមាក្នុងសមុទ្រ ។

**៩- ជាតស្សរេ សម្មតា** សន្មតសីមាក្នុងជាតស្រះ គឺស្រះកើតឯងឥតមានអ្នកណាជីក ។

សីមាវិបត្តិទាំង ៣ យ៉ាង តាំងពីទី ៧ ដល់ទី ៩ នេះ បើទុកជាសង្ឃសន្មតឲ្យជាសីមា ក៏ឈ្មោះថាមិនមែនជាសន្មតទេ គឺមិនឡើងជាសីមាឡើយ ព្រោះមានពុទ្ធប្បញ្ញត្តិថា **“សព្វា ភិក្ខវេ នទី អសីមា សព្វោ សមុទ្ទោ អសីមោ សព្វោ ជាតស្សរោ អសីមោ** ម្នាលភិក្ខុទាំងឡាយ ស្ទឹង ទន្លេទាំងមូល សមុទ្រទាំងមូល ជាតស្រះទាំងមូល មិនមែនជាសីមាទេ ” ។

**១០- សីមាយ សីមំ សម្ភិន្ទន្តេន សម្មតា** ទម្លាយនូវសីមាចាស់របស់ភិក្ខុដទៃ ដោយសីមារបស់ខ្លួនហើយសន្មត គឺសន្មតសីមារបស់ខ្លួនឲ្យប៉ះជាប់ទៅនឹងសីមាដទៃ ឬ ឲ្យគ្របទៅក្នុងទីសីមាដទៃ តាំងពីចំនួនទី ១ ចម្រៀកសក់ឡើងទៅ ដរាបដល់ទីដែលភិក្ខុ ៨ រូបអង្គុយមិនបាន ។

**១១- សីមា សីមំ អជ្ឈោត្ថរន្តេន សម្មតា** គ្របសង្កត់នូវសីមារបស់ភិក្ខុដទៃ ដោយសីមារបស់ខ្លួនហើយសន្មត គឺសន្មតសីមារបស់ខ្លួនឲ្យគ្របជ្រុលទៅក្នុងទីពទ្ធសីមារបស់ភិក្ខុដទៃ តាំងពីចំនួនទីប្រមាណភិក្ខុ៨រូបអង្គុយល្មមឡើងទៅ ឬ ធ្វើឲ្យគ្របទៅក្នុងទីពទ្ធសីមា របស់ភិក្ខុដទៃទាំងមូល ។

សម្បត្តិមាន ៣ យ៉ាងនោះគឺ

**និមិត្តសម្បត្តិ** បរិបូណ៌ដោយនិមិត្ត ១

**បរិសសម្បត្តិ** បរិបូណ៌ដោយបរិស័ទ ១

**កម្មវាចាសម្បត្តិ** បរិបូណ៌ដោយកម្មវាចា ១ ។

## និមិត្តសម្បត្តិ

និមិត្តសម្បត្តិនោះ គឺបរិបូណ៌ដោយនិមិត្តមាន ៨ យ៉ាងគឺ

**១- បព្វតនិមិត្តំ** យកភ្នំជានិមិត្ត, ភ្នំនោះមាន ៣ យ៉ាងគឺ ភ្នំដីសុទ្ធ ១ ភ្នំថ្មសុទ្ធ ១ ភ្នំមានដី និងថ្មលាយគ្នា ១ ។ ទំហំភ្នំនោះ តាំងពីប៉ុនរូបដំរីឡើងទៅ ដរាបដល់ប៉ុនភ្នំសិនេរុ គួរធ្វើជានិមិត្តបាន បើតូចជាងរូបដំរី ឬ ធំជាង ប៉ុន្តែជាគំនរខ្សាច់ទទេនោះ មិនគួរធ្វើជានិមិត្តបានឡើយ ។

**២- បាសាណនិមិត្តំ** យកថ្មជានិមិត្ត, ទំហំថ្មនោះយ៉ាងតូចបំផុត ប៉ុនដុំស្ករត្នោត ដែលគេថ្លឹងបានចំនួន ៣២ បល: គឺ ១៤ នាឡិយើងសព្វថ្ងៃនេះ បើតូចជាងនោះមិនគួរ តែបើធំឡើងទៅប៉ុនរូបគោ ឬ ក្របីយ៉ាងធំក៏គួរ តែធំជាងនោះទៅទៀតក៏មិនគួរដែរ ។ បើយកដុំឥដ្ឋធំប៉ុន្មានក្តី ឬ ដុំថ្មតូច ៗ ដែលមិនគួរធ្វើជានិមិត្តបាន យកមកប្រមូលគ្នាជាគំនរឲ្យធំឡើងក្តី ក៏មិនគួរទាំងអស់ ។

**៣- វននិមិត្តំ** យកព្រៃជានិមិត្ត, ព្រៃនោះបើមានសុទ្ធតែស្មៅ ឬ ដើមឈើដែលមានសម្បកខាងក្រៅជាខ្លឹម មានដើមត្នោត និងដើមដូងជាដើម ក៏មិនគួរនឹងធ្វើជានិមិត្តបានឡើយ, បើព្រៃនោះមានពពួកដើមឈើដែលមានខ្លឹមខាងក្នុង មានដើមរាំងជាដើម យ៉ាងតិចបំផុតត្រឹម ៤ ដើម ឬ ៥ ដើម ទើបគួរធ្វើជានិមិត្តបាន ។

**៤- រុក្ខនិមិត្តំ** យកឈើជានិមិត្ត, ឈើនោះបើមានសម្បកក្រៅជាខ្លឹម

មានដើមត្នោត និងដើមដូងជាដើម ក៏មិនគួរនឹងធ្វើជានិមិត្តបានឡើយ បើដើមឈើនោះមានខ្លឹមខាងក្នុង ហើយជាឈើរស់ដុះនៅលើផែនដី ទើបគួរធ្វើជានិមិត្តបាន ។

៥- **មគ្គនិមិត្តំ** យកផ្លូវជានិមិត្ត, ផ្លូវនោះបើវៀចៗ កួចៗ មានផ្លូវដើរចូលទៅកាន់ព្រៃ និងទៅកាន់ទីស្រែជាដើម ក៏មិនគួរនឹងធ្វើជានិមិត្តបានឡើយ, បើផ្លូវវែងៗ ហើយជាផ្លូវគេតែងដើរដោយជើងជាប្រក្រតី ផ្លូវដែលគេតែងបររទេះទៅមកជាប្រក្រតី នោះទើបគួរធ្វើជានិមិត្តបាន ។

៦- **វម្មិកនិមិត្តំ** យកដំបូកជានិមិត្ត កម្ពស់និងទំហំដំបូកនោះ បើយ៉ាងទាបតូចបំផុត កម្ពស់ត្រឹម ៨ ធ្នាប់ ទំហំប៉ុនស្នែងគោប៉ុណ្ណោះ ល្មមធ្វើជានិមិត្តបាន បើទាបតូចជាងនោះ មិនគួរនឹងធ្វើជានិមិត្តបានឡើយ ។

៧- **នទី និមិត្តំ** យកនទី គឺស្ទឹង ឬ ទន្លេជានិមិត្ត, គឺស្ទឹង ឬ ទន្លេដែលទឹកហូរមិនដាច់ ពុំនោះទីណាមួយក្នុងវស្សានរដូវ ទឹកភ្លៀងធ្លាក់ចុះរឿយៗ មានខ្សែទឹកហូរមិនដាច់ ទីនោះ ក៏ហៅថា នទីបាន ព្រះអដ្ឋកថាចារ្យសម្តែងពីលក្ខណៈនៃនទីនោះថា “ក្នុងវស្សានរដូវ ៤ ខែ ទីណាមួយមានខ្សែទឹកហូរមិនដាច់ ទឹកនោះមានជម្រៅល្មមទទឹកដល់ស្មងរបស់នាងភិក្ខុនី ដែលស្លៀកជាបរិមណ្ឌលហើយដើរឆ្លងទៅ ទីនោះក៏ហៅថា នទីបាន” ទីប៉ុណ្ណោះគួរធ្វើជានិមិត្តបាន ។

៨- **ឧទកនិមិត្តំ** យកទឹកជានិមិត្ត, ទឹកនោះបើយកទៅដាក់ក្នុងវត្ថុណាមួយ មានទូក ឬ ពាង អាង ជាដើម នោះមិនគួរនឹងកំណត់ធ្វើជានិមិត្តបានឡើយ ឯទឹកនោះចំពោះយកទឹកដែលដាក់នៅផ្ទាល់លើផែនដី គឺទឹកមិនហូរដែលដក់ក្នុងទីទាំងឡាយមានរណ្តៅ ស្រះបោក្ខរណី បាគស្រះ និងលោណមហាសមុទ្រជាដើម ទឹកយ៉ាងនេះគួរកំណត់ធ្វើជានិមិត្តបាន ។

មួយវិញទៀត (ប្រសិនណាបើទីនោះមិនមានផលទឹកទេ) គប្បីជីកដែនដីធ្វើជារណ្តៅ ហើយដងទឹកមកដាក់ឲ្យពេញក្នុងរណ្តៅនោះ ទឹកនោះឯង កាលណាបើលោកសូត្រកម្មវាចាចប់ទៅ, ក៏ដក់សល់នៅខ្លះទើបឡើងពេញជានិមិត្តបាន, កាលណាបើទឹករីងអស់ទៅ ក៏គប្បីយកគំនរថ្ម ឬ គំនរខ្សាច់មកដាក់ត្រង់ទីនោះ ពុំនោះដាំសសរឈើក្នុងទីនោះក៏បាន ដើម្បីឲ្យជាគ្រឿងសម្គាល់ថា ជានិមិត្ត ។

វត្ថុទាំង ៨ យ៉ាងមានភ្នំជាដើម គួរធ្វើជានិមិត្តបានទាំងអស់ បើបានតែវត្ថុ ១ មុខ ។ មកកំណត់ធ្វើជានិមិត្ត មិនលាយច្រឡំដោយវត្ថុដទៃក្តី និមិត្តនោះលាយច្រឡំគ្នា គឺ ភ្នំជានិមិត្ត ១ ថ្មជានិមិត្ត ១ ព្រៃជានិមិត្ត ១ លាយច្រឡំគ្នាដូច្នេះក្តី ក៏គួរទាំងអស់ ។

មួយវិញទៀត ឯចំនួននិមិត្តនោះមិនមានកំណត់ គិតតាំងពីនិមិត្ត ៣ ឡើងទៅ ដរាបដល់និមិត្តចំនួន ១០០ ក៏សឹងតែបានឥតមានទាស់អ្វីឡើយ តែបើគិតខាងបីគឺនិមិត្តតែ ១ ឬ ២ នោះមិនគួរនឹងកំណត់ជានិមិត្តបានឡើយ ។

សីមាឯណា បើសន្មតដោយនិមិត្តត្រឹមតែ ៣ សីមានោះមានទ្រង់សណ្ឋានជា ៣ ជ្រុង ឬ សណ្ឋានដូចក្បាលក្របី, បើសន្មតដោយនិមិត្ត ៤ សីមានោះមានទ្រង់សណ្ឋានជា ៤ ជ្រុងខ្លះ សណ្ឋានដូចស្គរសម្ភោរខ្លះ បើសន្មតដោយនិមិត្តច្រើនឡើងទៅ ទីសីមានោះរមែងមានសណ្ឋានផ្សេង ៗ គ្នា តាមសមគួរដល់ផែនទីដីដែលមានក្នុងទីនោះ ។

វិធីដែលនឹងកំណត់និមិត្តនោះ គឺថា កាលណាបើបាននិមិត្តទាំង ៨ យ៉ាងនោះ និមិត្តណាមួយល្មមគ្រប់ចំនួនហើយ គប្បីឲ្យភិក្ខុជាវិន័យធរ ១ រូប សួរដណ្តឹងនិមិត្តក្នុងទិសខាងកើតជាមុនថា " **បុរត្ថិមាយ ទិសាយ កឹ និមិត្តំ** អ្វីជានិមិត្តក្នុងទិសខាងកើត ? លំដាប់នោះ ភិក្ខុ ឬ សាមណេរ ឬ គ្រហស្ថគប្បីឆ្លើយប្រាប់មកវិញ, បើនិមិត្តនោះជាថ្មគប្បីឆ្លើយថា " **បាសាណោ ភន្ត**

ថ្មព្រះករុណាម្ចាស់” រួចហើយ ភិក្ខុជាវិន័យធរ គប្បីកំណត់នូវនិមិត្តដោយពាក្យថា “ឯសោ បាសាណោ និមិត្តំ ថ្មនុ៎ះជានិមិត្ត” (កិច្ចដែលសួរ និង ឆ្លើយ និងកំណត់នូវនិមិត្តក្នុងទិសជាលំដាប់ទៅ ដូចគ្នា ប្លែកគ្នាតែឈ្មោះទិស និង ឈ្មោះនិមិត្តប៉ុណ្ណោះ) ។

បើទិសអាគ្នេយ៍ វិន័យធរគប្បីសួរថា “បុរត្ថិមាយ អនុទិសាយ កឹ និមិត្តំ អ្វីជានិមិត្តក្នុងទិសអាគ្នេយ៍” ។ ទិសទក្សិណសួរថា “ទក្ខិណាយ ទិសាយ កឹ និមិត្តំ អ្វីជានិមិត្តក្នុងទិសទក្សិណ?

ទិសនិរតីសួរថា “ទក្ខិណាយ អនុទិសាយ កឹ និមិត្តំ អ្វីជានិមិត្តក្នុងទិសនិរតី? ទិសខាងលិចសួរថា “បច្ឆិមាយ ទិសាយ កឹ និមិត្តំ អ្វីជានិមិត្តក្នុងទិសខាងលិច?” ទិសពាយ័ព្យសួរថា “បច្ឆិមាយ អនុទិសាយ កឹ និមិត្តំ អ្វីជានិមិត្តក្នុងទិសពាយ័ព្យ?” ទិសខាងជើងសួរថា “ឧត្តរាយ ទិសាយ កឹ និមិត្តំ អ្វីជានិមិត្តក្នុងទិសខាងជើង?

ទិសឦសាណសួរថា “ឧត្តរាយ អនុទិសាយ កំ និមិត្តំ អ្វីជានិមិត្តក្នុងទិសឦសាណ?

ឯកិច្ចដែលនឹងឆ្លើយតបមកវិញ និងកំណត់នូវនិមិត្តនោះ បើភ្នំថា “បព្វតោ ភន្តេ” “ឯសោ បព្វតោ និមិត្តំ” ។ បើព្រៃថា “វនំ ភន្តេ” “ឯតំ វនំ និមិត្តំ ។ បើឈើថា “រុក្ខោ ភន្តេ” “ឯសោ រុក្ខោ និមិត្តំ” ។ បើផ្លូវថា “មគ្គោ ភន្តេ “ឯសោ មគ្គោ និមិត្តំ” ។ បើដំបូកថា “វម្មិកោ ភន្តេ

“ ឯសោ វម្មិកោ និមិត្តំ ” ។ បើស្ទឹង ឬ ទន្លេថា “ នទី ភន្តេ “ ឯសា នទី និមិត្តំ ” ។ បើទឹកមិនហូរថា “ ឧទកំ ភន្តេ “ ឯតំ ឧទកំ និមិត្តំ ” ។

កាលបើសួរនិងឆ្លើយ និងកំណត់នូវនិមិត្តគ្រប់ទិសជាលំដាប់រួចហើយ គប្បីសួរ និងឆ្លើយ និងកំណត់ នូវនិមិត្តក្នុងទិសខាងកើតត្រូវថែមម្តងទៀត ; យ៉ាងនេះឈ្មោះថា កំណត់នូវនិមិត្តដោយប្រពៃ បានឈ្មោះថា និមិត្តសម្បត្តិ ។

## បរិសសម្បត្តិ

បរិសសម្បត្តិនោះ គឺបរិបូណ៌ដោយភិក្ខុជាបរិស័ទ , គឺថាភិក្ខុយ៉ាងតិចបំផុតត្រឹម ៤ រូប ច្រើនឡើងទៅមិនកំណត់ ប្រជុំព្រមគ្នាក្នុងសីមា ហើយសន្មតសីមា, យ៉ាងនេះឈ្មោះ បរិសសម្បត្តិ ។

## កម្មវាចាសម្បត្តិ

កម្មវាចាសម្បត្តិនោះ គឺបរិបូណ៌ដោយកម្មវាចា គឺថាភិក្ខុជាអ្នកឈ្លាសស្ទាត់សន្មតសីមា ដោយញត្តិទុតិយកម្មវាចាថា “ សុណាតុ មេ ភន្តេ សង្ឃោ ។ល។ ឯវមេតំ ធារយាមិ ដោយត្រឹមត្រូវតាមបានករណៈ នៃអក្ខរៈ និងប្រភេទនៃអក្ខរៈ មានមិនច្រឡំសិថិលទៅជាធនិត ៗ មកជាសិថិលជាដើម ; យ៉ាងនេះឈ្មោះថា កម្មវាចាសម្បត្តិ ។

( ពាក្យញត្តិទុតិយកម្មវាចានោះ មានចារឹកទុកក្នុងខាងមុខឯណោះ )

សីមាដែលផុតចាកសីមាវិបត្តិ ១១ យ៉ាង និងប្រកបដោយសម្បត្តិទាំង៣យ៉ាង ដូចបានពោលមកហើយក្នុងខាងលើនេះ ឈ្មោះថា ពទ្ធសីមា ។ ពទ្ធសីមានោះមាន ៣ យ៉ាងគឺ សមានសំវាសសីមា ១ អវិប្បវាស-

សីមា ១ ខណ្ឌសីមា ១ ។

សមានសំវាសសីមា គឺសីមា មានសំវាសស្មើគ្នា ជាដែនសម្រាប់សង្ឃធ្វើសង្ឃកម្ម ដោយព្រមព្រៀងគ្នា ។

អវិប្បវាសសីមា គឺសីមាដែលសង្ឃសន្មត សង្កត់ត្រួតពីលើ សមានសំវាស-សីមា ដោយញត្តិទុតិយកម្មវាចា ដទៃពីសមានសំវាសសីមា ដើម្បីភិក្ខុសង្ឃនឹងនៅប្រាសចាកត្រៃចីវរបាន ( បាលីដែលសូត្យសន្មត សមានសំវាសសីមា និងអវិប្បវាសសីមានោះ មានចារិកទុកក្នុងខាងមុខ ។

ខណ្ឌសីមា គឺសីមាតូច ដែលសង្ឃសន្មតទុកក្នុងខាងក្នុងពទ្ធសីមាធំ (មហា-សីមា ) ដើម្បីនឹងធ្វើសង្ឃកម្មទាំងឡាយ មានឧបសម្បទាកម្មជាដើម បានដោយងាយ គឺថា មិនរង្កៀសដោយភិក្ខុដទៃ ដែលនឹងចូលមកក្នុងសីមានោះ ។

( ខណ្ឌសីមានោះ គឺសីមាដែលយើងធ្វើក្នុងស្រុកខ្មែរយើងសព្វថ្ងៃនេះ បានសន្មតទីរោងឧបោសថទាំងមូល ឲ្យជាខណ្ឌសីមា ។ ឯទំហំខណ្ឌសីមានោះ បើយ៉ាងតូចបំផុតត្រឹមភិក្ខុចំនួន ២១ រូបអង្គុយល្មម តូចជាងនោះមិនគួរ បើធំឡើងទៅភិក្ខុចំនួន ១០០ រូបអង្គុយល្មមក៏គួរ ។ ឯវិធីដែលនឹងសូត្យសន្មតខណ្ឌសីមានោះ គឺត្រូវសន្មតជាសមានសំវាសសីមាជាមុនហើយ សឹមសន្មតអវិប្បវាសសីមាជាខាងក្រោយ ដូចជាវិធីដែលសន្មតមហាសីមានោះដែរ ។ ព្រោះហេតុនោះបានជាដល់កាលដែលនឹងសូត្យដក ត្រូវសូត្យដកអវិប្បវាសសីមាមុន ហើយសឹមសូត្យដកសមានសំវាសសីមាជាខាងក្រោយ ព្រោះអវិប្បវាសសីមា បិតនៅខាងលើនៃសមានសំវាសសីមា ។

ឯកិច្ចដែលនឹងសូត្យដកសីមានោះ ព្រោះអាស្រ័យហេតុ ២ យ៉ាងគឺ

១- សីមាតូច សង្ឃចង់ធ្វើសីមានោះ ឲ្យធំចម្រើនជាងមុន ទើបសូត្យដកសីមាតូចនោះចេញ ហើយសន្មតជាថ្មីឡើង ។

២- សីមាធំ សង្ឃចង់ធ្វើសីមានោះឲ្យតូចទៅវិញ ប្រយោជន៍នឹងឲ្យមានឱកាសដល់វិហារនៃភិក្ខុវត្តឯទៀត ទើបសូត្រឲ្យដកសីមាធំនោះចេញ ហើយសន្មតវាថ្មីឡើង ។

( បាលីដែលសូត្រឲ្យដកអវិប្បវាសសីមា និងសមានសំវាសសីមានោះ មានវារិកទុកក្នុងខាងមុខ ) ។

ឯពទ្ធសីមា ដែលសង្ឃបានសន្មតហើយស្រេចជាមហាសីមាក្តី ខណ្ឌសីមាក្តី សីមាទាំងនេះដែលនឹងត្រឡប់ទៅជាទីទទេ មិនមែនជាទីសីមាទៅវិញនោះ ដោយហេតុ ២ យ៉ាងគឺ ដោយសង្ឃត្រូវការសូត្រឲ្យដកសីមានោះដោយញត្តិទុតិយកម្មវាចា១ ដោយផុតអស់ព្រះពុទ្ធសាសនា ១ ។ °

ពទ្ធសីមាចប់ ដោយសង្ខេបតែប៉ុណ្ណេះ ។

## អពទ្ធសីមា

សីមាដែលសង្ឃមិនបានសូត្រឲ្យចង មិនបានសន្មត ឈ្មោះថា **អពទ្ធសីមា** ។ នេះមាន ៣ យ៉ាង : **គាមសីមា ១ សត្តព្ភន្តរសីមា១ ឧទកុក្ខេបសីមា ១** ។

## គាមសីមា

ទីជាគាមក្ខេត្ត គឺទីស្រុកមួយ ៗ និគមមួយ ៗ ឈ្មោះថា **គាមសីមា** ។ នេះ ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតដល់ភិក្ខុ ជាគាមវាសីទាំងឡាយ គឺភិក្ខុដែលអាស្រ័យនៅក្នុងស្រុកជាប្រក្រតី ថា "**អសម្មតាយ ភិក្ខវេ សីមាយ អដ្ឋបិតាយ យំ គាមំ វា និគមំ វា ឧបនិស្សាយ វិហរតិ យា គាមស្ស វា គាមសីមា និគមស្ស វា និគមសីមា**

**អយំ គត្ថ សមានសំវាសា ឯកូបោសថា** ( សេចក្ដីថា ) ម្នាលភិក្ខុទាំងឡាយ កាលបើសីមាសង្ឃមិនទាន់បានសន្មត មិនទាន់បានតាំងទុក ហើយភិក្ខុចូលទៅអាស្រ័យនៅនឹងស្រុកនឹងនិគមឯណាមួយ ទីដែននៃស្រុក និង និគមនោះ មានទំហំធំតូចប៉ុន្មាន, ទីដែនប៉ុណ្ណោះជាសីមាទាំងអស់ មានសំវាស ស្មើគ្នា មានឧបោសថជាមួយគ្នា ។ ក្នុងអដ្ឋកថា ថា " **គាម** " សព្ទនេះប្រែ ថា " ស្រុក " ត្រូវសង្គ្រោះយក " **នគរ** " សព្ទដែលប្រែថា " ទីក្រុង " បញ្ចូលក្នុងគាមសព្ទនេះផង អាស្រ័យហេតុនេះ ទីក្រុងក្ដី ស្រុកក្ដី និគមក្ដី ឈ្មោះថា **គាមសីមា** ទាំងអស់ ។ មួយាងទៀត បើបរមក្សត្រ ស្ដេចបាន កំណត់ទីភូមិប្រទេសណាមួយ ក្នុងគាមក្ខេត្តឯណា ១ ថា " ទីនេះចូលជាវិសុំគាម (ស្រុកផ្សេងចុះ) ហើយបានព្រះរាជទានផ្ដាច់ដល់អ្នកណាមួយ, ទីភូមិប្រទេស នោះឈ្មោះ **វិសុំគាមសីមា** ; ព្រោះហេតុនោះ វិសុំគាមសីមា ទីសីមា ដទៃ គឺគាមសីមា, នគរសីមា, និគមសីមាក្ដី ក៏អាចសម្រេចនូវសង្ឃកម្មទាំង ពួង មានឧបសម្បទាកម្ម និងឧបោសថកម្មជាដើមដល់ភិក្ខុសង្ឃបាន ដូចជាពទ្ធសីមា ដែរ ប៉ុន្តែមិនអាចនឹងរក្សានូវ តិចីវរាវិប្បវាស គឺមិនអាចនឹងនៅប្រាសចាកត្រៃ-ចីវរ ឲ្យឆ្ងាយពីហត្ថបាសក្នុងគាមសីមានោះបានឡើយ គាមសីមាប្លែកគ្នានឹងពទ្ធ-សីមាតែមួយាងប៉ុណ្ណោះ ។

## សត្តព្ភន្តរសីមា

ក្នុងទីព្រៃសុទ្ធមិនមានស្រុក ក្នុងរវាង ៧ អព្ភន្តរៈដោយជុំវិញ ឈ្មោះថា **សត្តព្ភន្តរសីមា** ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់អនុញ្ញាតដល់ភិក្ខុជារនវាសី ទាំងឡាយ គឺភិក្ខុដែលអាស្រ័យនៅក្នុងព្រៃជាប្រក្រតីថា " **អគាមកេ ភិក្ខវេ អរញ្ញេ សមន្តា សត្តព្ភន្តរា អយំ គត្ថ សមាន-**

**សំវាសា ឯករត្តបាសថា** (សេចក្តីថា) ម្នាលភិក្ខុទាំងឡាយ ទី ៧ អព្ភន្តរៈដោយជុំវិញ ក្នុងព្រៃមិនមានស្រុក ទីប៉ុណ្ណោះជាទីមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ។ ក្នុងអដ្ឋកថា ថា អព្ភន្តរៈមួយ ៗ នោះ មានប្រវែង ២៨ ហត្ថ, ក៏ទី ៧ អព្ភន្តរៈដោយជុំវិញនោះ គឺវាស់អំពីភិក្ខុដែលអង្គុយនៅ ក្នុងទីបំផុតភិក្ខុជាបរិស័ទទាំងពួង ចេញទៅគ្រប់ៗទិសដោយជុំវិញ ព្រោះហេតុនោះឯង សីមានោះដែលនឹងចម្រើនធំឡើង ក៏ចម្រើនធំឡើងដោយអំណាចភិក្ខុដែលជាបរិស័ទមានច្រើន ដែលនឹងថយតូចចុះទៅ ក៏ថយតូចចុះដោយអំណាចភិក្ខុជាបរិស័ទមានតិច ។

សត្តព្ភន្តរសីមានេះ បានឈ្មោះថា តិចីវរាវិប្បវាសផង ព្រោះអាចនឹងនៅប្រាសចាកត្រៃចីវរបាន ក្នុងចន្លោះទី ៧ អព្ភន្តរៈដោយជុំវិញ តែថា កាលនឹងនៅប្រាសចាកត្រៃចីវរ ដែលទុកក្នុងរវាងទី ៧ អព្ភន្តរៈបាននោះ ឲ្យវាស់អំពីភិក្ខុជាម្ចាស់របស់ចេញទៅ ក្នុងទិសមួយ ៗ ៧ អព្ភន្តរៈដោយជុំវិញផ្សេង ៗ គ្នា បើវាស់គាត់ត្រង់អំពីទិសម្ខាងទៅម្ខាងនោះបាន ១៤ អព្ភន្តរៈគ្រប់ ៗ រូប, បើបែរជាទុកចីវរឲ្យផុតអំពីទី ៧ អព្ភន្តរៈ ដោយជុំវិញខ្លួននោះទៅ លុះអរុណរះឡើង ចីវរនោះជានិស្សគ្គិយ ភិក្ខុជាម្ចាស់ចីវរ ត្រូវអាបត្តិបាចិត្តិយ, ព្រោះហេតុនោះ បានជាត្រូវវាស់ទី ៧ អព្ភន្តរៈដោយជុំវិញចំពោះភិក្ខុ ១ រូប ៗ, ឯដែលឲ្យវាស់អំពីភិក្ខុជាទីបំផុត នៃបរិស័ទចេញទៅនោះ ចំពោះតែសីមាដែលសង្ឃធ្វើសង្ឃកម្មទាំងពួងនោះទេ ។ បើសង្ឃពីរពួក នឹងធ្វើវិនយកម្មផ្សេងគ្នា ដោយអព្ភន្តរសីមាក្នុងព្រៃជិតគ្នានោះ គប្បីទុកទីចន្លោះចំនួន ៧ អព្ភន្តរៈជាសីមន្តរិក (១) ក្នុងចន្លោះសត្តព្ភន្តរសីមាទាំងពីរនោះ ដើម្បីនឹងកុំឲ្យមានសេចក្តីទង្គៀសដល់សីមាទាំងពីរនោះឯង ។

---

១ សីមន្តរិក ប្រែថា "ទីឆាយចន្លោះនៃសីមា" គឺទីដីទំនេរ មិនមែនជាសីមាដែលសង្ឃទុកឲ្យនៅនៃសីមា មិនឲ្យជំពាក់គ្នា ។

## ឧទកុក្ខេបសីមា

ក្នុងនទី គឺ ស្ទឹង ឬ ទន្លេ សមុទ្រ និងជាតស្រះ ក្នុងរវាងទីដែលសាចទឹក ឈ្មោះថា **ឧទកុក្ខេបសីមា** ។ ទីទាំងឡាយមានស្ទឹងជាដើមនោះ កាលពីមុនដំបូង ព្រះសម្មាសម្ពុទ្ធ ទ្រង់ហាមមិនឲ្យធ្វើពទ្ធសីមាថា " **សព្វា ភិក្ខវេ នទី អសីមា សព្វោ សមុទ្ទោ អសីមោ សព្វោ ជាតស្សរោ អសីមោ** ( សេចក្តីថា ) ម្នាលភិក្ខុទាំងឡាយ នទី គឺ ស្ទឹង ឬ ទន្លេទាំងមូល មិនមែនជាទីសីមាទេ ( បើទុកជាសន្មត ក៏ឈ្មោះថា មិនមែនសន្មត គឺមិនឡើងជាសីមាឡើយ ) ។ លុះដល់មកខាងក្រោយ ទើបព្រះអង្គអនុញ្ញាតឧទកុក្ខេបសីមា ក្នុងទីទាំងឡាយមានស្ទឹងជាដើមនោះថា **នទិយា វា ភិក្ខវេ សមុទ្ទេ វា ជាតស្សរេ វា យំ មជ្ឈិមស្ស បុរិសស្ស សមន្តា ឧទកុក្ខេបា អយំ តត្ថ សមានសំវាសា ឯកូបោសថា** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ទីឯណាក្នុងស្ទឹង ឬ ទន្លេ ក្នុងសមុទ្រ ក្នុងជាតស្រះ ទីនោះកំណត់ត្រឹមខាងក្នុងរវាងទីដែលសាចទឹកនៃមជ្ឈិមបុរសដោយជុំវិញ នេះឈ្មោះថា សីមាមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ។

## អធិប្បាយដោយសង្ខេបតាមន័យ
## ក្នុងអដ្ឋកថា និង ដីកា

ដែលហៅថា **ឧទកុក្ខេប** "កិរិយាសាចទៅនូវទឹក នោះគឺ បុរសមានកម្លាំងយ៉ាងកណ្តាល យកទឹក ឬ ខ្សាច់សាចទៅ ឬបាចទៅដោយពេញកម្លាំងដៃ , ទឹក ឬខ្សាច់ដែលសាចបាចទៅនោះ ធ្លាក់ចុះក្នុងទីត្រឹមណា ទីត្រឹម

ណោះហៅថា មួយឧទកុក្ខេប គឺ ១ ផ្លូវទឹសាចទឹក ។ ឧទកុក្ខេបនេះគិតអំពីទីបំផុត ជុំវិញនៃភិក្ខុបរិស័ទជាប្រមាណ ។ បើមានភិក្ខុច្រើនពួកធ្វើសង្ឃកម្មផ្សេងគ្នា គប្បីទុកឱកាសចំនួនទី ១ ផ្លូវសាចទឹក ឲ្យជាសីមន្តរិកក្នុងចន្លោះនៃសីមាទាំងពីរនោះ ។ បើភិក្ខុទាំងឡាយ ចង់ធ្វើសង្ឃកម្មក្នុងស្ទឹង ឬ ទន្លេ ។ នោះមានទឹកច្រើន ក៏គប្បីស្ថិតនៅក្នុងទូក ហើយធ្វើសង្ឃកម្មចុះ បើទូកនោះអណ្តែតចុះឡើង នឹងធ្វើសង្ឃ-កម្មក៏មិនគួរ ព្រោះថាប្រមាណនៃទីសីមានោះ កំណត់ត្រឹមទីដែលសាចទឹកដោយជុំវិញប៉ុណ្ណោះ កាលបើទូកអណ្តែតទៅដោយរហ័ស កន្លងហួសទីសីមានោះទៅ ញត្តិក៏នឹងមានក្នុងសីមាដទៃ អនុសាវនានឹងមានក្នុងសីមាដទៃ ព្រោះហេតុនោះ គប្បីបោះបង្គោលចងទូកឲ្យនៅនឹងក្តី ចងជុំថ្មសណ្តូនទៅក្នុងទឹក ឬបោះយុថ្កាទប់ទូកឲ្យនៅនឹងក្តី ចងទូកនឹងដើមឈើដែលនៅក្នុងទឹកនោះក្តី ហើយសឹមធ្វើសង្ឃកម្មចុះ ។ បើទូកនោះអណ្តែតចុះឡើងតែក្នុងផ្លូវសាចទឹកដដែលនោះ ក៏គួរធ្វើសង្ឃកម្មបាន ។ មួយទៀត បើចងទូកភ្ជាប់នឹងដើមឈើដែលនៅក្នុងទឹកនោះ សូម្បីឈើនោះនៅខាងក្រៅផ្លូវសាចទឹកក៏គួរមិនជាទោស ព្រោះទឹកនិងឧទកុក្ខេបនោះ ជារបស់ត្រូវគ្នា អាស្រ័យគ្នាបាន ហាមដាច់តែមិនឲ្យចងទូកភ្ជាប់នឹងបង្គោល ឬ ដើមឈើដែលនៅលើច្រាំង ព្រោះទីច្រាំងនិងឧទកុក្ខេបនោះ មិនមែនជារបស់ត្រូវគ្នាអាស្រ័យគ្នាបានឡើយ ។ បើភិក្ខុស្ថិតនៅលើរាន , លើក្បូន , លើផែដែលនៅក្នុងទឹក ក៏គួរធ្វើសង្ឃកម្មបានប៉ុន្តែត្រូវធ្វើបាន តែក្នុងទីផ្លូវសាចទឹក ។ បើភិក្ខុស្ថិតនៅលើស្ពាន , ចុងស្ពានក្តី សសរស្ពានក្តី ស្ថិតនៅតែក្នុងទី នោះគួរនឹងធ្វើសង្ឃកម្មបាន ។ បើចុងស្ពានក្តី សសរស្ពានក្តី ជាប់តគ្នារហូតដល់មាត់ច្រាំង នោះមិនគួរនឹងធ្វើសង្ឃកម្មឡើយ ។ បើសសរស្ពាននៅក្នុងទី ប៉ុន្តែស្ពានវែងហួសទៅលើច្រាំងទាំងសងខាង អណ្តែតខ្ពស់ឡើងមិនជាប់នឹងផែនដីមាត់ច្រាំងទេ ភិក្ខុទាំងឡាយស្ថិតនៅលើស្ពាននោះ គួរនឹងធ្វើសង្ឃកម្មបាន ។

សីមាវិនិច្ឆ័យ ចប់ដោយសង្ខេប ។

សុណាតុ មេ ភន្តេ សង្ឃោ, យោ សោ សង្ឃេន តិចីវរេន អវិប្បវាសោ សម្មតោ, យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ តំ តិចីវរេន អវិប្បវាសំ សមូហនេយ្យ; ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ, យោ សោ សង្ឃេន តិចីវរេន អវិប្បវាសោ សម្មតោ, សង្ឃោ តំ តិចីវរេន អវិប្បវាសំ សមូហនតិ, យស្សាយស្មតោ ខមតិ, ឯតស្ស តិចីវរេន អវិប្បវាសស្ស សមុគ្ឃាតោ, សោ តុណ្ហស្ស, យស្ស នក្ខមតិ, សោ ភាសេយ្យ ។ សមូហតោ សោ សង្ឃេន តិចីវរេន អវិប្បវាសោ, ខមតិ សង្ឃស្ស, តស្មា តុណ្ហី, ឯវមេតំ ធារយាមិ ។

ពាក្យប្រែ

បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ ភូមិប្រទេសឯណា ដែលសង្ឃសន្មតហើយ ឲ្យជាដែនមិនទៅប្រាសចាកត្រៃចីវរ, បើសង្ឃកម្មនេះមានកាលដ៏សមគួរហើយ, សង្ឃគប្បីដកនូវភូមិប្រទេសមិនទៅប្រាសចាកត្រៃចីវរនោះ វាចានេះជាញត្តិ គឺវាចាប្រកាសឲ្យសង្ឃជ្រាប ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ ភូមិប្រទេសឯណា ដែលសង្ឃសន្មតហើយ ឲ្យជាដែនមិនទៅប្រាសចាកត្រៃចីវរ (ឥឡូវ) សង្ឃដកនូវភូមិប្រទេសមិនទៅប្រាសចាកត្រៃចីវរនោះ កិរិយាដកនូវភូមិប្រទេសមិនទៅប្រាសចាកត្រៃចីវរនោះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម

(បើ) មិនគួរដល់លោកដ៏មានអាយុ អង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវធ្វើយមកចុះ ។ ភូមិប្រទេសមិននៅប្រាសចាកត្រៃចីវរនោះ ដែលសង្ឃដករួចហើយ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវសេចក្ដីនេះ ដោយហេតុដែលសង្ឃស្ងៀមយ៉ាងនេះ ។

បាលីសូត្រដកសមានសំវាសសីមា

សុណាតុ មេ ភន្តេ សង្ឃោ, យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកុបោសថា, យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ តំ សីមំ សមូហនេយ្យ; ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ, យា សា សង្ឃេន សីមា សម្មតា, សមានសំវាសា ឯកុបោសថា, សង្ឃោ តំ សីមំ សមូហនតិ, យស្សាយស្មតោ ខមតិ, ឯតិស្សា សីមាយ សមានសំវាសាយ សមុគ្ឃាតោ, សោ តុណ្ហស្ស, យស្ស នក្ខមតិ, សោ ភាសេយ្យ ។ សមូហតា សា សីមា សង្ឃេន សមានសំវាសា ឯកុបោសថា, ខមតិ សង្ឃស្ស, តស្មា តុណ្ហី, ឯវមេតំ ធារយាមិ ។

ពាក្យប្រែ

បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្ដាប់ពាក្យរបស់ខ្ញុំ សីមាឯណាដែលសង្ឃសន្មតហើយ ឲ្យជាសីមាមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា, បើសង្ឃកម្មនេះ មានកាលដ៏សមគួរហើយ, សង្ឃគប្បីដកនូវសីមានោះ, វាចានេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្ដាប់ពាក្យរបស់ខ្ញុំ សីមា

ឯណាដែលសង្ឃសន្មតហើយ ឲ្យជាសីមាមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ( ឥឡូវ ) សង្ឃដកនូវសីមានោះ, កិរិយាដកនូវសីមា មានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នានោះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម ( បើ ) មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវឆ្លើយមកចុះ ។ សីមាមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នានោះ ដែលសង្ឃដករួចហើយ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវសេចក្ដីនេះ ដោយហេតុដែលសង្ឃស្ងៀមយ៉ាងនេះ ។

### បាលីសូធ្យសន្មតសមានសំវាសសីមា

សុណាតុ មេ ភន្តេ សង្ឃោ, យាវតិកា សមន្តា និមិត្តា កិត្តិតា, យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ ឯតេហិ និមិត្តេហិ សីមំ សម្មន្នេយ្យ សមានសំវាសំ ឯកុបោសថំ; ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ, យាវតិកា សមន្តា និមិត្តា កិត្តិតា, សង្ឃោ ឯតេហិ និមិត្តេហិ សីមំ សម្មន្នតិ សមានសំវាសំ ឯកុបោសថំ, យស្សាយស្មតោ ខមតិ, ឯតេហិ និមិត្តេហិ សីមាយ សម្មតិ សមានសំវាសាយ ឯកុ-បោសថាយ, សោ តុណ្ហស្ស, យស្ស នក្ខមតិ, សោ ភាសេយ្យ ។ សម្មតា (សា) សីមា សង្ឃេន ឯតេហិ និមិត្តេហិ សមានសំវាសា ឯកុបោសថា, ខមតិ សង្ឃស្ស, តស្មា តុណ្ហី, ឯវមេតំ ធារយាមិ ។

## ពាក្យប្រែ

បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ និមិត្តទាំងឡាយដែលគេកំណត់ទុកហើយដោយជុំវិញ ត្រឹមណា បើសង្ឃកម្មនេះ មានកាលដ៏សមគួរហើយ, សង្ឃគប្បីសន្មតសីមាឲ្យមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ដោយនិមិត្តទាំងឡាយនោះ វាចានេះ ជាញត្តិ ។

បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ និមិត្តទាំងឡាយដែលគេកំណត់ទុកហើយដោយជុំវិញ ត្រឹមណា ( ឥឡូវ ) សង្ឃសន្មតនូវសីមាឲ្យមានសំវាសស្មើគ្នា ឲ្យមានឧបោសថជាមួយគ្នា ដោយនិមិត្តទាំងឡាយនោះ ។ កិរិយាសន្មតិនូវសីមាឲ្យមានសំវាសស្មើគ្នា ឲ្យមានឧបោសថជាមួយគ្នាដោយនិមិត្តទាំងឡាយនោះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម ( បើ ) មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវឆ្លើយមកចុះ ។ សីមាដែលសង្ឃសន្មតហើយឲ្យមានសំវាសស្មើគ្នា ឲ្យមានឧបោសថជាមួយគ្នា ដោយនិមិត្តទាំងឡាយនោះ គួរដល់សង្ឃព្រោះហេតុនោះ បានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវសេចក្តីនេះ ដោយហេតុដែលសង្ឃស្ងៀមយ៉ាងនេះ ។

## បាលីសូត្រសន្មតតិចីវរាវិប្បវាស

សុណាតុ មេ ភន្តេ សង្ឃោ, យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកូបោសថា, យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ តំ សីមំ តិចីវរេន អវិប្បវាសំ សម្មន្នេយ្យ, ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ, យា សា សង្ឃេន សីមា សម្មតា សមានសំវាសា ឯកូបោសថា, សង្ឃោ តំ សីមំ

តិចីវរេន អវិប្បវាសំ សម្មតិ ឋបេត្វា គាមញ្ច គាមូបចារញ្ច ។ យស្សាយស្មតោ ខមតិ, ឯតិស្សា សីមាយ តិចីវរេន អវិប្បវាសាយ សម្មតិ ឋបេត្វា គាមញ្ច គាមូបចារញ្ច, សោ តុណ្ហស្ស, យស្ស នក្ខមតិ, សោ ភាសេយ្យ ។ សម្មតា សា សីមា សង្ឃេន តិចីវរេន អវិប្បវាសា ឋបេត្វា គាមញ្ច គាមូបចារញ្ច ខមតិ សង្ឃស្ស, តស្មា តុណ្ហី, ឯវមេតំ ធារយាមិ ។

ពាក្យប្រែ

បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ សីមាឯណា ដែលសង្ឃសន្មតហើយ ឲ្យមានសំវាសស្មើគ្នា ឲ្យមានឧបោសថជាមួយគ្នា, បើសង្ឃកម្មនេះ មានកាលដ៏សមគួរហើយ, សង្ឃគប្បីសន្មតសីមានោះ ឲ្យជាដែនមិននៅប្រាសចាកត្រៃចីវរ វៀរលែងតែស្រុកនិងឧបចារៈនៃស្រុកចេញ, វាចានេះ ជាញត្តិ គឺវាចាប្រកាសសង្ឃឲ្យជ្រាប ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ, សីមាដែលសង្ឃសន្មតហើយឲ្យមានសំវាសស្មើគ្នា ឲ្យមានឧបោសថជាមួយគ្នា (ឥឡូវ) សង្ឃសន្មតនូវសីមានោះ ឲ្យជាដែនមិននៅប្រាសចាកត្រៃចីវរ វៀរលែងតែស្រុក និងឧបចារៈនៃស្រុកចេញ ។ កិរិយាសន្មតនូវសីមានុ៎ះ ឲ្យជាដែនមិននៅប្រាសចាកត្រៃចីវរ វៀរលែងតែស្រុក និងឧបចារៈនៃស្រុកចេញ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវឆ្លើយមកចុះ ។ សីមានោះដែលសង្ឃបានសន្មតហើយ ឲ្យជាដែនមិននៅប្រាសចាកត្រៃចីវរ វៀរលែងតែស្រុក និងឧបចារៈនៃស្រុកចេញ គួរដល់

សង្ឃ, ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវសេចក្ដីនេះ ដោយហេតុដែលសង្ឃស្ងៀមយ៉ាងនេះ ។

ពាក្យសួរក្នុងរឿងសីមាវិនិច្ឆ័យនេះ

១- ហេតុដូចម្ដេច បានជាព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យសន្មតនូវសីមា ។

២. សីមាមានប៉ុន្មានយ៉ាង ។

៣. ដូចម្ដេចហៅថា ពទ្ធសីមា ។

៤- ដូចម្ដេចហៅថា អពទ្ធសីមា ។

៥- ពទ្ធសីមា មានសេចក្ដីអធិប្បាយដូចម្ដេច ។

៦. សីមាវិបត្តិ មានប៉ុន្មានយ៉ាង, អ្វីខ្លះ ។

៧- សីមាវិបត្តិទី ១០ និងទី ១១ មានសេចក្ដីប្លែកគ្នាដូចម្ដេចខ្លះ ។

៨- សម្បត្តិ មានប៉ុន្មានយ៉ាង, អ្វីខ្លះ ។

៩- និមិត្តសម្បត្តិ ដូចម្ដេច ។

១០- និមិត្តនោះ បើយ៉ាងតិចបំផុតត្រឹមចំនួនប៉ុន្មាន ទើបអាចនឹងសន្មតសីមាបាន ។

១១. និមិត្តថ្មយ៉ាងតូចបំផុត ទំហំ ប៉ុណ្ណា ។

១២- បរិសសម្បត្តិ ដូចម្ដេច ។

១៣- កម្មវាចាសម្បត្តិ ដូចម្ដេច ។

១៤- ពទ្ធសីមា មានប៉ុន្មានយ៉ាង ។

១៥- សមានសំវាសសីមា, អវិប្បវាសសីមា និងខណ្ឌសីមា មានសេចក្ដីប្លែកគ្នាដូចម្ដេចខ្លះ ។

១៦_ សីមាដែលតែងធ្វើក្នុងស្រុកយើងសព្វថ្ងៃ ហៅថា សីមាអ្វី ។

១៧- កិច្ចដែលសូធ្យដកពទ្ធសីមា ដោយអាស្រ័យហេតុប៉ុន្មានយ៉ាង ដូចម្តេចខ្លះ ។

១៨_ ពទ្ធសីមាដែលនឹងត្រឡប់ទៅជាមិនមែនសីមាវិញនោះ ដោយហេតុប៉ុន្មានយ៉ាង, ដូចម្តេចខ្លះ ។

១៩- អពទ្ធសីមា មានប៉ុន្មានយ៉ាង, គឺខ្លះ ។

២០_ គាមសីមា ដូចម្តេច ។

២១- សត្តព្ភន្តរសីមា ដូចម្តេច ។

២២- ឧទកុក្ខេបសីមា ដូចម្តេច ។

២៣- អពទ្ធសីមាទាំង ៣ យ៉ាង មានសេចក្តីប្លែកគ្នាដូចម្តេចខ្លះ ។

២៤- ពទ្ធសីមា និងអពទ្ធសីមា មានសេចក្តីប្លែកគ្នាយ៉ាងណាខ្លះ ។

សីមាវិនិច្ឆ័យសង្ខេប ចប់

ព្រះវិសុទ្ធិវង្ស **ហួត-តាត** វត្តឧណ្ណាលោម

រៀបរៀងសម្រេច ពីថ្ងៃ ៧ ៤ ៨ ឆ្នាំក ចត្វាស័ក ព.ស. ២៤៧៨ ។

# តាមការអនុញ្ញាតរបស់

- គណៈលេខាមជ្ឈិមបក្ស លេខ ១៣៣ ស.ខ ម.ប ចុះថ្ងៃទី ៧ សីហា ឆ្នាំ ១៩៨៦ បានសម្រេចជាគោលការណ៍អនុញ្ញាតឲ្យបោះពុម្ពសៀវភៅធម៌ ។
- ក្រសួងឃោសនាការនិងវប្បធម៌លេខ ៣៥៦/៨៧ គ.ប.ច ចុះថ្ងៃទី ២៧ កក្កដា ឆ្នាំ ១៩៨៧ ។

ការផ្សាយរបស់គណៈកម្មការរៀបចំបោះពុម្ពសៀវភៅធម៌-វិន័យ

ព្រះពុទ្ធសាសនា ព.ស ២៥៣២ / គ.ស ១៩៨៨ ។

**បោះពុម្ពលើកទី ១ ចំនួន ១០.០០០ក្បាល ។**

បោះពុម្ពនៅរោងពុម្ពពាណិជ្ជកម្ម (សហគ្រាសសម្ព័ន្ធទី II )

រក្សាសិទ្ធិ



**មានជាវថ្មី និង ជាវរាយ**

******

នូវសៀវភៅគ្រប់មុខ គ្រប់ប្រភេទ នៅ

"បណ្ណាគារត្រៃរតន៍" ផ្ទះលេខ 136 Eo

វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

សូមនិមន្ត និង យាងអញ្ជើញដោយមេត្រីភាព !